សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# បណ្តឹងឧបាស្រ័យនៅតុលាការជាន់ខ្ពស់ចំពោះរឿងក្តីរដ្ឋប្បវេណី

ស្រាវជ្រាវពីថ្ងៃទី ២៣ ខែ មីនា ដល់ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **យ៉ាំ ម៉ាណេត**

**លីម សុធារិទ្ធ**

សាស្ត្រាចារ្យណែនាំ

លោក **ទេព សុខ**


ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ

ជំនាន់ទី ២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **យ៉ាំ ម៉ាណេត** និង**លឹម សុធារិទ្ធ** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់២២ នៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ឆ្នាំសិក្សា ២០១៨-២០២២។ យើងខ្ញុំសូមធ្វើការថ្លែងអំណរគុណ និងសម្តែងនូវកត្តញ្ញូតាធម៌ ជូនចំពោះ ៖

យើងខ្ញុំសូមថ្លែងអំណរគុណដល់ **លោកឪពុក សៀវ នឿន** និង**អ្នកម្តាយ ក្រាញ់ វន់** រួមទាំង **លោកឪពុក ស៊ីម សុលីម** និង**អ្នកម្តាយ សុក ហ៊ួ** ជាទីគោរព និងជាទីស្រលាញ់របស់កូនៗទាំងទ្វេ ដែលលោកអ្នកមានគុណបានផ្តល់កំណើតដល់រូបកូនទាំងពីរ និងបានចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មាន ប្រៀបប្រដៅ ថែមទាំងបានផ្តល់ក្តីស្រលាញ់ជូនចំពោះរូបកូនៗបានយ៉ាងល្អឥតខ្ចោះតាំងពីពេលចាប់កំណើត រហូតមកដល់ពេលបច្ចុប្បន្ននេះ។ លើសពីនេះទៅទៀត លោកអ្នកដែលមានគុណបានខិតខំប្រឹងប្រែង និងលះបង់គ្រប់បែបយ៉ាងនូវកម្លាំងកាយចិត្ត ជាពិសេសពេលវេលាជាច្រើនដើម្បីផ្គត់ផ្គង់ដល់ជីវភាពរស់នៅរបស់កូនៗ និងឧបត្ថម្ភគ្រប់បែបយ៉ាង។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ **ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ថ្នាក់ដឹកនាំ និង លោក លោកស្រីសាស្ត្រាចារ្យ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានខិតខំប្រឹងប្រែងអស់ពីសមត្ថភាពក្នុងការបណ្តុះបណ្តាល ចែករំលែក ព្រមទាំងផ្តល់នូវការអប់រំ ចំណេះដឹង បទពិសោធន៍ និង រួមទាំងការណែនាំបង្ហាត់បង្រៀនដល់រូបយើងខ្ញុំ យ៉ាងយកចិត្តទុកដាក់បំផុតដើម្បី រូបយើងខ្ញុំបានសិក្សារៀនសូត្រ ក្រេបយកចំណេះវិជ្ជា រហូតដល់បានបញ្ចប់ការសិក្សាប្រកបដោយភាពជោគជ័យ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ **លោកសាស្ត្រាចារ្យ ទេព សុខ** ដែលជាសាស្ត្រាចារ្យណែនាំរបស់រូបយើងខ្ញុំផ្ទាល់លើកិច្ចការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះ ដោយលោកសាស្ត្រាចារ្យបានចំណាយពេលវេលាដ៏មានតម្លៃរបស់លោក ដើម្បីដឹកនាំ ផ្តល់ការប្រឹក្សា និងកែតម្រូវនូវរាល់ចំណុចខ្វះខាតទៅលើការស្រាវជ្រាវ និងចងក្រងកិច្ចការសារណាបញ្ចប់ការសិក្សាមួយនេះ តាំងពីពេលចាប់ផ្តើមហូតមកដល់ពេលដែលយើងខ្ញុំបានបញ្ចប់ និងសម្រេចបាននូវកិច្ចការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះ។

ជាចុងបញ្ចប់ ដើម្បីជាកិច្ចតបស្នង និងការដឹងគុណ យើងខ្ញុំសូមជូនពរដល់ លោកអ្នកមានគុណ ព្រមទាំងឯត្តមសាកលវិទ្យាធិកាការ សាកលវិទ្យាធិការរង លោក លោកស្រីសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ព្រមទាំងលោកសាស្ត្រាចារ្យ ទេព សុខ ជួបប្រទះតែសេចក្តីសុខទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានទទួលបានការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រអស់រយៈពេល ៤ឆ្នាំកន្លងមក នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំទាំងពីរទទួលបានចំណេះវិជ្ជាជាច្រើន និងទទួលបានចំណាត់ថ្នាក់ដែលបានតម្រូវឲ្យ សរសេរសារណាដើម្បីបញ្ចប់ការសិក្សាផងដែរ។ ហេតុនេះនៅក្នុងចំណោមមុខវិជ្ជាដែលបានសិក្សានាពេលកន្លងមក យើងខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងលើវិវាទក្នុងរឿងក្តីរដ្ឋប្បវេណីដែលទាក់ទងនឹងបណ្តឹងរបស់គូភាគី ជាងនេះទៅទៀត នីតិវិធីបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់នេះ គឺជានីតិវិធីមួយដ៏សំខាន់ ដែលអ្នកវិជ្ជាជីវៈ អ្នកសិក្សា និងប្រជាពលរដ្ឋគ្រប់រូបគប្បីត្រូវតែយល់ដឹងអំពីលំហូរនៃនីតិវិធីបណ្តឹងឧបាស្រ័យទៅសាលាជម្រះក្តីជាន់ខ្ពស់ នោះគឺសាលាឧទ្ធរណ៍ និងតុលាការកំពូល ។

យ៉ាងណាមិញប្រធានបទខាងលើ គឺជាប្រធានបទមួយដែលមានភាពស្មុគស្មាញ ទាំងបរិបទទ្រឹស្តី និង ការអនុវត្តជាន់ស្តែង ព្រោះថាក្រមនីតិវិធិរដ្ឋប្បវេណី ក៏ដូចជាច្បាប់សារធាតុទើបតែមានវត្តមានលើទឹកដីព្រះរាជាណាចក្រកម្ពុជា ដែលមានជំនោរតាមក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ដូច្នេះហើយទើបក្រុមរបស់យើងខ្ញុំសម្រេចយកមកសរសេរបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ។

យើងខ្ញុំសង្ឃឹមថា ស្នាដៃក្នុងការសរសេរសារណាមួយនេះ នឹងអាចក្លាយទៅជាឯកសារមួយដ៏សំខាន់ដែលបានផ្តល់នូវចំណេះដឹងជាច្រើន រួមទាំងជំនួយស្មារតី ដល់មិត្តអ្នកអាន និងនិស្សិតជំនាន់ក្រោយដែលបានសិក្សាស្រាវជ្រាវលើប្រធានបទ ឬបញ្ហាផ្សេងទៀត ដែលពាក់ព័ន្ធនឹងលំហូរនីតិវិធីបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ចំពោះរឿងក្តីរដ្ឋប្បវេណី។

យ៉ាងណាក៏ដោយ ទោះបីជាយើងខ្ញុំបានខឹតខំប្រឹងប្រែងយ៉ាងខ្លាំងក៏ដោយ ក៏សៀវភៅសារណាមួយនេះរមែងតែងតែមាននូវចំណុចខ្វះខាត និងកំហុសមួយចំនួនពុំខានឡើយ ដែលកើតឡើងចេញពីផ្នែក អក្ខរាវិរុទ្ធ និងអក្ខរាវិរុទ្ធដោយអចេតនា។ ហេតុនេះហើយយើងខ្ញុំសូមមេត្តាខន្តីអភ័យទោសទុកជាមុននូវកំហុសខុសឆ្គងដែលកើតមានឡើងដោយអចេតនា ហើយយើងខ្ញុំមានសេចក្តីសោមនស្សរីករាយក្នុងការរង់ចាំទទួលនូវរាល់ការរិះគន់ក្នុងន័យស្ថាបនាទាំងឡាយពីសំណាក់ លោក លោកស្រី សាស្ត្រាចារ្យ អ្នកសិក្សា ស្រាវជ្រាវ មិត្តអ្នកអាន និងសិស្សនិស្សិតទាំងអស់ ជួបប្រទះតែសំណាងល្អ និងទទួលបាននូវភាពជោគជ័យគ្រប់ភារកិច្ច។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម**......................................................................................................១

**ជំពូកទី១**

**បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និង បណ្តឹងឧទ្ធរណ៍**

**១.១. សញ្ញាណទូទៅនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់** ...................................... ៣

១.១.១. អត្ថន័យនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ..........................................៤

១.១.២. គោលគំនិតនៃរបបបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ...............................៥

១.១.៣. ប្រភេទនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ..............................................៦

**១.២. សញ្ញាណទូទៅនៃបណ្តឹងឧទ្ធរណ៍** ........................................................................ ៧

១.២.១. កម្មវត្ថុ និង មូលហេតុនៃបណ្តឹងឧទ្ធរណ៍.........................................................៨

១.២.២. ល័ក្ខខ័ណ្ឌនៃការធ្វើបណ្តឹងឧទ្ធរណ៍ .................................................................១២

១.២.៣. អានុភាពនៃការដាក់ពាក្យបណ្តឹងឧទ្ធរណ៍......................................................... ១៥

**១.៣. លំហូរនីតិវិធីនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍**................................................. ១៩

១.៣.១. របៀបធ្វើ និងការទទួលពាក្យបណ្តឹងឧទ្ធរណ៍..................................................... ១៩

១.៣.២. ការពិនិត្យ ការបញ្ជូន និងការបង់ពន្ធលើពាក្យបណ្តឹងឧទ្ធរណ៍.................................២២

១.៣.៣. នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ ..........................២៦

១.៣.៤. ការបញ្ចប់នីតិវិធីនៃបណ្តឹងឧទ្ធរណ៍.................................................................. ៣២

**ជំពូកទី ២**

**បណ្តឹងសាទុក្ខ និងបណ្តឹងជំទាស់**

**២.១. បណ្តឹងសាទុក្ខ**.......................................................................................................៣៩

២.១.១. សញ្ញាណទូទៅនៃបណ្តឹងសាទុក្ខ.......................................................................៣៩

២.១.២. លំហូរនីតិវិធីនៃការជំនុំជម្រះបណ្តឹងសាទុក្ខ ........................................................ ៤៨

**២.២. បណ្តឹងជំទាស់**...................................................................................................... ៥៩

២.២.១. សញ្ញាណទូទៅនៃបណ្តឹងជំទាស់ ......................................................................... ៥៩

២.២.២. លំហូរនីតិវិធីនៃការជំនុំជម្រះបណ្តឹងជំទាស់ ......................................................... ៦៤

**សេចក្តីសន្និដ្ឋាន**........................................................................................................ ៦៨

**អនុសាសន៍**......................................................................................................................៧០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ មានគន្ថីសរុបចំនួន ៩ គន្ថី ។ គន្ថីទី១ បទប្បញ្ញត្តិទូទៅគន្ថីទី២ នីតិវិធីនៃការជម្រះក្តីលើកទី១ គន្ថីទី៣ បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ គន្ថីទី៤ ការជំនុំជម្រះសាជាថ្មី គន្ថីទី៥ នីតិវិធីជាស់តឿន គន្ថីទី៦ ការអនុវត្តដោយបង្ខំ គន្ថីទី៧ ការចាត់ចែងរក្សាការពារ គន្ថីទី៨ អន្តរប្បញ្ញត្តិ និងគន្ថីទី៩ អវសានប្បញ្ញត្តិ។ ក្នុងនោះបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់នេះ ជាផ្នែកមួយដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ នៅគន្ថីទី ៣ ដែលជាចំណុចដ៏សំខាន់មួយផងដែរ សម្រាប់ការសិក្សាក៏ដូចជាការអនុវត្តជាក់ស្តែងនៅតាមសាលាជម្រះក្តីជាន់ខ្ពស់គឺសាលាឧទ្ធរណ៍និងតុលាការកំពូល។ អ្វីដែលពិសេស ចំពោះបណ្តឹងឧបាស្រ័យនេះ ជាការផ្តល់នូវសិទ្ធិដល់គូភាគីនៃបណ្តឹងនៅតុលាការនៃការជំនុំជម្រះលើកទី១ ( សាលាដំបូងរាជធានី ខេត្ត ) មានឳកាសក្នុងការបន្តបណ្តឹងរបស់ខ្លួនទៅតុលាការចំនួន ២ ទៀត ដើម្បីស្វែងរកលទ្ធផលមួយដែលភាគីទាំងសងខាង អាចទទួលយកបាន។

មិនថាតែនៅកម្ពុជានោះទេ គ្រប់បណ្តាលប្រទេសភាគច្រើន ប្រើប្រព័ន្ធឧបាស្រ័យនេះ ដើម្បីស្វែងរកយុត្តិធម៌យ៉ាងពិតប្រាកដជូនដល់គូភាគី ប៉ុន្តែប្រព័ន្ធឧបាស្រ័យនេះធ្វើភាគីទទួលផលពិបាកផងដែរ ដោយសារតែភាគីត្រូវចំណាយពន្ធ ចំណាយសេវាមេធាវី សេវាស្នាក់នៅ និងរកភស្តុតាងជាដើម ព្រោះតុលាការរដ្ឋប្បវេណីជាតុលាការអកម្ម ភស្តុតាងជាបន្ទុករបស់ភាគី។ ហេតុនេះហើយបានជាមានសំនួរមួយចំនួនបានលើកឡើងថា តើអ្វីទៅជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់? តើលំហូរនីតិវិធីនៃការជំនុំជម្រះនៅតុលាការជាន់ខ្ពស់ប្រព្រឹត្តិទៅយ៉ាងដូចម្តេច? តើបណ្តឹងឧបាស្រ័យមានផលប្រយោជន៍អ្វីខ្លះដល់ភាគី ?

បណ្តឹងឧបាស្រ័យជាប្រភេទបណ្តឹងមួយ ដែលនាំវិស័យយុត្តិធម៌នៅកម្ពុជា កាន់តែរីកចម្រើន ដោយសារតែប្រជាពលទូទៅដែលរស់នៅក្នុងសង្គមនីតិរដ្ឋ ចាំបាច់ត្រូវតែគោរព និងប្រតិបត្តិតាមច្បាប់ដែលនៅជាធរមាន ដូចនេះ នៅពេលដែលប្រជាពលរដ្ឋ មានវិវាទកើតឡើង រដ្ឋត្រូវតែធានានូវការផ្តល់យុត្តិធម៌ដល់ប្រជាពលរដ្ឋ បានឆាប់រហ័ស ហើយចាំបាច់នៅក្នុងការទុកសិទ្ធិឱ្យប្រជាពលរដ្ឋអាចប្តឹងបន្តឡើងទៅតុលាការជាន់ខ្ពស់ផងដែរ ហេតុនេះហើយបានជាក្រមនីតិវិធីរដ្ឋប្បវេណី បានបញ្ញត្តិនូវចំណុចបណ្តឹងឧបាស្រ័យនេះមក។

ការលើកយកនូវបណ្តឹងឧបាស្រ័យនេះ យើងខ្ញុំសូមធ្វើការបកស្រាយ រ៉ាយរ៉ាប់ ត្រឹមតែកម្រិត ដាក់ពាក្យបណ្តឹងឧទ្ធរណ៍ រហូតមកដល់ការចេញសាលដីការបស់សាលាឧទ្ធរណ៍ និងការដាក់ពាក្យបណ្តឹងសាទុក្ខ រហូតមកដល់ការចេញសាលដីការបស់តុលាការកំពូល និងការប្តឹងជំទាស់ចំពោះដីកាសម្រេចតែប៉ុណ្ណោះ មានន័យថាក្នុងគន្ថីទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦។

យើងខ្ញុំសង្ឃឹមថា សារណានេះនឹងអាចជាឯកសារជំនួសស្មារតី និងជាឯកសារសម្រាប់ធ្វើការសិក្សាស្រាវជ្រាវរបស់មិត្តនិស្សិត ជាពិសេសនោះគឺជានិស្សិតដែលកំពុងតែសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ទាំងអស់ ដែលពួកគាត់ កំពុងតែត្រូវការស្វែងយល់បន្ថែមនូវមុខវិជ្ជានីតិវិធីរដ្ឋប្បវេណីនេះ លើសពីនេះទៅទៀត យើងខ្ញុំក៏ចង់បន្សល់ទុកនូវស្នាដៃមួយសម្រាប់ជាការចងចាំមួយដែលមិនអាចបំភ្លេចបាន ដែលយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនេះផងដែរ។

ដើម្បីអាចចងក្រងសារណាបញ្ចប់ការសិក្សានេះបានយើងខ្ញុំបានសិក្សាទៅលើលិខិតបទដ្ឋានគតិយុត្ត ដូចជា ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមនីតិរដ្ឋប្បវេណី សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី និងឯកសារបន្ទាប់បន្សំផ្សេងៗទៀត។ ជាពិសេសជានេះទៅទៀតនោះ ដោយមានការជួយជ្រុំជ្រែង ពីលោកគ្រូសាស្ត្រាចារ្យ ក្នុងការណែនាំ ជួយបំពេញបន្ថែមនៅចំណុចខ្វះខាតជាច្រើនផងដែរ។

ប្រធានបទសារណានេះ ផ្តោតសំខាន់តែទៅលើបណ្តឹងឧទ្ធរណ៍ បណ្តឹងសាទុក្ខ និងបណ្តឹងជំទាស់ ដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី នូវគន្ថីទី៣ តែប៉ុណ្ណោះ។ ខ្លឹមសារនៃប្រធានបទសារណានេះ ត្រូវបានបែងចែកជា ២ (ពីរ) ជំពូកសំខាន់ៗ ដោយជំពូកទី១ គឺបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និងបណ្តឹងឧទ្ធរណ៍ ជំពូកទី២ គឺបណ្តឹងសាទុក្ខ និងបណ្តឹងជំទាស់។

ជំពូកទី១ ត្រូវបានបែងចែកជា ២ ចំណុចធំៗ រួមមាន ចំណុចទី១ (បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់) ដែលជាដំបូងបំផុតនោះ គឺយើងចាំបាច់ត្រូវតែយល់ដឹងជាមុនសិនអំពីសញ្ញាណទូទៅនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់។ ចំណុចទី២ (បណ្តឹងឧទ្ធរណ៍) ដែលជាប្រភេទនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដែលចាំបាច់ក្នុងការស្វែងយល់អំពីសញ្ញាណទូទៅនៃបណ្តឹងឧទ្ធរណ៍ និង លំហូរនីតិវិធីនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍។

ជំពូកទី២ ត្រូវបានបែងចែកជា ២ ចំណុចធំៗ រួមមាន ចំណុចទី១ (បណ្តឹងសាទុក្ខ) នៅក្នុងបណ្តឹងសាទុក្ខនេះ មានចែកជាចំណុចតូចផ្សេងទៀត ដូចជា សញ្ញាណទូទៅនៃបណ្តឹងសាទុក្ខ និងលំហូរនីតិវិធីនៃបណ្តឹងសាទុក្ខ។ ចំណែកឯចំណុចទី២ (បណ្តឹងជំទាស់) ហើយនៅក្នុងបណ្តឹងជំទាស់នេះក៏ចែកជាចំណុចតូចផ្សេងទៀត ដូចជា សញ្ញាណទូទៅនៃបណ្តឹងជំទាស់ និងលំហូរនីតិវិធីនៃការជំនុំជម្រះបណ្តឹងជំទាស់ផងដែរ។

# ជំពូកទី១
# បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និង បណ្តឹងឧទ្ធរណ៍

# ជំពូកទី១

# បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និង បណ្តឹងឧទ្ធរណ៍

## ១.១ សញ្ញាណទូទៅនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់

បណ្តឹងរដ្ឋប្បវេណីគឺជាសិទ្ធិមួយដែលច្បាប់ទទួលស្គាល់ សម្រាប់បុគ្គលឯកជន អាចជារូបវន្តបុគ្គល ឬ នីតិបុគ្គល ក្នុងការធ្វើបណ្តឹងទៅស្ថាប័នតុលាការ ជួយដោះស្រាយនូវបញ្ហាដែលកើតមានឡើង ក្នុងគោលបំណងទាមទារ តុលាការចេញសាលក្រមតាមការទាមទារដោយផ្អែកតាមភស្តុតាង និងគតិច្បាប់ជាធរមាន។ យើងក៏អាចបកស្រាយបានម្យ៉ាងទៀតផងដែរថា បណ្តឹងរដ្ឋប្បវេណី គឺជាលិខិតលាយលក្ខណ៍អក្សរដែលរៀបចំឡើងដោយដើមចោទ ( ជាម្ចាស់បណ្តឹង ) ធ្វើការអះអាងអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិទាមទារដោយផ្អែកតាមច្បាប់សារធាតុ និងច្បាប់ទម្រង់ ចំពោះភាគីម្ខាងទៀតហៅថាចុងចម្លើយ (អ្នកដែលត្រូវគេប្តឹង)។[1] ពិសេសជានេះទៅទៀត បណ្តឹងទាមទារ តុលាការទទួលស្គាល់អត្ថិភាព ឬនត្ថិភាពនៃសិទ្ធិទាមទារតាមច្បាប់សារធាតុ។ ដូច្នេះ វាជាសកម្មភាពទាមទារមួយដែល បានធ្វើឡើងដោយដើមចោទចំពោះចុងចម្លើយទៅតុលាការដែលមានសមត្ថកិច្ចក្នុងការជំនុំជម្រះក្តី ដោយអះអាងអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តតាមផ្លូវច្បាប់ហើយទាមទារឱ្យតុលាការចេញសេចក្តីសម្រេចជាសាលក្រម ឬសាលដីកា ឬដីកាសម្រេច។ចំពោះបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់នេះទៀតសោត ជាបណ្តឹងតវ៉ារបស់ភាគី ដែលពុំយល់ស្របជាមួយសេចក្តីសម្រេចណាមួយ អាចជាសាលក្រម សាលដីកា ឬ ដីកាសម្រេចរបស់ចៅក្រម ឬ តុលាការដើម្បីទាមទារឱ្យលុបចោល ឬ ផ្លាស់ប្តូរសេចក្តីសម្រេចដើម។

### ១.១.១ អត្ថន័យនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់

បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ គឺជានីតិវិធីធ្វើឧបាស្រ័យទាមទារដោយភាគីទៅតុលាការជាន់ខ្ពស់ឱ្យលុបចោល ឬ ផ្លាស់ប្តូរនូវសេចក្តីសម្រេចដែលចេញដោយសាលាដំបូងរាជធានី ខេត្ត នៅមុនពេលដែលសេចក្តីសម្រេចនោះចូលជាស្ថាពរ។[2] បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់នេះ អាចធ្វើទៅបានតែមុនពេលដែលសេចក្តីសម្រេចនោះចូលជាស្ថាពរតែប៉ុណ្ណោះ។ ស្របគ្នានេះផងដែរ នៅពេលដែលមានបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ គឺជាសេចក្តីសម្រេចដើមនោះ ដែលមិនទាន់ចូលជាស្ថាពររហូតដល់ដំណើរការ ឧបាស្រ័យទៅតុលាការជាន់ខ្ពស់នោះបានបញ្ចប់។[3] ផ្ទុយទៅវិញ ការចូលជាស្ថាពរនៃសេចក្តីសម្រេចមួយ គឺជាស្ថានភាពមួយដែលសេចក្តីសម្រេចនោះ មិនអាចធ្វើឧបាស្រ័យទៅតុលាការជាន់ខ្ពស់បាន ឬ ក្នុង

[1] មាត្រា ៣២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[2] មាត្រា ២៥៩ នៃក្រមនីតិវិធិរដ្ឋប្បវេណី ឆ្នាំ ២០០៦

[3] មាត្រា ១៩៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ករណីសហបណ្តឹងធម្មតា ដែលតុលាការបានចេញសាលក្រមតែមួយចំពោះភាគីសហបណ្តឹងទាំងអស់ ប្រសិនបើភាគីសហបណ្តឹងណាមួយប្តឹងឧបាស្រ័យ ហើយភាគីសហបណ្តឹងផ្សេងទៀតមិនបានប្តឹងឧបាស្រ័យ នោះសាលក្រមចូលជាស្ថាពរ ចំពោះភាគីសហបណ្តឹងដែលមិនបានប្តឹងឧបាស្រ័យនោះ នៅពេលផុតអំឡុងពេលប្តឹង ឧបាស្រ័យស្របច្បាប់។ ចំណែកឯបណ្តឹងទាមទារឱ្យជំនុំជម្រះសារជាថ្មី គឺជាការប្តឹងឧបាស្រ័យចំពោះ សាលក្រមដែលបានចូលជាស្ថាពរហើយហេតុដូច្នេះ មិនមែនជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ទេ។[4]

### ១.១.២ គោលគំនិតនៃរបបបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់

ជាទូទៅការសម្រេចសេចក្តីដែលធ្វើឡើងដោយចៅក្រមមួយរូប ឬ ក្រុមប្រឹក្សាជំនុំជម្រះ រមែងតែងតែមានការវិនិច្ឆ័យខុស ឬ ការភ័ន្តច្រឡំដោយប្រការណាមួយនោះជៀសមិនរួចនោះទេ។ ប៉ុន្តែប្រសិនបើទុកស្ថានភាពនៅតែដដែលនាំឱ្យកំហុសនោះ គឺមិនត្រឹមត្រូវហើយព្រមទាំងបំពានសិទ្ធិរបស់ភាគីផងដែរ ដែលជាហេតុធ្វើឱ្យប្រជាពលរដ្ឋបាត់បង់នូវជំនឿទុកចិត្តចំពោះប្រព័ន្ធតុលាការនោះតែម្តង។ ដូច្នេះហើយ ចាំបាច់ត្រូវមាននូវប្រព័ន្ធមួយតាមពាក្យប្តឹង ឬ ពាក្យសុំរបស់ភាគីម្ខាងដែលមិនសុខចិត្តចំពោះសេចក្តីសម្រេច ឬដីកាសម្រេច ហើយប្រសិនបើសេចក្តីសម្រេចថ្នាក់ក្រោមនោះមិនត្រឹមត្រូវតុលាការជាន់ខ្ពស់អាចនឹងពិនិត្យមើល នូវសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោមបាន តាមពាក្យសុំរបស់ភាគីម្ខាងដែលមិនសុខចិត្តចំពោះសេចក្តីសម្រេចនោះ ហើយប្រសិនបើសេចក្តីសម្រេចថ្នាក់ក្រោមនោះមិនត្រឹមត្រូវតុលាការថ្នាក់ខ្ពស់ជាងនោះ អាចធ្វើការកែប្រែ ឬលុបចោលនូវសេចក្តីសម្រេចនោះបាន។ ដោយសារតែការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់នេះ គឺជាប្រព័ន្ធមួយដែលតុលាការជាន់ខ្ពស់កែតម្រូវនូវសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោម ដោយរងចាំពាក្យសុំឧបាស្រ័យ ហេតុដូច្នេះ យើងអាចនិយាយបានថា វាជាយន្តការមួយសម្រាប់ធ្វើការសង្គ្រោះសិទ្ធិភាគីរួចផុតពីឥទ្ធិពលនៃការវិនិច្ឆ័យខុស ឬ កំហុសក្នុងនីតិវិធីនៃការជំនុំជម្រះ។

នីតិវិធីរដ្ឋប្បវេណី មានគោលបំណងការពារសិទ្ធិស្របច្បាប់របស់បុគ្គលឯកជន តាមរយៈការដោះស្រាយវិវាទដោយបង្ខំ។ ក្នុងគោលបំណងនេះ បណ្តឹងរដ្ឋប្បវេណីមានគោលបំណងឱ្យតុលាការដោះស្រាយវិវាទរដ្ឋប្បវេណីដោយផ្អែកលើច្បាប់ ដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន។[5]បណ្តឹងរដ្ឋប្បវេណី ដោះស្រាយវិវាទរវាងភាគីដោយបង្ខំ ភាគីដោយផ្ទាល់គោរពតាមសេចក្តីសម្រេចរបស់តុលាការ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ រដ្ឋបង្កើតប្រព័ន្ធ នីតិវិធីរដ្ឋប្បវេណីនេះឡើង មិនមែនក្នុងគោលបំណងធ្វើការដោះស្រាយវិវាទនោះទេ តែគឺដើម្បីធ្វើការទទួលស្គាល់ តាមរយៈតុលាការ ថាបុគ្គលម្នាក់មានសិទ្ធិស្របច្បាប់ និងដើម្បីការពារសិទ្ធិរបស់បុគ្គល

---

[4] មាត្រា ៣០៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[5] មាត្រា ២ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

នោះ ដោយបញ្ចប់នូវវិវាទ ហេតុដូច្នេះវាមិនមែនមានន័យថា ការដោះស្រាយវិវាទអាចនាំកើតជាលទ្ធផលអ្វីដល់ភាគីនោះទេ។ ម្យ៉ាងទៀត នីតិវិធីរដ្ឋប្បវេណីអាចសម្រេចគោលដៅបាន លុះត្រាតែមានការដោះស្រាយមួយដ៏ត្រឹមត្រូវ ហើយសិទ្ធិរបស់បុគ្គលដែលជាម្ចាស់សិទ្ធិនោះ ត្រូវបានទទួលស្គាល់ដោយផ្អែកទៅលើច្បាប់។ ការការពារសិទ្ធិតាមរយៈ នីតិវិធីរដ្ឋប្បវេណីបែបនេះ មិនមែនជាការដាក់ទានពីរដ្ឋទៅប្រជាពលរដ្ឋនោះទេ។ ផ្ទុយទៅវិញ គេត្រូវយល់ថា បុគ្គលឯកជនគ្រប់រូប ទាំងជនបរទេស និងជនជាតិខ្មែរ មានសិទ្ធិដាក់ពាក្យបណ្តឹងទៅតុលាការ ដើម្បីស្វែងរកការការពារសិទ្ធិរបស់ខ្លួន កាលណាសិទ្ធិនោះត្រូវបានគេបំពាននៅក្នុងវិវាទរដ្ឋប្បវេណី។[6] បើទោះបីជាសិទ្ធិមូលដ្ឋាន និងសិទ្ធិផ្សេងៗទៀត ត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ និងច្បាប់ក៏ដោយ តែបើពុំអាចស្វែងរកការការពារ និងការសង្គ្រោះនានា តាមរយៈការដាក់ពាក្យបណ្តឹងទៅតុលាការ នៅពេលណាដែលសិទ្ធិនោះត្រូវបានគេបំពានទេនោះការទទួលស្គាល់សិទ្ធិនោះនឹងពុំមានអត្ថន័យអ្វីឡើយ។

មួយវិញទៀតតាមរយៈការអនុញ្ញាតឱ្យធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ មានរឿងក្តីជាច្រើនដែលត្រូវបានពិនិត្យ និងធ្វើការជំនុំជម្រះបន្តដោយតុលាការជាន់ខ្ពស់មួយចំនួនតូច ហើយចុងបំផុតក្រោយ គឺតុលាការកំពូល។ ដើម្បីបានជាលទ្ធផលរួមមួយដែលជា សេចក្តីសម្រេចចុងក្រោយបានសេចក្តីថាសេចក្តីសម្រេចតាមសាលាដំបូង និងសាលាឧទ្ធរណ៍ត្រូវបានបង្រួបបង្រួមក្លាយទៅជាការបកស្រាយ និងអនុវត្តតែមួយដោយតុលាការកំពូល។ ហើយការរួមបញ្ចូលនូវការបកស្រាយច្បាប់នេះ ទៀតសោត គឺតុលាការត្រូវធានានូវប្រព័ន្ធគតិយុត្តដែលប្រកបដោយស្ថេរភាពមានសណ្តាប់ធ្នាប់ និងប្រកបដោយតុល្យភាពក្នុងនាមជាការតាំងនាមឱ្យប្រជារាស្ត្រខ្មែរ។

### ១.១.៣ ប្រភេទនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់

បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ មាន៣ ប្រភេទ គឺ បណ្តឹងឧទ្ធរណ៍ បណ្តឹងសាទុក្ខ និងបណ្តឹងជំទាស់។[7]

- បណ្តឹងឧទ្ធរណ៍ ៖ ជាប្រភេទនៃបណ្តឹងឧបាស្រ័យ ចំពោះសាលក្រមនៃតុលាការជំនុំជម្រះលើកទី ១ ទៅតុលាការនៃបណ្តឹងឧទ្ធរណ៍[8] ឬជាបណ្តឹងធ្វើឡើងចំពោះសាលក្រមរបស់សាលដំបូងដែល មិនទាន់ចូលជាស្ថាពរ។[9]

---

[6] មាត្រា ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[7] មាត្រា ២៥៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[8] សន្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស និងបារាំង រដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[9] មាត្រា ២៥៩ កថាខណ្ឌទី ១ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

- បណ្តឹងសាទុក្ខ ៖ ជាប្រភេទនៃបណ្តឹងឧបាស្រ័យទៅតុលាការកំពូល ចំពោះសាលដីកាចុងក្រោយដែលត្រូវបានជំនុំជម្រះលើកទី២ ដោយសាលាឧទ្ធរណ៍ ឬ សាលដីកាចុងក្រោយដែលសាលាឧទ្ធរណ៍បានជំនុំជម្រះលើកទី ១ តាមបញ្ញត្តិច្បាប់ពិសេស ឬសាលក្រមចុងក្រោយដែលបានជំនុំជម្រះលើកទី ១ ដោយសាលាដំបូងក្នុងករណីដែលភាគីបានព្រមព្រៀងគ្នាមិនប្តឹងឧទ្ធរណ៍ ប៉ុន្តែភាគីរក្សាទុកនូវសិទ្ធិប្តឹងសាទុក្ខ ឬ ជាបណ្តឹងធ្វើឡើងចំពោះសាលដីកាដែលមិនទាន់ចូលជាស្ថាពររបស់សាលាឧទ្ធរណ៍។[10] ឬ ម្យ៉ាងទៀត បណ្តឹងដែលប្តឹងដល់សាលាវិនិច្ឆ័យដោយមិនសុខចិត្ត និង សាលក្រម ឬ សាលដីកាណាមួយ។[11]
- បណ្តឹងជំទាស់ ៖ បណ្តឹងឧបាស្រ័យមួយប្រភេទទៅតុលាការជាន់ខ្ពស់(ដែលជាតុលាការនៃបណ្តឹងជំទាស់)ដើម្បីទាមទារឱ្យលុបចោល ឬ ផ្លាស់ប្តូរដីកាសម្រេចដើម។[12] ឬជាបណ្តឹងដែលធ្វើឡើងចំពោះដីកាសម្រេចរបស់តុលាការជាន់ទាប ប៉ុន្តែបណ្តឹងជំទាស់នេះអាចធ្វើទៅបានលុះត្រាតែមានបញ្ញត្តិក្នុងច្បាប់ហើយចំពោះដីកាសម្រេចលើបណ្តឹងជំទាស់ទៀតបានឡើយ។[13]

ដូច្នេះបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់មាន ៣ ប្រភេទផ្សេងៗគ្នា ដែលបែងចែកទៅតាមប្រភេទនៃសេចក្តីសម្រេចដើម។ សរុបជារួម បណ្តឹងឧទ្ធរណ៍ និងបណ្តឹងសាទុក្ខ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ចំពោះសាលក្រម ឬសាលដីកា រីឯបណ្តឹងជំទាស់វិញ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ចំពោះដីកាសម្រេច។

[10] មាត្រា ២៥៩ កថាខណ្ឌទី១ ចំណុច ខ

[11] ច្បាប់ភូមិបាល ឆ្នាំ១៩៩២ ផ្នែកសន្ទានុក្រមច្បាប់

[12] សន្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស និងបារាំង រដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៧

[13] មាត្រា ២៥៩ កថាខណ្ឌទី១ ចំណុច គ និងកថាខណ្ឌទី២ និងទី៣២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

## ១.២ សញ្ញាណទូទៅនៃបណ្តឹងឧទ្ធរណ៍

ជាធម្មតា នៅពេលដំណើរការរឿងក្តីនៃនីតិវិធីនៃជំនុំជម្រះលើកទី ១ ដល់ដំណាក់កាលចេញសាលក្រម ប៉ុន្តែមិនទាន់ចូលជាស្ថាពរ ភាគីណាដែលមិនពេញចិត្ត ឬ មិនសុខចិត្តទៅនឹងសាលក្រមដែលចេញដោយសាលាដំបូងរាជធានីខេត្តនោះ ភាគីអាចធ្វើបណ្តឹងឧទ្ធរណ៍ទៅតុលាការនៃបណ្តឹងឧទ្ធរណ៍បានដែលជាតុលាការនៃការជំនុំជម្រះលើកទី២។[14] បណ្តឹងឧទ្ធរណ៍ គឺជាប្រភេទនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់មួយប្រភេទដែលភាគីកើតទុក្ខមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់សាលសាដំបូង (សាលក្រម) គឺគាត់មានសិទ្ធិប្តឹងឧទ្ធរណ៍ទៅកាន់សាលាឧទ្ធរណ៍ដើម្បី ធ្វើការកាត់សេចក្តីទៅលើសាលក្រមរបស់សាលាដំបូងនោះ ពោលគឺ ភាគីណាមួយនៃរឿងក្តីរដ្ឋប្បវេណីណាមួយ មិនពេញចិត្តចំពោះការសម្រេចរបស់សាលាជម្រះក្តីជាន់ទាប គឺសាលាដំបូង ហើយភាគីនោះបានដាក់ពាក្យបណ្តឹងសុំការដោះស្រាយពីសាលាឧទ្ធរណ៍។[15] ក្រោយពេលដែលតុលាការនៅសាលាជម្រះក្តីជាន់ទាប គឺសាលាដំបូងបានធ្វើកិច្ចនីតិវិធីដោះស្រាយនៅរឿងក្តីរដ្ឋប្បវេណីមួយដោយធ្វើទៅតាមនីតិវិធីរហូតដល់បានចេញសាលក្រម។បើសិនជាមានភាគីណាមួយមិនសុខចិត្តចំពោះសេចក្តីសម្រេចនោះ គឺអាចដាក់ពាក្យបណ្តឹងបន្តទៅសុំការដោះស្រាយពីសាលាឧទ្ធរណ៍បាន ដែលគេទៅថាបណ្តឹងឧទ្ធរណ៍។ លើសពីនេះទៅទៀត បណ្តឹងឧទ្ធរណ៍ត្រូវគោរពតាមលំហូរនៃនីតិវិធីដូចជា ការដាក់ពាក្យបណ្តឹងឧទ្ធរណ៍តាមរបៀបនៃការធ្វើបណ្តឹងឧទ្ធរណ៍ ដែលមានកម្មវត្ថុនិងល័ក្ខខ័ណ្ឌបានគ្រប់គ្រាន់អានុភាពនៃការដាក់ពាក្យបណ្តឹង និងបន្ថែមជាមួយបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំជាអាទិ៍។

បណ្តឹងឧទ្ធរណ៍ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ចំពោះសាលក្រមចុងក្រោយដែលមិនទាន់ចូលជាស្ថាពរនៃការជំនុំជម្រះលើកទី១ របស់សាលាដំបូង ក្នុងគោលបំណងលុបចោល ឬ ផ្លាស់ប្តូរនូវសាលក្រមចុងក្រោយនោះ។[16] ហើយការជំនុំជម្រះដោយតុលាការនៃបណ្តឹងឧទ្ធរណ៍នេះផងដែរ ហៅថា ការជំនុំជម្រះលើកទី២។ ការជំនុំជម្រះលើកទី២ គឺវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃការប្តឹងឧបាស្រ័យចំពោះសាលក្រមនៃការជំនុំជម្រះលើកទី១ ហើយជាមួយគ្នានេះដែរ ត្រូវពិនិត្យឡើងវិញទៅលើអង្គហេតុ និងអង្គច្បាប់ចំពោះការទាមទារនៃការជំនុំជម្រះលើកទី ១។[17] ករណីលើកលែង ក្នុងករណីការជំនុំជម្រះលើកទី ១ អាចអនុវត្តនៅតុលាការនៃបណ្តឹងឧទ្ធរណ៍បានដែរ ប្រសិនបើមានចែងនៅក្នុងបញ្ញត្តិពិសេស។ ឧទាហរណ៍ ៖ សេចក្តីសម្រេចរបស់គណៈមេធាវី បានសម្រេចថាតុលាការនៃបណ្តឹងឧទ្ធរណ៍ជាតុលាការនៃការជំនុំជម្រះលើក១។ ដូច្នេះ

[14] មាត្រា ២៦០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[15] មាត្រា ២៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[16] មាត្រា ២៦០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[17] មាត្រា ២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

តុលាការនៃបណ្តឹងឧទ្ធរណ៍ធ្វើក្នុងនាមជាការជំនុំជម្រះលើកទី ១ ចំពោះករណីមានចែងបញ្ញត្តិពិសេស និងធ្វើការជំនុំជម្រះលើកទី ២ ចំពោះសាលក្រមចុងក្រោយរបស់សាលាដំបូងដែលបញ្ញត្តិនៅក្នុងក្រមនីតិវិធី រដ្ឋប្បវេណី។[18] ចំពោះសាលក្រមរបៀបមិនអាចធ្វើបណ្តឹងឧទ្ធរណ៍បានទេ ដោយសារតែសាលក្រមនេះពុំមានអានុភាពអ្វីផ្សេង ក្រៅពីអានុភាពដើម្បីត្រៀមចេញសាលក្រមចុងក្រោយក្នុងការជំនុំជម្រះវាពុំមានអាជ្ញាអស់ជំនុំ ឬអានុភាពអនុវត្តទេ។

### ១.២.១ កម្មវត្ថុ និងមូលហេតុនៃបណ្តឹងឧទ្ធរណ៍

ជាធម្មតា មិនថាតែបណ្តឹងឧទ្ធរណ៍នោះទេ គ្រប់បណ្តឹងទាំងអស់តែងតែមាន កម្មវត្ថុ ( ១.២.១.១ ) និងមូលហេតុ ( ១.១.១.២ ) ជាចម្បង ទើបបណ្តាល ឱ្យមានបណ្តឹងកើតឡើងបាន ដោយភាគីមិនសុខចិត្តជាមួយនឹងសាលក្រមរបស់សាលាដំបូងដែលជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ និង ប្តឹងដោយសារតែមូលហេតុអ្វីមួយ ដូចជា សាលក្រមនៃការជំនុំជម្រះលើកទី១ មិនត្រឹមត្រូវ ឬ នីតិវិធីក្នុងតុលាការនៃការជំនុំជម្រះលើកទី១ នោះមានលក្ខណៈផ្ទុយនឹងច្បាប់ធ្ងន់ធ្ងរ ឬ ការលើកបណ្តឹងចោលរបស់សាលាដំបូងមិនត្រឹមត្រូវ និងចាំបាច់ក្នុងការទាញហេតុផលថែមទៀត ឬ ការជំនុំជម្រះលើកទី១ មានកំហុសចំពោះសមត្ថកិច្ចផ្តាច់មុខជាដើម។

#### ១.២.១.១ កម្មវត្ថុ

កម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ គឺសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី ១ របស់សាលាដំបូងដែលមិនទាន់ចូលជាស្ថាពរតែប៉ុណ្ណោះ។

ប៉ុន្តែផ្ទុយមកវិញ ក្នុងករណីមួយចំនួនមិនអាចប្តឹងឧទ្ធរណ៍បានទេ ឬយើងអាចនិយាយបានថា មិនមែនជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍មានដូចខាងក្រោម ៖

- គូភាគីបានព្រមព្រៀងគ្នាមិនប្តឹងឧទ្ធរណ៍ ដោយរក្សាទុកនូវសិទ្ធិប្តឹងសាទុក្ខ ក្រោយពេលតុលាការបានចេញសាលក្រមចុងក្រោយ។[19] ការព្រមព្រៀងប្តឹងសាទុក្ខផ្លោះទៅតុលាការកំពូល ដែលភាគីលះបង់នូវការ វិនិច្ឆ័យទៅលើអង្គសេចក្តីលើកទី២ របស់តុលាការនៃបណ្តឹងឧទ្ធរណ៍ ហើយអាចទាមទារការវិនិច្ឆ័យដោយតុលាការនៃបណ្តឹងសាទុក្ខបាន។ ពិសេសជាងនេះការព្រមព្រៀងនេះផងដែរ ចាំបាច់ត្រូវតែធ្វើជាលាយលក្ខណ៍អក្សរ ទើបមានអានុភាព។[20] ឧទាហរណ៍ ៖ ដើមចោទ "ក" និងចុងចម្លើយ "ខ" បានព្រមព្រៀងគ្នាមិនប្តឹងឧទ្ធរណ៍ដោយរក្សាសិទ្ធិប្តឹងសាទុក្ខទៅ

[18] មាត្រា ២៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[19] មាត្រា ២៦០ កថាខណ្ឌទី ១ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[20] មាត្រា ២៦០ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

តុលាការកំពូល ដោយធ្វើជាលាយលក្ខណ៍អក្សរក្នុងគោលបំណងលះបង់នូវការ វិនិច្ឆ័យទៅលើការជំនុំជម្រះលើកទី២ រួចផ្លោះទៅប្តឹងសាទុក្ខចំពោះសាលក្រម របស់សាលាដំបូង។

- សាលក្រមចុងក្រោយនោះវិនិច្ឆ័យទៅលើរឿងក្តីរដ្ឋប្បវេណី ឬ ពាណិជ្ជកម្មដែលមានតម្លៃកម្មវត្ថុនៃបណ្តឹងមិនលើសពី ៥លានរៀល។[21] កម្មវត្ថុនៃតម្លៃទឹកប្រាក់ចំនួន ៥ លានរៀលនេះ ដោយយោងតាមការស្នើសុំរបស់ភាគីកម្ពុជា នៅក្នុងសិក្ខាសាលាហ្វឹកហ្វឺនអ្នករៀបចំសេចក្តីព្រាងច្បាប់ នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០១ ហើយចាំបាច់ត្រូវសម្រួលជាមួយនឹងសេចក្តីព្រាងច្បាប់ស្តីពីការចាត់តាំងតុលាការផងដែរ។ ឧទាហរណ៍ ៖ ភាគី "ក" បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ចំនួន ៣លានរៀល ដែលជារឿងក្តីចេញពីសាលក្រមចុងក្រោយមកមានតម្លៃនៃកម្មវត្ថុតិចជាង ៥លានរៀល ដូច្នេះសាលក្រមនេះមិនអាចប្តឹងឧទ្ធរណ៍បានទេ។
- សាលក្រមរៀប មិនអាចក្លាយជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍នោះទេ ពីព្រោះសាលក្រមមិនមែនជាសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី១ ។ ដោយឆ្លងកាត់តាមការលើកឡើងពីខាងលើ សាលក្រមរៀបពុំមានអានុភាពអ្វីផ្សេង ក្រៅអ្វីអានុភាពដើម្បីត្រៀមចេញសាលក្រមចុងក្រោយក្នុងការជំនុំជម្រះ ហើយពុំមានអាជ្ញាអស់ជំនុំ ឬអានុភាពអនុវត្តទេ ដូច្នេះ សាលក្រមរៀប នេះមិនមែនជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ទេ។[22]
- សេចក្តីសម្រេចរបស់សាលាដំបូងដែលមិនអាចធ្វើការឧបាស្រ័យតែម្តង ៖ គឺមិនមែនជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ទេ ដូចជាដីកាសម្រេចអំពីការតវ៉ាចំពោះការដឹកនាំនីតិវិធី ឬ ដីកាសម្រេចបង្អង់នីតិវិធីនៃបណ្តឹងជាដើម។
- សេចក្តីសម្រេចដែលអាចធ្វើឧបាស្រ័យដោយបណ្តឹងជំទាស់ ៖ គឺមិនអាចប្តឹងឧទ្ធរណ៍បានទេ ពោលមិនមែនជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ឬដីកាសម្រេចរបស់សាលាដំបូង មិនអាចធ្វើបណ្តឹងឧទ្ធរណ៍បានទេ។ ឧទាហរណ៍ ៖ ដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ ឬ ដីកាសម្រេចលើកចោលពាក្យសុំថែរក្សាការពារភស្តុតាងជាដើម។
- ចំពោះសេចក្តីសម្រេចលើបន្ទុកនៃប្រាក់ប្រដាប់ក្តី ដែលជាប់ជាមួយនឹងសាលក្រមចុងក្រោយ មិនអាចប្តឹងឧទ្ធរណ៍ដោយឯករាជ្យបានឡើយ។[23]

---

[21] មាត្រា ២៦០ កថាខណ្ឌទី ១ ចំណុច ខ ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[22] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគ ១ នីតិវិធីបណ្តឹង

[23] មាត្រា ២៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

បន្ថែមពីលើនេះទៅទៀត ក្នុងករណីដែលតុលាការនៃការជំនុំជម្រះលើកទី១ ចេញសាលក្រមកំបាំងមុខ បើភាគីបន្តការវិនិច្ឆ័យនៅតុលាការនៃការជំនុំជម្រះលើកទី១ ហើយភាគីមានល័ក្ខខ័ណ្ឌគ្រប់គ្រាន់ដើម្បីប្តឹងទាស់មិនអាចធ្វើបណ្តឹងឧទ្ធរណ៍។[24] ប៉ុន្តែបើភាគីនោះលះបង់នូវផលប្រយោជន៍ដែលបន្តការវិនិច្ឆ័យនៅតុលាការនៃការជំនុំជម្រះលើកទី១ គឺអាចប្តឹងឧទ្ធរណ៍បានចំណែកឯភាគីដែលខ្វះល័ក្ខខ័ណ្ឌគ្រប់គ្រាន់ដើម្បីប្តឹងទាស់ ក៏អាចប្តឹងឧទ្ធរណ៍បានដែរ ហើយចំពោះការប្តឹងទាស់លើសាលក្រមកំបាំងមុខបានចេញសាលក្រមចុងក្រោយរួចហើយក៏អាចប្តឹងឧទ្ធរណ៍បានដែរ។

មួយវិញទៀត បណ្តឹងឧបាស្រ័យចំពោះសាលដីកាចុងក្រោយរបស់សាលាឧទ្ធរណ៍ ដែលបានចេញក្នុងនាមជាការសម្រេចសេចក្តីនៃការជំនុំជម្រះលើកទី១ អាចប្តឹងបានត្រឹមតែសាទុក្ខប៉ុណ្ណោះ។[25] លើសពីនេះទៅទៀត ក្នុងករណីដែលតុលាការនៃការជំនុំជម្រះលើកទី១ ចេញសាលក្រមកំបាំងមុខ ទោះបីជាលក្ខខណ្ឌដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ មាត្រា ២០៤ ត្រូវបានបំពេញក៏ដោយក៏ភាគីអាចលះបង់ផលប្រយោជន៍ ក្នុងការបន្តអោយវិនិច្ឆ័យនៅថ្នាក់ដដែលដោយដាក់បណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខនោះ ហើយអាចប្តឹងឧទ្ធរណ៍បានដែរ។ ប្រសិនបើលក្ខខណ្ឌដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ មាត្រា ២០៤ នោះ មិនត្រូវបានបំពេញភាគីមិនអាចប្តឹងទាស់ចំពោះសាលក្រមកំបាំងមុខបានឡើយ ហេតុដូច្នេះបណ្តឹងឧទ្ធរណ៍ គឺជាវិធីតែមួយនៃបណ្តឹងឧបាស្រ័យចំពោះសាលក្រមកំបាំងមុខនោះ។

**១.២.១.២ មូលហេតុ**

មូលហេតុដែលភាគីអាចប្តឹងឧទ្ធរណ៍បានមាន ៤ ស្ថានភាព ដូចជា ៖

- សាលក្រមនៃការជំនុំជម្រះលើកទី១ មានកំហុស[26] ៖ ជាស្ថានភាពដែលសាលក្រមនោះមានកំហុសឬសេចក្តីសម្រេចបញ្ចប់នៃសាលក្រមដើម មានលក្ខណៈមិនត្រឹមត្រូវផ្អែកតាមសំអាងហេតុផ្សេងៗរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ ( ភស្តុតាង និងច្បាប់សារធាតុ ) ដូចជាអត្ថិភាពឬនត្ថិភាពនៃកាតព្វកិច្ច ការលើកឡើងអំពីមូលហេតុនៃការរំលោយ ឬលុបចោល ឬមោឃភាពនៃកិច្ចសន្យាជាអាទិ៍។ ឧទាហរណ៍ ៖ ដើមចោទ " ក " បានប្តឹង ចុងចម្លើយ " ខ " ទៅសាលាដំបូងខេត្តព្រៃវែង តុលាកាចេញសាលក្រមលេខ ១៧៧ " ច " ចុះថ្ងៃទី ០១ ខែមីនា ឆ្នាំ ២០២២ ដែលមានខ្លឹមសារថា បង្គាប់ចុងចម្លើយ " ខ " ធ្វើនីតិវិធីលុបចោលការចុះបញ្ជីផ្ទេរកម្មសិទ្ធិលើដីទាំងមូលមួយកន្លែងដែលមានទីតាំង នៅខេត្តព្រៃវែង ដោយមូលហេតុរំលាយកិច្ចសន្យាលក់ទិញចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០២១។

---

[24] មាត្រា ២០៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[25] មាត្រា ២៥៩ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[26] មាត្រា ២៧៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

តុលាការយល់ឃើញថា មានមូលហេតុនៃការរំលាយកិច្ចសន្យា ប៉ុន្តែភាគីយល់ថា តាមលក្ខណៈសារធាតុ គ្មានមូលហេតុរំលាយកិច្ចសន្យាទេ ដូចនេះ សាលក្រមនេះត្រូវបាន " ខ " ប្ដឹងឧទ្ធរណ៍។

- នីតិវិធីនៅតុលាការនៃការជំនុំជម្រះលើកទី ១ នោះមានលក្ខណៈផ្ទុយនឹងច្បាប់ធ្ងន់ធ្ងរ ៖ ជាស្ថានភាពដែលសាលាដំបូងបានជម្រះក្ដីដោយបំពានលើនីតិវិធី ដែលច្បាប់បានកំណត់ដូចជាទាក់ទងទៅនឹងការពិនិត្យ ភស្តុតាង ការបញ្ជូន និងការប្រកាសសាលក្រមជាដើម។[27] ចំណុចទាក់ទងនឹងការពិនិត្យភស្តុតាង ៖ ឧទាហរណ៍ ៖ ដើមចោទ " ក " បានដាក់ពាក្យបណ្ដឹងប្ដឹង " ខ " បង់ប្រាក់ចំនួន ៥០០០០ ដុល្លារ ដោយយោងទៅលើមូលហេតុនៃកិច្ចសន្យាលក់ទិញរថយន្ត ចុះថ្ងៃទី ០៨ ខែមករា ឆ្នាំ២០២២។ តុលាការបានធ្វើការសាកសួរ " គ " ដែលជាសាក្សីរបស់ " ក " នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ ដោយផ្អែកលើចម្លើយសាក្សី " គ " ដែលបានធ្វើនៅក្នុងនីតិវិធីត្រៀមនោះ តុលាការបានយកជាមូលដ្ឋាននៃការសម្រេច " ខ " បង់ប្រាក់ ៥០០០០ ដុល្លារ ទៅ " ក "។ " ខ " បានធ្វើបណ្ដឹងឧទ្ធរណ៍ចំពោះសាលក្រមនេះ ដោយមូលហេតុការជំនុំជម្រះលើកទី១ មានកំហុសនីតិវិធីធ្ងន់ធ្ងរ។ ជាធម្មតា នៅក្នុងនីតិត្រៀមសម្រាប់ការទាញហេតុផលមិនមានការសាកសួរសាក្សីទេ គ្រាន់តែជាដំណាក់កាលរៀបចំការអះអាងចំណុចវិវាទ និងភស្តុតាងតែប៉ុណ្ណោះ។
- ការលើកបណ្ដឹងចោលរបស់សាលាដំបូងមានលក្ខណៈមិនត្រឹមត្រូវ និងមានភាពចាំបាច់ក្នុងការទាញហេតុផលថែមទៀត ៖ ជាស្ថានភាពដែលសាលាដំបូង បានលើកចោលពាក្យបណ្ដឹងរបស់ដើមចោទដោយសាលក្រមមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ ដោយមូលហេតុពាក្យបណ្ដឹងរបស់ដើមចោទផ្ទុយច្បាប់មិនអាចកែតម្រូវបាន។[28] ឧទាហរណ៍ ៖ ដើមចោទ " ក " បានដាក់ពាក្យបណ្ដឹងប្ដឹងចុងចម្លើយ " ខ " សងប្រាក់ ២០០០០$ ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ដែលកំណត់ពេលសងនៅថ្ងៃទី១ ខែមករា ឆ្នាំ២០២២។ សាលាដំបូងបានលើកចោលពាក្យបណ្ដឹងដោយសាលក្រម ដោយមូលហេតុគ្មានផលប្រយោជន៍នៃបណ្ដឹង។ ដូច្នេះ ដើមចោទ " ក " បានធ្វើបណ្ដឹងឧទ្ធរណ៍ចំពោះសាលក្រមនេះ ដោយមូលហេតុថាសាលក្រមលើកចោលនេះមិនត្រឹមត្រូវ។
- ការជំនុំជម្រះលើកទី ១ មានកំហុសចំពោះសមត្ថកិច្ចផ្ដាច់មុខ ៖ ជាស្ថានភាពដែលសាលាដំបូងបានចេញសាលក្រម ចំពោះការទាមទារដែលមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន ដោយសារច្បាប់កំណត់ សមត្ថកិច្ចផ្ដាច់មុខចំពោះករណីណាមួយ ដូចជាបណ្ដឹងលែងលះ បណ្ដឹងទាមទារ បញ្ជាក់អំពី

---

[27] មាត្រា ២៧៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[28] មាត្រា ២៨១ កថាខណ្ឌទី១ និងទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

អត្ថិភាព ឬនត្ថិភាពនៃបុគ្គភាពជាអាទិ៍។[29] ឧទាហរណ៍ ៖ ដើមចោទ " ក " បានដាក់ពាក្យបណ្តឹងទាមទារ ទទួលស្គាល់កូន ដោយយក " ខ " ជាចុងចម្លើយ។ ដើមចោទ " ក " មានលំនៅឋាននៅខេត្តបាត់ដំបង " ខ " មានវត្តមានចុងក្រោយនៅប្រទេសកម្ពុជានៅក្នុងខេត្ត ព្រៃវែង ប៉ុន្តែបានចាកចេញទៅបរទេសជាង ១២ ឆ្នាំមកហើយ។ សាលាដំបូងខេត្តព្រៃវែង បានចាត់ការពាក្យបណ្តឹងនេះហើយសម្រេច ទទួលស្គាល់ "ក" ជាកូនរបស់ " ខ "។ " ខ " បានប្តឹងឧទ្ធរណ៍ចំពោះសាលក្រមនេះ ដោយមូលហេតុថា សាលាដំបូងខេត្ត ព្រៃវែង មិនមានសមត្ថកិច្ចក្នុងចាត់ការបណ្តឹង ព្រោះការជំនុំជម្រះលើបណ្តឹងទាមទារ ទទួលស្គាល់កូន គឺជាសមត្ថកិច្ចផ្តាច់មុខរបស់សាលាដំបូង នៃលំនៅឋានរបស់ភាគីនៃទំនាក់ទំនងឋានៈបុគ្គល។ ក្នុងករណីលំនៅឋាន ឬ ទីសំណាក់របស់ភាគីនៃទំនាក់ទំនងឋានៈបុគ្គលមិនអាចកំណត់បានដោយសារករណីជាក់ស្តែងនីមួយៗ ច្បាប់សន្មតថា តុលាការដែលមានសមត្ថកិច្ចលើរឿងក្តីប្រភេទនេះ គឺសាលាដំបូងរាជធានីភ្នំពេញ។

### ១.២.២ ល័ក្ខខ័ណ្ឌនៃការធ្វើបណ្តឹងឧទ្ធរណ៍

នៅពេលដែលភាគីបានយល់ដឹងនៅកម្មវត្ថុ និងមូលហេតុដែលអាចប្តឹងឧទ្ធរណ៍រួចហើយ។ បន្ទាប់មកភាគីបានដឹងខ្លួនឯងហើយថាមាន សិទ្ធិក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ ( ១.២.២.១ ) និង ភាគីត្រូវដឹងអំពីអំឡុងពេលក្នុងការធ្វើបណ្តឹង ( ១.២.២.២ ) ដើម្បីការប្តឹងឧទ្ធរណ៍ប្រព្រឹត្តទៅបានដោយត្រឹមត្រូវ និងមានអានុភាពតាមដំណើរការនៃនីតិវិធីផងដែរ។

#### ១.២.២.១ អ្នកដែលមានសិទ្ធិប្តឹងឧទ្ធរណ៍

ភាគី ( ដើមចោទ ឬចុងចម្លើយ ) ដែលបាត់បង់នូវផលប្រយោជន៍ដោយសារតែសាលក្រមនៃការជំនុំជម្រះលើកទី ១ មានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍។ ការដែលបាត់បង់នូវផលប្រយោជន៍នោះ គេហៅថា មានផលប្រយោជន៍ក្នុងការប្តឹងឧបាស្រ័យ បានសេចក្តីថា ភាគីណាដែលបាត់បង់ផលប្រយោជន៍ពីការជំនុំជម្រះនៅសាលាដំបូង គឺគាត់មានផលប្រយោជន៍ក្នុងការទាមទារ ផលប្រយោជន៍របស់គាត់មកវិញតាមរយៈការប្តឹងឧទ្ធរណ៍។[30] លើលពីនេះទៅទៀត បើយកខ្លឹមសារនៃសាលក្រមដែលដើមចោទ ឬចុងចម្លើយនៃការជំនុំជម្រះលើកទី១ ដែលដាក់ពាក្យបណ្តឹងឧទ្ធរណ៍ បានទាមទារអោយតុលាការចេញ នៅក្នុងការជំនុំជម្រះលើកទី១ មកបើប្រៀបធៀបជាមួយនឹងសាលក្រមនៃការជំនុំជម្រះលើកទី ១ ហើយក្នុងករណីដែលសាលក្រមនោះ មានទំហំតូចជាងការទាមទាររបស់របស់ភាគីនោះ ទើបផលប្រយោជន៍ក្នុងការប្តឹងឧទ្ធរណ៍ ត្រូវបានតុលាការទទួលស្គាល់។ ប្រសិនបើភាគីណាដែលឈ្នះក្តីទាំងស្រុងនៅក្នុងការជំនុំជម្រះលើកទី ១ នោះគ្មានផលប្រយោជន៍ក្នុង

[29] មាត្រា ២៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[30] មាត្រា ២៦០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ការប្តឹងឧបាស្រ័យ គឺគ្មានសិទ្ធិប្តឹងឧទ្ធរណ៍នោះទេ ហើយបើភាគីនោះនៅតែប្តឹងឧទ្ធរណ៍ នាំបណ្តឹងឧទ្ធរណ៍នោះត្រូវបានលើកចោលដោយចៅក្រម ដោយសារតែបណ្តឹងនោះមានលក្ខណៈផ្ទុយនឹងច្បាប់។[31] ឧទាហរណ៍ ៖ ដើមចោទ "ក" បានដាក់ពាក្យបណ្តឹងទាមទារ តុលាការបង្គាប់ ចុងចម្លើយ "ខ" សងប្រាក់មកខ្លួនចំនួន ២០០០០ ដុល្លារ លុះមកដល់នីតិវិធីចេញសាលក្រម តុលាការក៏បានចេញសាលក្រមបង្គាប់ ចុងចម្លើយ "ខ" សងប្រាក់ចំនួន ២០០០០ ដុល្លារ មក ដើមចោទ "ក" ដូចនេះនាំឱ្យចុងចម្លើយ "ខ" ជាភាគីដែលបាត់បង់ផលប្រយោជន៍ដោយសារសាលក្រមរបស់សាលាដំបូង ហេតុនេះ ចុងចម្លើយ "ខ" មានផលប្រយោជន៍ក្នុងការធ្វើបណ្តឹងឧទ្ធរណ៍បាន។ ឧទាហរណ៍ ៖ ដើមចោទ "ក" បានដាក់ពាក្យបណ្តឹងទាមទារទៅតុលាការបង្គាប់ឱ្យចុងចម្លើយ "ខ" សងប្រាក់មកខ្លួនចំនួន ២០០០០ ដុល្លារ លុះមកដល់នីតិវិធីចេញសាលក្រម តុលាការក៏បានចេញសាលក្រមច្រាលចោលការទាមទាររបស់ដើមចោទ "ក" នាំឱ្យដើមចោទ "ក" ជាភាគីដែលបាត់បង់ផលប្រយោជន៍ដោយសារតែសាលក្រមរបស់សាលាដំបូង ហេតុនេះដើមចោទ "ក" មានផលប្រយោជន៍ក្នុងការធ្វើបណ្តឹងឧទ្ធរណ៍បាន។ ឧទាហរណ៍ ៖ យោងតាមករណីទាំងពីរខាងលើ បើសាលាដំបូងចេញសាលក្រម បង្គាប់ចុងចម្លើយភាគី "ខ" បង់ប្រាក់ចំនួន ១០០០០ ដុល្លារនៃការទាមទារប្រាក់ចំនួន ២០០០០ ដុល្លារមក ដើមចោទភាគី "ក"។ ក្នុងករណីនេះទាំងចុងចម្លើយ និងដើមចោទ សុទ្ធសឹងតែជាភាគីដែលបាត់បង់ផលប្រយោជន៍ ហេតុនេះភាគីទាំងពីរ មានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ ប៉ុន្តែការប្តឹងឧទ្ធរណ៍របស់ ដើមចោទ គឺជាបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ។

ផ្ទុយមកវិញ សិទ្ធិប្តឹងឧទ្ធរណ៍ មិនអាចកើតមានឡើងទេ ក្នុងករណីដែលភាគីមានការព្រមព្រៀងជាមុនថា មិនប្តឹងឧទ្ធរណ៍ ដោយភាគីរក្សាសិទ្ធិប្តឹងសាទុក្ខ។ ការព្រមព្រៀងមិនប្តឹងឧទ្ធរណ៍នេះ មានលក្ខណៈខុសពីការព្រមព្រៀងផ្លោះទៅបណ្តឹងសាទុក្ខ គឺត្រូវបិទប្តឹងសាទុក្ខផងដែរដូចនេះ។

ក្រោយពេលសិទ្ធិប្តឹងឧទ្ធរណ៍កើតឡើង ភាគីដែលមានសិទ្ធិប្តឹងឧទ្ធរណ៍ អាចលះបង់សិទ្ធិនេះបានដែរ[32] ការលះបង់សិទ្ធិប្តឹងឧទ្ធរណ៍នេះត្រូវធ្វើឡើងតាមសេចក្តីថ្លែងការណ៍។ ប្រសិនបើភាគីលះបង់សិទ្ធិប្តឹងឧទ្ធរណ៍ក្រោយពេល ដាក់ពាក្យបណ្តឹងឧទ្ធរណ៍ សេចក្តីថ្លែងការណ៍អំពីការលះបង់សិទ្ធិប្តឹងឧទ្ធរណ៍នោះ ត្រូវធ្វើឡើងជាមួយគ្នា នឹងការដកពាក្យបណ្តឹងឧទ្ធរណ៍។[33]

[31] មាត្រា ២៦៨ និង ២៧៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[32] មាត្រា ២៦៣ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[33] មាត្រា ២៦៣ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

### ១.២.២.២ អំឡុងពេលប្តឹងឧទ្ធរណ៍

បណ្តឹងឧទ្ធរណ៍ត្រូវធ្វើឡើងក្នុងអំឡុងពេល ១ ខែ ដោយគិតពីថ្ងៃដែលបានទទួលនូវការបញ្ជូននៃលិខិតសាលក្រម នៃការជំនុំជម្រះលើកទី១។[34] ឧទាហរណ៍ ៖ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២២ ភាគីបានទទួលលិខិតសាលក្រម ច្បាប់ទុករយៈពេលភាគីណាមួយដែលបាត់បង់ផលប្រយោជន៍ ឬមិនសុខចិត្តទៅនឹងសេចក្តីសម្រេចរបស់តុលាការជាន់ទាប ក្នុងរយៈពេល ១ខែ ដូច្នេះផុតអំឡុងពេលប្តឹងឧទ្ធរណ៍នៅ ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ ២០២២។

ចំពោះករណីតុលាការលើកចោល ឬច្រានចោលបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ ការប្តឹងឧទ្ធរណ៍អាចធ្វើទៅបានដែលភាគីមានប្រយោជន៍ក្នុងការប្តឹងឧទ្ធរណ៍ត្រូវធ្វើឡើងក្នុងអំឡុងពេល ១ ខែ គិតចាប់ពីថ្ងៃបានទទួលដំណឹងអំពីដីកាសម្រេចច្រានចោល ឬលើកចោលនូវបណ្តឹងទាស់នោះ។ ឧទាហរណ៍ ៖ នៅថ្ងៃទី១០ ខែ មករា ឆ្នាំ ២០២២ ជាថ្ងៃដែលភាគីបាន ទទួលសាលក្រមកំបាំងមុខ ច្បាប់ទុកអំឡុងពេលសម្រាប់ប្តឹងទាស់ចំនួន ១៤ ថ្ងៃ ឬ២ សប្តាហ៍។ នៅថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០២២ ភាគីក៏បានដាក់ពាក្យបណ្តឹងទាស់ ក្រោយមកនៅថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០២២ ភាគីក៏បានទទួលដំណឹងអំពីការសម្រេចច្រានចោលនូវបណ្តឹងទាស់នោះ ដូចនេះ គិតចាប់ពីថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០២២ រហូតដល់ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០២២ មានរយៈពេល ១ ខែ គឺជាអំឡុងពេលប្តឹងឧទ្ធរណ៍ ចំពោះចាប់ពីថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០២២ តទៅជាថ្ងៃដែលផុតអំឡុងពេលប្តឹងឧទ្ធរណ៍។

ជាធម្មតាអំឡុងពេលប្តឹងឧទ្ធរណ៍មិនអាចពន្យាបានឡើយ ប៉ុន្តែក្នុងករណីដែលភាគីដែលមានសិទ្ធិប្តឹងឧទ្ធរណ៍ មិនអាចប្តឹងឧទ្ធរណ៍បានក្នុងអំឡុងពេលនេះ ដោយមូលហេតុដែលមិនមែនជាកំហុសរបស់ខ្លួនទេ ភាគីនោះអាចបំពេញនូវសកម្មភាពបណ្តឹងពេលក្រោយបាន អំឡុងពេល ១ សប្តាហ៍ ឬ២ ខែ ចំពោះភាគីដែលនៅបរទេសក្រោយពីមូលហេតុនោះបានរលត់ហើយ។[35]

ដើម្បីធ្វើបណ្តឹងឧទ្ធរណ៍ក្នុងករណីនេះ ភាគីគ្រាន់តែដាក់ពាក្យបណ្តឹងឧទ្ធរណ៍ជាធម្មតា ក្នុងអំឡុងពេលមួយ សប្តាហ៍គិតពីថ្ងៃដែលហេតុ នាំឱ្យខកខាននោះបានរលត់ និងភាគីត្រូវធ្វើការអះអាង និងបញ្ជាក់ដោយ ភស្តុតាងថា ការមិនអាចធ្វើបណ្តឹងឧទ្ធរណ៍ ក្នុងអំឡុងពេលកំណត់នោះបាន មិនមែនដោយសារកំហុសរបស់ខ្លួនទេជាការគ្រប់គ្រាន់។

ប្រសិនបើអំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍កន្លងហួស ភាគីដែលមានសិទ្ធិប្តឹងឧទ្ធរណ៍ បាត់បង់សិទ្ធិនោះ។ បើពាក្យបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ ក្រោយអំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍កន្លងហួសបណ្តឹង

---

[34] មាត្រា ២៦៤ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[35] មាត្រា ២៤៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ឧទ្ធរណ៍នោះ នឹងត្រូវបានលើកចោលដោយសាលដីកា ដោយសារបណ្តឹងឧទ្ធរណ៍នោះមានលក្ខណៈផ្ទុយនឹងច្បាប់។[36] ម្យ៉ាងទៀត ក្រោយពេលសាលក្រមនៃការជំនុំជម្រះលើកទី ១ ត្រូវបានប្រកាសទោះបីជាមិនទាន់ទទួលការបញ្ជូនសាលក្រមក៏ដោយ ក៏ភាគីអាចប្តឹងឧទ្ធរណ៍ដោយស្របច្បាប់បានដែរ។[37] ម្យ៉ាងទៀតក្រោយពេលសាលក្រមនៃការជំនុំជម្រះលើកទី១ ត្រូវបានប្រកាស ទោះបីជាមិនទាន់ទទួលបានការបញ្ជូនសាលក្រមក៏ដោយ ក៏ភាគីអាចប្តឹងឧទ្ធរណ៍ដោយស្របច្បាប់បានដែរ។ បានសេចក្តីថាទោះបីជាសិទ្ធិប្តឹងឧទ្ធរណ៍ត្រូវបានរលត់ហើយក៏ដោយ ភាគីក៏នៅតែអាចប្តឹងឧទ្ធរណ៍បានដែរ បណ្តឹងនេះហៅថា បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំដែលជាបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំធ្វើឡើងដោយឯករាជ្យ។

### ១.២.៣ អានុភាពនៃការដាក់ពាក្យបណ្តឹងឧទ្ធរណ៍

ដើម្បីមានអានុភាពទៅ លើសាលក្រមដើមដែលអាច (បង្អាក់នូវការចូលជាស្ថាពរនៃសាលក្រម ១.២.៣.១) បាន នោះការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ចាំបាច់បំផុត គឺត្រូវដាក់ ទាន់ពេលវេលា។ ហើយដំណើរការនៃការជម្រះក្តីនៅតុលាការដើមត្រូវបានផ្ទេរមក តុលាការនៃបណ្តឹងឧទ្ធរណ៍ ដែលគេឈ្មោះថា (អានុភាពនៃការផ្ទេរការជំនុំជម្រះក្តីដោយបណ្តឹងឧទ្ធរណ៍១.២.៣.២) ដែលតុលាការនៃបណ្តឹងឧទ្ធរណ៍មានសិទ្ធិពេញលេញក្នុងការវិនិច្ឆ័យនៃការទាមទារនោះ។ ជួនកាលភាគីដែលធ្វើបណ្តឹងឧទ្ធរណ៍ មិនសុខចិត្តលើសាលក្រមតែផ្នែកណាមួយនៃ សាលក្រមប៉ុណ្ណោះ ប៉ុន្តែអានុភាពបង្អាប់នូវការចូលជាស្ថាពរនៃសាលក្រមទាំងមូលតែម្តង ដែលមិនមានអានុភាពក្នុងការអនុវត្តសាលក្រមឡើយ នេះហៅថា (អានុភាពអវិភាគនៃបណ្តឹងឧទ្ធរណ៍ ១.២.៣.៣)។

#### ១.២.៣.១ អានុភាពបង្អាក់នូវការចូលជាស្ថាពរនៃសាលក្រម

ជាធម្មតាពេលដែលបណ្តឹងឧទ្ធរណ៍ត្រូវបានធ្វើក្នុងអំឡុងពេលដែលបានកំណត់ ទោះជាអំឡុងពេលដែលកំណត់នោះបានកន្លងផុតទៅហើយក៏ដោយ ក៏សាលក្រមដើមនៃការជំនុំជម្រះលើកទី ១ មិនទាន់ចូលជាស្ថាពរដែរ នេះគេហៅថាអានុភាពបង្អាក់នូវការចូលជាស្ថាពរនៃសាលក្រម។[38] បានសេចក្តីថា អានុភាពបង្អាក់ការចូលជាស្ថាពរនៃសាលក្រម ជាស្ថានភាពដែលរារាំងការចូលជាស្ថាពរនៃសាលក្រម ចុងក្រោយ នៃការជំនុំជម្រះលើកទី ១ ដោយសារអានុភាពនៃការដាក់ពាក្យបណ្តឹងឧទ្ធរណ៍តាមច្បាប់កំណត់។ ពេលដែលបណ្តឹងឧទ្ធរណ៍ត្រូវបានធ្វើ ក្នុងអំឡុងពេលដែលកំណត់អោយធ្វើបណ្តឹងឧទ្ធរណ៍ ទោះជាអំឡុងពេលដែលកំណត់ធ្វើ

[36] មាត្រា ២៦៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[37] មាត្រា ២៦៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធិរដ្ឋប្បវេណី ឆ្នាំ ២០០៦

[38] មាត្រា ១៩៣ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

បណ្តឹងឧទ្ធរណ៍នោះបានកន្លងផុតទៅហើយក៏ដោយ ក៏សាលក្រមដើម ឬសាលក្រមនៃការជំនុំជម្រះលើកទី ១ មិនចូលជាស្ថាពរដែរ។[39]

### ១.២.៣.២ អានុភាពនៃការផ្ទេរការជម្រះក្តី

អានុភាពនៃការផ្ទេរការជម្រះក្តីដោយបណ្តឹងឧទ្ធរណ៍ គឺនៅពេលដែលបណ្តឹងឧទ្ធរណ៍ ការចាត់ចែងនៃការទាមទារដែលបានជំនុំជម្រះក្នុងសាលក្រមដើមត្រូវផ្ទេរពីសាលាជំនុំជម្រះលើកទី ១ ទៅតុលាការនៃបណ្តឹងឧទ្ធរណ៍។ បណ្តឹងឧទ្ធរណ៍ដែលបានធ្វើឡើងក្នុងអំឡុងពេលដែលបានកំណត់ មានអានុភាពផ្ទេរការទាមទារពីសាលាដំបូងទៅសាលាឧទ្ធរណ៍ គឺមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដើមទៀតទេ ពោលគឺស្ថិតក្រោមសមត្ថកិច្ចរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍។[40]

### ១.២.៣.៣ អានុភាពនៃអវិភាគនៃបណ្តឹងឧទ្ធរណ៍

ភាពអវិភាគនៃបណ្តឹងឧទ្ធរណ៍ ដើមចោទ ប្តឹងឧបាស្រ័យតែផ្នែកណាមួយនៃសាលក្រមដើមក៏ដោយ ក៏នាំ អានុភាពនៃការបង្អាក់នូវការចូលជាស្ថាពរនៃសាលក្រម និងអានុភាពនៃការផ្ទេរការជម្រះក្តី កើតមានឡើងចំពោះការទាមទារទាំងអស់ដែលបានសម្រេចនៅក្នុងសាលក្រមដើម។ បានសេចក្តីថា បណ្តឹងឧទ្ធរណ៍ដែលបានធ្វើឡើងក្នុងអំឡុងពេល ដែលច្បាប់បានកំណត់ មានអានុភាពបង្អាក់ការចូលជាស្ថាពរនៃសាលក្រមចុងក្រោយរបស់ សាលាដំបូងទាំងមូល ទោះបីជាបណ្តឹងឧទ្ធរណ៍ធ្វើឡើយចំពោះតែផ្នែកណាមួយនៃសាលក្រមចុងក្រោយរបស់សាលាដំបូងក៏ដោយ។[41] ឧទាហរណ៍ ៖ សាលក្រមរបស់សាលាដំបូងលេខ ៨៤៨ " ឆ១ " ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារ ៖

១. បង្គាប់ឱ្យចុងចម្លើយសងប្រាក់ដើមចំនួន ៦០០០០$ មកដើមចោទ។

២. បង្គាប់ឱ្យចុងចម្លើយសងការប្រាក់ចំនួន ១៤ % ក្នុងមួយឆ្នាំ។

៣. បង្គាប់ឱ្យចុងចម្លើយសងការប្រាក់ពិន័យស្មើចំនួន ២ដង នៃអត្រាការប្រាក់ក្នុងកិច្ចសន្យា។

៤. បង្គាប់ឱ្យចុងចម្លើយសងការខូចខាត ពេលវេលា និងជំងឺចិត្តចំនួន ១០០០$។

ក្រោយមកចុងចម្លើយប្តឹងឧទ្ធរណ៍ចំនុច ទី២ ទី៣ និងទី៤។ ដូច្នេះ ក្នុងករណីចុងចម្លើយធ្វើបណ្តឹងឧទ្ធរណ៍តែចំណុចទី២ ទី៣ និងទី៤ នាំឱ្យសាលក្រមទាំងមូលមិនចូលជាស្ថាពរនោះទេ ហេតុនេះទោះបីជាចំណុចទី១ ដែលចុងចម្លើយមិនប្តឹងឧទ្ធរណ៍ក៏ដោយ ក៏ចំណុចទី១ នេះមិនចូលជាស្ថាពរដែរ។ សរុបជារួមបើទោះបីដើមបណ្តឹងឧទ្ធរណ៍ប្តឹងឧបាស្រ័យតែផ្នែកណាមួយនៃសាលក្រមដើមក៏ដោយ

[39] មាត្រា ១៩៣ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[40] មាត្រា ២៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[41] មាត្រា ១៩៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ក៏នៅតែមានអានុភាពនៃការបង្អាក់នូវការចូលជាស្ថាពរនៃសាលក្រម និងមានអានុភាពនៃការផ្ទេរការជម្រះក្តីកើតមានឡើងដែរ ចំពោះការទាមទារទាំងអស់នៅក្នុងសាលក្រមដើម ដែលគេហៅថា អានុភាពអវិភាគនៃបណ្តឹងឧទ្ធរណ៍។

ដូច្នេះនៅពេលដែលមានបណ្តឹងឧទ្ធរណ៍ ដោយហេតុថាសាលក្រមដើម ត្រូវបានរារាំងនូវអានុភាពចូលស្ថាពរ ហើយសូម្បីតែផ្នែកដែលដើមបណ្តឹងឧទ្ធរណ៍បានឈ្នះក្តី ក៏ត្រូវបានបង្អាក់មិន ចូលជាស្ថាពរដែរនោះ ដើមបណ្តឹងឧទ្ធរណ៍បានឈ្នះក្តី ក៏ត្រូវបានបង្អាក់មិន ចូលជាស្ថាពរដែរនោះ ដើមបណ្តឹងឧទ្ធរណ៍ មិនអាចនឹងធ្វើការអនុវត្តដោយបង្ខំដោយផ្អែកលើសាលក្រមដើមបានទេ ប្រសិនបើមិនមានការប្រកាស ធ្វើការអនុវត្តជាបណ្តោះអាសន្ន ទៅលើផ្នែកដែលខ្លួនឈ្នះនៅក្នុងសាលក្រមទេ នោះ។ ឧទាហរណ៍ ៖ ដើមចោទបានប្តឹងដោយរួមបញ្ចូលនូវការទាមទារ ចុងចម្លើយសងប្រាក់ចំនួន ៤០ លានរៀល និងការទាមទារ បញ្ជាក់ដី ( Y ) មួយកន្លែង។ ប៉ុន្តែចុងចម្លើយក៏បានដឹងពាក្យបណ្តឹងតបដែលទាមទារ បញ្ជាក់ថា ចុងចម្លើយនៅតែ មានកម្មសិទ្ធិលើដី (Y) នោះដដែល ពេលនោះតុលាការសម្រេចទទួលស្គាល់សិទ្ធិលើបំណុលរបស់ដើមចោទ ចំនួន ៤០ លានរៀល តែតុលាការច្រានចោលនូវការទាមទារនៃបណ្តឹងតបរបស់ចុងចម្លើយ។ ក្នុងករណីនេះប្រសិនបើដើមចោទ ដាក់ពាក្យបណ្តឹងឧទ្ធរណ៍ដោយប្តឹងចំពោះផ្នែកដែលតុលាការដើម ច្រានចោលនូវទាមទារ បញ្ជាក់កម្មសិទ្ធិរបស់ខ្លួន និងផ្នែកដែលទទួលស្គាល់ការទាមទារឱ្យបញ្ជាក់កម្មសិទ្ធិរបស់ចុងចម្លើយផងដែរ។ នាំអោយសាលក្រមទាំងមូលត្រូវរារាំងនូវការចូលជាស្ថាពរដូច្នេះ ដើមចោទមិនអាចធ្វើការអនុវត្តសិទ្ធិទាមទារ ចុងចម្លើយសងប្រាក់ កំចីដោយផ្អែកទៅលើសាលក្រមដើមរបស់សាលាដំបូងបានទេ។ ប៉ុន្តែក្នុងករណីខ្លះ ប្រសិនបើចុងចម្លើយ មិនធ្វើឧបាស្រ័យចំពោះការទាមទារឱ្យសងប្រាក់កំចីនេះទេ ដើមចោទអាចដាក់ពាក្យសុំទៅតុលាការនៃបណ្តឹងឧទ្ធរណ៍ សុំឱ្យប្រកាសនូវការអនុវត្តជាបណ្តោះអាសន្ន ទៅលើតែផ្នែកនៃសិទ្ធិលើបំណុលដែលសម្រេចដោយសាលក្រមដើមបាន។[42] បើធ្វើដូច្នេះ ទោះបីជាសាលក្រមនោះមិនទាន់ចូលជាស្ថាពរ ក៏ដោយ ក៏អាចអនុវត្តដោយបង្ខំបានដែរ។

ប៉ុន្តែក្នុងករណីតុលាការបានចេញសាលក្រម ហើយភាគីបានព្រមព្រៀងគ្នា មិនប្តឹងឧទ្ធរណ៍ចំពោះផ្នែកណាមួយនៃការទាមទារ ឬភាគីទាំងសងខាងលះបង់សិទ្ធិប្តឹងឧទ្ធរណ៍ និងសិទ្ធិប្តឹងឧទ្ធរណ៍បន្ទាប់បន្សំចំពោះផ្នែកណាមួយនៃការទាមទារនាំឱ្យផ្នែកនោះនៃសាលក្រមចុងក្រោយ ត្រូវចូលជាស្ថាពរ។ ឧទាហរណ៍ ៖ ដើមចោទ "ក" ប្តឹងចុងចម្លើយ "ខ" ទៅសាលាដំបូង ដែលមានខ្លឹមសារ ៖

១. បង្គាប់ឱ្យចុងចម្លើយ "ខ" បង់ប្រាក់ ២០០០០ ដុល្លារ ដើមចោទ "ក"។

[42] មាត្រា ២៧១ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

២. បង្គាប់ឱ្យចុងចម្លើយ "ខ" បង់ប្រាក់ក្នុងអត្រា ១០% ក្នុងមួយឆ្នាំនៃទឹកប្រាក់ ២០០០០ ដុល្លារ គិតចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០២២ រហូតសងរួច។

៣. បង្គាប់ឱ្យចុងចម្លើយ "ខ" បង់ប្រាក់ ១០០០០ ដុល្លារ មកដើមចោទ "ក"។

តុលាការចេញសេចក្ដីសម្រេចបញ្ចប់៖

១. បង្គាប់ឱ្យចុងចម្លើយ "ខ" បង់ប្រាក់ ១៣០០០ ដុល្លារ មកដើមចោទ "ក"

២. បង្គាប់ឱ្យចុងចម្លើយ "ខ" បង់ប្រាក់ក្នុងអត្រា ១០% ក្នុងមួយឆ្នាំ នៃទឹកប្រាក់ ១៣០០០ ដុល្លារ គិតចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០២២ រហូតសងរួច។

៣. បង្គាប់ឱ្យចុងចម្លើយ "ខ" បង់ប្រាក់ ១០០០០ ដុល្លារមក ដើមចោទ "ក"។

ដើមចោទ និង ចុងចម្លើយ បានព្រមព្រៀង មិនធ្វើបណ្ដឹងឧទ្ធរណ៍ និងបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំចំពោះចំណុចទី ១ និងទី ២ នៃសេចក្ដីសម្រេចបញ្ចប់របស់សាលក្រមនៃការជំនុំជម្រះលើកទី ១ ប៉ុន្តែចំពោះចំណុចទី ៣ ចុងចម្លើយអាចប្ដឹងឧទ្ធរណ៍។ ក្នុងករណីនេះ ចំណុចទី១ និងទី២ ត្រូវចូលជាស្ថាពរ ដោយមិនរង់ចាំផុតអំឡុងពេលនៃការប្ដឹងឧទ្ធរណ៍ទេ ហេតុនេះ ការព្រមព្រៀងមិនប្ដឹងឧទ្ធរណ៍ និងមិនប្ដឹងឧទ្ធរណ៍បន្ទាប់បន្សំនូវចំណុចណាមួយ ចំណុចដែលបានព្រមព្រៀងនោះនឹងចូលជាស្ថាពរ ទោះបីជាចំណុចផ្សេងទៀត ភាគីបានប្ដឹងឧទ្ធរណ៍។

មួយវិញទៀត ចំពោះផ្នែកដែលដើមបណ្ដឹងឧទ្ធរណ៍មិនអាចឧបាស្រ័យ ភាគីមិនចាំបាច់ធ្វើការទាញហេតុផលនោះទេ មានន័យថា ការទាញហេតុផលដោយផ្ទាល់មាត់ត្រូវធ្វើ ត្រឹមតែក្នុងទំហំដែលភាគីបានទាមទារ ផ្លាស់ប្ដូរនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ តែប៉ុណ្ណោះ។[43] ការផ្លាស់ប្ដូរសាលក្រមនៃការជំនុំជម្រះលើកទី ១ អាចធ្វើបានត្រឹមតែកម្រិតនៃឧបាស្រ័យ ដោយបណ្ដឹងឧទ្ធរណ៍ ឬបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំតែប៉ុណ្ណោះ មានន័យថា តុលាការក៏មិនអាចផ្លាស់ប្ដូរការវិនិច្ឆ័យអំពីផ្នែកនោះនៅក្នុងសាលក្រមដើមរបស់សាលាដំបូងនោះទេ។[44] ព្រោះជាការហាមឃាត់មិន ផ្លាស់ប្ដូរអ្វីដែល ខូចប្រយោជន៍ដោយវាមានលក្ខណៈដូចគ្នាទៅនឹង សាលាដំបូងដែរ តុលាការមិនអាច ចេញសាលក្រមដែលវិនិច្ឆ័យទៅលើការទាមទារ និងចំណុចណាដែលភាគីមិនបានសុំឡើយ នោះតុលាការនៃបណ្ដឹងឧទ្ធរណ៍អាចចេញសាលដីកាផ្លាស់ប្ដូរសាលក្រមនៃការជំនុំជម្រះលើកទី ១ បានត្រឹមតែទំហំដែលដើមបណ្ដឹងឧទ្ធរណ៍នោះបានធ្វើឧបាស្រ័យដោយបណ្ដឹងឧទ្ធរណ៍តែប៉ុណ្ណោះ ហើយតុលាការនៃបណ្ដឹងឧទ្ធរណ៍មិនអាចធ្វើការ

[43] មាត្រា ២៧២ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[44] មាត្រា ២៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ផ្លាស់ប្តូរ ខូចខាតផលប្រយោជន៍របស់ដើមបណ្តឹងឧទ្ធរណ៍លើសាលក្រមនៃការជំនុំជម្រះលើកទី ១ បានឡើយ។

## ១.៣ លំហូរនីតិវិធីនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍

ចំពោះលំហូរនីតិវិធីនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ឬការជំនុំជម្រះលើកទី២ បើយោងទៅតាមស្មារតីច្បាប់ ការអនុវត្តចំពោះការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ត្រូវអនុវត្តដូចគ្នាទៅតាមបញ្ញត្តិស្តីពីនីតិវិធីនៃការជំនុំជម្រះលើក ទី១ ប៉ុន្តែមិនយកមកអនុវត្តឡើយចំពោះ ការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង ការសាកល្បងផ្សះផ្សារនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល សាលក្រមកំបាំងមុខ និងរឿងក្តីចំនួនទឹកប្រាក់តិច។[45] បានសេចក្តីថា តុលាការនៃបណ្តឹងឧទ្ធរណ៍អាចធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន នៅក្នុងការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ក៏ប៉ុន្តែ ដោយសារតែបានធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នៅតុលាការនៃការជំនុំជម្រះលើកទី១ រួចហើយនោះតុលាការនៃបណ្តឹងឧទ្ធរណ៍ពុំចាំបាច់ធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុសារជាថ្មីម្តងទៀតឡើយ។ ជាមួយគ្នានេះដែរ គោលការណ៍សាកល្បងផ្សះផ្សាជាមុននៅក្នុងនីតិវិធីត្រៀមសម្រាប់កាទាញហេតុផល ក៏មិនត្រូវយកមកអនុវត្តឡើយ។ រីឯ រឿងក្តីចំនួនទឹកប្រាក់តិចវិញ ដោយវាជានីតិវិធីដែលត្រូវធ្វើតែនៅក្នុងការជំនុំជម្រះលើកទី១ ដូចនេះពុំអនុវត្តចំពោះបណ្តឹងឧទ្ធរណ៍ ឡើយ។ ចំពោះសាលក្រមកំបាំងមុខវិញ នៅក្នុងនីតិវិធីនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ គឺច្បាប់មិនទទួលស្គាល់នោះទេ ប៉ុន្តែភាគីអាចប្តឹងទាមទារ ជំនុំជម្រះសារជាថ្មីបាន។ សរុបជារួមលំហូរនីតិវិធីនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នេះ ដកតែផ្នែកមួយចំនួនប៉ុណ្ណោះដែរមិនអនុវត្តដូចទៅនឹងការជំនុំជម្រះលើកទី១ ក្រៅពីនេះត្រូវអនុវត្តដូចទៅនឹងការជំនុំជម្រះលើកទី១ ដែលមានដូចជា (របៀបធ្វើ និង ការទទួលពាក្យបណ្តឹងឧទ្ធរណ៍ ១.៣.១) (ការពិនិត្យ ការបញ្ជូន និងការបង់ពន្ធលើពាក្យបណ្តឹងឧទ្ធរណ៍ ១.២.២) (នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់និងបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ ១.២.៣) និង (ការបញ្ចប់នីតិវិធីបណ្តឹងឧទ្ធរណ៍ ២.២.៤)។

### ១.៣.១ របៀបធ្វើ និងការទទួលពាក្យបណ្តឹងឧទ្ធរណ៍

ជាធម្មតា មុននឹងឈានដល់ការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ភាគីត្រូវឆ្លងការដំបូងបំផុតនោះគឺ (របៀបធ្វើបណ្តឹងឧទ្ធរណ៍ ១.៣.១.១) និង (ការទទួលពាក្យបណ្តឹងឧទ្ធរណ៍ ១.៣.១.២)។ ចំពោះរបៀបធ្វើបណ្តឹងឧទ្ធរណ៍ភាគីត្រូវតែធ្វើដោយខ្លួនឯង ឬធ្វើតាមរយៈមេធាវីរបស់ខ្លួន រីឯការទទួលពាក្យបណ្តឹងឧទ្ធរណ៍ជាភារកិច្ចរបស់តុលាការ។

[45] មាត្រា ២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

#### ១.៣.១.១. របៀបធ្វើបណ្តឹងឧទ្ធរណ៍

ពាក្យបណ្តឹងឧទ្ធរណ៍ត្រូវសរសេរជាលាយលក្ខណ៍អក្សរ ដោយត្រូវបញ្ជាក់អំពី ៖

- អត្តសញ្ញាណរបស់ភាគី។[46] ឧទាហរណ៍ ៖ ដើមបណ្តឹងឧទ្ធរណ៍ លោក "ខ" អាយុ ៣៧ ឆ្នាំ សញ្ជាតិ ខ្មែរ មានអាសយដ្ឋានផ្ទះលេខ ០០១ ផ្លូវលេខ B57 ភូមិ ប្ដូរ ឃុំ ប្ដូរ ស្រុក ភ្នំព្រឹក ខេត្តបាត់ដំបង មុខរបរ កសិករ ទូរស័ព្ទលេខ ១២៣៤៥៦៧ មានមេធាវីតំណាងដោយអាណត្តិលោក "គ" អត្តលេខ 000 ជាមេធាវីក្រុមមេធាវី LAW FRIM មានការិយាល័យទីតាំងនៅភ្នំពេញ។ ចុងបណ្តឹងឧទ្ធរណ៍ លោក "ក" អាយុ ៣៥ ឆ្នាំ សញ្ជាតិ ខ្មែរ មានអាសយដ្ឋានផ្ទះលេខ ១៥៦ ផ្លូវលេខ B57 ភូមិ អូរដា ឃុំ ប្ដូរ ស្រុក ភ្នំព្រឹក ខេត្តបាត់ដំបង មុខរបរ កសិករ ទូរស័ព្ទលេខ ៧៦៥៤៣២១ មានមេធាវីតំណាងដោយអាណត្តិលោក "ឃ" អត្តលេខ ០០១ ជាមេធាវីក្រុមមេធាវី LAW FIRM BTB មានការិយាទីតាំង ខេត្តបាត់ដំបង។
- សញ្ញាណនៃសាលក្រមនៃការជំនុំជម្រះលើកទី១។[47] ឧទាហរណ៍ ៖ សាលក្រមរដ្ឋប្បវេណីលេខ ១៨៨ "ឆ" ស.ដ.ប ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០២២ របស់សាលាដំបូងខេត្តបាត់ដំបង។
- សេចក្តីដែលប្តឹងចំពោះសាលក្រមនោះ។[48] ឧទាហរណ៍ ៖ សាលក្រមដើម ១. ដើមចោទ "ក" លែងលះចុងចម្លើយ "ខ"។ ២. បង្គាប់ ចុងចម្លើយ "ខ" ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិលើដី X មួយផ្នែកមក ដើមចោទ "ក" ដោយមូលហេតុបែងចែងទ្រព្យរួម។ ដើមបណ្តឹងឧទ្ធរណ៍ "ខ" បានប្តឹងឧទ្ធរណ៍នឹងសេចក្តីសម្រេចបញ្ចប់ត្រង់ចំណុច ទី ២ នៃសាលក្រមដើម។
- មូលហេតុនៃការទាមទារ លុបចោល ឬផ្លាស់ប្តូរនូវសាលក្រម។[49] ឧទាហរណ៍ ៖ សាលក្រមនៃការជំនុំជម្រះលើកទី ១ មានកំហុសនីតិវិធីធ្ងន់ធ្ងរ ឬសាលក្រមនៃការជំនុំជម្រះលើកទី ១ មិនត្រឹមត្រូវ។ ប្រសិនបើមិនបានសរសេរអំពីមូលហេតុ នៃការទាមទារនោះទេ អ្នកធ្វើបណ្តឹងឧទ្ធរណ៍ត្រូវដាក់លិខិតលាយលក្ខណ៍អក្សរដែលសរសេរអំពីមូលហេតុនោះ ក្នុងអំឡុងពេល ៣០ថ្ងៃ បន្ទាប់ពីថ្ងៃដែលបានដាក់ពាក្យបណ្តឹងឧទ្ធរណ៍នេះ។ ដោយឡែកទោះបីអ្នកធ្វើបណ្តឹងឧទ្ធរណ៍មិនដាក់លិខិតនោះក៏ដោយក៏បណ្តឹងឧទ្ធរណ៍នោះមិនចាត់ទុកថាផ្ទុយនឹងច្បាប់ឡើយ ហើយក៏មិនត្រូវបានលើកបណ្តឹងចោលនោះទេ ព្រោះមូលហេតុនៃបណ្តឹងមិនមែនជាចំណុចចាំបាច់

[46] មាត្រា ២៦៥ កថាខណ្ឌទី២ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[47] មាត្រា ២៦៥ កថាខណ្ឌទី២ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[48] មាត្រា ២៦៥ កថាខណ្ឌទី២ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[49] មាត្រា ២៦៥ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ដែលត្រូវសរសេរក្នុងពាក្យបណ្ដឹងឧទ្ធរណ៍នោះឡើយ ព្រោះតុលាការនៃបណ្ដឹងឧទ្ធរណ៍វិនិច្ឆ័យលើអង្គហេតុ និងអង្គច្បាប់ដែលខុសនីតិវិធីប៉ុណ្ណោះ។

ដើម្បីប្ដឹងឧទ្ធរណ៍ ភាគីត្រូវដាក់ពាក្យបណ្ដឹងទៅតុលាការដើម។[50] តុលាការដើមនៅទីនេះ គឺច្បាប់សំដៅទៅដល់តុលាការនៃការជំនុំជម្រះលើកទី១ ឬដំណាក់កាលជម្រះនៅសាលាដាន់ទាប ឬសាលាដំបូងរាជធានី ខេត្ត។ ច្បាប់ចែងមកបែបនេះ វាធ្វើ មានការងាយស្រួលដល់ភាគីណាដែលចង់ប្ដឹងឧទ្ធរណ៍ ដោយភាគីមិនចាំបាច់ទៅឆ្ងាយឡើយ គាត់អាចដាក់ពាក្យបណ្ដឹងនោះ ទៅតុលាការនៃការជំនុំជម្រះលើកទី១បាន។ ឧទាហរណ៍ ៖ លោក "ក" ជាចុងចម្លើយនៃការជំនុំជម្រះ លើកទី ១ ដោយមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់សាលាដំបូងខេត្ត ព្រៃវែង លោក "ក" ក៏បានដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ ទៅសាលាដំបូងខេត្ត ព្រៃវែង ដដែល។

បន្ទាប់ពីដាក់ពាក្យបណ្ដឹងទៅតុលាការដើមរួច តុលាការដើមត្រូវធ្វើឱ្យបានឆាប់រហ័សនូវពាក្យបណ្ដឹងឧទ្ធរណ៍ និងសំណុំរឿងទៅតុលាការនៃបណ្ដឹងឧទ្ធរណ៍។[51] ដោយសារតែតុលាការដើមជាតុលាការដែលទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ឬហៅថា ជាអ្នកបើកឱ្យមានផ្លូវបណ្ដឹងឧទ្ធរណ៍ ក៏ពិតមែន ប៉ុន្តែ តុលាការដើមមិនមានសមត្ថកិច្ចពិនិត្យពាក្យបណ្ដឹងឧទ្ធរណ៍នោះទេ។ តុលាការដើមអាចត្រឹមតែពិនិត្យទៅលើល័ក្ខខ័ណ្ឌនៃបណ្ដឹងឧទ្ធរណ៍ អំឡុងពេលនៃបណ្ដឹងឧទ្ធរណ៍ ការបង់ពន្ធដាក់ពាក្យសុំជាអាទិ៍ មុននឹងធ្វើការបញ្ជូនពាក្យបណ្ដឹងនោះជាមួយនឹងសំណុំរឿងក្ដីដែលពាក់ព័ន្ធទៅតុលាការនៃបណ្ដឹងឧទ្ធរណ៍តែប៉ុណ្ណោះ។

**១.៣.១.២ ការទទួលពាក្យបណ្ដឹងឧទ្ធរណ៍**

ពេលដែលបានទទួលពាក្យបណ្ដឹងឧទ្ធរណ៍ហើយ តុលាការនៃបណ្ដឹងឧទ្ធរណ៍ ត្រូវពិនិត្យពាក្យបណ្ដឹងឧទ្ធរណ៍នោះ ហើយប្រសិនបើពិនិត្យទៅឃើញថា មានចំណុចខ្វះខាត តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវបង្គាប់ភាគីធ្វើការកែតម្រូវនូវចំណុចខ្វះខាតទាំងនោះ។[52] បើទោះបីជាមានការបង្គាប់ឱ្យកែតម្រូវក៏ដោយតែដើមបណ្ដឹងឧទ្ធរណ៍មិនព្រមកែតម្រូវទេ តុលាការនៃបណ្ដឹងឧទ្ធរណ៍ ត្រូវលើកចោលពាក្យបណ្ដឹងឧទ្ធរណ៍នោះ ដោយដីកាសម្រេច ចំណុចនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ក្នុងករណីដែលដើមបណ្ដឹងឧទ្ធរណ៍មិនបានបង់ពន្ធសម្រាប់ដាក់ពាក្យបណ្ដឹងឧទ្ធរណ៍នោះ។[53] ប្រសិនបើពាក្យបណ្ដឹងឧទ្ធរណ៍ត្រឹមត្រូវតាមទម្រង់ច្បាប់ ក្រឡាបញ្ជីត្រូវបញ្ជូនពាក្យបណ្ដឹងឧទ្ធរណ៍នោះទៅ ចុងបណ្ដឹងឧទ្ធរណ៍។[54]

[50] មាត្រា ២៦៥ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[51] មាត្រា ២៦៥ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[52] មាត្រា ២៦៦ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[53] មាត្រា ២៦៦ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[54] មាត្រា ២៦៧ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

### ១.៣.២ ការពិនិត្យ ការបញ្ជូន និងការបង់ពន្ធលើពាក្យបណ្ដឹងឧទ្ធរណ៍

ឆ្លងមកដល់ចំណុចនេះភារកិច្ចរបស់ភាគីគឺត្រូវតែ (បង់ពន្ធដាក់លើពាក្យបណ្ដឹងឧទ្ធរណ៍ ១.៣.២.១)។ ក្រៅពីនេះដូចជា (ការពិនិត្យពាក្យបណ្ដឹងឧទ្ធរណ៍ ១.២.២.២)និង(ការបញ្ជូនពាក្យបណ្ដឹងឧទ្ធរណ៍ ១.៣.២.៣) នោះសុទ្ធតែជាភារកិច្ចរបស់តុលាការ។

#### ១.៣.២.១ ការពិនិត្យ

នៅពេលដែលសាលាឧទ្ធរណ៍បានទទួលពាក្យបណ្ដឹងពីសាលាដំបូងរួចហើយនោះ តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវតែពិនិត្យមើលទៅលើពាក្យបណ្ដឹងឧទ្ធរណ៍ជាមុន ដូចជា[55] ៖

- ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី និងអ្នកតំណាងដែលច្បាប់បានកំណត់
- សញ្ញាណសាលក្រមនៃការជំនុំជម្រះលើកទី ១
- សេចក្ដីដែលប្ដឹងឧទ្ធរណ៍ចំពោះសាលក្រមនោះ និងមូលហេតុនៃការទាមទារ
- ការបង់ប្រាក់ប្រដាប់ក្ដី។

ប្រសិនបើតុលាការនៃបណ្ដឹងឧទ្ធរណ៍ ពិនិត្យមើលទៅដោយឃើញថាមានចំណុចខ្វះខាត តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវបង្គាប់ភាគីធ្វើការកែតម្រូវនូវចំណុចខ្វះខាតទាំងនោះ ក្នុងអំឡុងពេលសមរម្យមួយផងដែរ។ តុលាការនៃបណ្ដឹងឧទ្ធរណ៍នឹងលើកបណ្ដឹងនោះចោល បើក្នុងករណីដែលតុលាការបានបង្គាប់ ដើមចោទកែតម្រូវហើយ ភាគីដើមចោទនៅតែមិនព្រមកែតម្រូវ តុលាការនៃបណ្ដឹងឧទ្ធរណ៍នឹងលើកបណ្ដឹងឧទ្ធរណ៍នោះចោល ដោយដីកាសម្រេច ហើយភាគីអាចប្ដឹងជំទាស់នឹងដីកាសម្រេចនេះបាន។ ករណីនេះក៏ត្រូវតែយកមកអនុវត្តផងដែរ ក្នុងចំណុចដែលដើមបណ្ដឹងឧទ្ធរណ៍មិនបានបង់ពន្ធដាក់ពាក្យសុំសម្រាប់បណ្ដឹងឧទ្ធរណ៍ផងដែរ។ ចំពោះការបង់ដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ និងបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំពន្ធដាក់ពាក្យសុំត្រូវគណនាទៅតាមតម្លៃកម្មវត្ថុនៃបណ្ដឹងដែលមានចំនួន ១,៥ ដង នៃពន្ធដាក់ពាក្យសុំនៅតុលាការជាន់ដំបូង។[56]

#### ១.៣.២.២ ការបញ្ជូន

ក្រោយពីតុលាការពិនិត្យពាក្យបណ្ដឹងឧទ្ធរណ៍ ក្នុងករណីពាក្យបណ្ដឹងបានបំពេញលក្ខខណ្ឌតាមច្បាប់ តុលាការនឹងបញ្ជូនពាក្យបណ្ដឹងឧទ្ធរណ៍ទៅចុងបណ្ដឹងឧទ្ធរណ៍ ដើម្បីឲ្យចុងបណ្ដឹងឧទ្ធរណ៍បានដឹង និងត្រៀមខ្លួនក្នុងការឆ្លើយតបជាមួយនឹងបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងឧទ្ធរណ៍។[57]

---

[55] មាត្រា ២៦៥ និង ២៦៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[56] មាត្រា ៦១ កថាខណ្ឌទី៣ និង មាត្រា ២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[57] មាត្រា ២៦៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ឆ្លងកាត់តាមការអនុវត្តជាក់ស្តែង កាលណាបើពាក្យបណ្តឹងត្រឹមត្រូវតាមទម្រង់ច្បាប់ នោះក្រឡាបញ្ជី ត្រូវបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍នោះ ទៅ ចុងបណ្តឹងឧទ្ធរណ៍ ដើម្បីឱ្យចុងបណ្តឹងឧទ្ធរណ៍បានដឹង និងត្រៀម ខ្លួនក្នុងការឆ្លើយតបជាមួយនឹងបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងឧទ្ធរណ៍។

**១.៣.២.៣ ការបង់ពន្ធ**

ជាទូទៅក្នុងរឿងក្តីរដ្ឋប្បវេណី គឺជាវិវាទបុគ្គលឯកជន ដោយប្រើប្រាស់តាមរយៈប្រព័ន្ធតុលាការរបស់ រដ្ឋ ហេតុដូច្នេះនៅក្នុងរឿងក្តីរដ្ឋប្បវេណី ឃើញថាតុលាការតែងតែតម្រូវ ដើមបណ្តឹងធ្វើការបង់ប្រាក់ថ្លៃពន្ធ និង សោហ៊ុយចំណាយផ្សេងៗ ដើម្បីដំណើរការនីតិវិធីនៃរឿងក្តីនោះ ដោយត្រូវបានកំណត់ដោយតុលាការ ដោយ ការគណនាតាមកំណត់ច្បាប់។ ឧទាហរណ៍៖ ដើមចោទ (ក) បានប្តឹងទាមទារ (ខ) ដែលជាចុងចម្លើយបង់ ប្រាក់ចំនួន ៤០ លានរៀល ការប្រាក់ ១០% ក្នុងមួយឆ្នាំ ការប្រាក់យឺតយ៉ាវ ១៥% ក្នុងមួយឆ្នាំ។ សេចក្តី សម្រេចបញ្ចប់នៃសាលក្រម មានខ្លឹមសារថា ទី១ (ខ) បង់ប្រាក់ ៣២ លានរៀល។ ទី២ ការប្រាក់ ១០%ក្នុង មួយឆ្នាំ និងទី៣ ការប្រាក់យឺតយ៉ាវ ១៥% ក្នុងមួយឆ្នាំ។ (ខ) បានប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចទាំងមូល ហើយ (ក) បានធ្វើបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំចំពោះចំណុចទី១។ (ខ) បានប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេច ទាំងមូល ហើយ (ក) បានធ្វើបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំចំពោះចំណុចទី ១។ ដូច្នេះ វានាំឲ្យមានករណីចំនួន ២ កើតឡើង ៖

ទី១ (ខ) ជាដើមបណ្តឹងឧទ្ធរណ៍ បានប្តឹងឧទ្ធរណ៍នឹងសាលក្រមទាំងមូល។

ទី២ (ក) ជាចុងបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំចំណុចទី ១។

\+ គណនាការបង់ពន្ធដាក់ពាក្យបណ្តឹងឧទ្ធរណ៍របស់ (ខ)

ដោយតម្លៃកម្មវត្ថុនៃបណ្តឹង ដែលជាមូលដ្ឋាននៅក្នុងការគណនាពន្ធដាក់ពាក្យសុំនោះ គឺគេកម្រិត ត្រឹមតែការទាមទារចម្បងតែប៉ុណ្ណោះ រីឯការទាមទារបន្ទាប់បន្សំ មិនត្រូវក្លាយជាតម្លៃកម្មវត្ថុនៃបណ្តឹងនោះទេ។ ហេតុនេះមានតែប្រាក់ដើម ៤០លានរៀល ប៉ុណ្ណោះ ដែលក្លាយជាតម្លៃនៃកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍នោះ ហើយ ចាំបាច់ត្រូវយកមកគណនា ឯការបង់ការប្រាក់១០% ក្នុងមួយឆ្នាំ និងការប្រាក់យឺតយ៉ាវ ១៥% ក្នុងមួយឆ្នាំ មិនត្រូវយកមកគណនាឡើយ ព្រោះវាជាការទាមទារបន្ទាប់បន្សំ។ ក្នុងករណីនេះ ខ ត្រូវបង់ពន្ធដាក់ពាក្យសុំ ដែលមានតម្លៃស្មើនឹងកម្មវត្ថុនៃបណ្តឹងដើម គឺប្រាក់ចំនួន ៤០ លានរៀល ព្រោះ ខ បានធ្វើការទាមទារចំពោះ សាលក្រមទាំងមូល។

គណនាពន្ធដាក់ពាក្យសុំ ដែលមានកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ចំនួន ៤០ លានរៀល

$Y_{1(Max)}$ = ( ១០,០០០,០០០/១០០,០០០ ) x ១,០០០ = ១០០,០០០

$Y_2$ = [( ៤០,០០០,០០០ - ១០,០០០,០០០ )/១០០,០០០] x ៧០០ = ២១០,០០០

$Y=Y_{1(Max)} + Y_2$ = ១០០,០០០ + ២១០,០០០ = ៣១០,០០០

ពន្ធដាក់សុំនៃបណ្តឹងឧទ្ធរណ៍ = Y x ១.៥ = ៣១០,០០០ x ១.៥ = ៤៦៥,០០០ រៀល

+ ការបង់ពន្ធដាក់ពាក្យបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំរបស់ "ក"

ការទាមទារក្នុងបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំរបស់ "ក" ចំនួន ៨ លានរៀល ហេតុនេះ តម្លៃកម្មវត្ថុនៃបណ្តឹងដែលជាមូលដ្ឋាននៅក្នុងការគណពន្ធដាក់ពាក្យសុំគឺចំនួន ៨ លានរៀល មិនមែន ៤០ លានរៀល នោះទេ ព្រោះចំណុចដែល "ក" បានធ្វើការទាមទារនៅក្នុងបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ គឺចំនួនទឹកប្រាក់ ៨ លានរៀល ដែលនៅសល់ពីការសម្រេចរបស់តុលាការជាន់ខ្ពស់ទាបដែលបានសម្រេចសិទ្ធិ "ក" ចំនួន ៣២ លានរៀល ស្របពេលដែលបានធ្វើការទាមទារ ៤០ លានរៀល។

គណនាពន្ធដាក់ពាក្យសុំ ដែលមានកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ ចំនួន ៨ លានរៀល

$Y_1$ = ( ៨,០០០,០០០/១០០,០០០ ) x ១,០០០ = ៨០,០០០

ពន្ធដាក់ពាក្យសុំនៃបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ = $Y_1$ x ១.៥ = ៨០,០០០ x ១.៥ = ១២០,០០០ រៀល។

ដូចនេះ ពន្ធដាក់ពាក្យសុំរបស់ "ក" ចំនួន ៤៦៥,០០០ រៀល

ពន្ធដាក់ពាក្យសុំរបស់ "ខ" ចំនួន ១២០,០០០ រៀល។

ការដកពាក្យបណ្តឹងឧទ្ធរណ៍ ភាគីអាចដកពាក្យបណ្តឹងឧទ្ធរណ៍វិញបាន រហូតដល់ពេលដែលសាលដីកាចុងក្រោយរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវបានដកចេញ។[58] ទោះបីជាបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់រួចហើយក៏ដោយ ភាគីនៅតែមានសិទ្ធិនៅក្នុងការដកពាក្យបណ្តឹងវិញ នៅពេលណាក៏បាន រហូតដល់ពេលដែលសាលដីកាចុងក្រោយរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវបានប្រកាស ដោយមិនបាំបាច់ទទួលការយល់ព្រមពីចុងបណ្តឹងឧទ្ធរណ៍។[59] ការដកពាក្យបណ្តឹងឧទ្ធរណ៍ ត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ប៉ុន្តែនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬកាលបរិច្ឆេទផ្សះផ្សា ការដកពាក្យបណ្តឹង អាចធ្វើដោយផ្ទាល់មាត់បាន។[60]

តាមរយៈការដកពាក្យបណ្តឹងឧទ្ធរណ៍ នោះនាំឲ្យបណ្តឹងឧទ្ធរណ៍ ត្រូវបានចាត់ទុកថា មិនបានចាត់ការនៅតុលាការនៃបណ្តឹងឧទ្ធរណ៍តាំងពីដំបូង។[61] ប្រសិនបើសាលក្រមដើម ត្រូវបានចូលជាស្ថាពរ នៅអំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍បានកន្លងហួស។ បើការដកពាក្យបណ្តឹងឧទ្ធរណ៍នោះបានធ្វើឡើងក្រោយពេល

[58] មាត្រា ២៦៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[59] មាត្រា ២៦៩ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[60] មាត្រា ២៦៩ កថាខណ្ឌទី ២ នៃនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[61] មាត្រា ២៦៩ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ដែលកំណត់សម្រាប់ធ្វើបណ្តឹងឧទ្ធរណ៍ ពេលនោះសាលក្រមនៃតុលាកាជំនុំជម្រះលើកទី ១ នឹងចូលជាស្ថាពរ តាំងពីថ្ងៃផុតអំឡុងពេលនៃការប្តឹងឧទ្ធរណ៍។ ឧទាហរណ៍ ៖ នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២ ភាគីបានទទួលលិខិតសាលក្រម បន្ទាប់មកនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ ដើមបណ្តឹងឧទ្ធរណ៍ បានដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ក្រោយមកនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២ ដើមបណ្តឹងឧទ្ធរណ៍បានដកពាក្យបណ្តឹងឧទ្ធរណ៍វិញ ដូច្នេះនាំ សាលក្រមនៃការជំនុំជម្រះលើកទី ១ ចូលជាស្ថាពរ នៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០២២ មកម្លេះ ដោយសារតែនៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២ ដើមបណ្តឹងឧទ្ធរណ៍បានប្តឹងឧទ្ធរណ៍ ដូច្នេះ បើគិតមកដល់ថ្ងៃទី ០២ ខែមេសា ឆ្នាំ២០២២ គឺមានរយៈពេល ១ ខែចាប់តាំងពីថ្ងៃដែលភាគីបានទទួលលិខិតសាលក្រមរបស់សាលាដំបូង ហើយច្បាប់ទុករយៈពេល ភាគីប្តឹងឧទ្ធរណ៍រយៈពេល ១ ខែ។[62]

ការដកពាក្យបណ្តឹងឧទ្ធរណ៍ មិនមានឥទ្ធិពលអ្វីទៅលើសាលក្រមដើម ហើយមិនមានការខូចខាតផលប្រយោជន៍ដល់ចុងបណ្តឹងឧទ្ធរណ៍នោះទេ ដូច្នេះមិនចាំបាច់មានការយល់ព្រមពីចុងបណ្តឹងឡើយ។ ប៉ុន្តែក្រោយពេលដកពាក្យបណ្តឹងឧទ្ធរណ៍ បើអំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍មិនទាន់កន្លងផុតទេ ភាគីម្ខាងទៀត ព្រមទាំងដើមបណ្តឹងឧទ្ធរណ៍ដែលបានដកពាក្យបណ្តឹងឧទ្ធរណ៍ម្តងហើយក៏អាចប្តឹងឧទ្ធរណ៍បាន ដែរ។[63] ការចាត់ទុកថាដកពាក្យបណ្តឹង ប្រសិនបើភាគីសងខាងមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ នៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ត្រូវចាត់ទុកថា ដកពាក្យបណ្តឹងឧទ្ធរណ៍ដោយអនុលោមទៅតាមករណីនៃការដកពាក្យបណ្តឹង។[64] បានសេចក្តីថា ភាគីទាំងសងខាង មិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហើយមិនបានដាក់ពាក្យសុំ តុលាការកំណត់កាលបរិច្ឆេទជាថ្មីទៀត ក្នុងអំឡុងពេលដែលកំណត់ នោះត្រូវចាត់ទុកថា បានដកពាក្យបណ្តឹង ដោយសន្និដ្ឋានថា គូភាគីទាំងសងខាងគ្មានចំណង់ និងសេចក្តីត្រូវការក្នុងការធ្វើទៅតាមនីតិវិធីនៃបណ្តឹង។ ក្នុងករណីដែល ដើមចោទ និងចុងចម្លើយ មិនបានបង្ហាញខ្លួនជាប់ៗគ្នា ប៉ុន្មានដងដែលបានកំណត់ក៏ត្រូវចាត់ទុកថា បានដកពាក្យបណ្តឹងដែរ។ ការមិនបានបង្ហាញខ្លួន ក្នុងករណីដែល ភាគីមិនបានមកបង្ហាញខ្លួននៅសាលសវនាការ និងក្នុងករណីដែលភាគីបានបង្ហាញខ្លួនពិតមែន តែបានចេញពីសាលសវនាការ ដោយមិនបានឆ្លើយដោះសារ នៅក្នុងនីតិវិធីត្រៀបសម្រាប់ការទាញហេតុផល ឬដោយមិនបានធ្វើសេចក្តីថ្លែងការណ៍នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់។[65]

[62] មាត្រា ២៦៩ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[63] មាត្រា ២៦៤ កថាខណ្ឌទី ១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[64] មាត្រា ២១៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[65] មាត្រា ២១៩ និង ២៦៩ កថាខណ្ឌទី ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ការសងពន្ធដាក់ពាក្យសុំ នៅក្នុងករណីដែលបណ្តឹងឧទ្ធរណ៍ ត្រូវបានដកមុនកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់លើកដំបូង នៅតុលាការនៃបណ្តឹងឧទ្ធរណ៍ ដើមបណ្តឹងឧទ្ធរណ៍ អាចដាក់ពាក្យសុំ សងពាក់កណ្តាលនៃពន្ធដាក់ពាក្យសុំ។[66] ឧទាហរណ៍ ៖ ប្រសិនបើ "ខ" ប្តឹងឧទ្ធរណ៍ "ខ" ត្រូវបង់ពន្ធដាក់ពាក្យសុំនៃបណ្តឹងឧទ្ធរណ៍ ចំនួន ១០៩៥០០០ រៀល។ ក្នុងករណីនេះប្រសិនបើ ខ ដកបណ្តឹងឧទ្ធរណ៍ មុនពេលទាញហេតុផលដោយផ្ទាល់មាត់ "ខ" អាចដាក់ពាក្យសុំឱ្យសងពន្ធខាងលើនេះពាក់កណ្តាលវិញ ដែលមានចំនួនស្មើនឹង ៥៤៧៥០០ រៀល។

### ១.៣.៣ នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ

ការចាប់ផ្តើមជំនុំជម្រះនៅតុលាការនៃបណ្តឹងឧទ្ធរណ៍ គឺតុលាការធ្វើការទាញហេតុផលដោយផ្ទាល់យកតែម្តងមិនចាំបាច់ធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ទៀតនោះទេដោយសារតែតុលាការទទួលបានសញ្ញាណខ្លះទៅហើយដោយផ្អែកទៅលើកំណត់ហេតុនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល កាលនៅដំណាក់កាលនៃការជំនុំជម្រះលើកទី១ រួចហើយ។ ចំពោះបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំវិញនោះតុលាការនៃបណ្តឹងឧទ្ធរណ៍ ក៏ត្រូវតែធ្វើចំណាត់ការដូចគ្នា។

#### ១.៣.៣.១. នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

ចំពោះនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់នេះ ជាដំបូងតុលាការចាំបាច់ត្រូវតែ (កំណត់កាលបរិច្ឆេទនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ (ក) ) ជាមុនសិនហើយតុលាការកំណត់កាលបរិច្ឆេទនោះយ៉ាងណាដើម្បីអោយភាគីទាំងសងខាងអាចចូលរួមបាន ព្រោះនីតិវិធីនៃការជម្រះលើកទី២ នេះ តុលាការមិនអាចចេញសាលដីកាកំបាំងមុខបានឡើយ ក្នុងនាមខ្លួនជាតុលាការជាន់ខ្ពស់ ដែលត្រូវជំនុំជម្រះទាំងអង្គហេតុ និងអង្គច្បាប់។ ក្រោយពីតុលាការកំណត់កាលបរិច្ឆេទហើយតុលាការនឹងចាប់ផ្តើមនៅ(ដំណាក់កាលនៃការទាញហេតុផលដោយផ្ទាល់មាត់ (ខ)ដោយមានការចូលរួមពីភាគីទាំងសងក្នុងការចូលចូលទៅសវនាការ ។

##### ក. ការកំណត់កាលបរិច្ឆេទនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

ក្រោយពេលដែលបានទទួល និងពិនិត្យពាក្យបណ្តឹងរួចរាល់ ឃើញថាបណ្តឹងនោះធ្វើឡើងដោយគោរពតាមទម្រង់ច្បាប់ហើយ តុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវធ្វើការកំណត់នូវកាលបរិច្ឆេទសម្រាប់ធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់ បានឆាប់រហ័ស និងធ្វើការកោះហៅគូភាគីដើម្បីចូលរួមផងដែរ។[67]

ជាគោលការណ៍ តុលាការនៃបណ្តឹងឧទ្ធរណ៍មិនធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះទេ លើកលែងតែការកំណត់ចំណុចវិវាទរបស់តុលាការជាន់ទាបមានលក្ខណៈមិនត្រឹមត្រូវ ហើយមានភាពចាំបាច់

[66] មាត្រា ៦១ កថាខណ្ឌទី ៨ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[67] មាត្រា ១១៣ និង ២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ពិសេសត្រូវកំណត់ចំណុចវិវាទជាថ្មី។ ឧទាហរណ៍ ៖ នៅក្នុងការជំនុំជម្រះលើកទី ១ ដើមចោទអះអាងអំពីសិទ្ធិលើបំណុលចំនួន ១០000 ដុល្លារ ដោយផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ ចុងចម្លើយបានអះអាងអំពីការរលត់សិទ្ធិលើបំណុលដោយអាជ្ញាយុកាល ហើយតុលាការបានកំណត់ចំណុចវិវាទថា ( តើមានអត្ថិភាពនៃសិទ្ធិលើបំណុល ដែរ ឬទេ ? ) ការកំណត់ចំណុចវិវាទនេះមិនត្រឹមត្រូវទេ ចំណុចវិវាទដែលត្រឹមត្រូវ គឺ ( តើសិទ្ធិលើបំណុលនេះត្រូវរលត់ដោយអាជ្ញាយុកាល ដែរ ឬទេ ? )។ នាំ តុលាការជាន់ទាបបានកំណត់វិវាទដែលមិនត្រឹមត្រូវថា ( តើមានអត្ថិភាពនៃសិទ្ធិលើបំណុល ដែរ ឬទេ ) និងបានចេញសេចក្តីសម្រេចបញ្ចប់ បង្គាប់ ចុងចម្លើយបង់ប្រាក់ ១០000 ដុល្លារ មក ដើមចោទ។ លុះពេលដែលបានមកដល់តុលាការនៃបណ្តឹងឧទ្ធរណ៍ឃើញថាមានចំណុចវិវាទមិនត្រឹមត្រូវរលត់ដោយអាជ្ញាយុកាល ដែរ ឬទេ ? )។ ដូច្នេះ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវធ្វើការជំនុំជម្រះលើកទី ២ ដោយត្រូវធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក្នុងករណីត្រូវកំណត់វិវាទជាថ្មី។[68] នៅក្រោយពេលដែលបានកំណត់កាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់រួចរាល់តុលាការត្រូវធ្វើការបញ្ជូនដីកាកោះទៅភាគី ដើម្បី ភាគីចូលរួមក្នុងនីតិវិធី ព្រោះចាំបាច់ត្រូវតែគោរពជាគោលការណ៍ចំពោះមុខ។ ការបញ្ជូនដីកាកោះអាចធ្វើការបញ្ជូនទៅភាគីជាមួយគ្នា និងលិខិតទទួលពាក្យបណ្តឹងលើកលែងតែករណីដែលតុលាការលើកចោលពាក្យបណ្តឹងឧទ្ធរណ៍នោះ ឬតុលាការចេញដីកាបង្គាប់ឱ្យកែតម្រូវជា អាទិ៍។[69]

### ខ. ការទាញហេតុផលដោយផ្ទាល់មាត់

សមាសភាពក្នុងការធ្វើការជំនុំជម្រះដោយក្រុមប្រឹក្សាជំនុំជម្រះដែលមានចៅក្រម ៣ រូប រួមមានប្រធានជំនុំជម្រះ ១ រូប និងចៅក្រម ២ រូបទៀត ជាសមាជិកក្រុមប្រឹក្សាជំនុំជម្រះ និងមានការចូលរួមដោយក្រឡាបញ្ជីជាអ្នកកត់ត្រា និងចូលរួមពីសំណាក់អយ្យការ និងមេធាវីតំណាង ឬអ្នកការពារសិទ្ធិ ភាគី ដោយអនុលោមតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី។[70] សម្រាប់រឿងក្តីដែលត្រូវបានតុលាការកំពូលសម្រេចបង្វិលមកវិញ នោះសាលាឧទ្ធរណ៍ចាំបាច់ត្រូវធ្វើការជំនុំជម្រះម្តងទៀត ដោយមានក្រុមប្រឹក្សាជំនុំជម្រះដោយមានចៅក្រមចំនួន ៥ រូប និងចៅក្រម ៤ រូបផ្សេងទៀត សុទ្ធតែជាចៅក្រមដែលមិនបានចូលរួមជំនុំជម្រះកាលពីលើកមុន។[71]

[68] មាត្រា ១០៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[69] មាត្រា ២៦៧ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[70] មាត្រា ២៣ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[71] មាត្រា ៣៩ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

រីឯសកម្មភាពនៃការជំនុំជម្រះលើកទី ២ របស់តុលាការនៃបណ្តឹងឧទ្ធរណ៍ ចំពោះសាលក្រមដើម ដោយចេញសាលដីកា ហេតុនេះដើម្បីអាចវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវបានតុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់។

ចំពោះការទាញហេតុផលដោយផ្ទាល់មាត់ នៅតុលាការនៃបណ្តឹងឧទ្ធរណ៍ គឺជាការបន្តការវិនិច្ឆ័យ ដោយបើកឡើងវិញនូវការទាញហេតុផលដោយផ្ទាល់មាត់ជាថ្មី ដែលត្រូវបានបញ្ចប់ម្តងរួចហើយ នៅក្នុងការជំនុំជម្រះលើកទី ១ ដូចនេះ សកម្មភាពបណ្តឹង ( ការអះអាងអង្គហេតុការស្នើសុំ សុំពិនិត្យភស្តុតាង ការសារភាព ជាដើម ) ដែលបានធ្វើនៅក្នុងការជំនុំជម្រះលើកទី ១ មានអានុភាពនៅក្នុងការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍។[72]

ហេតុនេះបានជាការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវធ្វើត្រឹមទំហំដែលភាគីបានទាមទារ ផ្លាស់ប្តូរសាលក្រមនៃការជំនុំជម្រះលើកទី ១ តែប៉ុណ្ណោះ។ តុលាការនៃបណ្តឹងឧទ្ធរណ៍ ធ្វើការសម្រេចសេចក្តីដោយពិនិត្យមើលទាំងអង្គហេតុ និងអង្គច្បាប់។ ការទាញហេតុផលដោយផ្ទាល់មាត់នៅតុលាការនៃបណ្តឹងឧទ្ធរណ៍ តម្រូវ ភាគីធ្វើសេចក្តីថ្លែងការណ៍ អំពីលទ្ធភាពផលនៃការទាញហេតុផលដោយផ្ទាល់មាត់នៅតុលាការនៃការជំនុំជម្រះលើកទី ១ ដោយសារនៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ចៅក្រមត្រូវបានផ្លាស់ប្តូរពីចៅក្រមនៃការជំនុំជម្រះលើកទី១។[73] ហេតុនេះសេចក្តីថ្លែងការណ៍គ្រាន់តែជាសកម្មភាពរាយការណ៍ដែលមានលក្ខណៈជាទម្រង់ ដើម្បីបំពេញគោលការណ៍វិនិច្ឆ័យដោយផ្ទាល់។[74] បន្ទាប់មកនឹងមានការបន្តវិនិច្ឆ័យ ដោយបើកឡើងវិញនូវការទាញហេតុផលដោយផ្ទាល់មាត់ជាថ្មី ដែលត្រូវបានបញ្ចប់ម្តងរួចហើយនៅក្នុងការជំនុំជម្រះលើកទី ១ នេះហៅថាការទាញហេតុផលដោយផ្ទាល់មាត់នៅតុលាការនៃបណ្តឹងឧទ្ធរណ៍។ ឧទាហរណ៍ ៖ បញ្ចប់ការជំនុំជម្រះលើកទី១ នៅតុលាការជាន់ទាប ដែលមានសាក្សីចូលរួមដោយលោក គ រួចបន្តការវិនិច្ឆ័យជាថ្មីនៃការជំនុំជម្រះលើកទី២ នៅតែបន្តប្រើលទ្ធផលនៃការសួរសាក្សី គ នោះដដែល។ ហេតុនេះនៅក្នុងការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ តុលាការនៃបណ្តឹងឧទ្ធរណ៍ មិនអនុញ្ញាឱ្យដាក់មធ្យោបាយតទល់ ឬការពារខ្លួន (ភស្តុតាង) បន្ថែម ឬថ្មីនោះទេ។ ឧទាហរណ៍ ៖ ការជំនុំជម្រះលើកទី១ ភស្តុតាង Y ភាគីមិនបានដាក់នោះទេ លុះមកដល់ការជំនុំជម្រះលើកទី២ ភាគីក៏បានស្នើទៅតុលាការដើម្បីសុំដាក់ ភស្តុតាង Y នោះ ដូចនេះ ភស្តុតាង Y នោះមិនត្រូវបានតុលាការអនុញ្ញាតអោយដាក់នោះទេ។ ប៉ុន្តែភាគីអាចត្រូវបានផ្តល់ឱកាស ដាក់មធ្យោបាយតទល់ ឬការពារខ្លួនដែលមិនបានដាក់នៅក្នុងការជំនុំជម្រះលើកទី១ ប្រសិនបើមធ្យោបាយតទល់ ឬការពារខ្លួន

[72] មាត្រា ២៧៤ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[73] មាត្រា ២៧២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[74] មាត្រា ១៨៥ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

(ភស្តុតាង) នោះ មិនផ្ទុយនឹងបញ្ញត្តិច្បាប់។[75] ឧទាហរណ៍ ៖ នៅក្នុងការជំនុំជម្រះលើកទី១ ដើមចោទ បានដាក់ពាក្យសុំ សាកសួរសាក្សី "គ" ប៉ុន្តែដោយសារ សាក្សីមានជំងឺធ្ងន់ធ្ងរត្រូវទៅព្យាបាលនៅឯបរទេស ដោយមិនដឹងពេលណាអាចត្រឡប់មកវិញបាន ហេតុនេះ សាក្សី "គ" មិនត្រូវបានសាកសួរនៅក្នុងការជំនុំជម្រះលើកទី១ ទេ ប៉ុន្តែនៅក្នុងការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ សាក្សី "គ" បានជាសះស្បើយពីជំងឺ និងត្រឡប់មកកម្ពុជាវិញ ក្នុងករណីនេះតុលាការនៃបណ្តឹងឧទ្ធរណ៍អនុញ្ញាតចំពោះការដាក់ភស្តុតាងថ្មីនេះ។ បញ្ជាក់ ៖ ការជំនុំជម្រះលើកទី២ តុលាការនៃបណ្តឹងឧទ្ធរណ៍ មិនធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះទេ ពីព្រោះសកម្មភាពនៃការជំនុំជម្រះលើកទី១ (សកម្មភាពបណ្តឹងដែលបានធ្វើឡើងនៅក្នុងការជំនុំជម្រះលើកទី១ ដោយរាប់បញ្ចូលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល) មានអានុភាពចំពោះការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ ហៅថា របបជំនុំជម្រះបន្ត។[76]

**១.៣.៣.២ ការប្តឹងឧទ្ធរណ៍បន្ទាប់បន្សំ**

ពេលដែលមានបណ្តឹងឧទ្ធរណ៍ ការទាមទារទាំងមូលដែលត្រូវបានវិនិច្ឆ័យដោយសាលក្រមនៃសាលាដំបូងដែលត្រូវបានប្តឹងឧបាស្រ័យ ត្រូវផ្ទេរទៅតុលាការនៃបណ្តឹងឧទ្ធរណ៍ វានាំឲ្យចុងបណ្តឹងឧទ្ធរណ៍អាចឆ្លៀត ឱកាសនេះដើម្បីធ្វើឧបាស្រ័យទាមទារ ផ្លាស់ប្តូរនូវភាគនៃសាលក្រមនៃការជំនុំជម្រះលើកទី១ ដែលខ្លួនបាត់បង់ផលប្រយោជន៍ ទទួលបានផលប្រយោជន៍នោះត្រឡប់មកវិញ។[77] បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ ជាយន្តការមួយការពារភាគីម្ខាង ដែលបានបង់ផលប្រយោជន៍ពីស្ថានភាពដែលសាលក្រមនៃការជំនុំជម្រះលើកទី ១ បានទទួលស្គាល់នូវការទាមទារមួយភាគ ឬច្រានចោលនូវការទាមទារមួយភាគរបស់ដើមចោទ ហើយប្រសិនបើភាគីណាម្ខាងគិតឃើញថា បើភាគីម្ខាងទៀត ពេញចិត្តមិនសាលក្រមនោះ ខ្លួនក៏មិនប្តឹងឧទ្ធរណ៍នោះដែរ។ ឧទាហរណ៍ ៖ ចុងចម្លើយបានចាញ់ក្តីចំពោះការទាមទារ សងប្រាក់កំចី ចំនួន ៥០០០០ $ ប៉ុន្តែចុងចម្លើយបានឈ្នះចំពោះការទាមទារ បញ្ជាក់កម្មសិទ្ធិអចលនវត្ថុ។ ក្នុងករណីនេះ ប្រសិនបើចុងចម្លើយគិតថា បើដើមចោទដាក់ពាក្យបណ្តឹងឧទ្ធរណ៍ បណ្តឹងនោះគង់តែនឹងត្រូវបន្តទៅសាលាឧទ្ធរណ៍ដដែល ដូច្នេះហើយខ្លួនក៏អាចធ្វើបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំនេះឡើង ដើម្បីទាមទារ លុបចោលនូវភាគនៃសាលក្រមដើម ដែលទទួលស្គាល់នូវការទាមទារ សងប្រាក់កំចីបានដែរ។ ប្រសិនបើមិនមានយន្តការនេះទេ ចុងចម្លើយចាំបាច់ត្រូវតែធ្វើបណ្តឹងឧទ្ធរណ៍តែម្តងហើយ ដោយសង្ឃឹមថាដើមចោទដាក់ពាក្យបណ្តឹងទៅឧទ្ធរណ៍ប្តឹងខ្លួន។ ឧទាហរណ៍ ៖ ដើមចោទ ក ទាមទារទៅ

[75] មាត្រា ១០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[76] មាត្រា ២៧២ និង ២៧៤ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[77] មាត្រា ២៧០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

សាលាដំបូង ចុងចម្លើយ ខ បង់ប្រាក់ចំនួន ១០០០០ ដុល្លារ ហើយតុលាការក៏បានសម្រេច ៩០០០ ដុល្លារ ក្នុងករណីនេះ ដើមចោទ ក អាចប្តឹងឧទ្ធរណ៍បានចំពោះសាលក្រមនេះប៉ុន្តែ ក មិនបានធ្វើបណ្តឹងឧទ្ធរណ៍ទេ។ បន្ទាប់មកចុងចម្លើយ ខ ធ្វើបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមនេះ ពេលនោះដើមចោទក៏បានធ្វើបណ្តឹងឧទ្ធរណ៍ ដែលបណ្តឹងឧទ្ធរណ៍របស់ដើមចោទ ហៅថា បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ។

បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ អាចធ្វើបាននៅគ្រប់ដំណាក់កាលនៃនីតិវិធីបណ្តឹងឧទ្ធរណ៍ ប៉ុន្តែត្រូវធ្វើនៅមុនពេលការទាញហេតុផលដោយផ្ទាល់មាត់នៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍បានបញ្ចប់ មានន័យថា ទោះបីជាសិទ្ធិប្តឹងឧទ្ធរណ៍ត្រូវបានរលត់ក៏ដោយ ( ហួសអំឡុងពេលប្តឹងឧទ្ធរណ៍ ) ក៏ចុងបណ្តឹងឧទ្ធរណ៍អាចធ្វើបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំបានដែរ។ ឧទាហរណ៍ ៖ ដំណាក់កាលដាក់ពាក្យបណ្តឹងឧទ្ធរណ៍រហូតដល់កាលនៃការទាញហេតុផលដោយផ្ទាល់មាត់ នេះជាអំឡុងពេលនៃការធ្វើបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ។ បន្ទាប់មកដល់ដំណាក់កាលនៃការប្រកាសសាលដីកា នោះនាំអោយសិទ្ធិក្នុងការធ្វើបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំត្រូវបានរលត់។

អំឡុងពេលធ្វើបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ ដូចគ្នានឹងបណ្តឹងឧទ្ធរណ៍ដែរ ពោលគឺ ០១ ខែ គិតចាប់ពីថ្ងៃទទួលបានលិខិតសាលក្រម ប៉ុន្តែទោះបីជា អំឡុងពេល ០១ ខែ កន្លងផុតក៏ដោយ ក៏អាចធ្វើបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំបានដែរ។ ក្នុងករណី បណ្តឹងឧទ្ធរណ៍ត្រូវ បាត់បង់អានុភាព នៅពេលដែលតុលាការនៃបណ្តឹងឧទ្ធរណ៍លើកចោលបណ្តឹងឧទ្ធរណ៍ឬដើមបណ្តឹងឧទ្ធរណ៍បានដកពាក្យបណ្តឹង បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំបាត់បង់អានុភាពដែរ ប្រសិនបើបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំនោះធ្វើឡើងហួសអំឡុងពេលប្តឹងឧទ្ធរណ៍។ បានសេចក្តីថា បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំនៅតែអាចធ្វើបានដដែល បើទោះជាសិទ្ធិប្តឹងឧទ្ធរណ៍របស់ចុងបណ្តឹងឧទ្ធរណ៍បានរលត់ ដោយហេតុថា អំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍កន្លងផុតហើយក៏ដោយ។[78] ក្នុងករណីបែបនោះ បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំកាន់តែមានន័យថែមទៀត ព្រោះអំឡុងពេលដែលកំណត់ ធ្វើបណ្តឹងឧទ្ធរណ៍មាន ១ខែ ដោយគិតពីថ្ងៃដែលទទួលការបញ្ជូនលិខិតនៃសាលក្រមចំពោះភាគីនីមួយៗ ហេតុដូច្នេះ ថ្ងៃចុងក្រោយនៃអំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍ អាចខុសគ្នាចំពោះភាគីម្នាក់ទៅភាគីម្នាក់។ ឧទាហរណ៍ ៖ ភាគីបានទទួលសាលក្រមនៅថ្ងៃទី ៣ ខែមីនា ឆ្នាំ២០២២ ក្រោយមកនៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០២២ ភាគី "ខ" បានប្តឹងឧទ្ធរណ៍ ដែលច្បាប់ទុករយៈពេលសម្រាប់ភាគីដែលបាត់បង់ផលប្រយោជន៍អាចប្តឹងឧទ្ធរណ៍បាន។ ក្រោយមក "ខ" ដែលជាចុងបណ្តឹងឧទ្ធរណ៍ ក៏បានប្តឹងឧទ្ធរណ៍បន្ទាប់បន្សំផងដែរ នៅថ្ងៃទី ១៣ ខែមេសា ឆ្នាំ ២០២២ ដែលជាកាលបរិច្ឆេទហួសអំឡុងពេលដែលច្បាប់បើកសិទ្ធិអោយប្តឹងឧទ្ធរណ៍គឺអំឡុងពេល ១ ខែ គិត

[78] មាត្រា ២៧០ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ពីថ្ងៃដែលភាគីទទួលបានសាលក្រម ប៉ុន្តែភាគី "ក" នៅតែមានសិទ្ធិនៅក្នុងការប្តឹងឧទ្ធរណ៍បន្ទាប់បន្សំមួយទៀតដែរ។

ផ្ទុយមកវិញ នៅក្នុងករណីដែលបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ បានធ្វើឡើងដោយឯករាជ្យ ទោះបីជាតុលាការលើកចោល ឬដើមបណ្តឹងឧទ្ធរណ៍ដកពាក្យបណ្តឹងឧទ្ធរណ៍ក៏ដោយ ក៏មិនប៉ះពាល់ដល់បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំដែរ ក្នុងករណីនេះបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ នឹងក្លាយជាបណ្តឹងឧទ្ធរណ៍ឯករាជ្យ ហើយតុលាការនៃបណ្តឹងឧទ្ធរណ៍នឹងបន្តចាត់ការលើបណ្តឹងឧទ្ធរណ៍នោះ។ ដោយសារតែបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំគឺជាបណ្តឹងឧបាស្រ័យដែលត្រូវបានធ្វើឡើង ដោយឆ្លៀតឱកាសដែលមានបណ្តឹងឧទ្ធរណ៍ពីភាគីម្ខាងទៀត ហេតុដូច្នេះ បើពាក្យបណ្តឹងឧទ្ធរណ៍ត្រូវបានដក ឬបណ្តឹងឧទ្ធរណ៍លើកចោល នោះបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំត្រូវបាត់បង់អានុភាព ប៉ុន្តែប្រសិនបើបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំនោះ ត្រូវបានធ្វើឡើងនៅក្នុងអំឡុងពេលដែលចុងបណ្តឹងឧទ្ធរណ៍អាចដាក់ពាក្យបណ្តឹងឧទ្ធរណ៍បាន បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំនោះ ត្រូវចាត់ទុកថាជាបណ្តឹងឧទ្ធរណ៍ឯករាជ្យ។[79]

តាមបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ ទំហំនៃឧបាស្រ័យដែលត្រូវបានវិនិច្ឆ័យនៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ត្រូវបានពង្រីក មានន័យថា សាលាឧទ្ធរណ៍ ត្រូវវិនិច្ឆ័យមិនមែនតែអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃឧបាស្រ័យរបស់ដើមបណ្តឹងឧទ្ធរណ៍ ប៉ុណ្ណោះទេ គឺត្រូវវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃឧបាស្រ័យរបស់ចុងចម្លើយឧទ្ធរណ៍ផងដែរ។[80] ប្រសិនបើមានតែដើមបណ្តឹងឧទ្ធរណ៍ទេ ដែលធ្វើឧបាស្រ័យតុលាការនៃបណ្តឹងឧទ្ធរណ៍មិនអាចផ្លាស់ប្តូរសាលក្រមដើម ដោយខូតខាតផលប្រយោជន៍ចំពោះដើមបណ្តឹងឧទ្ធរណ៍ ដោយហួសទំហំនៃសាលក្រមដើមបានឡើយ ប៉ុន្តែបើមានបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំពីចុងបណ្តឹងឧទ្ធរណ៍ តុលាការនៃបណ្តឹងឧទ្ធរណ៍ អាចធ្វើការផ្លាស់ប្តូរយ៉ាងដូច្នោះបាន។

ចំណែកឯរបៀបប្តឹងឧទ្ធរណ៍បន្ទាប់បន្សំវិញ ត្រូវអនុលោមទៅតាមបញ្ញត្តិនៃបណ្តឹងឧទ្ធរណ៍។[81] ហេតុដូច្នេះ ដើមបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ ( ចុងបណ្តឹងឧទ្ធរណ៍ ) ត្រូវដាក់លិខិតពាក្យបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ រីឯតុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវពិនិត្យពាក្យបណ្តឹងបន្ទាប់បន្សំនោះ ហើយត្រូវបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំនោះទៅដើមបណ្តឹងឧទ្ធរណ៍។

[79] មាត្រា ២៧០ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[80] មាត្រា ២៧០ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[81] មាត្រា ២៧០ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

### ១.៣.៤ ការបញ្ចប់នីតិវិធីនៃបណ្តឹងឧទ្ធរណ៍

ជាចុងបញ្ចប់នៃបណ្តឹងឧទ្ធរណ៍បន្ទាប់ពីការទាញហេតុផលដោយផ្ទាល់មាត់រួច ត្រូវតែបញ្ចប់បណ្តឹងឧទ្ធរណ៍ដោយវិធីពីរយ៉ាងដូចជា (ការបញ្ចប់បណ្តឹងឧទ្ធរណ៍ដោយមិនឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ ១.៣.៤.១) និង (ការបញ្ចប់បណ្តឹងឧទ្ធរណ៍ដោយឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ ១.៣.៤.២ )។

#### ១.៣.៤.១. ការបញ្ចប់បណ្តឹងឧទ្ធរណ៍ដោយមិនឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ

ការបញ្ចប់បណ្តឹងឧទ្ធរណ៍ដោយមិនឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ គឺអាចជា (ការបញ្ចប់បណ្តឹងឧទ្ធរណ៍ដោយស្វ័យប្រវត្តិ (ក) ) ឬ (ការបញ្ចប់បណ្តឹងឧទ្ធរណ៍ដោយសកម្មភាពភាគី (ខ) )។

**ក. ការបញ្ចប់បណ្តឹងឧទ្ធរណ៍ដោយស្វ័យប្រវត្តិ**

នីតិវិធីនៃបណ្តឹងឧទ្ធរណ៍កំពុងតែដំណើរការ ក្នុងករណីដែលមានភាគីណាមួយបានទទួលមរណភាព ហើយគ្មានអ្នកណាទទួលបន្តនូវសិទ្ធិ ឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងនាំ បណ្តឹងនោះត្រូវបានបញ្ចប់។ ជាទូទៅបើមានភាគីណាម្ខាងបានទទួលមរណភាពក៏ដោយ ក៏សន្តតិជនរបស់ភាគីនោះនឹងត្រូវទទួលបន្តនូវនីតិវិធីនៃបណ្តឹងដែលបានធ្វើពីមុនមក ហើយនីតិវិធីបណ្តឹងឧទ្ធរណ៍នោះមិនត្រូវបានបញ្ចប់ទេ ប៉ុន្តែបើមានករណីដែលភាគីបានទទួលរណភាពនោះ ពុំមានអ្នកដែលត្រូវទទួលបន្តនូវនីតិវិធីនៃបណ្តឹងដោយសារសិទ្ធិ ឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹង តុលាការនៃបណ្តឹងឧទ្ធរណ៍នឹងចេញសាលដីកាបញ្ចប់បណ្តឹងនោះ ដោយស្វ័យប្រវត្តិ ដោយខ្លឹមសារថាបណ្តឹងឧទ្ធរណ៍ត្រូវបានបញ្ចប់ដោយសារមរណភាពរបស់ភាគី។

ក្នុងករណីដែលសិទ្ធិ ឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងបានរលត់ដោយសារការរួមបញ្ចូលគ្នានៃនីតិបុគ្គលនាំ សិទ្ធិ ឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងត្រូវធ្លាក់លើបុគ្គលតែម្នាក់ ហើយដើមបណ្តឹងឧទ្ធរណ៍ និងចុងបណ្តឹងឧទ្ធរណ៍បានក្លាយទៅជាបុគ្គលតែមួយ ដោយសារតែភាគីណាម្ខាងបានទទួលបន្តនូវឋានៈតាមផ្លូវបណ្តឹងរបស់ភាគីម្ខាងទៀត ដោយសារការរួមបញ្ចូលគ្នានៃនីតិបុគ្គល ឬដោយសន្តតិកម្ម។ ករណីនេះ តុលាការ នឹងចេញសាលដីកាបញ្ចប់បណ្តឹងដោយស្វ័យប្រវត្តិ ដោយសារតែមានភាគីជាបុគ្គលតែមួយ។

**ខ. ការបញ្ចប់បណ្តឹងឧទ្ធរណ៍ដោយសកម្មភាពរបស់ភាគី**

ការបញ្ចប់បណ្តឹងដោយសកម្មភាពរបស់ភាគី ក្នុងនោះអាចជាសកម្មភាពនៃការដកពាក្យបណ្តឹងការលះបង់ ឬការទទួលស្គាល់ការទាមទារ និងការសះជាតាមផ្លូវបណ្តឹងរបស់ភាគី នឹងសកម្មភាពនៃបណ្តឹងត្រូវបានបញ្ចប់ផងដែរ ៖

⇒ ទោះបីជាបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់រួចហើយក៏ដោយ ភាគីនៅតែមានសិទ្ធិនៅក្នុងការដកពាក្យបណ្តឹងវិញនៅពេលណាក៏បានរហូតដល់ពេលដែល សាលដីកាចុងក្រោយរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវបានប្រកាស ដោយមិនចាំបាច់ទទួលបានការយល់ព្រមពីចុងចម្លើយបណ្តឹង

ឧទ្ធរណ៍។[82] ជាក់ស្តែងអំឡុងពេលនៃការដកពាក្យបណ្តឹង គឺចាប់ពីការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ រហូតដល់ការប្រកាសសាលដីកានៃការជំនុំជម្រះលើកទី២ ឬក្នុងនាមការជំនុំជម្រះលើកទី១ នៅពេលដែលប្រកាសសាលដីការួច សិទ្ធិក្នុងការដកពាក្យបណ្តឹងឧទ្ធរណ៍ត្រូវបានរលត់។ ការដកពាក្យបណ្តឹងឧទ្ធរណ៍ គឺជាការដកចេញនូវការធ្វើឧបាស្រ័យចំពោះសាលក្រមនៃការជំនុំជម្រះលើកទី១ ហេតុនេះអានុភាពនៃការដកពាក្យបណ្តឹងឧទ្ធរណ៍នាំ នីតិវិធីនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ត្រូវបានបញ្ចប់ និងត្រូវបានចាត់ទុកថាគ្មានបណ្តឹងឧទ្ធរណ៍តាំងពីដើមហើយសាលក្រមនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ត្រូវបានបញ្ចប់ និងត្រូវបានចាត់ទុកថាគ្មានបណ្តឹងឧទ្ធរណ៍តាំងពីដើមហើយសាលក្រមនៃការជំនុំជម្រះលើកទី១ ត្រូវចូលជាស្ថាពរតាំងពីថ្ងៃផុតអំឡុងពេលនៃការប្តឹងឧទ្ធរណ៍។[83] ក្នុងករណីនេះការចាត់ទុកបណ្តឹងទាំងមូល រួមទាំងសាលក្រមនៃការជំនុំជម្រះលើកទី១ នឹងត្រូវរលត់ដោយអានុភាពប្រតិសកម្ម។ ដកពាក្យបណ្តឹងឧទ្ធរណ៍ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ប៉ុន្តែនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬកាលបរិច្ឆេទនៃការផ្សះផ្សារ ការដកពាក្យបណ្តឹងឧទ្ធរណ៍អាចធ្វើដោយផ្ទាល់មាត់បាន។ ដោយឡែកការដកពាក្យបណ្តឹងឧទ្ធរណ៍មួយផ្នែក គឺហៅថា មោឃៈ ដោយសារគោលការណ៍នៃភាពអវិភាគនៃបណ្តឹងឧទ្ធរណ៍។ ការដកពាក្យបណ្តឹងមិនមានឥទ្ធិពលទៅលើសាលក្រមដើម ឬអានុភាពនៃការជំនុំជម្រះលើកទី១ ទេ ហើយមិនមានការខូចផលប្រយោជន៍ដល់ចុងបណ្តឹងឧទ្ធរណ៍ទេ ហេតុដូច្នេះមិនចាំបាច់មានការយល់ព្រមពីចុងបណ្តឹងឧទ្ធរណ៍ឡើយ។ ក្រោយការដកពាក្យបណ្តឹងឧទ្ធរណ៍ បើអំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍មិនទាន់កន្លងផុតទេ ភាគីម្ខាងទៀតព្រមទាំងដើមបណ្តឹងឧទ្ធរណ៍ដែលបានដកពាក្យបណ្តឹងរួចហើយ ក៏អាចប្តឹងឧទ្ធរណ៍ម្តងទៀតបានដែរ។ នៅពេលដែលដកពាក្យបណ្តឹងឧទ្ធរណ៍អាចមានការសងពន្ធដាក់ពាក្យសុំពាក់កណ្តាល លុះត្រានៅក្នុងករណីដែលបណ្តឹងឧទ្ធរណ៍ត្រូវបានដកមុនកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ លើកដំបូងនៅតុលាការនៃបណ្តឹងឧទ្ធរណ៍ នាំឱ្យដើមបណ្តឹងឧទ្ធរណ៍អាចដាក់ពាក្យសុំ សងពាក់បណ្តាលនៃពន្ធដាក់ពាក្យសុំ។

⇒ ការលះបង់ ឬការទទួលស្គាល់នូវការទាមទារ[84] ៖ គឺភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍ដែលធ្វើ មានការខូចផលប្រយោជន៍របស់ខ្លួនទទួលស្គាល់ថា ការទាមទាររបស់ខ្លួនពុំមានមូលហេតុត្រឹមត្រូវ ឬទទួលស្គាល់ថាការទាមទាររបស់ភាគីម្ខាងទៀតមានមូលហេតុត្រឹមត្រូវចំពោះការទាមទារ។ ដោយការ

[82] មាត្រា ២៦៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[83] មាត្រា ២៦៣ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[84] មាត្រា ២៦៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

លះបង់ ឬការទទួលស្គាល់ថាការទាមទារជាសេចក្តីថ្លែងការណ៍តាមផ្លូវបណ្តឹងដែលភាគីម្ខាងទទួលស្គាល់ពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃការទាមទារ ហើយវិវាទរវាងភាគីទាំងសងខាងត្រូវបានដោះស្រាយដោយសេចក្តីថ្លែងការណ៍នេះ សកម្មភាពទាំងនេះនាំឱ្យបណ្តឹងត្រូវបានបញ្ចប់ដោយមិនចាំបាច់រងចាំសាលដីកាទេ។ ចំពោះល័ក្ខខ័ណ្ឌចាំបាច់ក្នុងការទទួលស្គាល់នូវការទាមទារ គឺជាសកម្មភាពបណ្តឹងមួយយ៉ាងសំខាន់ក្នុងការបញ្ចប់នីតិវិធីនៃបណ្តឹងឧទ្ធរណ៍ ដូច្នេះហើយភាគីចាំបាច់ត្រូវតែជាបុគ្គលដែលមានសមត្ថភាពក្នុងការធ្វើបណ្តឹង។ ចំពោះអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅអាចធ្វើការលះបង់ ឬទទួលស្គាល់នូវការទាមទារមានសុពលភាពបាន លុះត្រាតែត្រូវបានធ្វើដោយអ្នកតំណាងដែលច្បាប់បានកំណត់ លើកលែងតែអនីតិជនដែលអាចធ្វើសកម្មភាពដោយឯករាជ្យ។ រីឯជននៅក្រោមហិតូបត្ថម្ភ ឬអ្នកតំណាងដែលច្បាប់បានកំណត់ត្រូវមានការប្រគល់សិទ្ធិពិសេស ដើម្បីធ្វើសកម្មភាពក្នុងការលះបង់ការទាមទារ ឬទទួលស្គាល់នូវការទាមទារនេះ។ ចំពោះអានុភាពនៃការលះបង់ ឬការទទួលស្គាល់នូវការទាមទារនេះ តុលាការនៃបណ្តឹងឧទ្ធរណ៍ បើពិនិត្យទៅឃើញថាភាគីមានល័ក្ខខ័ណ្ឌគ្រប់គ្រាន់ក្នុងការលះបង់ ឬទទួលស្គាល់នូវការទាមទារក្រឡាបញ្ជីត្រូវចុះក្នុងកំណត់ហេតុនាំ បណ្តឹងត្រូវបានបញ្ចប់ ហើយកំណត់ហេតុនោះមានអានុភាពដូចគ្នានឹងសាលដីកាស្ថាពរដែរ។

⇒ ការសះជាតាមផ្លូវបណ្តឹង ៖ ជាសកម្មភាពមួយដែលដើមបណ្តឹងឧទ្ធរណ៍ និងចុងបណ្តឹងឧទ្ធរណ៍ធ្វើឱ្យសម្បទាន គ្នាទៅវិញទៅមកនូវការអះអាងអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្តឹង នេះជាការព្រមព្រៀងគ្នាបញ្ចប់វិវាទនៅក្នុងនីតិវិធីបណ្តឹងតាមរយៈការសម្រុះសម្រួលគ្នាចំពោះទំនាក់ទំនងនៃសិទ្ធិដែលជាចំណុចវិវាទ ដោយភាគីទាំងសងខាងចាំបាច់ត្រូវបង្ហាញខ្លួននៅចំពោះមុខតុលាការនៃបណ្តឹងឧទ្ធរណ៍ នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយព្រមព្រៀងគ្នាដោយផ្ទាល់មាត់។ចំពោះល័ក្ខខ័ណ្ឌចាំបាច់នៃការសះជាតាមផ្លូវបណ្តឹងក៏ជាសកម្មភាពបណ្តឹងដែរ ដូច្នេះដើម្បីធ្វើការសះជាបាន ភាគីចាំបាច់ត្រូវតែជាបុគ្គលដែលមានសមត្ថភាពក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ ដូច្នេះបើមានភាគីណាមួយជាបុគ្គលដែលត្រូវបានកម្រិតសមត្ថភាពបានធ្វើការសះជានោះ គឺពុំមានអានុភាព ឡើយ។ អានុភាពនៃការសះជាមានអានុភាពបញ្ចប់បណ្តឹងដោយការសះជា គឺជាការព្រមព្រៀងបញ្ចប់វិវាទរបស់ភាគីនៃបណ្តឹងឧទ្ធរណ៍ដែលបានកត់ត្រានៅក្នុងកំណត់ហេតុ ដូច្នេះលទ្ធផលនៃការសះជាតាមផ្លូវបណ្តឹងនេះ នាំឱ្យនីតិវិធីនៃបណ្តឹង

ឧទ្ធរណ៍ត្រូវបានបញ្ចប់ផងដែរ។[85] កំណត់ហេតុនៃការសះជា មានអានុភាពដូចគ្នានឹងសាលដីកាស្ថាពរដែរប្រសិនបើក្នុងកំណត់ហេតុនេះ មានចុះអំពីសិទ្ធិទាមទារ ផ្តល់តាវកាលិកជាក់ស្តែងដោយមានការកំណត់ពេលអនុវត្ត និងបែបផែននៃការអនុវត្ត ដូច្នេះហើយកំណត់ហេតុសះជាត្រូវមានអានុភាព អនុវត្ត ហើយកំណត់ហេតុនេះក្លាយទៅជាលិខិតអនុវត្ត ដែលភាគីះអាចសម្រេចនូវសិទ្ធិទាមទារតាម រយៈការអនុវត្តដោយបង្ខំបាន។ បើការសះជាតាមផ្លូវបណ្តឹងមានវិការៈភាគីអាចអះអាងអំពីមោឃភាព ឬការលុបចោលការសះជានោះដោយយកវិការៈ ក្នុងការបង្ហាញឆន្ទៈមកធ្វើជាមូលហេតុនៅពេលក្រោយបាន។ ករណីមានជម្លោះអំពីអានុភាពនៃការសះជា នោះនីតិវិធីនៃការដោះស្រាយនេះមិនមែនជាការសុំជំនុំជម្រះសាជាថ្មីដូចករណីសាលដីកាទេ គឺគ្រាន់តែជាការស្នើសុំតុលាការនៃបណ្តឹងឧទ្ធរណ៍ កំណត់នូវកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់សាជាថ្មីតែប៉ុណ្ណោះ។ បើសិនជាមានពាក្យសុំ តុលាការនៃបណ្តឹងឧទ្ធរណ៍កំណត់នូវកាលបរិច្ឆេទជាថ្មីម្តងទៀតដោយមានមូលហេតុមានវិការៈក្នុងការសះជា តុលាការនៃបណ្តឹងឧទ្ធរណ៍ចាំបាច់ត្រូវកំណត់ នូវកាលបរិច្ឆេទនោះម្តងទៀតតាមពាក្យសុំរបស់ភាគី ហើយនៅកាលបរិច្ឆេទជាថ្មីនេះ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវវិនិច្ឆ័យជាមុនថា ការសះជាដែលបានធ្វើពីមុននោះមានសុពលភាព ឬគ្មានសុពលភាព។[86] ប៉ុន្តែបើការ វិនិច្ឆ័យឃើញថា ការសះជានោះមានវិការៈតុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវធ្វើការបញ្ជាក់ថា បណ្តឹងនោះមិនទាន់ត្រូវបានបញ្ចប់ទេ ហើយត្រូវបន្តការវិនិច្ឆ័យលើបណ្តឹងនោះ។ ប៉ុន្តែបើវិនិច្ឆ័យឃើញថា ការសះជាដែលបានធ្វើពីមុននោះមានសុពលភាព តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវចេញសាលដីកាដែលប្រកាសអំពីការបញ្ចប់បណ្តឹងដោយការសះជានោះ។ ចំពោះបន្ទុកនៃប្រាក់ប្រដាប់ក្តីភាគីដែលត្រូវទទួលបន្ទុកនៃប្រាក់ប្រដាប់ក្តី គឺអាស្រ័យទៅលើការព្រមព្រៀងរបស់ភាគីនោះ ប៉ុន្តែប្រសិនបើភាគីគ្មានការព្រមព្រៀងគ្នាអំពីប្រាក់ប្រដាប់ក្តីទេ ភាគីនីមួយៗត្រូវទទួលបន្ទុកក្នុងការបង់រៀងៗខ្លួន។ បើការសះជាបានសម្រេចលទ្ធផលមុនពេល ធ្វើការទាញហេតុផលមាត់ដើមបណ្តឹងឧទ្ធរណ៍ទទួលបានការសងវិញនូវចំនួនពាក់កណ្តាលនៃពន្ធដែលបានបង់រួចហើយ។

**១.៣.៤.២. ការបញ្ចប់បណ្តឹងឧទ្ធរណ៍ដោយឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ**

ការបញ្ចប់បណ្តឹងឧទ្ធរណ៍ដោយឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការវិញ គឺជាការចេញសាលដីកាចំពោះបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ ដែលអាចជាសាលដីកាលើកចោលបណ្តឹងឧទ្ធរណ៍ ឬសាលដីកាច្រានបណ្តឹងឧទ្ធរណ៍ ឬសាលដីកាទទួលស្គាល់បណ្តឹងឧទ្ធរណ៍។

[85] មាត្រា ២២២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[86] មាត្រា ១១៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

### ក. សាលដីកាលើកចោលបណ្តឹងឧទ្ធរណ៍

តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវចេញសាលដីកាចុងក្រោយ ចំពោះបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ។ ប្រសិនបើបណ្តឹងឧទ្ធរណ៍នោះមិនស្របច្បាប់ ដោយសារខ្វះនូវល័ក្ខខ័ណ្ឌនៃបណ្តឹងឧទ្ធរណ៍ តុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវចេញសាលដីកាលើកចោលបណ្តឹងឧទ្ធរណ៍នោះ។[87] បើបណ្តឹងឧទ្ធរណ៍មានលក្ខណៈផ្ទុយនឹងច្បាប់ ហើយចំណុចខ្វះខាតចំពោះល័ក្ខខ័ណ្ឌនោះមិនអាចគេតម្រូវបានទេ តុលាការអាចលើកចោលបណ្តឹងឧទ្ធរណ៍ ដោយសាលដីកា ដោយមិនឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់បាន។ តុលាការនៃបណ្តឹងឧទ្ធរណ៍ ចេញសាលដីកាលើកបណ្តឹងឧទ្ធរណ៍ចោល ក្នុងករណីបណ្តឹងឧទ្ធរណ៍មិនស្របច្បាប់ ឬខុសល័ក្ខខ័ណ្ឌនៃបណ្តឹងឧទ្ធរណ៍ដែលមិនអាចកែតម្រូវបាន ដូចជាករណីផុតសិទ្ធិប្តឹងឧទ្ធរណ៍ ឬគ្មានផលប្រយោជន៍នៃបណ្តឹងឧទ្ធរណ៍ជាអាទិ៍ ហេតុនេះតុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវចេញសាលដីកាលើកបណ្តឹងឧទ្ធរណ៍ចោល ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់។[88] ឧទាហរណ៍ ៖ ដើមបណ្តឹងឧទ្ធរណ៍ ដាក់ពាក្យប្តឹងឧទ្ធរណ៍ប្តឹងចុងបណ្តឹងឧទ្ធរណ៍ ដោយផុតកំណត់នៃការប្តឹងឧទ្ធរណ៍ នាំឱ្យបណ្តឹងឧទ្ធរណ៍មិនស្របនឹងច្បាប់ដែលមិនអាចកែតម្រូវ នោះតុលាការនៃបណ្តឹងឧទ្ធរណ៍ចេញសេចក្តីសម្រេចបញ្ចប់ដែលមានខ្លឹមសារ លើកចោលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ របស់ដើមបណ្តឹងឧទ្ធរណ៍ និងប្រាក់ប្រដាប់ក្តីក៏ជាបន្ទុករបស់ដើមបណ្តឹងឧទ្ធរណ៍។

ក្នុងករណីបណ្តឹងឧទ្ធរណ៍ត្រូវបានលើកចោល នោះនាំឱ្យបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំក៏ត្រូវលើកចោលដែរ ប្រសិនបើបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំនោះធ្វើឡើងហួសអំឡុងពេលប្តឹងឧទ្ធរណ៍ ដែលនាំឱ្យបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំបានបាត់បង់អានុភាពព្រោះមិនស្របនឹងច្បាប់។ ប៉ុន្តែបើបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំនោះធ្វើឡើងមិនហួសអំឡុងពេលប្តឹងឧទ្ធរណ៍ និងមានល័ក្ខខ័ណ្ឌនៃបណ្តឹងឧទ្ធរណ៍គ្រប់គ្រាន់ ដែលហៅថាបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំដោយឯករាជ្យ ហើយទោះបីជាតុលាការលើកចោលបណ្តឹងឧទ្ធរណ៍ក៏ដោយ ក៏មិនប៉ះពាល់ ឬបាត់បង់អានុភាពដល់បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំដែរ។

### ខ. សាលដីកាច្រានចោលបណ្តឹងឧទ្ធរណ៍

តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវចេញសាលដីកាច្រានចោលបណ្តឹងឧទ្ធរណ៍ ក្នុងករណីតុលាការយល់ឃើញថាសាលក្រមនៃការជំនុំជម្រះលើកទី១ ត្រឹមត្រូវ ទោះបីជាសំអាងហេតុនៃការជំនុំជម្រះលើកទី១ មិនត្រឹមត្រូវក៏ដោយបើយល់ឃើញថាសេចក្តីសម្រេចបញ្ចប់នៃសាលក្រមនៃការជំនុំជម្រះលើកទី ១ នោះត្រឹមត្រូវ បើ

[87] មាត្រា ២៦៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[88] មាត្រា ២៦៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ផ្អែកលើសំអាងហេតុផ្សេងទៀត។[89] នេះដោយសារតែអាជ្ញាអស់ជំនុំមិនត្រូវកើតឡើងទៅលើសេចក្តីវិនិច្ឆ័យ នៅក្នុងសំអាងហេតុនៃសាលក្រមដើមទេ ហេតុដូច្នេះភាពមិនត្រឹមត្រូវនៃសំអាងហេតុនោះគ្មានឥទ្ធិពលទៅលើអានុភាពនៃសាលក្រមឡើយ។[90]

**គ. សាលដីកាទទួលស្គាល់បណ្តឹងឧទ្ធរណ៍**

ប្រសិនបើការប្តឹងឧបាស្រ័យចំពោះសាលក្រមនៃការជំនុំជម្រះលើកទី១ មានមូលហេតុត្រឹមត្រូវ ហើយសាលក្រមនៃការជំនុំជម្រះលើកទី ១ មិនត្រឹមត្រូវ ឬប្រសិនបើនីតិវិធីនៃការជំនុំជម្រះលើកទី ១ ខុសច្បាប់ធ្ងន់ធ្ងរ ហើយតុលាការនៃបណ្តឹងឧទ្ធរណ៍មិនអាចយកនីតិវិធីនៃការជំនុំជម្រះលើកទី ១ នោះមកធ្វើជាមូលដ្ឋាននៃការវិនិច្ឆ័យ តុលាការនៃបណ្តឹងឧទ្ធរណ៍ ហើយត្រូវលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១ នោះ។[91]ផ្ទុយមកវិញតុលាការនៃបណ្តឹងឧទ្ធរណ៍ចេញសាលដីកាទទួលស្គាល់បណ្តឹងឧទ្ធរណ៍ ក្នុងករណីតុលាការនៃបណ្តឹងឧទ្ធរណ៍យល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី១ មានភាពមិនត្រឹមត្រូវ ឬខុសនីតិវិធីធ្ងន់ធ្ងរតុលាការត្រូវលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី១ ហើយតុលាការនៃបណ្តឹងឧទ្ធរណ៍អាចធ្វើការវិនិច្ឆ័យដោយខ្លួនឯងជំនួសសាលាដំបូង ឬបញ្ជូនត្រលប់ ឬផ្ទេររឿងក្តី។ ដោយព្រោះការលុបចោលនូវសាលក្រមនៃការជំនុំជម្រះលើកទី១ បានសេចក្តីថាតុលាការមិនឆ្លើយតបទៅនឹងបណ្តឹងដែលបានប្តឹងតុលាការត្រូវចាត់ការនូវវិធានសមរម្យដូចតទៅ ៖

**គ.១. ការលុបចោល និងការវិនិច្ឆ័យដោយខ្លួនឯង**

នៅពេលតុលាការនៃបណ្តឹងឧទ្ធរណ៍ទទួលស្គាល់បណ្តឹងឧទ្ធរណ៍ក្នុងពីរករណី គឺតុលាការនៃបណ្តឹងឧទ្ធរណ៍យល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី១ មានភាពមិនត្រឹមត្រូវ ឬខុសនីតិវិធីធ្ងន់ធ្ងរ ៖

⇒ ក្នុងករណីតុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី១ ប្រសិនបើយល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី១ មានភាពមិនត្រឹមត្រូវគឺជាសាលក្រមដែលមាន កំហុស។[92] ឧទាហរណ៍ ៖ សាលក្រមដើមសម្រេច ដើមចោទឈ្នះក្តីដែលមានខ្លឹមសារថា បង្គាប់ឱ្យចុងចម្លើយលុបចោលនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិលើដី L ទាំងមូល ដោយមូលហេតុរំលាយកិច្ចសន្យាលក់ទិញចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ ផ្អែកលើអត្ថិភាពនៃអង្គហេតុរំលាយកិច្ចសន្យា ប៉ុន្តែតុលាការនៃបណ្តឹងឧទ្ធរណ៍យល់ឃើញថាគ្មានអត្ថិភាពនៃអង្គហេតុរំលាយទេដែលមិន

[89] មាត្រា ២៧៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[90] មាត្រា ១៩៤ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[91] មាត្រា ២៧៩ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[92] មាត្រា ២៧៩ កថាខណ្ឌទី១ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

មានភាពត្រឹមត្រូវ ដោយផ្អែកលើសំអាងហេតុផ្សេង គប្បីឱ្យដើមចោទចាញ់ក្តី ( ចុងបណ្តឹងឧទ្ធរណក្នុងករណីនេះតុលាការនៃ បណ្តឹងឧទ្ធរណ៍មិនលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី១ ទាំងស្រុងនោះទេ ប៉ុន្តែធ្វើការផ្លាស់ប្តូរ ឬកែប្រែខ្លឹមសារសាលក្រមនៃការជំនុំជម្រះលើកទី ១។ ដូច្នេះ ករណីនេះតុលាការនៃបណ្តឹងឧទ្ធរណ៍ជំនុំជម្រះលើសាលក្រមដើម ដោយចេញសេចក្តីសម្រេចបញ្ចប់នៃសាលដីកាដោយកែប្រែ ឬផ្លាស់ប្តូរនូវសាលក្រមដើម។[93]

⇒ ចំពោះករណីតុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១ បើយល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី១ ខុសនីតិវិធីធ្ងន់ធ្ងរ។[94] កំហុសនីតិវិធីធ្ងន់ធ្ងរមានដូចជាការសាកសួរសាក្សីនៅក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬការប្រកាសសាលក្រមដោយចៅក្រមដែលមិនមែនជាអ្នកវិនិច្ឆ័យជាអាទិ៍។

**គ.២. ការលុបចោល និងការបញ្ជូនត្រលប់ទៅតុលាការដើមវិញ**

តុលាការនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ បានទទួលពាក្យបណ្តឹងចំពោះសាលក្រមលើកចោលបណ្តឹងរបស់តុលាការនៃការជំនុំជម្រះលើកទី១ បើតុលាការនៃបណ្តឹងឧទ្ធរណ៍យល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី១ មិនត្រឹមត្រូវតាមច្បាប់ ហើយមានភាពចាំបាច់ត្រូវទាញហេតុផលបន្ថែមទៀតចំពោះរឿងក្តីនោះ តុលាការនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ត្រូវលុបចោលសាលក្រមនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ត្រូវលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី១ ដោយបញ្ជូនត្រឡប់ទៅតុលាការដើម នោះគឺជាសាលាដំបូងរាជធានីខេត្តវិញ។[95] លើសពីនេះទៅទៀត តុលាការអាចលើកចោលបណ្តឹង ដោយមូលហេតុខ្វះលក្ខខណ្ឌនៃបណ្តឹងផ្ទុយច្បាប់ដែលមិនអាចកែតម្រូវបាន។

**គ.៣. ការលុបចោល និងផ្ទេររឿងក្តី**

តុលាការនៃបណ្តឹងឧទ្ធរណ៍លុបចោលសាលក្រមដើម និងផ្ទេររឿងក្តីទៅតុលាការដែលមានសមត្ថកិច្ចក្នុងករណី តុលាការនៃការជំនុំជម្រះលើកទី១ បានធ្វើការជំនុំជម្រះលើរឿងក្តីដែលខ្លួនគ្មានសមត្ថកិច្ច[96]។ នៅក្នុងរឿងក្តីទាក់ទងនឹងឋានៈបុគ្គល សមត្ថកិច្ចជម្រះក្តី ជាសមត្ថកិច្ចផ្តាច់មុខរបស់សាលាដំបូង ដែលមានសមត្ថកិច្ចលើលំនៅឋានរបស់ភាគីនៃទំនាក់ទំនងឋានៈបុគ្គល ឬលំនៅឋានរបស់ភាគីនោះទទួលមរណភាព។ ក្នុងករណីលំនៅឋានរបស់ភាគីមិនច្បាស់លាស់ គឺកំណត់យកទីសំណាក់ បើគ្មានទីសំណាក់ គឺកំណត់យកទី

[93] មាត្រា ២៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[94] មាត្រា ២៧៩ កថាខណ្ឌទី១ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[95] មាត្រា ២៨០ កថាខណ្ឌទី១ និងទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[96] មាត្រា ២៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

តាំងស្នាក់ការចុងក្រោយប៉មិនអាចកំណត់បានទេ បណ្តឹងឋានៈបុគ្គលស្ថិតក្រោមសមត្ថកិច្ចរបស់សាលាដំបូងរាជធានី ភ្នំពេញ។ ឧទាហរណ៍ ៖ ដើមចោទ "ក" ប្តឹងលែងលះជាមួយនឹងចុងចម្លើយ "ខ"។ "ក" មានលំនៅឋានខេត្តកំពង់ឆ្នាំង ហើយ "ខ" មានលំនៅឋាននៅខេត្តបាត់ដំបង ពួកគេបានចុះសំបុត្រអាពាហ៍អាពាហ៍នៅខេត្តបាត់ដំបង បន្ទាប់មក អ្នកទាំងពីរបានរស់នៅខេត្ត កំពង់ចាមអស់រយៈពេល៥ឆ្នាំក្នុងអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយ អ្នកទាំងពីរមានភាពមិនចុះសម្រុងនឹងគ្នា "ខ" បានចាកចេញពីកំពង់ចាមមករស់នៅភ្នំពេញ។ "ក" បានប្តឹងលែងលះ "ខ" មកសាលាដំបូងរាជធានីភ្នំពេញ ហើយសាលាដំបូងនេះ ក៏បានចាត់ការលើបណ្តឹង និងចេញសាលក្រម បន្ទាប់មក "ខ" បានប្តឹងឧទ្ធរណ៍នឹងសាលក្រមនេះ។

# ជំពូកទី២

# បណ្តឹងសាទុក្ខ និងបណ្តឹងជំទាស់

# ជំពូកទី២
# បណ្តឹងសាទុក្ខ និងបណ្តឹងជំទាស់

## ២.១ បណ្តឹងសាទុក្ខ

ក្រោយពេលដែលសាលាឧទ្ធរណ៍បានចេញនូវសេចក្តីសម្រេច ភាគីនៅតែមិនសុខចិត្តទៅនឹងសេចក្តីសម្រេចនោះទៀត ភាគីនៅតែមានសិទ្ធិធ្វើបណ្តឹងសាទុក្ខទៅតុលាការកំពូលដែលជាតុលាការនៃការជំនុំជម្រះលើកចុងក្រោយ។ បណ្តឹងសាទុក្ខនេះ ក៏ត្រូវតែគោរពទៅតាមកម្មវត្ថុ និងល័ក្ខខ័ណ្ឌ បានគ្រប់គ្រាន់ ក៏ដូចជាអានុភាពនៃការដាក់ពាក្យបណ្តឹងសាទុក្ខ។ លើសពីនេះទៅទៀត ចំពោះបណ្តឹងសាទុក្ខក៏ចាំបាច់គោរពទៅតាមលំហូរនីតិវិធីនៃការជំនុំជម្រះបណ្តឹងសាទុក្ខផងដែរ ដូចជា ការធ្វើបណ្តឹងសាទុក្ខនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ បណ្តឹងសាទុក្ខបន្ទាប់បន្សំ និងការបញ្ចប់បណ្តឹងសាទុក្ខ ជានីតិវិធីចុងក្រោយ។ ដើម្បីមានភាពងាយស្រួលក្នុងការសិក្សា លើកបណ្តឹងសាទុក្ខយើងគួរគប្បីសិក្សាចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

### ២.១.១ សញ្ញាណទូទៅនៃបណ្តឹងសាទុក្ខ

បណ្តឹងសាទុក គឺជាបណ្តឹងឧបាស្រ័យទៅតុលាការ ចំពោះសាលក្រម ឬសាលដីកាចុងក្រោយដែលទាមទារ វិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃសាលក្រម ឬសាលដីកាចុងក្រោយ ចំពោះការអនុវត្តច្បាប់ប៉ុណ្ណោះ។ ជាគោលការណ៍ បណ្តឹងសាទុក្ខ អាចធ្វើបានចំពោះសាលដីកាចុងក្រោយនៃការ ជំនុំជម្រះបណ្តឹងឧទ្ធរណ៍។[97] ក៏ប៉ុន្តែ ក្នុងករណីដែលមានការព្រមព្រៀងស្តីពីការប្តឹងសាទុក្ខផ្លោះទៅតុលាកំពូល[98] និងក្នុងករណីដែលសាលាឧទ្ធរណ៍ជាតុលាការនៃការជំនុំជម្រះលើទី១។[99] ការជំនុំជម្រះនៃបណ្តឹងសាទុក្ខ គឺជាការជំនុំជម្រះលើអង្គច្បាប់ ដែលតុលាការកំពូលវិនិច្ឆ័យអំពីភាពត្រឹមត្រូវ មិនត្រឹមត្រូវនៃសាលក្រម ឬសាលដីកាដើមចុងក្រោយ ក្នុងនាមតុលាការនៃបណ្តឹងសាទុក្ខហេតុដូច្នេះខុសគ្នាពីការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៅក្នុងការជំនុំជម្រះបណ្តឹងសាទុក្ខ តុលាការធ្វើការពិនិត្យមើលជាថ្មីម្តងទៀតនៅលើសាលក្រម ឬសាលដីកាដើមដោយផ្អែកទៅលើធនធានដែលបានប្រើប្រាស់សម្រាប់វិនិច្ឆ័យនៅក្នុងសាលក្រម ឬសាលដីកានោះ។ តុលាការនៃបណ្តឹងសាទុក្ខមិនធ្វើការទទួលស្គាល់នូវអង្គហេតុឡើងវិញទេ គឺគ្រាន់តែវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវក្នុងការអនុវត្តច្បាប់ចំពោះ អង្គហេតុដោយផ្អែកលើការទទួលស្គាល់នូវអង្គហេតុដោយតុលាការដើម។ ក្នុង

[97] មាត្រា ២៨៣ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[98] មាត្រា ២៦០ កថាខណ្ឌទី១ ចំណុច ក និង មាត្រា ២៨៣ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[99] មាត្រា ២៨៣ កថាខណ្ឌ ទី១ វាក្យខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ន័យនេះ ជាគោលការណ៍ តុលាការនៃបណ្តឹងសាទុក្ខ ត្រូវបានចងដោយអង្គហេតុដែលត្រូវបានទទួលស្គាល់ជាស្ថាពរ ដោយស្របច្បាប់ ក្នុងសាលក្រម ឬសាលដីកាដើម។[100]

**២.១.១.១. កម្មវត្ថុ មូលហេតុ និងលក្ខខណ្ឌនៃបណ្តឹងសាទុក្ខ**

ដើម្បីមានភាពងាយស្រួលសិក្សា លើកម្មវត្ថុ មូលហេតុ និង លក្ខខណ្ឌនៃបណ្តឹងឧទ្ធរណ៍ យើងគប្បីសិក្សាចំណុចនីមួយៗដូចខាងក្រោម ៖

**ក. កម្មវត្ថុនៃបណ្តឹងសាទុក្ខ**

កម្មវត្ថុនៃបណ្តឹងសាទុក្ខ គឺសំដៅលើសេចក្តីសម្រេចដែលអាចប្តឹងសាទុក្ខបាន មានតែសេចក្តីសម្រេចចុងក្រោយដែលចេញពីសាលាដំបូង ឬសាលាឧទ្ធរណ៍ ប៉ុន្តែការចេញសេចក្តីសម្រេចមិនទាន់ចូលជាស្ថាពរ។[101] តួយ៉ាង ក្នុងករណីពិសេស ប្រសិនបើភាគីមានការព្រមព្រៀងគ្នាប្តឹងសាទុក្ខផ្លោះទៅតុលាការកំពូលថាមិនធ្វើបណ្តឹងឧទ្ធរណ៍នៅក្រោយពេលដែលសាលាដំបូងចេញសាលក្រម ដោយរក្សាសិទ្ធិធ្វើបណ្តឹងសាទុក្ខហើយបានធ្វើជាលាយលក្ខណ៍អក្សរនោះ ភាគីអាចធ្វើបណ្តឹងសាទុក្ខទៅតុលាការកំពូលបានតែម្តងដោយមិនចាំបាច់ឆ្លងកាត់សាលាឧទ្ធរណ៍។ ចំពោះការយល់ព្រមដើម្បីផ្លោះសាលាឧទ្ធរណ៍ទៅតុលាការកំពូលនេះបានក្នុងករណីដែលជារឿងក្តីផ្នែករដ្ឋប្បវេណី ឬពាណិជ្ជកម្មដែលតម្លៃកម្មវត្ថុនៃបណ្តឹងមិនលើសពី៥លានរៀល។[102]ម្យ៉ាងវិញទៀតកម្មវត្ថុដែលមិនអាចប្តឹងសាទុក្ខបានគឺប្រភេទនៃ សាលក្រមរបៀប ឬដីកាសម្រេច ឬសេចក្តីសម្រេចដែលមិនមែនជាសាលក្រម ឬសាលដីកាមិនអាចយកមកធ្វើបណ្តឹងសាទុក្ខបាននោះឡើយ។ ចំពោះសាលក្រមរបៀបមិនអាចយកមកធ្វើជាមូលដ្ឋានសម្រាប់ធ្វើបណ្តឹងសាទុក្ខដោយឯករាជ្យបានឡើយ ការប្តឹងត្រូវផ្អែកលើសាលក្រម ឬសាលដីកាចុងក្រោយ។[103] ប្រសិនបើគេបានប្តឹងសាទុក្ខចំពោះសាលក្រមចុងក្រោយ ឬសាលដីកាចុងក្រោយ សាលក្រមរបៀបនោះមិនក៏ជាកម្មវត្ថុនៃការវិនិច្ឆ័យជាមួយគ្នានៅតុលាការកំពូលផងដែរ។ ដូច្នេះចំពោះសេចក្តីសម្រេចលើបន្ទុកនៃប្រាក់ប្រដាប់ក្តី ដែលជាប់ជាមួយសាលក្រម ឬសាលដីកាចុងក្រោយក៏មិនអាចយកមកធ្វើជាមូលដ្ឋានសម្រាប់ ការធ្វើបណ្តឹងសាទុក្ខដោយឯករាជ្យតែឯងបានឡើយ។[104]

**ខ. មូលហេតុនៃបណ្តឹងសាទុក្ខ**

មូលហេតុនៃបណ្តឹងសាទុក្ខ ច្បាប់បានបែងចែកជា ២ ទៀត គឺ មូលហេតុទូទៅនៃបណ្តឹងសាទុក្ខ និងមូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខ។

---

[100] មាត្រា ២៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[101] មាត្រា ២៨៣ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[102] មាត្រា ២៦០,២៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[103] មាត្រា ១៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[104] មាត្រា ៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

### ខ.១. មូលហេតុទូទៅនៃបណ្តឹងសាទុក្ខ

បណ្តឹងសាទុក្ខអាចធ្វើបាន ដោយយកមូលហេតុនៃភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ ឬបទដ្ឋានគតិយុត្ត ដែលមានឥទ្ធិពលលើសាលដីកាឬសាលក្រម។[105] ប៉ុន្តែ ច្បាប់នេះពុំកម្រិតលើបណ្តឹងសាទុក្ខដោយគិតទៅលើ ចំនួនប្រាក់ដែលជាកម្មវត្ថុនៃបណ្តឹង ឬចំនួនទឹកប្រាក់ដែលជាកម្មវត្ថុនៃការប្តឹងឧបាស្រ័យ។ ម្យ៉ាងវិញទៀត មូលហេតុនៃការធ្វើឧបាស្រ័យចំពោះសាលដីកាដើម ឬសាលក្រមដើម ហេតុដែលធ្វើបានត្រឹមត្រូវក្នុងការ បដិសេធនូវសាលដីកាដើម (សាលក្រមដើម)។[106] បានសេចក្តីថា នៅក្នុងករណីដែលមានមូលហេតុដូចនេះ មែន តុលាការនៃបណ្តឹងសាទុក្ខត្រូវបដិសេធចោលនូវសាលដីកាដើម។ ផ្ទុយទៅវិញប្រសិនបើគ្មានមូលហេតុ ដូចនេះទេ តុលាការនៃបណ្តឹងសាទុក្ខត្រូវចោលនូវបណ្តឹងសាទុក្ខនោះ។ អត្ថិភាពនៃមូលហេតុដើម្បីប្តឹងសាទុក្ខ មិនមែនជា លក្ខខណ្ឌស្របច្បាប់ ដើម្បីដាក់ពាក្យបណ្តឹងសាទុក្ខ តែវាជាមូលហេតុនៃបដិសេធចោល នូវសាលដីកាដើម ឬសាលក្រមដើម។ នៅប្រទេសកម្ពុជា មានប្រពន្ធនៃបណ្តឹងទៅលើអធម្មនុញ្ញភាពចំពោះ រឿងក្តីជាក់ស្តែងដែលទាក់ទងនឹងអធម្មនុញ្ញភាព ទៅក្រុមប្រឹក្សាធម្មនុញ្ញ។[107] យោងតាមច្បាប់នេះ រឿងត្រូវ បានបញ្ជូនដោយ ឆ្លងកាត់តាមតុលាការកំពូល(ប្រធានតុលាការ) ទៅក្រុមប្រឹក្សាធម្មនុញ្ញ ហើយក៏អាចបញ្ជូន ទៅដោយឆន្ទានុសិទ្ធិបានដែល។ វិនិច្ឆ័យតែចំពោះបញ្ហាថា តើមានភាពផ្ទុយនឹងច្បាប់ ឬបទដ្ឋានគតិយុត្ត ដែរ ឬទេ? ក្នុងសាលដីកាចុងក្រោយនៃសាលាឧទ្ធរណ៍ ជាអាទិ៍ ភាគីមិនអាចធ្វើបណ្តឹងបានដោយគ្រាន់តែផ្អែកលើ មូលហេតុថា ខ្លួនទទួលរងនូវការខាតប្រយោជន៍ពីសាលដីកាដែលជាកម្មវត្ថុនៃបណ្តឹងសាទុក្ខ បាន។ ដើម បណ្តឹងសាទុក្ខត្រូវតែអះអាងមូលហេតុនៃបណ្តឹងសាទុក្ខថា មានភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ ឬបទដ្ឋានគតិ យុត្ត ដែលជះឥទ្ធិពលទៅដល់សាលក្រម ឬសាលដីកា។[108] បានសេចក្តីថា ដើម្បីប្រើប្រព័ន្ធនៃបណ្តឹងសាទុក្ខ មិនគ្រាន់តែមានប្រយោជន៍ក្នុងប្តឹងឧបាស្រ័យ ហេតុដូច្នេះ បើភាគីដែលឈ្នះក្តីទាំងស្រុង នៅការជំនុំជម្រះដើម គ្មានផលប្រយោជន៍ក្នុងការប្តឹងសាទុក្ខ ហើយបណ្តឹងសាទុក្ខបែបនេះនឹងត្រូវបានលើចោលជាដាច់ខាត ដោយសារបណ្តឹងនោះមានលក្ខណៈផ្ទុយច្បាប់។ ប្រសិនបើតុលាការទទួលស្គាល់ថាមានកំហុស ឬបំពាន ច្បាប់ ឬបទដ្ឋានគតិយុត្តិផ្សេងទៀត នៅក្នុងការចាត់ចែងនីតិវិធី ឬក្នុងការវិនិច្ឆ័យរបស់តុលាការនៃបណ្តឹង ឧទ្ធរណ៍ ហើយការណ៍នោះមានឥទ្ធិពលទៅលើ ការវិនិច្ឆ័យដែលបានបង្ហាញក្នុង សេចក្តីសម្រេចបញ្ចប់នៃ សាលដីកានោះពិតប្រាកដមែន ទើបបណ្តឹងសាទុក្ខនោះមានមូលហេតុត្រឹមត្រូវ។[109] ប៉ុន្តែក្នុងចំណោមភាព

[105] មាត្រា ២៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[106] មាត្រា ២៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[107] មាត្រា ១៩ និង មាត្រា ១៥ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

[108] មាត្រា ២៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[109] មាត្រា ២៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ផ្ទុយនឹងច្បាប់ ឬបទដ្ឋានគតិយុត្ត មានកំហុសធ្ងន់ធ្ងរខាងនីតិវិធី ដែលភាគីអាចយកធ្វើជាមូលហេតុនៃបណ្តឹងសាទុក្ខបានដោយគ្មានល័ក្ខខណ្ឌ និងដោយពុំចាំបាច់អះអាងអំពីឥទ្ធិពលជាក់លាក់ទៅលើសាលក្រម ឬសាលដីកា ដែលកើតចេញពីការបំពាននោះទេ។ នេះគេហៅថា មូលហេតុទូទៅនៃបណ្តឹងសាទុក្ខ។[110]

ផ្ទុយមកវិញ ល័ក្ខខ័ណ្ឌស្របច្បាប់នៃបណ្តឹងសាទុក្ខមានដូចជា[111] ៖

- សេចក្តីសម្រេចដើមមានលក្ខណៈអាចប្តឹងសាទុក្ខបាន (មិនអាចប្តឹងសាទុក្ខចំពោះសាលក្រមរបៀបឬចំពោះដីកាសម្រេចដែលចេញនៅមុនពេលចេញសាលដីកា ឬសាលក្រមសម្រេចអង្គសេចក្តី ដោយឯករាជ្យដាច់តែឯងទេ។ ប្រសិនបើមានការខកខានក្នុងការសម្រេចសេចក្តីនូវការទាមទារណាមួយ តុលាការត្រូវចេញសាលដីកា (សាលក្រម) បន្ថែមទៀត គេមិនអាចធ្វើបណ្តឹងសាទុក្ខបានទេ)។
- មានការដាក់ពាក្យបណ្តឹងសាទុក្ខទៅតុលាការដែលមានសមត្ថកិច្ច
- ពាក្យបណ្តឹងសាទុក្ខ និងលិខិតបញ្ជាក់ពីមូលហេតុនៃបណ្តឹងសាទុក្ខ ត្រូវបានធ្វើទៅតាម ទម្រង់ស្របហើយត្រូវបានដាក់ក្នុងអំឡុងពេលដែលបានកំណត់ ទៅតុលាការនៃបណ្តឹងសាទុក្ខ។
- មានសុពលទៅលើការដាក់ និងបញ្ជូនពាក្យបណ្តឹងជាអាទិ៍
- ដើមបណ្តឹងសាទុក្ខមានសេចក្តីឧបាស្រ័យ ចំពោះការសម្រេចសេចក្តីរបស់តុលាការដើម
- ដើមបណ្តឹងសាទុក្ខមិនបានលះបង់ចោលនូវសិទ្ធិប្តឹងសាទុក្ខរបស់ខ្លួនឬមិនមានការព្រមព្រៀងថាមិនប្តឹងសាទុក្ខ
- មិនបានធ្វើបណ្តឹងសាទុក្ខត្រួតគ្នា
- មិនបំពានសិទ្ធិប្តឹងសាទុក្ខ
- មានល័ក្ខខ័ណ្ឌនៃបណ្តឹងត្រឹមត្រូវ។

### ខ.២. មូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខ

ជាការសំដៅទៅដល់ការខុសនីតិវិធីធ្ងន់ធ្ងរ។[112] ប្រសិនបើពិនិត្យឃើញថាមានកំហុសធ្ងន់ធ្ងរផ្នែកនីតិវិធី នោះដើមបណ្តឹងសាទុក្ខអាចយកមូលហេតុនេះ មកធ្វើជាមូលហេតុនៃបណ្តឹងសាទុក្ខបានដោយពុំចាំបាច់បញ្ជាក់អំពីឥទ្ធិពលនៃការបំពាននោះមកលើសាលក្រម ឬសាលដីកាដែលតុលាការចេញ។ មូលហេតុដែលផ្ទុយពីនីតិវិធីនេះមានដូចជា ៖

[110] មាត្រា ២៨៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[111] មាត្រា ២៨៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[112] មាត្រា ២៨៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

- តុលាការដែលចេញសាលក្រមឬសាលដីកា មិនត្រូវបានចាត់តាំងស្របទៅតាមច្បាប់ ៖[113] ជាករណីមានបញ្ហាអំពីបញ្ហាចៅក្រមនៃក្រុមប្រឹក្សាជំនុំជម្រះដែលធ្វើឡើងផ្ទុយនឹងបញ្ញត្តិ មាត្រា ២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឬករណីដែលចៅក្រមមិនត្រូវបានចាត់តាំងជាចៅក្រមជំនុំជម្រះតាមច្បាប់ដូចមានចែងក្នុងមាត្រា ២៦ និងមាត្រា ២៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ជាដើម។ ឧទាហរណ៍ ៖ សាលដីកាដែលចេញដោយក្រឡាបញ្ជី ឬចៅក្រម០២ នាក់ចេញសាលក្រមដែលត្រូវធ្វើដោយក្រុមប្រឹក្សាជំនុំជម្រះ០៣នាក់ ឬសាលដីកាដែលចេញដោយចៅក្រមដែលមិនមែនជាចៅក្រមនៅពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។
- ចៅក្រមដែលច្បាប់មិនអនុញ្ញាត ចូលរួមក្នុងការចេញសាលក្រម ឬសាលដីកាបានចូលរួម ៖[114] តាមច្បាប់មានតែចៅក្រមដែលបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ទេដែលជាមូលដ្ឋាននៃការចេញសាលក្រម ឬសាលដីកាបាន។[115] ក្នុងករណីដែលចៅក្រមមិនបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីជាមូលដ្ឋាននៃការចេញសាលក្រមឬសាលដីកានោះ ដើមបណ្តឹងសាទុក្ខ អាចយកបញ្ហានេះមកធ្វើជាមូលហេតុនៃការប្តឹងសាទុក្ខបាន។
- ភាពផ្ទុយនឹងបញ្ញត្តិស្តីពីសមត្ថកិច្ចផ្តាច់មុខរបស់តុលាការ៖[116] សមត្ថកិច្ចផ្តាច់មុខជាសមត្ថកិច្ចដែលកំណត់ដោយបញ្ញត្តិច្បាប់ ដោយមិនទទួលស្គាល់សមត្ថកិច្ចតុលាការផ្សេងទៀត ហើយក៏មិនអនុញ្ញាត ផ្តល់សមត្ថកិច្ចនេះទៅតុលាការណាមួយដោយឆន្ទៈរបស់ភាគីឡើយ។ ឧទាហរណ៍៖ បណ្តឹងលែងលះ និងបណ្តឹងទាមទារបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃបុត្តភាព ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់សាលាដំបូង ដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់ភាគីនៃទំនាក់ទំនងឋានៈបុគ្គលដែលពាក់ព័ន្ធនឹងបណ្តឹងនោះ ឬលំនៅឋាននាពេលដែលភាគីនោះទទួលមរណភាព។[117]
- ការខ្វះសិទ្ធិតំណាងដែលកំណត់ដោយច្បាប់ សិទ្ធិតំណាងដោយអាណត្តិ ឬការប្រគល់សិទ្ធិចាំបាច់សម្រាប់អ្នកតំណាង ដើម្បីធ្វើសកម្មភាពបណ្តឹង៖[118] ជាទូទៅសិទ្ធិតំណាងក្នុងការធ្វើសកម្មភាពបណ្តឹងកើតមានតាមរយៈកិច្ចសន្យា និងការកំណត់ដោយច្បាប់។ ឧទាហរណ៍ ៖ ជនដែលបានធ្វើ

[113] មាត្រា ២៨៥ កថាខណ្ឌទី១ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[114] មាត្រា ២៨៥ កថាខណ្ឌទី១ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[115] មាត្រា ១៨៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[116] មាត្រា ២៨៥ កថាខណ្ឌទី១ ចំណុច គ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[117] មាត្រា ១០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[118] មាត្រា ២៨៥ កថាខណ្ឌទី១ ចំណុច ឃ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

សកម្មភាពក្នុងនាមជាអ្នកអាណាព្យាបាលទូទៅ ទាំងខ្លួនមិនមែនជាអ្នកអាណាព្យាបាលទូទៅឬមេធាវីដែលមិនបានទទួលការប្រគល់សិទ្ធិបានធ្វើសកម្មភាពបណ្តឹងជាដើម។

- ភាពផ្ទុយនឹងបញ្ញត្តិស្តីពីការបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសារណៈ៖[119] ជាទូទៅសវនាការត្រូវបើកជាសាធារណៈដែលអនុញ្ញាត សាធារណៈជនអាចចូលរួមស្តាប់បាន ប៉ុន្តែករណីដែលតុលាការធ្វើជាសាធារណៈដែលផ្ទុយនឹងបញ្ញត្តិមាត្រា១១៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។
- សាលក្រម ឬសាលដីកាគ្មានសំអាងហេតុ ឬមានសំអាងហេតុតែផ្ទុយនឹងគ្នា ៖[120] ក្នុងសាលក្រមឬសាលដីកាត្រូវតែមានសំអាងហេតុ ហើយសំអាងហេតុនោះត្រូវតែស្របទៅនឹងសេចក្តីសម្រេចផងដែរ។ ចំពោះភាពគ្មានសំអាងហេតុ គឺជាសំអាងហេតុដែលខ្វះទាំងស្រុង ឬមួយផ្នែក ដើម្បីឈានដល់ការចេញសេចក្តីសម្រេចបញ្ចប់។ មួយវិញទៀត ភាពដែលមានសំអាងហេតុផ្ទុយគ្នា គឺជាសំអាងហេតុដែលសរសេរខ្លឹមសារមុនក្រោយផ្ទុយគ្នា ចំពោះចំណុចសំខាន់ដែលមានឥទ្ធិពលខ្លាំងដល់សាលក្រមឬសាលដីកា។ ឧទាហរណ៍ ៖ ខ្លឹមសារដែលសរសេរក្នុងសំអាងហេតុផ្ទុយគ្នានឹងចំនួនទឹកប្រាក់ដែលត្រូវបង្គាប់ បង់។

### គ. លក្ខខណ្ឌនៃបណ្តឹងសាទុក្ខ

ជាគោលការណ៍គ្រប់បណ្តឹងទាំងអស់អាចមានប្រសិទ្ធិភាព ឬអាចនិយាយម្យ៉ាងទៀតថាអាចមាននូវអានុភាពទៅបាន លុះត្រាតែបណ្តឹងនោះបង្កើតឡើងស្របទៅតាមច្បាប់ដែលបានចូលជាធរមានរួចហើយ។ មិនខុសគ្នាពីបណ្តឹងផ្សេងៗនោះទេ បណ្តឹងសាទុក្ខអាចកើតមាន ឬអាចធ្វើបាន មានអានុភាព គឺតម្រូវ ការធ្វើបណ្តឹងនោះស្របច្បាប់ ឬល័ក្ខខ័ណ្ឌស្របច្បាប់នៃបណ្តឹងសាទុក្ខនោះ។ បណ្តឹងសាទុក្ខនេះទៀតសោត ក៏មាននូវល័ក្ខ ខ័ណ្ឌពីរយ៉ាងដែលច្បាប់បានតម្រូវ ៖[121]

- អ្នកមានសិទ្ធិធ្វើបណ្តឹងសាទុក្ខ
- អំឡុងពេលនៃការធ្វើបណ្តឹងសាទុក្ខ

#### គ.១. អ្នកមានសិទ្ធិធ្វើបណ្តឹងសាទុក្ខ

ជាទូទៅអ្នកដែលមានសិទ្ធិប្តឹងសាទុក្ខ គឺជាភាគីដែលមិនពេញចិត្ត និងសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី១ របស់សាលាដំបូង ឬសាលដីកាចុងក្រោយនៃសវនាការជំនុំជម្រះលើកទី២ របស់សាលាឧទ្ធរណ៍ ឬសាលដីកាចុងក្រោយក្នុងនាមការជំនុំជម្រះលើកទី១ របស់សាលាឧទ្ធរណ៍ដែលមិនទាន់ចូលជា

[119] មាត្រា ២៨៥ កថាខណ្ឌទី១ ចំណុច ង នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[120] មាត្រា ២៨៥ កថាខណ្ឌទី១ ចំណុច ច នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[121] មាត្រា ២៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ស្ថាពរ។[122] នៅក្នុងនីតិវិធីនៃបណ្តឹងសាទុក្ខត្រូវបានហៅថា ដើមបណ្តឹងសាទុក្ខ និងចុងបណ្តឹងសាទុក្ខ។ មានន័យថាបណ្តឹងសាទុក្ខអាចធ្វើឡើងដោយដើមចោទ ឬចុងចម្លើយ ឬដើមបណ្តឹងឧទ្ធរណ៍ ឬចុងបណ្តឹងឧទ្ធរណ៍ ដែលមិនពេញចិត្ត និងបាត់បង់នូវផលប្រយោជន៍ដោយមានសាលក្រមនៃការជំនុះជម្រះលើកទី១ របស់សាលាដំបូង ឬសាលដីកានៃការជំនុំជម្រះលើកទី២ របស់សាលាឧទ្ធរណ៍។ ម្យ៉ាងទៀតភាគីដែលបាត់បង់ផលប្រយោជន៍ គឺជាភាគីដែលចាញ់ក្តីទាំងស្រុង ឬមួយផ្នែក ភាគីនោះមានសិទ្ធិក្នុងការធ្វើបណ្តឹងសាទុក្ខ ហេតុនេះភាគីដែលឈ្នះក្តីទាំងស្រុង គ្មានផលប្រយោជន៍ក្នុងការធ្វើបណ្តឹងសាទុក្ខ បណ្តឹងសាទុក្ខនោះនឹងត្រូវតុលាការលើកចោលដោយមូលហេតុផ្ទុយនឹងច្បាប់។

ជានិច្ចកាលសិទ្ធិប្តឹងសាទុក្ខកើតឡើង ក្នុងករណីដែលមានការព្រមព្រៀងរវាងភាគីទាំងសងខាងជាមុនថាមិនប្តឹងឧទ្ធរណ៍ការព្រមព្រៀង មិនប្តឹងឧទ្ធរណ៍នោះគឺជាការព្រមព្រៀងឆ្លោះទៅបណ្តឹងសាទុក្ខតែម្តង។ ចំពោះការយល់ព្រមដើម្បីឆ្លោះ សាលាឧទ្ធរណ៍ទៅតុលាការកំពូល នេះអាចធ្វើបានក្នុងករណីដែលជា រឿងក្តីផ្នែករដ្ឋប្បវេណី ឬពាណិជ្ជកម្មដែលតម្លៃកម្មវត្ថុនៃបណ្តឹងមិនលើសពី ៥,០០០,០០០ រៀល។[123]

### គ.២. អំឡុងពេលនៃការធ្វើបណ្តឹងសាទុក្ខ

អំឡុងពេលនៃការធ្វើបណ្តឹងសាទុក្ខ គឺជាស្ថានភាពមួយដែលចង់សំដៅទៅលើថេរវេលាកំណត់ មានបណ្តឹងសាទុក្ខ។ ដើម្បីមានភាពងាយស្រួល សិក្សាលើចំណុច អំឡុងពេលនៃបណ្តឹងសាទុក្ខ យើងត្រូវពិភាក្សាលើចំណុចសំខាន់ៗដូចខាងក្រោម៖

- ❖ អំឡុងពេលនៃការដាក់ពាក្យបណ្តឹងសាទុក្ខ

ជាទឡ្ហីភាព២៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចែងថានីតិវិធីបណ្តឹងសាទុក្ខអនុវត្តដូចគ្នានឹងនីតិវិធីបណ្តឹងឧទ្ធរណ៍ ដូច្នេះអំឡុងពេលនៃការដាក់ពាក្យបណ្តឹងសាទុក្ខក៏ដូចគ្នា គឺមានអំឡុងពេល០១ខែ គិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូលលិខិតសាលក្រម ឬសាលដីកា ឬថ្ងៃដែលបានជូនដំណឹងអំពីការសម្រេចច្រានចោល ឬលើកចោលនូវបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ។ នៅត្រង់នេះមានន័យថាប្រសិនបើភាគីណាមួយ ដែលបានទទួលការបញ្ជូននូវលិខិតសាលក្រមរបស់សាលាដំបូង ឬសាលដីការបស់សាលាឧទ្ធរណ៍ បើភាគីមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់តុលារការជាន់ទាបនោះ ដោយមូលហេតុថាការសម្រេចនោះផ្ទុយពីច្បាប់ ឬមិនស្របតាមរដ្ឋធម្មនុញ្ញ ឬបទដ្ឋានគតិយុត្តផ្សេងទៀត ឬខុសនីតិវិធីធ្ងន់ធ្ងរ ភាគីអាចមានសិទ្ធិក្នុងការដាក់ពាក្យបណ្តឹងសាទុក្ខចំពោះសេចក្តីសម្រេចនៅរយៈពេល០១ខែ។[124]

---

[122] មាត្រា ២៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[123] មាត្រា២៨៣កថាខណ្ឌទី២នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[124] មាត្រា២៦៥កថាខណ្ឌទី១នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

ផ្ទុយមកវិញប្រសិនបើភាគីមិនបានធ្វើប្តឹងសាទុក្ខក្នុង អំឡុងពេលដែលច្បាប់បានកំណត់នោះទេ មានន័យថាសេចក្តីសម្រេចរបស់តុលាការជាន់ទាបបានស្ថាពរដែលមានអានុភាពអនុវត្ត។ កាលណាសេចក្តីសម្រេចរបស់តុលាការជាន់ទាបចូលជាស្ថាពរដែលអាចមានអានុភាពហើយនោះ មានន័យថាភាគីដែលមិនសុខចិត្ត នឹង សេចក្តីសម្រេចនោះ នឹង បាត់បង់សិទ្ធិក្នុងការធ្វើបណ្តឹងសាទុក្ខហើយនោះ មានន័យថាភាគីដែលមិនសុខចិត្ត និងសេចក្តីនោះនឹងបាត់បង់សិទ្ធិក្នុងការធ្វើបណ្តឹងសាទុក្ខហើយ។ ម្យ៉ាងវិញទៀតក្នុងករណីដែលភាគីបានទទួលនូវការជូនដំណឹងអំពីដីកាសម្រេចច្រាល ឬលើកចោលនូវបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ ហើយភាគីមិនបានធ្វើការនៅក្នុងរយៈពេល១ខែ ដូចដែលច្បាប់បានកំណត់នោះទេ ភាគីក៏បាត់បង់នូវសិទ្ធិធ្វើបណ្តឹងសាទុក្ខនេះដែរ ចំពោះដីកាសម្រេចត្រង់នេះ គឺសំដៅទៅលើតែសម្រេចដែលចេញដោយ សាលាដំបូងដែលជាតុលាការនៃនីតិវិធីជំនុំជម្រះលើកទី១ប៉ុណ្ណោះ។ បន្ថែមពីនេះ សេចក្តីសម្រេចនេះមិនមែនចេញដោយសាលាឧទ្ធរណ៍នោះទេ ព្រោះថាសាលាឧទ្ធរណ៍មិនអាចចេញសាលក្រមកំបាំងមុខទេ។[125] ក្នុងករណីអនុវត្តដូចគ្នាទៅ នឹង ករណី ភាគីមានការព្រមព្រៀងគ្នា ជាលាយលក្ខណ៍អក្សរភាគីនឹងមិនប្តឹងឧទ្ធរណ៍ តែរក្សាទុកប្តឹងសាទុក្ខ។

❖ អំឡុងពេលនៃការដាក់លិខិតបញ្ជាក់មូលហេតុនៃបណ្តឹងសាទុក្ខ

បណ្តឹងសាទុក្ខក្នុងករណីដែលភាគីដើមបណ្តឹងសាទុក្ខ នៅពេលដាក់ពាក្យបណ្តឹងពុំបានសរសេរបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខនៅក្នុងពាក្យបណ្តឹងទេ នោះដើមបណ្តឹងសាទុក្ខត្រូវតែដាក់លិខិតបញ្ជាក់មូលហេតុនៃបណ្តឹងសាទុក្ខទៅតុលាការនៃបណ្តឹងសាទុក្ខ ក្នុងអំឡុងពេល ៣០ ថ្ងៃ បន្ទាប់ពីបានទទួលការ បញ្ជូនលិខិតទទួលពាក្យបណ្តឹង។[126] ប្រសិនបើភាគីសរសេរបញ្ជាក់អំពីការបានទទួលការបញ្ជាក់មូលហេតុនៃបណ្តឹងសាទុក្ខផ្ទុយនឹងមាត្រា ២៨៩ នៃនីតិវិធីរដ្ឋប្បវេណីដែលស្តីពីការសរសេរមូលហេតុនៃបណ្តឹងសាទុក្ខ នោះតុលាការនៃបណ្តឹងសាទុក្ខត្រូវកំណត់អំឡុងពេលសមរម្យ ហើយបង្គាប់ ដើមបណ្តឹងសាទុក្ខកែតម្រូវនូវចំណុចខ្វះខាតក្នុងអំឡុងពេលនោះដោយចេញដីកាសម្រេច។ ចំពោះអំឡុងពេលនៃការដាក់ពាក្យបណ្តឹងសាទុក្ខ និងការដាក់លិខិតបញ្ជាក់អំពីមូលហេតុមិនអាចពន្យាពេលបានទេ។

### ២.១.១.២. អានុភាពនៃបណ្តឹងសាទុក្ខ

ពេលណាដែលពាក្យបណ្តឹងសាទុក្ខ បានទៅដល់តុលាការនៃបណ្តឹងសាទុក្ខនោះមានន័យថាអានុភាពនៃបណ្តឹងសាទុក្ខនឹងកើតមាន។ នេះក៏មិនខុសគ្នាអំពីអានុភាពនៃពាក្យបណ្តឹងឧទ្ធរណ៍ ដែល

[125] មាត្រា២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[126] មាត្រា២៨៣ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

អានុភាពនោះអាចធ្វើ បង្អាក់ ឬរារាំងការចូលជាស្ថាពរនៃសាលក្រម ឬសាលដីកាដើម អានុភាពនៃការផ្ទេរការជំនុំជម្រះក្តី នឹង អានុភាពអវិភាគនៃបណ្តឹងសាទុក្ខ។

**ក. អានុភាពបង្អាក់ការចូលជាស្ថាពរ**

អានុភាពបង្អាក់ការចូលជាស្ថាពរគឺមានន័យថា នៅពេលដែលភាគីដើមបណ្តឹងសាទុក្ខបានដាក់ពាក្យបណ្តឹងសាទុក្ខក្នុងអំឡុងពេល ដែលច្បាប់បានកំណត់នោះវានឹងមានអានុភាពបង្អាក់ ឬរារាំងការចូលជាស្ថាពររបស់សាលក្រម ឬសាលដីកាដើម។[127] ត្រង់នេះមានន័យថាប្រសិនបើភាគីដើមបណ្តឹងសាទុក្ខបានដាក់ពាក្យបណ្តឹងក្នុងរយៈពេល ០១ ខែ ដែលជារយៈពេលច្បាប់កំណត់នោះ បន្ទាប់ពីទទួលបានលិខិតសាលក្រម ឬសាលដីកាទោះបីជារយៈពេលនៃការចូលជាស្ថាពរនៃសាលក្រម ឬសាលដីកាបានចូលមកដល់បានកន្លងផុតក៏ដោយ ក៏សាលក្រម ឬសាលដីកានោះមិនអាចចូលជាស្ថាពរដែរ។ ផ្ទុយមកវិញក្នុងករណីសាលក្រម ឬសាលដីកាដែលភ្ជាប់នឹងប្រកាស អនុវត្តជាបណ្តោះអាសន្ន ចំពោះផ្នែកណាមួយតាមពាក្យសុំដោយដីកាសម្រេចសាលក្រមឬ សាលដីកានោះមានអានុភាពអនុវត្តបាន ទោះបីជាមានបណ្តឹងសាទុក្ខក៏ដោយ។[128]

**ខ. អានុភាពនៃការផ្ទេរការជំនុះជម្រះក្តី**

នៅពេលដែលមានពាក្យបណ្តឹងសាទុក្ខ នោះការជំនុំជម្រះដោយតុលាការជាប់ទាប ពោលគឺសាលាដំបូង ឬសាលាឧទ្ធរណ៍ នឹងត្រូវផ្ទេរទៅតុលាការនៃបណ្តឹងសាទុក្ខជាអ្នកមានសមត្ថកិច្ចក្នុងការវិនិច្ឆ័យ និងចេញសេចក្តីសម្រេច ព្រោះបណ្តឹងសាទុក្ខមិនស្ថិតក្រោមសមត្ថកិច្ចរបស់តុលាការជាន់ទាបនោះទេ។

**គ. អានុភាពអវិភាគនៃបណ្តឹងសាទុក្ខ**

អានុភាពអវិភាគនៃបណ្តឹងសាទុក្ខ គឺជាការដែលដើមបណ្តឹងសាទុក្ខបានធ្វើឧបាស្រ័យតែផ្នែកណាមួយនៃសាលក្រម ឬសាលដីកាដើមក៏ដោយ ក៏បណ្តឹងនោះមានអានុភាពបង្អាក់ការចូលជាស្ថាពរ និងការផ្ទេរការជំនុំជម្រះត្រូវកើតមានឡើងទៅលើការទាមទារទាំងអស់ដែលមាននៅក្នុងសាលក្រម ឬសាលដីកានោះ។ បានសេចក្តីថាទោះបីជាដើមបណ្តឹងសាទុក្ខធ្វើបណ្តឹងឧបាស្រ័យមិនអាចចូលទេ ហើយក៏មិនអាចយកទៅអនុវត្តបានឡើយ។ លើកលែងតែមានការប្រកាស អនុវត្តជាបណ្តោះអាសន្នដោយតុលាការដើម ឬក៏ដោយតុលាការនៃបណ្តឹងសាទុក្ខទើបផ្នែកដែលមិនបានធ្វើឧបាស្រ័យនោះអាចអនុវត្តបាន។[129]

[127] មាត្រា ២៩៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[128] មាត្រា២៨៦,២៧៣ និងមាត្រា១៩៣ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[129] មាត្រា១៩៣,កថាខណ្ឌទី២ និង មាត្រា១៩៦,២៩៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

### ២.១.២. លំហូរនីតិវិធីនៃការជំនុំជម្រះបណ្ដឹងសាទុក្ខ

ដើម្បីមានភាពងាយស្រួលក្នុងការ ការសិក្សាលើលំហូរនីតិវិធីនៃការជម្រះបណ្ដឹងសាទុក្ខ យើងគប្បីស្វែងយល់ចំណុចមួយចំនួនដូចខាងក្រោម៖

#### ២.១.២.១. របៀបធ្វើ ការទទួលពាក្យ និងការពិនិត្យបណ្ដឹងសាទុក្ខ

តួនាទីរបស់ភាគី គឺត្រូវតែធ្វើបណ្ដឹងសាទុក្ខដោយគោរពទៅតាមច្បាប់ បន្ទាប់មកតុលាការជាអ្នកទទួលពាក្យ និងពិនិត្យបណ្ដឹងសាទុក្ខប្រសិនបើភាគីបំពេញត្រឹមត្រូវតាមទម្រង់ច្បាប់ និងភាគីបានបង់ពន្ធបានត្រឹមត្រូវផងដែរ។

**ក. របៀបធ្វើបណ្ដឹងសាទុក្ខ**

ជាការពិតណាស់ការធ្វើ បណ្ដឹងសាទុក្ខគឺដើមបណ្ដឹងសាទុក្ខតម្រូវ សរសេរពាក្យបណ្ដឹងជាលាយលក្ខណ៍អក្សរទៅតុលាការដើម ភាគីដើមបណ្ដឹងសាទុក្ខពុំត្រូវធ្វើបណ្ដឹងដោយផ្ទាល់មាត់ដូច នឹងនីតិវិធីរឿងក្ដីដែលមានតម្លៃទឹកប្រាក់តិចនោះទេ។ ចំពោះពាក្យបណ្ដឹងសាទុក្ខត្រូវសរសេរនូវចំណុចមួយចំនួនដូចជា៖[130]

- ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី និងអ្នកតំណាងដែលច្បាប់បានកំណត់។ ការសរសេរឈ្មោះ និងអាសយដ្ឋានរបស់ភាគីពិតជាមានសារៈសំខាន់ណាស់ ដើម្បី តុលាការធ្វើការបញ្ជូនដីកាកោះ និងលិខិត ឬឯកសារផ្សេងៗទៅភាគីនោះ។
- សញ្ញាណនៃសាលក្រម ឬសាលដីកាចុងក្រោយដែលតុលាការដើមបានចេញ និងសេចក្ដីដែលប្ដឹងសាទុក្ខនោះ។ ការសរសេរបែបនេះ គឺចង្អុលបង្ហាញអំពីអ្វីដែលខ្លួនមិនសុខចិត្ត និងអ្វីដែលខ្លួនទាមទារដើម្បី តុលាការយកមកធ្វើការវិនិច្ឆ័យ ដោយហេតុថាតុលាការមិនអាចធ្វើការវិនិច្ឆ័យនូវអ្វីដែលភាគីមិនបានធ្វើការឧបាស្រ័យឡើយជាគោលការណ៍តុលាការអសកម្ម។
- មូលហេតុនៃបណ្ដឹងសាទុក្ខ វាជាចំណុចសំខាន់នៃពាក្យបណ្ដឹងសាទុក្ខព្រោះតុលាការនៃបណ្ដឹងសាទុក្ខវិនិច្ឆ័យទៅលើអង្គច្បាប់ ហេតុនេះពាក្យបណ្ដឹងត្រូវសរសេរអំពីមូលហេតុនៃបណ្ដឹងនោះ។ បន្ទាប់ពីភាគីធ្វើបណ្ដឹងតាមល័ក្ខខ័ណ្ឌរួចត្រូវដាក់ពាក្យទៅតុលាការដើម។ ហើយតុលាការដើមត្រូវធ្វើការផ្ញើបានឆាប់រហ័សនូវពាក្យបណ្ដឹងសាទុក្ខនោះ និងសំណុំរឿងទៅតុលាការនៃបណ្ដឹងសាទុក្ខ[131] ជារួមការដាក់ពាក្យបណ្ដឹងសាទុក្ខស្រដៀងទៅនឹងការដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ដែរ។

[130] មាត្រា ២៨៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[131] មាត្រា២៨៧នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

**ខ. ការទទួលពាក្យបណ្ដឹងសាទុក្ខ**

ពាក្យបណ្ដឹងសាទុក្ខ ត្រូវដាក់នៅតុលាការដើមដែលបានចេញសាលក្រមឬសាលដីកានោះអំឡុងពេលកំណត់សម្រាប់ធ្វើបណ្ដឹងសាទុក្ខ។[132] ដោយឡែកតុលាការដើមពុំមានសមត្ថកិច្ចពិនិត្យពាក្យបណ្ដឹងសាទុក្ខទេ គ្រាន់តែជាតុលាការរបស់ភាគីតែប៉ុណ្ណោះ។ បន្ទាប់មកតុលាការដើមត្រូវធ្វើការផ្ញើ បានឆាប់រហ័សនូវពាក្យបណ្ដឹងសាទុក្ខនោះ និងសំណុំរឿងទៅតុលាការនៃបណ្ដឹងសាទុក្ខ។

**គ. ការពិនិត្យបណ្ដឹងសាទុក្ខ**

នាពេលតុលាការដើមបញ្ជូនមកតុលាការនៃបណ្ដឹងសាទុក្ខ បន្ទាប់ពីបានទទួលការដាក់ពាក្យបណ្ដឹងសាទុក្ខ របស់ភាគីនៃដើមបណ្ដឹងសាទុក្ខរួច តុលាការនៃបណ្ដឹងសាទុក្ខត្រូវពិចារណាពាក្យបណ្ដឹងនេះត្រឹមត្រូវតាមច្បាប់ឬទេ។ ក្នុងករណីតុលាការនៃបណ្ដឹងសាទុក្ខពិនិត្យឃើញថា ពាក្យបណ្ដឹងសាទុក្ខមិនសរសេចំណុចសំខាន់ដែលចែងក្នុងមាត្រា ២៦៥ និងមាត្រា ២៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ តុលាការនៃបណ្ដឹងសាទុក្ខត្រូវបង្គាប់ ភាគីដើមបណ្ដឹងសាទុក្ខកែតម្រូវពាក្យបណ្ដឹងនោះ ក្នុងអំឡុងពេលមួយដែលកំណត់ដែលច្បាប់បានកំណត់។[133] ផ្ទុយមកវិញប្រសិនបើភាគីដើមបណ្ដឹងសាទុក្ខ មិនបានកែប្រែពាក្យបណ្ដឹងសាទុក្ខនោះទេ ក្នុងរយៈពេលមួយដែលតុលាការបានកំណត់ តុលាការនៃបណ្ដឹងសាទុក្ខត្រូវលើកចោលពាក្យបណ្ដឹងសាទុក្ខនោះដោយដីកាសម្រេច។ ចំណែកប្រាក់ដាប់ក្ដីក៏តុលាការនៃបណ្ដឹងសាទុក្ខ និងបណ្ដឹងសាទុក្ខបន្ទាប់បន្សំត្រូវពិនិត្យផងដែរ លើពន្ធដាក់ពាក្យសុំដែលត្រូវគណនា ទៅតាមតម្លៃកម្មវត្ថុនៃបណ្ដឹងដែលមានចំនួន២ដង នៃពន្ធដាក់ពាក្យសុំផង ដែរ។[134]

**២.១.២.២. នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់**

ជាដំបូងដើម្បីមានភាពងាយស្រួល ក្នុងការសិក្សាទៅនីតិវិធីទាញហេតុផលផ្ទាល់មាត់លើបណ្ដឹងសាទុក្ខ យើងត្រូវសិក្សាចំនុចសំខាន់ៗដូចជា៖

**ក. នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ករណីបណ្ដឹងសាទុក្ខលើកទី១**

តុលាការនៃបណ្ដឹងសាទុក្ខ ត្រូវធ្វើការជម្រះលើចុងក្រោយចំពោះសាលក្រម ឬសាលដីកាដើមដែលការជំនុំជម្រះបណ្ដឹងសាទុក្ខ តុលាការនៃបណ្ដឹងសាទុក្ខត្រូវទាញហេតុផលដោយផ្ទាល់មាត់។ ចំពោះការទាញហេតុផលដោយផ្ទាល់មាត់ករណីបណ្ដឹងសាទុក្ខលើកទី១ មានសមាសភាពចៅក្រមជំនុំជម្រះ ពោលគឺសភារដ្ឋប្បវេណីនៃតុលាការកំពូលមានសមត្ថកិច្ចជំនុំជម្រះបណ្ដឹងសាទុក្ខ ចំពោះសាលដីកាផ្នែករដ្ឋប្បណីរបស់សាលា

---

[132] មាត្រា ២៨៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[133] មាត្រា ២៩១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[134] មាត្រា ២៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ឧទ្ធរណ៍ ឬសាលក្រមរដ្ឋប្បវេណីរបស់សាលាដំបូង។ ដូច្នេះការជំនុំជម្រះក្តីត្រូវធ្វើឡើងដោយមានចៅក្រមចំនួន ០៥ រូបនោះមានចៅក្រម ០១ ត្រូវបានចាត់តាំង ធ្វើជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ ដើម្បីធ្វើជាអ្នកដឹកនាំកិច្ចដំណើរនៃនីតិវិធី។[135] ចំណែកឯសកម្មភាពនៃការទាញហេតុផលដោយផ្ទាល់មាត់ ជាគោលការណ៍នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់របស់តុលាការនៃបណ្តឹងសាទុក្ខ គឺជាការវិនិច្ឆ័យតែលើអង្គច្បាប់ ប៉ុណ្ណោះ។ ដោយតុលាការនៃបណ្តឹងសាទុក្ខធ្វើការពិនិត្យ និង វិនិច្ឆ័យតែត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃសាលក្រម ឬសាលដីកាចុងក្រោយលើការអនុវត្តច្បាប់តែប៉ុណ្ណោះ។[136] ការវិនិច្ឆ័យនេះគឺផ្អែកលើការអះអាងរបស់ភាគីនិងភស្តុតាងដែលបានដាក់នៅតុលាការដើមតាមរយៈការវិនិច្ឆ័យភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវក្នុងការអនុវត្តច្បាប់ចំពោះអង្គហេតុដែលបានទទួលស្គាល់នៅតុលាការដើម ហើយតុលាការនៃបណ្តឹងសាទុក្ខមិនទទួលស្គាល់អង្គហេតុឡើងវិញទេ។ វិនិច្ឆ័យលើអង្គច្បាប់របស់តុលាការនៃបណ្តឹងសាទុក្ខ គឺដើម្បី មានការឯកភាពគ្នាចំពោះតុលាការជាន់ទាប ក្នុងការបកស្រាយច្បាប់ និងអនុវត្តច្បាប់។ ការទាញហេតុផលដោយផ្ទាល់មាត់នៅតុលាការនៃបណ្តឹងសាទុក្ខ តម្រូវ ភាគីធ្វើសេចក្តីថ្លែងការណ៍។ ដោយហេតុថាសេចក្តីសម្រេចរបស់តុលាការនៃបណ្តឹងសាទុក្ខជាសេចក្តីសម្រេចចុងក្រោយបិទផ្លូវតវ៉ា ហើយសេចក្តីសម្រេចនេះអាចក្លាយទៅជាយុត្តិសាស្ត្រសម្រាប់តុលាការជាន់ទាបអនុវត្តតាម។

### ខ. ការទាញហេតុផលដោយផ្ទាល់មាត់ករណីបណ្តឹងសាទុក្ខលើកទី២

ការទាញហេតុផលដោយផ្ទាល់មាត់ ករណីបណ្តឹងសាទុក្ខលើកទី២ គឺជាករណីដែលតុលាការនៃបណ្តឹងសាទុក្ខបានបដិសេធនូវសាលដីកាដើម ហើយបានបញ្ជូនរឿងក្តីនោះត្រលប់ទៅតុលាការដើមវិញឬផ្ទេររឿងក្តីនោះទៅតុលាការដើមវិញ ឬផ្ទេររឿងក្តីនោះទៅតុលាការផ្សេងដែលមានថ្នាក់ដូចគ្នា ដើម្បី ធ្វើការជម្រះរឿងក្តីនោះម្តងទៀត បន្ទាប់មកនៅពេលដែលតុលាការដើម ទទួលការបញ្ជូនរឿងក្តីត្រលប់មកវិញ ឬតុលាការដែលបានទទួលផ្ទេររឿងក្តី នោះបានចេញសាលដីកា ហើយមានភាគីណាមួយមិនសុខចិត្ត និង សេចក្តីសម្រេចនោះ និងបានប្តឹងសាទុក្ខម្តងទៀត ដូចនេះនីតិវិធីតុលាការនៃបណ្តឹងសាទុក្ខលើកទី២ នឹងធ្វើការជំនុំជម្រះដោយសភាពេញអង្គ។[137] សភាពេញអង្គត្រូវបង្កើត មានដំណើរដោយដីកាសម្រេចរបស់ប្រធានតុលាការកំពូល ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខលើកទី២ ក្នុងករណីដែលមានការស្នើសុំ មានការត្រួតពិនិត្យ និងសម្រេចឡើងវិញចំពោះរឿងក្តីណាមួយពីព្រះមហាក្សត្រ ដែលជាព្រះប្រធានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតាមរយៈរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ សភាពេញអង្គប្រព្រឹត្តទៅតាមការកោះអញ្ជើញរបស់ប្រធានតុលាការកំពូល

[135] មាត្រា៥៩ និងមាត្រា៦៥ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ ២០០៤

[136] មាត្រា ២៧២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[137] មាត្រា ២៩៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

សភានេះត្រូវមានសមាសភាពចៅក្រម ៩ រូបដែលមានចៅក្រមជាតំណាងនៃសភា ទាំងអស់នៃតុលាការកំពូល ហើយសភាពេញអង្គដំណើរការក្រោមអធិបតីភាព។ រីឯសកម្មភាពនៃការទាញហេតុផលផ្ទាល់មាត់ នៅក្នុងករណីបណ្តឹងសាទុក្ខលើកទី២នេះ គឺធ្វើទៅតាមលំដាប់លំដោយដូចគ្នានឹងសកម្មភាពទាញហេតុផលដោយផ្ទាល់មាត់ នៅក្នុងបណ្តឹងសាទុក្ខលើកដំបូងដែរ ប៉ុន្តែអាចមានសាក្សី និងអ្នកជំនាញចូលរួមក្នុងសវនាការដែរ ដោយប្រធានក្រុមប្រឹក្សាអាចអញ្ជើញសាក្សី និងជំនាញនោះឈរមុខតុលាការ ដើម្បី អ្នកទាំងអស់នោះជួយបំភ្លឺដល់រឿងក្តី ដើម្បី តុលាការងាយស្រួលក្នុងការវិនិច្ឆ័យ និងចេញសាលដីកា។ ករណីមានបន្ថែមសាក្សី និងអ្នកជំនាញនេះដោយសារតែបណ្តឹងសាទុក្ខលើកទី២ តុលាការនៃបណ្តឹងសាទុក្ខត្រូវធ្វើការពិនិត្យឡើងវិញទាំងអង្គហេតុ និងអង្គច្បាប់។[138]

### ២.១.២.៣. បណ្តឹងសាទុក្ខបន្ទាប់បន្សំ

បណ្តឹងសាទុក្ខបន្ទាប់បន្សំ គឺសំដៅទៅលើបណ្តឹងមួយដែលធ្វើឡើងដោយឆ្លៀតឱកាសនៅពេលមានបណ្តឹងសាទុក្ខ។ មានន័យថានៅក្រោយពេលដែលដើមបណ្តឹងសាទុក្ខបដិសេធចំពោះសាលក្រម ឬសាលដីកាដែលចេញដោយ តុលាការដើមនោះ ចុងបណ្តឹងសាទុក្ខសាទុក្ខបានឆ្លៀតឱកាសពេលនឹងធ្វើបណ្តឹងឧបាស្រ័យជាមួយ សាទុក្ខរបស់ដើមបណ្តឹងសាទុក្ខ ដើម្បីទាមទារនូវចំណុចដែលខ្លួនចាញ់នៅក្នុងសាលក្រម ឬសាលដីកាបស់តុលាការដើម។[139] ឧទាហរណ៍ ៖ សាលាឧទ្ធរណ៍បានចេញដីកា ដើមបណ្តឹងឧទ្ធរណ៍ ឈ្នះ៣ចំណុចក្នុងចំណោម ៤ ចំណុចដែលគាត់បានទាមទារ ហើយដើមបណ្តឹងឧទ្ធរណ៍មិនធ្វើបណ្តឹងសាទុក្ខនោះទេ។ ប៉ុន្តែបើចុងបណ្តឹងឧទ្ធរណ៍ បានធ្វើបណ្តឹងសាទុក្ខឧបាស្រ័យ នឹង សាលដីកាដែលតុលាការឧទ្ធរណ៍បានចេញសេចក្តីសម្រេចបញ្ចប់។ ពេលនោះដើមបណ្តឹងឧទ្ធរណ៍ក៏បានធ្វើបណ្តឹងសាទុក្ខដែរ ដែលបណ្តឹងសាទុក្ខនោះជាបណ្តឹងសាទុក្ខបន្ទាប់បន្សំ ដែលអមទៅជាមួយបណ្តឹងសាទុក្ខរបស់ចុងបណ្តឹងឧទ្ធរណ៍។ អំឡុងពេលធ្វើបណ្តឹងសាទុក្ខបន្ទាប់បន្សំ ដូចគ្នានឹងបណ្តឹងសាទុក្ខដែរ ពោលគឺ០១ ខែគិតចាប់ពីថ្ងៃទទួលបានលិខិតសាលក្រម ឬថ្ងៃដែលបានជូនដំណឹងអំពីការសម្រេចច្រានចោល ឬលើកចោលនូវបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខចំពោះអំឡុងពេល០១ខែ មិនអាចពន្យាពេលបានទេ។ ប៉ុន្តែក្នុងករណីបើបណ្តឹងសាទុក្ខបន្ទាប់បន្សំនោះធ្វើឡើងមិនហួសអំឡុងពេលប្តឹងសាទុក្ខ និងមានលក្ខខណ្ឌនៃបណ្តឹងសាទុក្ខគ្រប់គ្រាន់ករណីនេះហៅថា បណ្តឹងសាទុក្ខបន្ទាប់បន្សំបានធ្វើឡើងដោយឯករាជ្យ។ ចំពោះរបៀបធ្វើពាក្យបណ្តឹងសាទុក្ខបន្ទាប់បន្សំ និងនីតិវិធីនៃបណ្តឹងសាទុក្ខបន្ទាប់បន្សំ រមែងត្រូវអនុលោមទៅតាមបញ្ញត្តិនៃបណ្តឹងឧទ្ធរណ៍ពោលគឺត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងសាទុក្ខបន្ទាប់បន្សំ។

---

[138] មាត្រា ១១៥ និង ២៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[139] មាត្រា ២៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

### ២.១.២.៤. ការបញ្ចប់បណ្តឹងសាទុក្ខ

បន្ទាប់ពីធ្វើការជំនុំជម្រះដោយទាញហេតុផលដោយផ្ទាល់មាត់រួច តុលាការនៃបណ្តឹងសាទុក្ខត្រូវបញ្ចប់បណ្តឹងសាទុក្ខដោយមានពីរ ការបញ្ចប់បណ្តឹងសាទុក្ខដោយមិនឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ និងការបញ្ចប់បណ្តឹងសាទុក្ខដោយឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ។

#### ក. ការបញ្ចប់បណ្តឹងសាទុក្ខដោយមិនឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ

ការបញ្ចប់បណ្តឹងសាទុក្ខដោយមិនឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ អាចធ្វើឡើងក្នុងទម្រង់ពីរយ៉ាង អាចជាការបញ្ចប់បណ្តឹងសាទុក្ខដោយស្វ័យប្រវត្ត ឬការបញ្ចប់បណ្តឹងសាទុក្ខដោយសកម្មភាពភាគី។[140]

#### ក.១. ការបញ្ចប់បណ្តឹងសាទុក្ខដោយស្វ័យប្រវត្ត

ការបញ្ចប់បណ្តឹងសាទុក្ខដោយស្វ័យប្រវត្តមានន័យថា កាលណាភាគីណាមួយបានទទួលមរណភាពហើយគ្មានអ្នកណាទទួលបន្តនូវសិទ្ធិ ឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងនាំ ត្រូវបានបញ្ចប់ដោយស្វ័យប្រវត្ត។ តាមធម្មតាទោះបីជាមានភាគីណាម្ខាងទទួលមរណភាពក៏ដោយ ក៏សន្តតិជនរបស់ភាគីនោះ នឹងត្រូវទទួលបន្តនីតិវិធីនៃបណ្តឹងដែលបានធ្វើពីមុនមក ហើយនីតិវិធីបណ្តឹងសាទុក្ខនោះមិនត្រូវបានបញ្ចប់ទេ។ ក្នុងករណីដែលសិទ្ធិ ឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងបានរលត់ដោយសារការរួមបញ្ចូលគ្នានៃនីតិបុគ្គលនាំ សិទ្ធិឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងត្រូវធ្លាក់លើបុគ្គលតែម្នាក់ ហើយដើមបណ្តឹងសាទុក្ខ និងចុងបណ្តឹងសាទុក្ខបានក្លាយទៅជាបុគ្គលតែមួយ ដោយសារតែភាគីណាម្ខាងបានទទួលបន្តនូវឋានៈតាមផ្លូវបណ្តឹង របស់ភាគីម្ខាងទៀតដោយសារមូលហេតុនៃនីតិបុគ្គល ឬដោយសន្តតិកម្ម ដូច្នេះតុលាការចេញសេចក្តីសម្រេចបញ្ចប់ដោយស្វ័យប្រវត្តដោយសារមានភាគីម្ខាងទៀតតែមួយ។[141]

#### ក.២. ការបញ្ចប់បណ្តឹងដោយសកម្មភាពភាគី

ការបញ្ចប់បណ្តឹងដោយសកម្មភាពរបស់ភាគី ក្នុងនោះអាចជាសកម្មភាពនៃការដកពាក្យបណ្តឹង ការទទួលស្គាល់ការទាមទារ និងការសះជាតាមផ្លូវបណ្តឹងរបស់ភាគីនឹងធ្វើ សកម្មភាពនៃបណ្តឹងត្រូវបញ្ចប់ផងដែរ ។ ការដកពាក្យបណ្តឹង ទោះបីជានីតិវិធីបណ្តឹងកំពុងដំណើរការក៏ដោយក៏ដើមបណ្តឹងសាទុក្ខ អាចធ្វើការដកពាក្យបណ្តឹងទាំងអស់ ឬមួយផ្នែកបានដែលរហូតដល់ពេលដែលតុលាការ នៃបណ្តឹងសាទុក្ខចេញដីកាចុងក្រោយ។[142] ដោយហេតុថាបណ្តឹងជាសកម្មភាពរបស់ដើមបណ្តឹងសាទុក្ខ ក្នុងការទាមទារ តុលាការចេញ

---

[140] មាត្រា ២៨៦ និង ១៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[141] មាត្រា ២៨៦ និង ១៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[142] មាត្រា ២៨៦ និង ២៦៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

សេចក្តីសម្រេចលុបចោលឬកែប្រែសាលដីកាដើម ឬសាលក្រមដើម ដូច្នេះការដកពាក្យបណ្តឹង សាទុក្ខចេញសេចក្តីសម្រេចលុបចោល កែប្រែសាលដីកាដើម ឬសាលក្រមដើម ដូច្នេះការដកពាក្យបណ្តឹងសាទុក្ខធ្វើឡើងតាមឆន្ទៈរបស់ដើមបណ្តឹងសាទុក្ខប៉ុណ្ណោះ ហេតុនេះចុងបណ្តឹងសាទុក្ខពុំមានសិទ្ធិដកពាក្យបណ្តឹងសាទុក្ខឡើយ។ ប៉ុន្តែក្រោយចុងបណ្តឹងសាទុក្ខបានដាក់ឯកសារត្រៀមតាមការបង្គាប់របស់តុលាការ ឬបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់រួចហើយ ការដកពាក្យបណ្តឹងសាទុក្ខដោយផ្អែកទៅលើឆន្ទៈរបស់ដើមបណ្តឹងសាទុក្ខពុំមានអានុភាពឡើយ លើកលែងតែមានការយល់ព្រមពីចុងបណ្តឹងសាទុក្ខផងដែរ ពីព្រោះថាចុងបណ្តឹងសាទុក្ខបានឆ្លើយតបទៅនឹងការទាមទាររបស់ដើមបណ្តឹង សាទុក្ខ ហើយចុងបណ្តឹងសាទុក្ខ គឺមានផលប្រយោជន៍ក្នុងការទទួលសាលដីកាឈ្នះក្តីដែរ។[143] ចំណែកលក្ខខណ្ឌនៃការដកពាក្យបណ្តឹងសាទុក្ខ វិញនោះត្រូវធ្វើជាលាយលក្ខណ៍អក្សរ ប៉ុន្តែការដកពាក្យបណ្តឹងរបស់ដើមបណ្តឹងសាទុក្ខអាចធ្វើឡើយដោយផ្ទាល់មាត់ ក៏បាននៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់។ នៅពេលដែលមានការដកពាក្យបណ្តឹងដោយផ្ទាល់មាត់ក្រឡាបញ្ជីត្រូវចុះអំពីការដកពាក្យបណ្តឹងនោះនៅក្នុងកំណត់ហេតុនៃការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីកុំ មានវិវាទនៅពេលក្រោយ។ ប្រសិនបើការដកពាក្យបណ្តឹងធ្វើឡើងជាលាយលក្ខណ៍អក្សរ តុលាការនៃបណ្តឹងសាទុក្ខត្រូវ បញ្ជូនលិខិតដកពាក្យបណ្តឹងនោះទៅចុងបណ្តឹងសាទុក្ខ។ បើចុងបណ្តឹងសាទុក្ខមិនប្តឹងតវ៉ាក្នុងអំឡុងពេល ០២ សប្តាហ៍ បន្ទាប់ពីបានទទួលការបញ្ជូនលិខិតដកពាក្យបណ្តឹងទេ ត្រូវបានចាត់ទុកចុងបណ្តឹងសាទុក្ខ បានយល់ព្រមនឹងការដកពាក្យបណ្តឹងសាទុក្ខ។ បើដើមបណ្តឹងសាទុក្ខធ្វើការដកពាក្យបណ្តឹងដោយផ្ទាល់មាត់នៅកាលបរិច្ឆេទ នៃការទាញហេតុផលដោយផ្ទាល់មាត់ ប៉ុន្តែចុងបណ្តឹងសាទុក្ខបានអវត្តមាន នៅកាលបរិច្ឆេទនោះតុលាការនៃបណ្តឹងសាទុក្ខត្រូវធ្វើការបញ្ជូន ឯកសារចម្លងនៃកំណត់ហេតុ ដែលបានចុះអំពីការដកពាក្យបណ្តឹងនោះទៅចុងបណ្តឹងសាទុក្ខ។ ក្នុងអំឡុងពេល ០២សប្តាហ៍បន្ទាប់ពីបានទទួលនូវការបញ្ជូននោះបើបណ្តឹងសាទុក្ខមិនបានធ្វើការតវ៉ាទេ ត្រូវចាត់ទុកថាខ្លួនបានយល់ព្រមចំពោះការដកពាក្យបណ្តឹងសាទុក្ខនោះដែរ។ ប៉ុន្តែបើដើមបណ្តឹងសាទុក្ខធ្វើការដកពាក្យបណ្តឹងដោយផ្ទាល់មាត់ នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ដែលភាគីចុងបណ្តឹងសាទុក្ខអវត្តមាននៅកាលបរិច្ឆេទនោះដែរ បើចុងបណ្តឹងសាទុក្ខមិនបានតវ៉ាក្នុងអំឡុងពេល ០២ សប្តាហ៍គិតចាប់ពីការបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់នោះក៏ត្រូវចាត់ទុកថា ចុងបណ្តឹងសាទុក្ខ បានយល់ព្រមចំពោះការដកពាក្យបណ្តឹងនោះដែរ។ ត្រូវចាត់ទុកថាដកពាក្យបណ្តឹងផងដែរ ក្នុងករណីដែលភាគីទាំងសងខាងមិនបានបង្ហាញខ្លួននៅកាលវិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយភាគីទាំងសងខាង មិនបានដាក់ពាក្យសុំទៅ

[143] មាត្រា ២១៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

តុលាការនៃបណ្តឹងសាទុក្ខកំណត់កាល បរិច្ឆេទនោះជាថ្មីម្តងទៀត ក្នុងអំឡុងពេល ០១ ខែទេនោះ ក៏ត្រូវចាត់ទុកថាបានដកពាក្យបណ្តឹងសាទុក្ខ ដែរ។ ហើយបើភាគីទាំងសងខាងមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ពីរដងជាប់គ្នា ក៏ត្រូវចាត់ទុកថាបានដកពាក្យបណ្តឹងសាទុក្ខដែរ។[144] ដូចនេះការដកពាក្យបណ្តឹង សាទុក្ខអាចដកតែមួយផ្នែក ឬទាំងមូលនៅពេលដែលមានការដកពាក្យបណ្តឹងសាទុក្ខនោះបានធ្វើឡើង ផ្នែកដែលត្រូវដក ឬបណ្តឹងទាំងមូលត្រូវ មិនបានចាត់ទុកថាមិនបានចាត់ការតាំងពីដំបូង ហើយរឿងក្តីត្រូវរលត់ដោយអានុភាពប្រតិសកម្ម។ ពោលគឺត្រូវតុលាការមិនបានចាត់ការបណ្តឹងនោះពីដំបូងមកម៉្លេះ ចំណែកឯសកម្មភាពរបស់តុលាការ និង ភាគីដែលបានធ្វើកន្លងមករហូតដល់ពេលដកពាក្យបណ្តឹងសាទុក្ខ នោះក៏ត្រូវបាត់បង់អានុភាពផងដែរ។ ប្រសិនបើមានការដកពាក្យបណ្តឹងសាទុក្ខ នោះនាំអានុភាពនៃសាលក្រមដើម ឬសាលដីកាដើមត្រូវចូលជាស្ថាពរ ក្នុងករណីអំឡុងពេលសម្រាប់ធ្វើបណ្តឹងសាទុក្ខបានកន្លងផុត ក៏ប៉ុន្តែដើមបណ្តឹងសាទុក្ខមិនអាចធ្វើការដកពាក្យបណ្តឹងសាទុក្ខបានឡើង បើតុលាការនៃបណ្តឹងសាទុក្ខប្រកាសសាលដីកា។ យ៉ាងណាមិញនៅពេលដើមបណ្តឹងសាទុក្ខបានធ្វើការដកពាក្យបណ្តឹងសាទុក្ខ នៅមុនពេលចប់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ដើមបណ្តឹងសាទុក្ខអាចដាក់ ឬសុំតុលាការនៃបណ្តឹងសាទុក្ខ សងវិញនូវចំនួនពាក់កណ្តាលនៃពន្ធដាក់ពាក្យបណ្តឹងដែលខ្លួនបានបង់ទៅតុលាការរួមមកហើយ។[145]

ការលះបង់ ឬទទួលស្គាលនូវការទាមទារជាសេចក្តីថ្លែងការណ៍តាមផ្លូវបណ្តឹងដែលភាគីម្ខាងទទួលស្គាល់ពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃការទាមទារ ហើយវិវាទភាគីទាំងសងខាងត្រូវដោះស្រាយដោយសេចក្តីថ្លែងការណ៍នេះសកម្មភាពទាំងនេះនាំ បណ្តឹងត្រូវបានបញ្ចប់ដោយមិនចាំបាច់សាលដីកាទេ។ ចំពោះ ល័ក្ខខ័ណ្ឌចាំបាច់ក្នុងការទទួលស្គាលនូវការទាមទារ ភាគីចាំបាច់ត្រូវ បុគ្គលដែលមានសមត្ថភាពក្នុងការធ្វើបណ្តឹង។ យ៉ាងណាមិញ អានុភាពនៃការលះបង់ ឬទទួលស្គាល់នៅការទាមទារតុលាការនៃបណ្តឹង សាទុក្ខ ត្រូវពិនិត្យអំពីល័ក្ខនៃបណ្តឹង បើឃើញថាភាគីមានល័ក្ខខ័ណ្ឌគ្រប់គ្រាន់ក្នុងការលះបង់ឬទទួលស្គាល់នូវការទាមទារ ក្រឡាបញ្ជីត្រូវចុះក្នុងការកំណត់ហេតុនាំ បណ្តឹងត្រូវបានបញ្ចប់ ហើយកំណត់ហេតុនោះមានអានុភាពដូចគ្នានឹងសាលដីកាស្ថាពរដែរ។[146]

ការសះជាតាមផ្លូវបណ្តឹង គឺជាសកម្មភាពមួយដែលដើមបណ្តឹងសាទុក្ខ និង ចុងបណ្តឹងសាទុក្ខធ្វើការសម្រុះសម្រួលគ្នាបញ្ចប់នូវនីតិវិធីបណ្តឹង ដោយត្រូវបង្ហាញខ្លួននៅចំពោះមុខតុលាការនៃបណ្តឹងសាទុក្ខនូវ

---

144 មាត្រា ២១៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

145 មាត្រា ២៨៦ និង ២៦៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

146 មាត្រា ២២២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់។ ចំពោះល័ក្ខខ័ណ្ឌចាំបាច់នៃការសះជាតាមផ្លូវបណ្តឹងក៏ភាគីចាំបាច់ត្រូវជាបុគ្គលដែលមានសមត្ថភាពក្នុងការធ្វើបណ្តឹងសាទុក្ខ ដូច្នេះបើមានភាគីណាមួយជាបុគ្គលដែលត្រូវបានកម្រិតសមត្ថភាពបានធ្វើការសះជានោះមានអានុភាពឡើយ។ អានុភាពនៃការសះជា មានអានុភាពបញ្ចប់បណ្តឹងដោយការសះជា ដែលកត់ត្រានៅក្នុងកំណត់ហេតុហើយលទ្ធផលនៃការសះជាតាមផ្លូវបណ្តឹងនេះនាំ នីតិវិធីនៃបណ្តឹងសាទុក្ខត្រូវបានបញ្ចប់ផងដែរ និងមានអានុភាពដូចគ្នាផងដែលនឹងសាលដីកាស្ថាពរ។[147] ប្រសិនបើក្នុងកំណត់ហេតុនេះមានការចុះអំពីសិទ្ធិទាមទារ ផ្តល់តាវកាលិកជាក់ ស្តែង ដោយមានការកំណត់ពេលអនុវត្តដូចកំណត់ហេតុសះជាមានអានុភាពអនុវត្ត ដែលក្លាយទៅជាលិខិតអនុវត្ត។ ប៉ុន្តែអានុភាពអាជ្ញាអស់ជំនុំ ជាលក្ខណៈសារធាតុមិនមានឡើយ ទោះបីជាកំណត់ហេតុសះជាមានអានុភាពដូចគ្នានឹងសាលដីកាស្ថាពរក៏ដោយសារតែការសះជាតាមផ្លូវបណ្តឹង គឺជាបណ្តឹងវិវាទដែលមានខ្លឹមសារនៃទំនាក់ទំនងគតិយុត្តផ្អែកលើព្រមព្រៀងរបស់ភាគី ដែលមានលក្ខណៈខុសពី សាលដីកាដែលធ្វើការសម្រេចសេចក្តីដោយផ្អែកលើភស្តុតាង ដែលអនុវត្តច្បាប់ចំពោះអង្គហេតុនោះ។ បើការសះជា តាមផ្លូវបណ្តឹងមានវិការៈភាគីអាចអះអាងពីមោឃៈភាពនៃការលុបចោលការសះជា នោះដោយនីតិវិធីនៃការដោះស្រាយជម្លោះនេះមិនមែនជាការសុំជំនុំជម្រះសាជាថ្មីដូចករណីសាលដីកាទេ គឺគ្រាន់តែជាស្នើសុំ តុលាការនៃ បណ្តឹងសាទុក្ខកំណត់នូវកាលបរិច្ឆេទនៃការទាញហេតុផល ដោយផ្ទាល់មាត់សាជាថ្មីតែប៉ុណ្ណោះ។ បើសិនជាមានពាក្យសុំ តុលាការនៃបណ្តឹងសាទុក្ខត្រូវកំណត់នូវកាលបរិច្ឆេទថ្មី ដោយមានមូលហេតុមានវិការៈក្នុងការសះជា។ បើការវិនិច្ឆ័យឃើញថាការសះជានោះមានវិការៈតុលាការនៃបណ្តឹង សាទុក្ខត្រូវធ្វើការបញ្ជាក់ថាបណ្តឹងនោះមិនទាន់ត្រូវបានបញ្ចប់ទេ ហើយត្រូវបន្តការវិនិច្ឆ័យលើបណ្តឹងនេះ។[148] ប៉ុន្តែបើវិនិច្ឆ័យឃើញថា ការសះជាដែលបានធ្វើពីមុននោះមានសុពលភាព តុលាការនៃបណ្តឹងសាទុក្ខត្រូវចេញសាលដីកាដែលប្រកាសអំពីការបញ្ចប់បណ្តឹងដោយការសះជានោះ។ ចំពោះបន្ទុកនៃប្រាក់ប្រដាប់ក្តីភាគីដែលត្រូវទទួលបន្ទុកនៃប្រាក់ប្រដាប់ក្តី គឺអាស្រ័យទៅលើការព្រមព្រៀងរបស់ភាគីនោះ ប៉ុន្តែប្រសិនបើភាគីគ្មានការព្រមព្រៀងគ្នាអំពីប្រាប់ប្រដាប់ក្តីទេ ភាគីនីមួយៗត្រូវទទួលបន្ទុកក្នុងការបង់ប្រាក់រៀងខ្លួន។ បើការសះជាបានសម្រេចលទ្ធផលមុនពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ដើមបណ្តឹងសាទុក្ខទទួលបានការសងមកវិញនូវចំនួន ពាក់កណ្តាលនៃពន្ធដែលបង់រួចមកហើយ។

[147] មាត្រា ៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[148] មាត្រា ២២២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

### ខ. ការបញ្ចប់បណ្តឹងដោយឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ

ផ្ទុយមកវិញបើមានការបញ្ចប់បណ្តឹងសាទុក្ខ ដោយមិនឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការនោះទេ តុលាការនៃបណ្តឹងសាទុក្ខ នឹងបញ្ចប់បណ្តឹងសាទុក្ខដោយចេញសាលដីកា ឬការលើកចោលនូវបណ្តឹងសាទុក្ខដោយដីកាសម្រេច ឬសាលដីកាច្រាលចោលបណ្តឹងសាទុក្ខ ឬសាលដីកាទទួលស្គាល់នូវបណ្តឹងសាទុក្ខ។[149]

#### ខ.១ ការលើកចោលបណ្តឹងសាទុក្ខដោយដីកាសម្រេច

ការលើកចោលនូវបណ្តឹងសាទុក្ខមានន័យថា បណ្តឹងសាទុក្ខនោះមិនបានធ្វើដោយស្របទៅតាមច្បាប់ ឬផ្ទុយច្បាប់ ហើយមិនអាចកែប្រែបាន ឬលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខមិនត្រូវបានដាក់ទៅតុលាការតាមថេរវេលាដែលច្បាប់បានកំណត់ ឬមួយលិខិតបញ្ជាក់អំពីមូលហេតុនោះមិនបានដាក់ទៅតុលាការនៃបណ្តឹងសាទុក្ខ។ ហើយការលើកចោលមួយនេះ តុលាការនៃបណ្តឹងសាទុក្ខធ្វើការលើកចោលដោយចេញនូវដីកាសម្រេច។ បន្ថែមពីនេះប្រសិនបើតុលាការនៃបណ្តឹងសាទុក្ខមិនបានចេញនូវដីកាសម្រេចលើកចោលបណ្តឹងសាទុក្ខនោះទេ ជាគោលការណ៍តុលាការនៃបណ្តឹង សាទុក្ខត្រូវបញ្ជូនឯកសារចម្លងនៃលិខិតបញ្ជាក់ពីមូលហេតុនៃបណ្តឹងសាទុក្ខចុងបណ្តឹងសាទុក្ខ ហើយការធ្វើបែបនេះក្នុងគោលបំណងផ្តល់ឱកាស ចុងបណ្តឹងសាទុក្ខដាក់នូវឯកសារត្រៀម។[150]

#### ខ.២ សាលដីកាច្រានចោលបណ្តឹងសាទុក្ខ

ក្នុងការជំនុំជម្រះលើអង្គសេចក្តីតុលាការត្រូវមើល ជាបឋមទៅលើឯកសារជាលាយលក្ខណ៍អក្សរដែលដូចជា លិខិតពាក្យបណ្តឹង លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ឯកសារត្រៀមដំបូងដែលចុងបណ្តឹងសាទុក្ខបានដាក់ និងឯកសារផ្សេងៗទៀត។ ហើយប្រសិនបើតុលាការរកឃើញដោយផ្អែកលើឯកសារទាំងអស់នោះថាគ្មានមូលហេតុប្តឹងសាទុក្ខ តុលាការនៃបណ្តឹងសាទុក្ខអាចចេញសាលដីកាច្រាលចោលនូវបណ្តឹងសាទុក្ខនោះដោយមិនចាំបាច់ឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់។ តុលាការនៃបណ្តឹងសាទុក្ខនៅតែអាចច្រានចោលពាក្យបណ្តឹងសាទុក្ខនោះ ទោះបីជាបានទាញហេតុផលដោយផ្ទាល់មាត់ហើយព្រោះថាបើតុលាការពិនិត្យ និងយល់ឃើញថាពុំមានមូលហេតុសម្រាប់ធ្វើបណ្តឹងសាទុក្ខទេ។[151]

[149] មាត្រា ៣០០ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[150] មាត្រា ២៨៤ និង មាត្រា ២៩២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[151] មាត្រា ២៧៧ និងមាត្រា២៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី

### ខ.៣ សាលដីកាទទួលស្គាល់បណ្តឹងសាទុក្ខ

តុលាការនៃបណ្តឹងសាទុក្ខទទួលស្គាល់ពាក្យបណ្តឹងសាទុក្ខ មានន័យថាពាក្យបណ្តឹងនោះធ្វើឡើងត្រឹមត្រូវតាមច្បាប់។ ដូច្នេះកាលដែលតុលាការនៃបណ្តឹងសាទុក្ខទទួលស្គាល់នូវបណ្តឹងសាទុក្ខហើយ តុលាការត្រូវលុបចោលនូវសាលក្រម និងសាលដីកាដើម។ ការបដិសេធចោលត្រង់នេះមានន័យថាតុលាការនៃការជំនុំជម្រះលើអង្គច្បាប់ លុបចោលនូវសាលក្រមដើម ឬសាលដីកាដើម។[152]

#### ខ.៣.១ ការបដិសេធចោល និងបញ្ជូនត្រលប់ទៅតុលាការដើមវិញ

ក្នុងករណីដែលតុលាការនៃបណ្តឹងសាទុក្ខទទួលស្គាល់ថា ពាក្យបណ្តឹងសាទុក្ខនោះមានមូលហេតុត្រឹមត្រូវតុលាការនៃបណ្តឹងសាទុក្ខត្រូវធ្វើការបដិសេធនូវសាលក្រម ឬសាលដីកាដើម ហើយត្រូវបញ្ជូនរឿងក្តីនោះ ត្រលប់ទៅតុលាការដើមវិញ។ ការបដិសសេធចោលរឿងក្តីនៃបណ្តឹងសាទុក្ខគឺមានភាពខុសពីការលុបចោលរឿងក្តី ដោយតុលាការនៃបណ្តឹងឧទ្ធរណ៍ ព្រោះថាក្រោយការបដិសេធសារជាថ្មីលើអង្គហេតុនៃរឿងក្តីនោះទេ គ្រាន់តែបញ្ជូនរឿងក្តីទៅតុលាការដើមវិញ។ ជាបឋមក្នុងករណីដែលមិនបានធ្វើការទទួលស្គាល់អង្គហេតុសារជាថ្មីមិនអាចធ្វើការជំនុំជម្រះចំពោះសាលក្រម ឬសាលដីកាដើមទេតុលាការនៃបណ្តឹងសាទុក្ខត្រូវបញ្ជូនរឿងក្តីនោះទៅតុលាការដើមវិញ ឬក្នុងករណីដែលយល់ឃើញថា ការបញ្ជូនត្រលប់នោះមិនសមស្របទេត្រូវផ្ទេររឿងក្តីនោះទៅតុលាការផ្សេងដែលមានថ្នាក់ដូចគ្នា។[153] ហើយតុលាការដែលបានទទួលនូវការបញ្ជូនត្រលប់មកវិញ ឬដែលបានទទួលនូវការផ្ទេរនោះ ត្រូវធ្វើការជំនុំជម្រះដោយធ្វើការទាញហេតុផលដោយផ្ទាល់មាត់សារជាថ្មី ចំពោះរឿងក្តីនោះតាមនីតិវិធីនៃថ្នាក់ជំនុំជម្រះនោះ។ ការទាញហេតុផលដោយផ្ទាល់មាត់នេះទៀតសោត គឺជាការបើកឡើងវិញ និងបន្តនូវការទាញហេតុផលដោយផ្ទាល់មាត់ដែលត្រូវបានធ្វើពីមុនមក ហើយចៅក្រមដែលពាក់ព័ន្ធនឹងសាលដីកាដើម ឬសាលក្រមដើម មិនអាចចូលរួមក្នុងការទាញហេតុផលដោយផ្ទាល់មាត់បានទេ។ ក្នុងករណីដែលមានការផ្លាស់ប្តូរចៅក្រម នៅមុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍នូវលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ដែលបានធ្វើពីមុនមក។ ក្នុងការផ្លាស់ប្តូរចៅក្រមដូចនេះ ព្រោះថាប្រសិនបើតុលាការដើមនៅតែធ្វើការវិនិច្ឆ័យដូចមុន ឬធ្វើការចាត់ចែងដូចមុននោះ ទោះតុលាការនៃបណ្តឹងសាទុក្ខបានបញ្ជូនត្រលប់ទៅវិញប៉ុន្មានក៏ដោយ ក៏រឿងក្តីនោះមិនអាចដោះស្រាយចប់ឡើយ។[154] សេចក្តីវិនិច្ឆ័យលើអង្គហេតុដែលមានអានុភាពចងត្រូវបានកម្រិត តែសេចក្តីវិនិច្ឆ័យអំពី អង្គហេតុដោយតុលាការនៃបណ្តឹងសាទុក្ខអាចវិនិច្ឆ័យបានដូចជា អង្គហេតុដែលទាក់ទង

[152] មាត្រា ៣០០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[153] មាត្រា ២៩៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[154] មាត្រា ២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ទៅនឹងចំណុចដែលតុលាការត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិប៉ុណ្ណោះ។ ជារួមមកវិញដើម្បី មានអានុភាពចង ក្នុងការវិនិច្ឆ័យនោះបាន គឺចៅក្រមណាដែលមានការពាក់ព័ន្ធនឹងសាលក្រម ឬសាលដីកាដើមដែលត្រូវបានបដិសេធចោល មិនត្រូវអនុញ្ញា ចូលរួមក្នុងការសម្រេចសេចក្តីក្រោយបាននោះទេ។[155]

### ខ.៣.២ ការបដិសេធចោល និងការផ្ទេររឿងទៅតុលាការផ្សេង

ជាគោលការណ៍តុលាការនៃបណ្តឹងសាទុក្ខបដិសេធចោលនូវសាលដីកាដើម ឬសាលក្រមដើម តុលាការនៃបណ្តឹងសាទុក្ខត្រូវបញ្ជូនរឿងក្តីនោះត្រលប់ទៅតុលាការដើមវិញ ក៏ប៉ុន្តែក្នុងករណីដូចជាតុលាការអាចរកចៅក្រមផ្សេងមកជំនួសចៅក្រមដែលមានការទាក់ទងនឹងការចេញសាលក្រម ឬសាលដីកាដើម ដែលត្រូវបានតុលាការនៃបណ្តឹងសាទុក្ខបដិសេធចោលនោះ ដោយសារតែចំនួនចៅក្រមនៅក្នុងតុលាការដើមនោះមិនគ្រប់គ្រាន់តុលាការនៃបណ្តឹងសាទុក្ខត្រូវផ្ទេររឿងក្តីនោះទៅតុលាការផ្សេងដែលមានថ្នាក់ដូចគ្នា។ការកំណត់បែបនេះក្នុងគោលបំណងជៀសវាងយឺតយ៉ាវ ឬការរាំងស្ទះដល់ដំណើរនៃនីតិវិធីបណ្តឹង។ ចំពោះតុលាការដែលទទួលការផ្ទេររឿងក្តីនេះ ត្រូវធ្វើការសម្រេចសេចក្តីដោយផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់សារជាថ្មី ហើយចំនួនចៅក្រមត្រូវអនុវត្តដូចគ្នានឹងករណីបញ្ជូនរឿងក្តីត្រលប់ទៅតុលាការដើមវិញដែរ។ ចំណែកឯភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ដែលបានធ្វើពីមុនមក។

### ខ.៣.៣ ការបដិសេធចោល និងការវិនិច្ឆ័យដោយខ្លួនឯង

តុលាការនៃបណ្តឹងសាទុក្ខ ត្រូវធ្វើការសម្រេចសេចក្តីអំពីរឿងក្តីផ្ទាល់ដោយខ្លួនក្នុងករណី ដូចខាងក្រោម៖

- តុលាការនៃបណ្តឹងសាទុក្ខបានបដិសេធចោលនូវសាលក្រម ឬសាលដីកាដើមដោយហេតុថាតុលាការនៃការជំនុំជម្រះដើមមានកំហុសក្នុងការអនុវត្តរដ្ឋធម្មនុញ្ញ ឬច្បាប់ ឬបទដ្ឋានគតិយុត្ត ចំពោះអង្គហេតុដែលបានចូលជាស្ថាពរ ហើយតុលាការនៃបណ្តឹងសាទុក្ខអាចសម្រេចសេចក្តីអំពីរឿងនោះដោយផ្អែកលើអង្គហេតុនេះបាន។ មានន័យថាតុលាការនៃបណ្តឹងសាទុក្ខអាចធ្វើការវិនិច្ឆ័យដោយខ្លួនឯងចំពោះសាលក្រមឬសាលដីកាដើមនោះបានក្នុងករណីដែលសាលក្រម ឬសាលដីកានោះធ្វើឡើងដោយមានកំហុសក្នុងការអនុវត្តរដ្ឋធម្មនុញ្ញ ឬច្បាប់ ឬបទដ្ឋានគតិយុត្តលើអង្គហេតុដែលបានកំណត់ជាស្ថាពរនៅក្នុងសាលក្រម ឬសាលដីកាដើមនោះប៉ុណ្ណោះ។[156]

---

[155] មាត្រា ២៨៥ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[156] មាត្រា ២៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

- តុលាការនៃបណ្ដឹងសាទុក្ខបដិសេធចោលនូវសាលក្រម ឬសាលដីកាដើមដោយយកមូលហេតុថារឿងក្ដីនោះមិនស្ថិតនៅក្រោមសិទ្ធិជម្រះក្ដីរបស់តុលាការ។ មានន័យថាតុលាការដើមបានធ្វើការជំនុំជម្រះលើរឿងក្ដីដោយខ្លួនឯង។

## ២.២ បណ្ដឹងជំទាស់

បណ្ដឹងជំទាស់ គឺជាប្រព័ន្ធនៃបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលឯករាជ្យ និងសង្ខេប ដែលអាចធ្វើឡើងចំពោះដីកាសម្រេចដែលជាសេចក្ដីសម្រេចមិនមែនជាសាលក្រមឬសាលដីកា។ នីតិវិធីនៃបណ្ដឹងជំទាស់មានលក្ខណៈងាយស្រួល និងឆាប់រហ័ស បើប្រៀបធៀបជាមួយនឹងការប្ដឹងឧទ្ធរណ៍ ឬសាទុក្ខ ហើយត្រូវបញ្ចប់ដោយដីកាសម្រេចដែលជានីតិវិធីចេញដីកាសម្រេច។[157] ដោយបណ្ដឹងជំទាស់ គឺជាបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ហេតុដូច្នេះត្រង់ចំណុចនោះ ខុសពីការតវ៉ាដែលជាឧបាស្រ័យចំពោះដីកាសម្រេចទៅតុលាការដើម។

### ២.២.១ សញ្ញាណទូទៅនៃបណ្ដឹងជំទាស់

បណ្ដឹងជំទាស់ ត្រូវបានកំណត់ដោយច្បាប់នីតិវិធីរដ្ឋប្បវេណី ដើម្បីផ្ដល់ផលប្រយោជន៍ សម្រាប់ភាគីដែលមានជម្លោះកើតទុក្ខមិនសុខចិត្ត ទៅនឹងសេចក្ដីសម្រេចរបស់តុលាការ ដែលធ្វើខូចប្រយោជន៍របស់ខ្លួន។ តួយ៉ាងបណ្ដឹងជំទាស់ គឺជាប្រព័ន្ធនៃបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលឯករាជ្យ និងសង្ខេប ដែលអាចធ្វើឡើងចំពោះដីកាសម្រេចដែលសេចក្ដីសម្រេចមិនមែនជាសាលក្រម ឬសាលដីកា។ នីតិវិធីនៃបណ្ដឹងជំទាស់ មានលក្ខណៈងាយស្រួល និងឆាប់រហ័ស បើប្រៀបធៀបជាមួយនឹងការប្ដឹងឧទ្ធរណ៍ ឬប្ដឹងសាទុក្ខ ហើយត្រូវបញ្ចប់ដោយដីកាសម្រេចដែលជានីតិវិធីចេញដីកាសម្រេច។

#### ២.២.១.១. កម្មវត្ថុ មូលហេតុ និង ល័ក្ខខ័ណ្ឌនៃបណ្ដឹងជំទាស់

ជាបឋមដើម្បីមានភាពងាយស្រួលសិក្សាលើ កម្មវត្ថុ មូលហេតុ និងល័ក្ខខ័ណ្ឌនៃបណ្ដឹងជំទាស់យើងគប្បីស្វែងយល់ចំណុចមួយចំនួនដូចខាងក្រោម៖

**ក. កម្មវត្ថុ**

កម្មវត្ថុនៃបណ្ដឹងជំទាស់គឺ ត្រូវតែជាដីកាសម្រេចតែមួយប៉ុណ្ណោះ។[158] ចំពោះដីកាសម្រេចដែលអាចធ្វើការប្ដឹងជំទាស់បានមានដូចជា៖

- ដីកាសម្រេចបដិសេធ៖

[157] មាត្រា ៣០៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[158] មាត្រា ២៥៩ កថាខណ្ឌទី១ ចំណុច គ នៃក្រមនីតិវិធីរដ្ឋប្បវេណី

- ការសម្រេច លុបចោលដីកាសម្រេចជួយសង្គ្រោះលើពាក្យបណ្ដឹង។[159]
- ដីកាសម្រេច លុបចោលប្រាតិភោគ។[160]
- ដីកាសម្រេចលើកបណ្ដឹងចោល។[161]
- ដីកាសម្រេចលើចោលពាក្យសុំទទួលបន្តនីតិវិធីនៃបណ្ដឹង។[162]
- ដីកាសម្រេចលើចោលពាក្យសុំ រក្សាការពារភស្តុតាង។[163]
- ដីកាសម្រេចលើចោលពាក្យសុំទទួលបន្តនីតិវិធីនៃបណ្ដឹង។[164]
- ដីកាសម្រេចលើកចោល និងច្រានចោលបណ្ដឹងទាមទារ ជំនុំជម្រះសារជាថ្មី។[165]
- ដីកាសម្រេចលើកចោលនូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន។[166]
- ដីកាសម្រេចកាលុបចោលការរឹបអូស។[167]
- ដីកាសម្រេចលើកចោលពាក្យសុំ អនុវត្តដោយបង្ខំចំពោះចលនវត្ថុ។[168]
- ដីកាសម្រេចលើកចោលការទាមទារ ចែករំឡែក។[169]
- ដីកាសម្រេចលុបចោលដីកាសម្រេចអនុញ្ញាតឬមិនអនុញ្ញាត លក់។[170]
- ដីកាសម្រេចរបស់តុលាការអនុវត្ត ដែលលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ។[171]
- ដីកាសម្រេចរបស់សាលាដំបូង ដែលលើកចោលពាក្យសុំតវ៉ាចំពោះការចែងរបស់អាជ្ញាសាលា ដែលលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ។[172]

➢ ដីកាសម្រេចអនុញ្ញាត មិនអនុញ្ញា និងបញ្ជាះ

[159] មាត្រា ៧០ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[160] មាត្រា ៧៣ កថាខណ្ឌទី៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[161] មាត្រា ៧៨ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[162] មាត្រា ១៧៥ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[163] មាត្រា ១៦៨ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋវេណី ឆ្នាំ២០០៦
[164] មាត្រា ១៧៥ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[165] មាត្រា ១៣៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[166] មាត្រា ៣២៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[167] មាត្រា ៣៨១ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[168] មាត្រា ៤១៩ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[169] មាត្រា ៤០៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[170] មាត្រា ៤៧៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[171] មាត្រា ៣៨៥ កថាខណ្ឌទី១ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[172] មាត្រា ៣៨៥ កថាខណ្ឌទី១ ចំណុច គ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

- ដីកាសម្រេចនូវការអនុញ្ញាតឬមិនអនុវញ្ញា ចូលអន្តរាគមន៍។[173]
- ដីកាសម្រេចបង្គាប់ ដាក់ប្រាតិភោគ។[174]
- ដីកាសម្រេច ជួយសង្គ្រោះលើពាក្យបណ្តឹង។[175]
- ដីកាសម្រេចបង្គាប់ នាំខ្លួនសាក្សី និងដីកាសម្រេចពិន័យសាក្សីជាសាច់ប្រាក់ដោយមិនចូលតាមដីកាកោះ។[176]
- ដីកាសម្រេចពិន័យភាគីដែលបន្លំសេចក្តីថ្លែងការណ៍។[177]
- ដីកាសម្រេចបង្គាប់ ផ្តល់ឯកសារ។[178]
- ដីកាសម្រេច តតិយជនបង់ប្រាក់ពិន័យ ដោយមិនគោរពដីការសម្រេចបង្គាប់ ផ្តល់ឯកសារ។[179]
- ដីកាសម្រេចរបស់សាលាដំបូង ដែលបង្គាប់ អាជ្ញាសាលាលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ។[180]
- ដីកាសម្រេចអនុញ្ញាត រឹបអូស។[181]
- ដីកាសម្រេចបង្គាប់ ប្រគល់ចលនវត្ថុដែលត្រូវរឹបអូស។[182]
- ដីកាសម្រេចបង្គាប់ អាជ្ញាសាលាលក់សិទ្ធិលើបំណុល។[183]
- ដីកាសម្រេចអនុញ្ញាមិនអនុញ្ញាត លក់។[184]
- ដីកាសម្រេចអនុញ្ញាត វត្ថុបញ្ចាំមកសងផ្ទាល់។[185]

➢ ដីកាសម្រេចផ្សេងៗ៖

- ដីកាសម្រេចផ្ទេរសិទ្ធិ និងដីកាសម្រេចលើបណ្តឹង។[186]

---

[173] មាត្រា ៤៥ កថាខណ្ឌទី៣ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៦
[174] មាត្រា ៦៧ កថាខណ្ឌទី៥ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៦
[175] មាត្រា ៧៩ កថាខណ្ឌទី៤ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៦
[176] មាត្រា ១៣២ កថាខណ្ឌទី៤ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៦
[177] មាត្រា ១៤០ កថាខណ្ឌទី៤ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៦
[178] មាត្រា ១៥២ កថាខណ្ឌទី៣ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៦
[179] មាត្រា ១៥៤ កថាខណ្ឌទី២ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៦
[180] មាត្រា ៣៤៥ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៦
[181] មាត្រា ៣៨១ កថាខណ្ឌទី៤ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៦
[182] មាត្រា ៣៩០ កថាខណ្ឌទី៣ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៦
[183] មាត្រា ៤១៣ កថាខណ្ឌទី៤ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៦
[184] មាត្រា ៤៧៥ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៦
[185] មាត្រា ៥០៤ កថាខណ្ឌទី៦ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៦
[186] មាត្រា ២១ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៦

- ដីកាសម្រេចសេចក្តីថា កាដកហូតឬបណ្តឹងដឹតចិត្ត ពុំត្រឹមត្រូវ។[187]
- ដីកាសម្រេចអំពីពាក្យសុំ តុលាការបង្គាប់ ដើមចោទ ដាក់ប្រាតិភោគលើប្រាក់ប្រដាប់ក្តីដោយដើមចោទគ្មានលំនៅច្បាស់លាស់ឬពិតប្រាកដ។[188]
- ដីកាសម្រេចដែលសម្រេចថា បណ្តឹងផាត់ចោលគ្មានមូលហេតុត្រឹមត្រូវ។[189]
- ដីកាសម្រេចកែតម្រូវសាលក្រម។[190]
- ដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី។[191]

### ខ. មូលហេតុនៃបណ្តឹងជំទាស់

ជាគោលការណ៍មិនថាបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងសាទុក្ខនោះទេតែងតែមានមូលហេតុរបស់វានីមួយៗដែលកើត មានបណ្តឹង។ តួយ៉ាង បណ្តឹងជំទាស់កើតមានឡើងក៏ព្រោះតែ ភាគីមិនពេញចិត្តទៅដីកាសម្រេចដែលចេញដោយសាលាដំបូង ឬសាលាឧទ្ធរណ៍នោះ។ គ្រប់បញ្ហាទាំងអស់ដែលទាក់ទងនឹងដំណើរការនៃនីតិវិធី ឬដែលកើតឡើងដោយនីតិវិធីនៃការជំនុំជម្រះ សុទ្ធតែដាក់ តុលាការជាន់ខ្ពស់សម្រេចដែលនោះ និង រឹតតែមានភាពស្មុគស្មាញទៅវិញ ហើយអាចធ្វើ មានភាពស្មុគស្មាញទៅវិញ ហើយអាចធ្វើ មានការយឺតយ៉ាវក្នុងការជំនុំជម្រះរឿងក្តីនោះដោយសារតែបញ្ហាដែលកើតចេញ ដូច្នេះការជាល្អប្រសិនបើ បញ្ហាដែលមិនសូវពាក់ព័ន្ធនិងអង្គសេចក្តីនៃរឿងក្តី ហើយដែលត្រូវការសម្រេច ឆាប់អាចដោះស្រាយបានដោយប្រើនីតិវិធីសង្ខេបដែលអាចធ្វើឡើង ដាច់ដោយឡែកនោះដែលហៅបណ្តឹងជំទាស់។[192] មួយវិញទៀតក៏មានមូលហេតុមួយទៀតដែលបណ្តាល មានបណ្តឹងជំទាស់ គឺនៅពេលភាគីណាមួយទទួលនូវឥទ្ធិពលពីដីកាសម្រេច ដែលនាំ នាំខូចប្រយោជន៍ដល់សិទ្ធិឬឋានៈគតិយុត្តរបស់ខ្លួន។ ហើយបណ្តឹងជំទាស់នេះអាចធ្វើបានក្នុងមូលហេតុដែលមានភាពផ្ទុយនឹងច្បាប់ ឬបទដ្ឋានគតិយុត្តដែលមានឥទ្ធិពលលើដីកាសម្រេចដើម។[193]

### គ. ល័ក្ខខ័ណ្ឌនៃបណ្តឹងជំទាស់

ក្នុងការធ្វើបណ្តឹងជំទាស់បាន លុះត្រាតែមានលក្ខខណ្ឌត្រូវបំពេញជាមុនសិន ហើយល័ក្ខខ័ណ្ឌនោះមានដូចជា ៖

[187] មាត្រា ៣០ កថាខណ្ឌទី៤ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៦
[188] មាត្រា ៦៧ កថាខណ្ឌទី៦ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៦
[189] មាត្រា ១៤៥ កថាខណ្ឌទី៥ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៦
[190] មាត្រា ១៩២ កថាខណ្ឌទី២ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៦
[191] មាត្រា ៣១៥ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៦
[192] មាត្រា ៣០១ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៦
[193] មាត្រា ២៨៤ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៦

### គ.១ ភាគីនៃបណ្តឹងជំទាស់

ក្នុងករណីចំណុចដែលត្រូវបានវិនិច្ឆ័យដោយដីកាសម្រេចដែលជាកម្មវត្ថុនៃបណ្តឹងជំទាស់មាន មូលដ្ឋានដែលមានបុគ្គលពាក់ព័ន្ធនឹងផលប្រយោជន៍ ដើមបណ្តឹងជំទាស់ត្រូវធ្វើពាក្យសុំប្តឹងជំទាស់ប្រឆាំងទៅនឹងបុគ្គលនោះហើយតុលាការក៏ត្រូវ បុគ្គលនោះ ចូលរួមនៅក្នុងនីតិវិធី ទាំងឡាយនៃការប្តឹងជំទាស់នោះ។[194] ឧទាហរណ៍៖ ក្នុងករណីដែលដើមចោទបានដាក់ពាក្យសុំ តុលាការចេញដីកាសម្រេចបង្គាប់ ចុងចម្លើយ ផ្តល់ឯកសារដែលចុងចម្លើយកាន់កាប់ ហើយតុលាការចេញដីកាសម្រេចបង្គាប់ ផ្តល់ឯកសារ ដោយទទួលស្គាល់ពាក្យសុំនោះ ប្រសិនបើចុងចម្លើយប្តឹងជំទាស់ចំពោះដីកាសម្រេចនោះ ចុងចម្លើយត្រូវយកដើមចោទមកធ្វើជាភាគីម្ខាងទៀត។ ប្រសិនបើដើមចោទប្តឹងជំទាស់ចំពោះដីកាសម្រេចច្រានចោលពាក្យសុំ ដើមចោទនោះត្រូវយកចុងចម្លើយមកធ្វើជាភាគីម្ខាងទៀតវិញ។ ក៏ប៉ុន្តែមានករណីខ្លះដែលសេចក្តីសម្រេចធ្វើឡើងតាមរយៈដីកាសម្រេច តែគ្មានបុគ្គលណាពាក់ព័ន្ធនឹងផលប្រយោជន៍ទេ។ ឧទាហរណ៍៖ ដីកាសម្រេចដាក់ពិន័យស៊ីវិលចំពោះសាក្សី ឬដីកាសម្រេចដាក់ពិន័យស៊ីវិលចំពោះ តតិយជនដែលមិនគោរពតាម ដីកាសម្រេចបង្គាប់ផ្តល់ឯកសារ។

### គ.២ អំឡុងពេលក្នុងការធ្វើបណ្តឹងជំទាស់

ការធ្វើបណ្តឹងជំទាស់ គឺធ្វើបានចំពោះភាគីដែលបានបាត់បង់នូវផលប្រយោជន៍ដោយសារដីកាសម្រេចពីតុលាការដើម។ ការដាក់ពាក្យបណ្តឹងជំទាស់ធ្វើបានក្នុងអំឡុងពេលចំនួន ១សប្តាហ៍គិតចាប់ពីថ្ងៃដែលបានទទួលនូវដំណឹងអំពីដីកាសម្រេច។ ហើយអំឡុងពេលនៃបណ្តឹងជំទាស់នេះ គឺមិនអាចពន្យារពេលបាននោះទេ។[195]

### ២.២.១.២ អានុភាពនៃបណ្តឹងជំទាស់

ជាទូទៅនៅពេលដែលដាក់ពាក្យបណ្តឹងជំទាស់ហើយ តុលាការពិនិត្យឃើញថាត្រឹមត្រូវទៅតាមច្បាប់នៃបណ្តឹងជំទាស់បានកំណត់ដែលដូចជាល័ក្ខខ័ណ្ឌ និងរបៀបបណ្តឹងជំទាស់នោះ អានុភាពនៃបណ្តឹងជំទាស់គឺនឹងកើតមានឡើង។[196] ជាគោលការណ៍ដីកាសម្រេចអាចមានអានុភាពអនុវត្ត ឬអាចមានអានុភាពបង្កើតទំនាក់ទំនង គតិយុត្តលុះត្រាតែត្រូវបានជូនដំណឹងដែលគេទទួលស្គាល់ថាសមរម្យ។ ដូចនេះកាលណាដែលបណ្តឹងជំទាស់មាននូវអានុភាព ដីកាសម្រេចដើមដែលមានអានុភាពនោះនឹងត្រូវបង្អាក់។ ឧទាហរណ៍៖ ក្នុងករណីដែលបណ្តឹងជំទាស់ ត្រូវបានដាក់ចំពោះដីកាសម្រេចបង្គាប់ប្រគល់ចលនវត្ថុដែលត្រូវបានរឹបអូស

[194] មាត្រា ៣០៤ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៦

[195] មាត្រា ៣០៣ កថាខណ្ឌទី១,ទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[196] មាត្រា ៣០៦ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៦

ដូចនេះភាគីដែលត្រូវបង្គាប់នោះ មិនចាំបាច់ប្រគល់ចលនវត្ថុដែលត្រូវបានរឹបអូស ដែលតុលាការដើមបង្គាប់ប្រគល់ឡើយ។[197] ប៉ុន្តែបើការផ្អាកការអនុវត្តដោយបង្ខំជាបណ្តោះអាសន្ន ឬការចាត់ចែងផ្សេងទៀតនោះ អាចធ្វើបានតាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិរបស់តុលាការ ទើបអាចបង្គាប់ ផ្អាកការអនុវត្តដោយបង្ខំជាបណ្តឹងបណ្តោះអាសន្ន ឬបង្គាប់ ធ្វើការចាត់ចែងចាំបាច់ផ្សេងទៀត រហូតដល់ពេលមានដីកាសម្រេចអំពីបណ្តឹងជំទាស់នោះ។

### ២.២.២ លំហូរនីតិវិធីនៃការជម្រះបណ្តឹងជំទាស់

ដើម្បីមានភាពងាយស្រាយក្នុងការសិក្សា លើលំហូរនីតិវិធីនៃការជម្រះបណ្តឹងជំទាស់ យើងគប្បីសិក្សាចំណុចមួយចំនួនដូចខាងក្រោម៖

#### ២.២.២.១. របៀបធ្វើ ការទទួល និងការពិនិត្យលើពាក្យបណ្តឹងជំទាស់

##### ក. របៀបធ្វើបណ្តឹងជំទាស់

មិនខុសពីបណ្តឹងដទៃទៀតនោះទេ ដើម្បីធ្វើបណ្តឹងជំទាស់ភាគីក៏ត្រូវ ចុះអត្តសញ្ញាណខ្លួនដូចឈ្មោះ អាសយដ្ឋានភាគី និងអ្នកតំណាងដែលច្បាប់បានកំណត់ បានច្បាស់លាស់។ ជាមួយគ្នានេះដែរបណ្តឹងជំទាស់ក៏ទាមទារ ភាគីនៃដើមបណ្តឹងជំទាស់ចុះអំពីមូលហេតុច្បាស់លាស់នៃការសុំលុបចោល ឬកាផ្លាស់ប្តូរដីកាសម្រេចដើម។ ប្រសិនបើភាគីមិនបានសរសេរនូវមូលហេតុច្បាស់លាស់នោះទេ ដើមបណ្តឹងជំទាស់គប្បីដាក់លិខិតបញ្ជាក់អំពី មូលហេតុនៃបណ្តឹងជំទាស់នោះទៅតុលាការនៃបណ្តឹងជំទាស់ ក្នុងអំឡុងពេល ២សប្តាហ៍ គិតចាប់ពីពេលដែលបានដាក់នូវពាក្យបណ្តឹងជំទាស់នោះ។[198] ប្រសិនបើដើមបណ្តឹងជំទាស់មិនបានដាក់លិខិតបញ្ជាក់ពីមូលហេតុក្នុងអំឡុងពេលដែលច្បាប់បានកំណត់ឬមិនបានចុះបញ្ជីនោះទេ ពាក្យបណ្តឹងជំទាស់មួយនោះនឹងគ្មានសុពលភាព។ ពាក្យបណ្តឹងជំទាស់ត្រូវដាក់ទៅតុលាការដើម បន្ទាប់មកតុលាការដើមត្រូវបញ្ជូនពាក្យជំទាស់ និងសំណុំរឿងទៅតុលាការនៃបណ្តឹងជំទាស់ ឬតុលាការជាន់ខ្ពស់។[199]

##### ខ. ការទទួលពាក្យបណ្តឹងជំទាស់

ពាក្យបណ្តឹងជំទាស់ត្រូវដាក់នៅតុលាការដើមចំពោះដីកាសម្រេចនោះ ក្នុងអំឡុងពេលកំណត់សម្រាប់ធ្វើបណ្តឹងជំទាស់។ ដោយតុលាការដើមពុំមានសមត្ថកិច្ចពិនិត្យពាក្យបណ្តឹងជំទាស់ទេ គ្រាន់តែជាតុលាការដែលទទួលពាក្យបណ្តឹងជំទាស់របស់ភាគីតែប៉ុណ្ណោះ។ បន្ទាប់មកតុលាការដើមត្រូវធ្វើការផ្ញើ បានឆាប់រហ័សនូវពាក្យបណ្តឹងជំទាស់នោះ និងសំណុំរឿងទៅតុលាការនៃបណ្តឹងជំទាស់ឬតុលាការជាន់ខ្ពស់។

---

[197] មាត្រា ៣០៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[198] មាត្រា ៣០១ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[199] មាត្រា ៣០១ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៦

**គ. ការពិនិត្យពាក្យបណ្ដឹងជំទាស់**

តុលាការនៃបណ្ដឹងជំទាស់ត្រូវធ្វើការពិនិត្យ ប្រសិនបើមានចំណុចមិនសមស្រប តុលាការត្រូវបង្គាប់ដើមបណ្ដឹងជំទាស់ធ្វើការកែប្រែ។ ក្នុងករណីដែលភាគីនោះមិនធ្វើតាមការបង្គាប់ កែប្រែរបស់តុលាការទេ តុលាការនឹងមានសិទ្ធិលើកចោលពាក្យបណ្ដឹងជំទាស់នោះដោយដីកាសម្រេច។ ប្រសិនបើពាក្យបណ្ដឹងជំទាស់ត្រឹមត្រូវតាមទម្រង់ច្បាប់ តុលាការត្រូវបញ្ជូនពាក្យជំទាស់នោះទៅ ចុងបណ្ដឹងជំទាស់។[200]

**២.២.២.២. ការទាញហេតុផលដោយផ្ទាល់មាត់**

ចំពោះនីតិវិធីបណ្ដឹងជំទាស់ មិនមែនធ្វើវិធីតទល់គ្នារវាងភាគីនៅគ្រប់ពេលវេលាទេ។ យ៉ាងណាមិញ ចំពោះនីតិវិធីនៃការជំនុំជម្រះបណ្ដឹងជំទាស់វិញនោះត្រូវបញ្ចប់ដោយដីកាសម្រេច តុលាការអាចសម្រេចដោយឆន្ទានុសិទ្ធិបានក្នុងការធ្វើ ឬមិនធ្វើកាទាញហេតុផលដោយផ្ទាល់មាត់។ ប្រសិនបើតុលាការនៃបណ្ដឹងជំទាស់មិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់ទេ តុលាការអាចធ្វើការសួរដើមបណ្ដឹងជំទាស់ ឬអ្នកផ្សេងទៀតដែលមានទំនាក់ទំនងនឹងផលប្រយោជន៍នៃបណ្ដឹងបាន។[201] ក្នុងការជំនុំជម្រះនៃបណ្ដឹងជំទាស់នេះ គឺផ្អែកទៅលើការអះអាងរបស់ភាគីនិងភស្តុតាងដែលដាក់នៅ តុលាការដើមតាមរយៈការវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវក្នុងការអនុវត្តច្បាប់ ដូច្នេះភាគីអាចដាក់អង្គហេតុថ្មី និងភស្តុតាងថ្មីបាន។[202]

**២.២.២.៣. វិសាលភាពនៃការជំនុំជម្រះលើបណ្ដឹងជំទាស់**

នៅក្នុងផ្នែកទី៧ ដែលស្ដីអំពីវិសាលភាពនៃបណ្ដឹងជំទាស់ នឹងលើកយកពីចំណុចមកពន្យល់ដែលចំណុចទី១ និយាយអំពីការប្ដឹងជំទាស់ចំពោះដីកាសម្រេចនៃសាលាឧទ្ធរណ៍ និងចំណុចទី២ និយាយអំពីការប្ដឹងជំទាស់ចំពោះដីកាសម្រេចរបស់ចៅក្រមដែលទទួលការបញ្ជា ឬការប្រគល់សិទ្ធិ។

**ក. វិសាលភាពនៃការជំនុំជម្រះបណ្ដឹងជំទាស់ចំពោះដីកាសម្រេចនៃសាលាឧទ្ធរណ៍**

បើទោះជាការប្ដឹងជំទាស់អាចធ្វើឡើងទៅតាមការកំណត់ក្នុងបញ្ញត្តិច្បាប់ក៏ដោយ ក៏ប៉ុន្តែចំពោះដីកាសម្រេចចុងក្រោយនៃការជំនុំជម្រះបណ្ដឹងជំទាស់ដែលតុលាការនៃបណ្ដឹងជំទាស់បានចេញ មិនអាចប្ដឹងជំទាស់ទៀតបានឡើយ។[203] ឧទាហរណ៍៖ ប្រសិនបើមានបណ្ដឹងជំទាស់ចំពោះដីកាសម្រេចបង្គាប់ផ្ដល់ឯកសារដែលបានចេញដោយសាលាដំបូងក្នុងនាមតុលាការនៃការជំនុំជម្រះលើកទី១ ភាគីអាចប្ដឹងជំទាស់បានទៅសាលាឧទ្ធរណ៍ ប៉ុន្តែនៅពេលតុលាការនៃបណ្ដឹងឧទ្ធរណ៍ចេញដីកាសម្រេចចុងក្រោយនៃបណ្ដឹងជំទាស់នោះហើយ គឺ

[200] មាត្រា ២៦៦ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៦

[201] មាត្រា ៣០៦ កថាខណ្ឌទី២ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៦

[202] មាត្រា ១២៣ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៦

[203] មាត្រា ៣៥៩ កថាខណ្ឌទី២ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៦

មិនអាចប្តឹងជំទាស់ទៅតុលាការកំពូលថែមទៀតបានទេ។ ការអនុវត្តបែបនេះ គឺដើម្បីសម្រាលនូវបន្ទុករបស់តុលាការកំពូល។

ផ្ទុយមកចំពោះដីកាសម្រេចដែលសាលាឧទ្ធរណ៍បានធ្វើឡើង ក្នុងនាមតុលាការនៃការជំនុំជម្រះលើកទី១ អាចប្តឹងជំទាស់ទៅតុលាការកំពូលបាន បើមានបញ្ញត្តិច្បាប់អនុញ្ញាត ប្តឹងជំទាស់ចំពោះដីកាសម្រេចនោះ។ បណ្តឹងជំទាស់ត្រង់ចំណុចនេះ គឺជាបណ្តឹងជំទាស់ទៅតុលាការកំពូលដែលជាតុលាការវិនិច្ឆ័យទៅលើអង្គច្បាប់ ហើយនីតិវិធីនៃការប្តឹងជំទាស់ទៅតុលាការកំពូលក្នុងករណីនេះ គឺស្រដៀងគ្នាទៅនឹងការអនុវត្តបណ្តឹងសាទុក្ខ ចំពោះសាលដីកាចុងក្រោយរបស់សាលាឧទ្ធរណ៍ ដែលចេញក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី១ ដោយហេតុនេះបញ្ញត្តិស្តីពីបណ្តឹងសាទុក្ខ និងនីតិវិធីទាក់ទងនឹងការជំនុំជម្រះបណ្តឹងសាទុក្ខទាំងនោះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងជំទាស់លើដីកាសម្រេចដែលសាលាឧទ្ធរណ៍បានចេញក្នុងនាមតុលាការនៃការជំនុំជម្រះលើកទី១ និងនីតិវិធីដែលទាក់ទងនឹងបណ្តឹងជំទាស់នោះ។[204] ហេតុដូច្នេះបណ្តឹងជំទាស់នេះអាចធ្វើទៅបាន ដោយយកមូលហេតុនៃភាពផ្ទុយច្បាប់ឬបទដ្ឋានគតិយុត្តិដែលមានឥទ្ធិពលលើដីកាសម្រេចដើមតែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀតមានករណីខ្លះដែលសាលាឧទ្ធរណ៍ចេញដីកាសម្រេច ក្នុងនាមជាតុលាការនៃកាជំនុំជម្រះបណ្តឹងឧទ្ធរណ៍។ ក្នុងករណីនេះភាពអាច ឬមិនអាចប្តឹងជំទាស់ចំពោះដីកាសម្រេចដែលសាលាឧទ្ធរណ៍ចេញក្នុងនាមជាតុលាការនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍។[205] ដូច្នេះលើកលែងតែករណីដែលមានបញ្ញត្តិច្បាប់អនុញ្ញាត ប្តឹងជំទាស់ ភាគីមិនអាចប្តឹងជំទាស់ចំពោះដីកាសម្រេចរបស់សាលាឧទ្ធរណ៍បានឡើយ។ ក្នុងករណីដែលសាលាឧទ្ធរណ៍ចេញដីការសម្រេចជាដំបូងក្នុងនាមជាតុលាការនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ប្រសិនបើបណ្តឹងជំទាស់ចំពោះដីកាសម្រេចត្រូវបានធ្វើឡើងផ្អែកលើបញ្ញត្តិនៃគន្ថីទី១ ដែលអាចអនុវត្តដោយផ្ទាល់ចំពោះបណ្តឹងឧទ្ធណ៍ ភាគីអាចប្តឹងជំទាស់បាន។ ឧទាហរណ៍ៈ ចំពោះដីកាសម្រេចដែលសម្រេចថាការដកហូត ឬបណ្តឹងដឹតចិត្តចៅក្រមនៃសាលាឧទ្ធរណ៍មិនត្រឹមត្រូវ អាចប្តឹងជំទាស់បាន។[206] ផ្ទុយមកវិញចំពោះដីកាសម្រេចបង្គាប់ ផ្តល់ឯកសារដែលសាលាឧទ្ធរណ៍បានចេញ ក្នុងនាមជាតុលាការនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ មិនអាចប្តឹងជំទាស់បានឡើយដោយសារបញ្ញត្តិនៃកថាខណ្ឌទី៣ មាត្រា ១៥២ មិនត្រូវអនុវត្តដោយផ្ទាល់ចំពោះបណ្តឹងឧទ្ធរណ៍មិនអាចប្តឹងជំទាស់បានឡើងដោយសារបញ្ញត្តិនៃកថាខណ្ឌទី៣ មាត្រា ១៥២ មិនត្រូវអនុវត្តដោយផ្ទាល់ចំពោះបណ្តឹងឧទ្ធរណ៍ទេ ហើយត្រូវអនុវត្តដូចគ្នាផងដែរ ក្នុងនាមជាបញ្ញត្តិដែលទាក់ទងនឹង គន្ថីទី២ ស្តីពីនីតិវិធីនៃការជម្រះលើកទី១ ដោយយោងតាមដូច

[204] មាត្រា ៣០៤ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៦

[205] មាត្រា ២៥៩ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៦

[206] មាត្រា ៣០ កថាខណ្ឌទី៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

គ្នាផងដែរ ក្នុងនាមជាបញ្ញត្តិដែលទាក់ទងនឹង គន្លឹទី២ ស្តីពីនីតិវិធិនៃការជម្រះលើកទី១ ដោយយោងតាមបញ្ញត្តិនៃមាត្រា២៧២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**ខ.វិសាលភាពនៃការជំនុំជម្រះបណ្តឹងជំទាស់ចំពោះដីកាសម្រេចរបស់ចៅក្រមដែលទទួលការបញ្ជា ឬ ប្រគល់សិទ្ធិ**

ចំពោះដីកាសម្រេចរបស់ចៅក្រមទទួលបញ្ជាឬចៅក្រមទទួលបន្ទុកនេះគឺខុសគ្នា នឹងដីកាសម្រេចរបស់តុលាការ ដោយនៅទីនេះគេតម្រូវ មានការគ្រប់គ្រងពិនិត្យដោយតុលាការដែលទទួលបណ្តឹង។ ហេតុនេះបើ ភាគីមានការតវ៉ា តុលាការដែលទទួលបណ្តឹងត្រូវសម្រេចសេចក្តីដោយដីកាសម្រេច។ ចំពោះដីកាសម្រេចរបស់ចៅក្រមទទួលបញ្ជា ឬចៅក្រមទទួលបន្ទុកដែលត្រូវបានជ្រើសរើសតាំងចំពោះរឿងក្តីដែលសាលាឧទ្ធរណ៍ ឬតុលាការកំពូលកំពុងចាត់ការវិញក៏ដូចគ្នានឹងករណីដែលសាលាដំបូងជាតុលាការទទួលបណ្តឹងដែលភាគីអាចដាក់ពាក្យសុំប្តឹងតវ៉ាទៅសាលាឧទ្ធរណ៍ឬតុលាការកំពូលដែលតុលាការទទួលបណ្តឹង។ ចំពោះការស្នើសុំប្តឹងតវ៉ាដែលមានចែងក្នុងមាត្រា៣០២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រសិនបើដីកាសម្រេចនោះត្រូវបានធ្វើឡើងដោយតុលាការទទួលបណ្តឹងនោះភាគីត្រូវធ្វើបណ្តឹងជំទាស់ ហេតុនេះភាគីត្រូវធ្វើបណ្តឹងតវ៉ានៅក្នុងអំឡុងពេល ១សប្តាហ៍ ក្រោយថ្ងៃទទួលដំណឹងអំពីដីកាសម្រេច។[207] ប្រសិនបើតុលាការទទួលបណ្តឹងឧទ្ធរណ៍ ចំពោះករណីនៃកថាខណ្ឌទី២ នៃមាត្រា ៣០៤ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍ឬបណ្តឹងសាទុក្ខ)អាចប្តឹងជំទាស់ចំពោះដីកាសម្រេចលើពាក្យសុំដែលមានចែងក្នុងកថាខណ្ឌទី១ មាត្រា ៣០២ បានតែប្រសិនបើតុលាការទទួលពាក្យបណ្តឹងជាតុលាកាកំពូលវិញ មិនអាចប្តឹងជំទាស់បានឡើយ

[207] មាត្រា ៣០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការបកស្រាយខាងលើរួចមក យើងឃើញថា បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ចំពោះរឿងក្តីរដ្ឋប្បវេណី គឺជាបណ្តឹងមួយដែលភាគីមិនសុខចិត្តនឹងសាលក្រម ឬសាលដីកា ឬដីកាសម្រេចរបស់តុលាការជាន់ដំបូង និងសាលាឧទ្ធរណ៍ ហើយភាគីបានធ្វើការប្តឹងតវ៉ាទៅតុលាការជាន់ខ្ពស់។ ដូច្នេះ បណ្តឹងឧបាស្រ័យមានបីប្រភេទ គឺបណ្តឹងឧទ្ធរណ៍ បណ្តឹងសាទុក្ខ និងបណ្តឹងជំទាស់។ បណ្តឹងឧបាស្រ័យនេះផងដែរ គឺអាចប្តឹងបានតែចំពោះ សាលក្រមឬសាលដីកាឬដីកាសម្រេចដែលមិនទាន់ចូលស្ថាពរប៉ុណ្ណោះ។ ប្រសិនបើសាលក្រម ឬសាលដីកា ឬដីកាសម្រេចបានចូលជាស្ថាពរហើយនោះ ភាគីមិនអាចប្តឹងឧបាស្រ័យបាននោះទេ ប៉ុន្តែ ភាគីអាចធ្វើប្តឹងតវ៉ាចំពោះប្រភេទបណ្តឹងផ្សេងបានផងដែរ ពោលគឺបណ្តឹងទាមទារជំនុំជម្រះសាជាថ្មីបាន។ បណ្តឹងឧបាស្រ័យផ្តល់សិទ្ធិ ភាគី ក្នុងការស្វែងរកយុត្តិធម៌តាមរយៈតុលាការជាន់ខ្ពស់ ចំពោះភាគីដែលមិនពេញចិត្ត សាលក្រមឬសាលដីកា របស់តុលាការដើម។ ភាគីអាចប្តឹងបន្តទៅតុលាការជាន់ខ្ពស់ដើម្បី តុលាការជាន់ខ្ពស់រើកញ៉ែករកយុត្តធម៌ជូនភាគីដែលខាតប្រយោជន៍ ដែលបណ្តាលពីសាលក្រម ឬសាលដីការបស់តុលាការដើម។

ចំពោះបណ្តឹងឧទ្ធរណ៍ ភាគីអាចដាក់ពាក្យបណ្តឹងឧទ្ធរណ៍ទៅតុលាការដើមបាន ទៅតាមអំឡុងពេលដែលច្បាប់បានកំណត់ព្រមទាំងបង់ពន្ធជូនតុលាការ។ បន្ទាប់មកតុលាការ និងទទួលពាក្យបណ្តឹងនោះ ប្រសិន បណ្តឹងភាគីបានបំពេញតាមទម្រង់ដែលច្បាប់បានកំណត់។ តុលាការដើមនឹងបញ្ជូនពាក្យបណ្តឹងនោះទៅសាលាឧទ្ធរណ៍ បានឆាប់រហ័ស ដើម្បី សាលាឧទ្ធរណ៍ពិនិត្យលើបណ្តឹងឧទ្ធរណ៍នោះ រួចតុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ និងបញ្ជូនពាក្យបណ្តឹងនោះទៅចុងបណ្តឹងឧទ្ធរណ៍។ តុលាការនៃបណ្តឹងឧទ្ធរណ៍បើកសវនាការជំនុំ និងសាលដីកាជូនភាគី។

ចំពោះបណ្តឹងសាទុក្ខចំពោះលំហូរនីតិវីធីនៃការជំនុំជម្រះក៏មិនខុសអីពីបណ្តឹងឧទ្ធរណ៍នោះទេ ព្រោះច្បាប់បានកំណត់ថា លំហូរនីតិវិធីនៃការជំនុំជម្រះលើបណ្តឹងសាទុក្ខ ត្រូវអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍ផងដែរ។ ចំណែកឯ បណ្តឹងជំទាស់ ជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលឯករាជ្យ និងសង្ខេបដែលអាចធ្វើឡើងចំពោះដីកាសម្រេច។ ចំពោះលំហូរនីតិវិធីនៃការជំនុំជម្រះលើបណ្តឹងជំទាស់វិញនោះ ច្បាប់បានបញ្ញត្តិ អនុវត្តដូចគ្នាទៅនឹងបណ្តឹងឧទ្ធរណ៍ និងបណ្តឹងសាទុក្ខ ដែរ។

យោងតាមការសិក្សាស្រាវជ្រាវច្រើនខែ កន្លងមកខ្ញុំយល់ឃើញថា បណ្តឹងឧបាស្រ័យមានចំណុចល្អជាច្រើន ដែលផ្តល់សារៈប្រយោជន៍ ដល់ភាគីដែលមិនសុខជាមួយនឹង សាលក្រម ឬសាលដីកា ដែលទទួលបាននូវភាពលំអៀងពីតុលាការដើម ឬមានការភាន់ច្រឡំក្នុងការអនុវត្តច្បាប់នៅដំណាក់កាលនីតិវិធីជំនុំជម្រះនូវតុលាការដើម។ ជាងនេះទៅទៀត គឺបានទប់ស្កាត់នូវការចេញសាលក្រម ឬសាលដីការបស់តុលាការដើម

ដែលជួយសម្រួល ដល់ការស្វែងរកយុត្តិធម៌ជូនភាគីដែលបានបាត់បង់ផលប្រយោជន៍ មានភាពយុត្តធម៌តាមកាជំនុំជម្រះរបស់តុលាការជាន់ខ្ពស់ ដោយផ្តល់សិទ្ធិ ភាគីដែលខាតប្រយោជន៍ពិតប្រាកដ ទទួលបានការឈ្នះក្តីនៅតុលាការជាន់ខ្ពស់។

សរុបសេចក្តីមក បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ចំពោះរឿងក្តីរដ្ឋប្បវេណី ពិតជាបានផ្តល់សារៈប្រយោជន៍ចំពោះភាគី ដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់តុលាការដើម។ ដូច្នេះ ភាគីអាចទទួលបានយុត្តិធម៌បានរយៈការជំនុំជម្រះរឿងក្តីនៅតុលាការជាន់ខ្ពស់ ដោយតុលាការជាន់ខ្ពស់ច្រានចោលសាលក្រមដើមឬសាលដីកាដើម ហើយចេញសាលដីកាសម្រេច ភាគីដែលបាន បាត់បង់ផលប្រយោជន៍ទទួលបានយុត្តិធម៌ត្រឹមត្រូវតាមច្បាប់។ ក្នុងនាមជានិស្សិត ដែលបានស្រាវជ្រាវលើប្រធានបទ ខាងលើខ្ញុំពិតជាមានសេចក្តីរីករាយយ៉ាងខ្លាំង ដែលព្រះរាជាណាចក្រកម្ពុជាបានបង្កើត តុលាការជាន់ខ្ពស់ ដែលជាស្នាមញញឹមរបស់ប្រជាពលរដ្ឋគ្រប់រូប ក្នុងការដោះស្រាយបញ្ហានាពេលមានវិវាទណាមួយកើតឡើង ជាពិសេសបាន ផ្តល់ ប្រជាពលរដ្ឋដែលមិន ពេញចិត្តនូវសាលក្រមដើម មានសិទ្ធិក្នុងការធ្វើឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដើម្បីស្វែងរកភាពយុត្តិធម៌។ លើសពីនេះ ថ្នាក់ដឹងនាំក្រសួងយុត្តិធម៌បានយកចិត្តទុកដាក់លើការធ្វើកំណែទម្រង់ច្បាប់ និង មានយន្តការជាច្រើនក្នុងការដោះស្រាយជូនប្រជាពលរដ្ឋ។ ដូចពាក្យស្លោក របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានពោលថា លឿន រហ័ស យុត្តិធម៌ មិនពុករលួយ ។

# អនុសាសន៍

# អនុសាសន៍

យោងតាមការសិក្សាស្រាវជ្រាវរួចមក ប្រធានបទខាងលើបានបង្ហាញ ឃើញថាវាមានទាំងចំណុចវិជ្ជមាន និងចំណុចអវិជ្ជមាន។

ចំពោះចំណុចវិជ្ជមាន យើងឃើញថា ពិតជាល្អមែនទែនដែលប្រព័ន្ធច្បាប់របស់កម្ពុជាបានទុកសិទ្ធិសម្រាប់ភាគី ប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ចំពោះសាលក្រម សាលដីកា ឬដីកាសម្រេចដែលមិនទាន់ចូលជាស្ថាពរ។ ភាគីអាចប្តឹងឧបាស្រ័យដល់ទៅ ២ ថ្នាក់ គឺសាលាឧទ្ធរណ៍ និងតុលាការកំពូល។ រីតែតែពិសេសជាងនេះទៅទៀតនោះ ការប្តឹងឧបាស្រ័យ ក្នុងករណីខ្លះតុលាការជាន់ខ្ពស់បានបញ្ជូនសំណុំរឿងដែលប្តឹងឧទ្ធរណ៍នោះ ទៅតុលាការដើមវិញ ក្នុងករណីដែលចាំបាច់ក្នុងការទាញហេតុផលបន្ថែមទៀត។ ការធ្វើបែបជាការដាស់តឿនដ៏សំខាន់មួយចំពោះសាលាដំបូង មានការជំនុំជម្រះដោយយកចិត្តទុកដាក់ទ្វេឡើង ជៀសវាងការជំនុំជម្រះ ហើយតែពីរដៃ។ កាន់តែពិសេសនោះគឺចៅក្រមដែលជាអ្នកកាត់សេចក្តីតំណាង ស្ថាប័នតុលាការប្រកាន់ខ្ជាប់នូវ អភិក្រមទាំង៥ របស់សម្តេចតេជោនាយករដ្ឋមន្ត្រី គឺ ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់។ បន្ថែមលើសពីនេះទៅទៀតត្រូវប្រកាន់ខ្ជប់នូវគុណធម៌ប្រកបដោយ វីរយសម្បយុត្ត សុចរិតយុត្តិធម៌ បញ្ញត្តិគារវោ សមទណ្ឌោ និងបញ្ញាវុឌវិនិឆ្ឆ័យ ប៉ុន្តែត្រូវជៀស ឆ្ងាយពី ឆន្ទាគតិ ទោសាគតិ មោហោគតិ និងភយាគតិ។

រីឯចំណុចអវិជ្ជមានវិញនោះ គឺ គួរណាស់តែបង្កើត មានបន្ថែមទៀតចំពោះសាលាជម្រះក្តីជាន់ខ្ពស់គឺសាលាឧទ្ធរណ៍នៅតាមបណ្តាតំបន់ទាំងអស់នៅប្រទេសកម្ពុជា ដើម្បីបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការធ្វើឧបាស្រ័យទៅតុលាការជាន់ខ្ពស់ កាត់បន្ថយការចំណាយ និងពេលវេលាក្នុងការស្វែងរកយុត្តិធម៌។ ព្រោះថាសព្វថ្ងៃនេះសាលាឧទ្ធរណ៍គឺមានតែសាលាឧទ្ធរណ៍ភ្នំពេញ និងតំបន់ចំនួន ៣ តំបន់តែប៉ុណ្ណោះ ដូច្នេះភាគីណាមួយមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់សាលាជម្រះក្តីជាន់ទាបនោះគឺមានលក្ខណៈពិបាកក្នុងការប្តឹងមកសាលាឧទ្ធរណ៍ ជាពិសេសប្រជាជនក្រីក្រនៅតាមតំបន់ដាច់ស្រយាល។ ដូចនេះដើម្បីសម្រួលដល់ប្រជាជន និងសម្រួលដល់ការងារតុលាការកុំ មានភាពរាំងស្ទះក្នុងដំណើរការនីតិវិធីមានការយឺតយ៉ាវ និងដើម្បីចេញសេចក្តីសម្រេច បានឆាប់រហ័សជូនប្រជាជន។ លើសពីនេះទៅទៀតប្រព័ន្ធតុលាការក៏គួរតែខិតខំធ្វើយ៉ាងណាបង្កើត មានចៅក្រមដែលទទួលបន្ទុកជំនុំជម្រះលើរឿងតែមួយជំនាញបានហើយ ដូចជាចៅក្រមផ្នែករដ្ឋប្បវេណី ផ្នែកព្រហ្មទណ្ឌ ផ្នែកពាណិជ្ជកម្ម និងផ្នែកការងារផ្សេងគ្នា មិនគួរអោយចៅក្រមតែម្នាក់ធ្វើការវិនិច្ឆ័យគ្រប់ជំនាញបានឡើយ ដែលនាំ មានការសម្រេចសេចក្តីពុំសូវទទួលបាននូវលទ្ធផលល្អ។ ចំណែកឯពន្ធដាក់ពាក្យសុំវិញ ចំពោះការប្តឹងឧបាស្រ័យច្បាប់មិនគួរដំឡើងពន្ធ លើសពីពន្ធដាក់ពាក្យសុំនៅសាលាដំបូងឡើង ព្រោះតុលាការនៃបណ្តឹងឧទ្ធរណ៍មានតែ ៤ និងតុលាការកំពូលមានតែមួយ ធ្វើ ភាគី

ចំណាយប្រាក់ក្នុងការធ្វើដំណើរ ការហូបចុក និងស្នាក់នៅអស់ជាច្រើនរួចស្រេចទៅហើយ។ ចំពោះពន្ធដាក់ពាក្យសុំប្តឹងទៅសាលាឧទ្ធរណ៍ គឺលើសពីពន្ធដាក់ពាក្យសុំប្តឹងទៅសាលាដំបូង ១,៥ ដង និងចំពោះតុលាការកំពូលវិញ ២ដងនៃពន្ធដាក់ពាក្យសុំនៅសាលាដំបូង។ មួយវិញទៀតចំពោះ សាលក្រមដែលភ្ជាប់ជាមួយនឹងការអនុវត្តជាបណ្តោះអាសន្ន ច្បាប់មិនគួរអនុញ្ញាតអោយអនុវត្តមុនពេលដែល ភាគីប្តឹងឧបាស្រ័យនោះទេ ព្រោះកាលណាភាគីដែលបានការអនុញ្ញាតអនុវត្តជាបណ្តោះអាសន្ន ក្នុងករណីភាគីនោះធ្វើ សំណុំរឿងកាន់តែពិបាក ស្មុគស្មាញជាងមុន និងធ្វើ ប៉ះពាល់ផលប្រយោជន៍ដល់តតិយជនជាដើម។

# ឯកសារយោង

## ១.លិខិតបទដ្ឋានគតិយុត្ត

១.១ រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣

១.២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

១.៣. ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

១.៤. ច្បាប់ស្តីពីនីតិវីធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

១.៥ ច្បាប់ស្តីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

## ២.សៀវភៅ និង ស្នាដៃអ្នកនិពន្ធ

២.១សេចក្តីកំណត់ក្រមនីតិវិធីរដ្ឋប្បវេណីភាគ១  ដល់ ភាគ៦

២.២. បណ្តឹងឧទ្ធរណ៍របស់ លោកមេធាវី អ៊ីវ ប៉ូលី

២.៣ សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ នីតិវិធីនៃបណ្តឹង

៣.៤ បណ្តឹងសាទុក្ខក្នុងបណ្តឹងរដ្ឋប្បវេណី UCHIYAMA JUN

៣.៤ វចនានុក្រមច្បាប់តាមបទដ្ឋានគតិយុត្តខ្មែរ ឆ្នាំ២០១៨ របស់ សមាគមស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ខ្មែរ

៣.៥ ការវិភាគក្រមនីតិវិធីរដ្ឋប្បវេណីក្នុងនីតិវិធីបណ្តឹង បង្រៀនដោយ ឯកឧត្តម យឹម សារី

៣.៦ បញ្ហានានាដែលមាននៅក្នុងរឿងក្តីរដ្ឋប្បវេណី របស់ក្រសួងយុត្តិធម៌ វិទ្យាស្ថានស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

៣.៧ នីតិវិធីរដ្ឋប្បវេណីសង្ខេបសម្រាប់អនុវត្តរឿងក្តីរដ្ឋប្បវេណី របស់សាស្ត្រាចារ្យ គី ប៊ុនទ្រាន

៣.៨  នីតិវិធីនៃការជំនុំជម្រះនៅតុលាការជាន់ខ្ពស់ របស់ឯកឧត្តម គង់ ស្រ៊ីម

# ឧបសម្ព័ន្ធ

## បញ្ជីឧបសម្ព័ន្ធ

### ឧបសម្ព័ន្ធទី១៖ គំរូពាក្យបណ្ដឹង

- ពាក្យបណ្ដឹងសាទុក្ខ
- ពាក្យបណ្ដឹងឧទ្ធរណ៍
- ពាក្យបណ្ដឹងសាទុក្ខ
- ពាក្យបណ្ដឹងជំទាស់
- ពាក្យសុំអនុវត្តដោយបណ្ដោះអាសន្ន
- ពាក្យសុំដកពាក្យបណ្ដឹង
- លិខិតបញ្ជាក់អំពីមូលហេតុនៃការដកពាក្យបណ្ដឹង

### ឧបសម្ព័ន្ធទី២៖ គំរូសាលក្រម និងសាលដីកា

### ឧបសម្ព័ន្ធទី៣៖ គន្លឹ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

# ឧបសម្ព័ន្ធទី១

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យបណ្តឹង**
**សូមគោរពជូន**
**ឯកឧត្តមប្រធានសាលាដំបូងរាជធានី/ខេត្ត**.................

- **ដើមចោទ** ៖ ឈ្មោះ........................ភេទ........អាយុ............ជនជាតិ..........សញ្ជាតិ................
កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ............................ដែលមានអាសយដ្ឋាន
បច្ចុប្បន្ននៅផ្ទះលេខ........ផ្លូវលេខ.........ចំណុច........ភូមិ/មណ្ឌល........................ឃុំ/
សង្កាត់.....................ស្រុក/ខណ្ឌ....................ខេត្ត/រាជធានី.......................មុខរបរ
........................ទូរស័ព្ទលេខ................................................។
- **អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ** ៖ លោកមេធាវី...............................ការិយាល័យស្ថិត
នៅ.......ផ្លូវលេខ................ ភូមិ/មណ្ឌល.........................ឃុំ/សង្កាត់.................ស្រុក/
ខណ្ឌ.................ខេត្ត/រាជធានី...........................។
- **ចុងចម្លើយ** ៖ ឈ្មោះ........................ភេទ........អាយុ............ជនជាតិ..........សញ្ជាតិ................
កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ............................ដែលមានអាសយដ្ឋាន
បច្ចុប្បន្ននៅផ្ទះលេខ........ផ្លូវលេខ.........ចំណុច........ភូមិ/មណ្ឌល........................ឃុំ/
សង្កាត់.....................ស្រុក/ខណ្ឌ....................ខេត្ត/រាជធានី.......................មុខរបរ
........................ទូរស័ព្ទលេខ................................................។
- **អ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយ** ៖ លោកមេធាវី...............................ការិយាល័យស្ថិត
នៅ.......ផ្លូវលេខ................ ភូមិ/មណ្ឌល.........................ឃុំ/សង្កាត់.................ស្រុក/
ខណ្ឌ.................ខេត្ត/រាជធានី...........................។
- **ពន្ធដាក់ពាក្យសុំ** ៖ ចំនួន...........................................ជាអក្សរ....................................................។

**I. សាលក្រមសុំចេញដោយដើមចោទ**

១/.......................................................................................................................................។
២/.......................................................................................................................................។
៣/.......................................................................................................................................។
៤/.......................................................................................................................................។

**II. អង្គហេតុចាំបាច់បញ្ជាក់នូវការទាមទារ**

.........................................................................................................................................
.........................................................................................................................................
.........................................................................................................................................។

**III. អង្គហេតុដែលជាមូលហេតុនៃការទាមទារ និងអង្គហេតុសំខាន់ៗដែលពាក់ព័ន្ធ**

.........................................................................................................................

.........................................................................................................................

.........................................................................................................................។

IV. **ភស្តុតាងសុំជូនពិនិត្យបឋម**

១/.......................................................................................................................។

២/.......................................................................................................................។

៣/.......................................................................................................................។

៤/.......................................................................................................................។

អាស្រ័យហេតុដូចដែលបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវពាក្យបណ្ដឹង និងចាត់ការតាមនីតិវិធីច្បាប់ ដោយសម្រេចតាមការទាមទារពីខាងលើ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។

រាជធានី/ខេត្ត................ថ្ងៃទី........ខែ.........ឆ្នាំ..........

**សូមភ្ជាប់មកជាមួយ :** **ស្នាមមេដៃស្តាំអ្នកប្តឹង**

**១....................**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**<u>ពាក្យបណ្តឹងឧទ្ធរណ៍</u>**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ............................ភេទ.............អាយុ..............ជនជាតិ..................... មានអាសយដ្ឋានផ្ទះលេខ..........ផ្លូវ........ភូមិ/មណ្ឌល..............ឃុំ/សង្កាត់...............ស្រុក/ខណ្ឌ......... រាជធានី/ខេត្ត......................................។

**សូមគោរពចូលមក**

**ឯកឧត្តមប្រធានសាលាដំបូងរាជធានី/ខេត្ត**.....................

**កម្មវត្ថុ៖** សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមលេខ................ចុះថ្ងៃទី........ខែ.........ឆ្នាំ...........របស់សាលាដំបូង រាជធានី/ខេត្ត..................ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល/ចំណុចទី................................។

**យោង៖** -ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

-សំណុំរឿងរដ្ឋប្បវេណីលេខ.............ចុះថ្ងៃទី...........ខែ........ឆ្នាំ.............របស់សាលាដំបូងរាជធានី/ ខេត្ត.........................។

-សាលក្រមលេខ..........................ចុះថ្ងៃទី............ខែ............ឆ្នាំ.........របស់សាលាដំបូងរាជធានី/ ខេត្ត........................។

តបតាមកម្មវត្ថុ និងយោងខាងលើខ្ញុំបាទ/នាងខ្ញុំ សូមជម្រាប **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា ៖ កាលពីថ្ងៃទី.........ខែ........ឆ្នាំ........... សាលាដំបូងរាជធានី/ខេត្ត............បានចេញសាលក្រមលេខ ........................ចុះថ្ងៃទី........ខែ.........ឆ្នាំ...........។ ដោយសាលក្រមខាងលើមានភាពអយុត្តិធម៌ និង ធ្វើឲ្យបាត់បង់ផលប្រយោជន៍របស់ខ្ញុំបាទ/នាងខ្ញុំ ហេតុនេះហើយបានជាខ្ញុំបាទ/នាងខ្ញុំសុំប្តឹងឧទ្ធរណ៍នឹងសាលក្រម លេខ............ចុះថ្ងៃទី........ខែ.......ឆ្នាំ............របស់សាលាដំបូងរាជធានី/ខេត្ត...........ត្រង់ចំណុចសេចក្តី សម្រេច............អាស្រ័យហេតុដូចបានគោរពជូនខាងលើសូម លោកប្រធាន មេត្តាទទួលនិងបញ្ជូនទៅសាលា ឧទ្ធរណ៍តាមនីតិវិធីច្បាប់ដោយក្តីអនុគ្រោះ។

អាស្រ័យហេតុដូច្នេះបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាទទួល និងចុះបញ្ជីបណ្តឹង ឧទ្ធរណ៍តាមនីតិវិធីច្បាប់ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំ។

រាជធានី/ខេត្ត ថ្ងៃទី.......ទី.......ឆ្នាំ.........

**ស្នាមមេដៃស្តាំដើមបណ្តឹងឧទ្ធរណ៍**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# <u>ពាក្យបណ្តឹងសាទុក្ខ</u>

**ដើមបណ្តឹងសាទុក្ខ៖**លោក............ជនជាតិខ្មែរ........អាយុ..........និងប្រពន្ធឈ្មោះ...........................
មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ...... .ផ្លូវលេខ.........
ភូមិ/មណ្ឌល............ឃុំ/សង្កាត់..............ស្រុក/ខណ្ឌ.................រាជធានី/ខេត្ត.....................។

**ចុងបណ្តឹងសាទុក្ខ៖** លោក............ជនជាតិ............អាយុ..........មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ........ ផ្លូវលេខ.........ភូមិ/មណ្ឌល............ឃុំ/សង្កាត់..............ស្រុក/ខណ្ឌ................. រាជធានី/ខេត្ត.....................។

**សូមគោរពជូន**
**ឯកឧត្តមប្រធានសាលាឧទ្ធរណ៍ភ្នំពេញ/តំបន់**................

**កម្មវត្ថុ៖** ប្តឹងសាទុក្ខនឹងសាលក្រមដីកាលេខ..............ចុះថ្ងៃទី........ខែ........ឆ្នាំ.......របស់................។

**យោង៖** -ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា
-សំណុំរឿងរដ្ឋប្បវេណីលេខ..........ចុះថ្ងៃទី.......ខែ........ឆ្នាំ.........របស់សាលាឧទ្ធរណ៍...........។
-សាលដីកាលេខ...........ចុះថ្ងៃទី.......ខែ.......ឆ្នាំ..........របស់សាលាឧទ្ធរណ៍.......................។

តបតាមវត្ថុ និងយោងខាងលើ យើងខ្ញុំសូមគោរពជម្រាបជូន ឯកឧត្តមប្រធាន មេត្តាជ្រាបថាកាលពីថ្ងៃទី..........ខែ.........ឆ្នាំ......... សាលាឧទ្ធរណ៍បានចេញសាលដីកាលេខ..............ដែលមានខ្លឹមសារដូចក្រោម៖

-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ.........ចុះថ្ងៃទី......ខែ......ឆ្នាំ........របស់មេធាវីឈ្មោះ....................... អ្នកតំណាងដោយអាណត្តិឲ្យចុងចម្លើយឈ្មោះ......................ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

-លុបចោលសាលក្រមរដ្ឋប្បវេណីលេខ...........ចុះថ្ងៃទី.......ខែ......ឆ្នាំ........របស់សាលាក្រមដំបូង........ ចោលជាអសារបង់។

-ច្រានពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ.............ចុះថ្ងៃទី.......ខែ.......ឆ្នាំ...........ចោលជាអសារបង់។

-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

ការសម្រេចសេចក្តីខាងលើនេះ គឺពិតជាបានផ្តល់នូវភាពអយុត្តិធម៌ជាទីបំផុតដល់យើងខ្ញុំដែលជាជនរងគ្រោះដោយសារការរំលោភបំពានរបស់ភាគីចុងចម្លើយ ដែលយើងខ្ញុំពុំអាចទទួលយកបានទេ។

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាទទួលយកបណ្តឹងសាទុក្ខ និងចាត់ការតាមនីតិវិធីច្បាប់ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ។

រាជធានី/តំបន់ ថ្ងៃទី.......ខែ......ឆ្នាំ........

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យបណ្តឹងជំទាស់

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.....................អាយុ..........ជនជាតិ........សញ្ជាតិ............មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ........ផ្លូវលេខ.........ភូមិ/មណ្ឌល............ឃុំ/សង្កាត់..............ស្រុក/ខណ្ឌ.................រាជធានី/ខេត្ត.....................។

**សូមគោរពចូលមក**

**ឯកឧត្តមប្រធាន**.............................

**កម្មវត្ថុ៖**សុំប្តឹងជំទាស់លើដីកាសម្រេចលេខ.................ចុះថ្ងៃទី........ខែ........ឆ្នាំ...........របស់ ..................។

**យោង៖** មាត្រា...........នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

ដីកាសម្រេចលេខ..........ចុះថ្ងៃទី........ខែ........ឆ្នាំ...............។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមគោរពជូន ឯកឧត្តមប្រធាន អោយបានជ្រាបថា៖ កាលពីថ្ងៃទី.......ខែ.......ឆ្នាំ.........តុលាការឧទ្ធរណ៍បានចេញសេចក្តីសម្រេចលើសំណុំរឿងលេខ.................. ចុះថ្ងៃទី......ខែ.......ឆ្នាំ..........។ ការសម្រេចសេចក្តីខាងលើនេះបានធ្វើអោយប៉ះពាល់ដល់ប្រយោជន៍ខ្ញុំបាទ/នាងខ្ញុំយ៉ាងធ្ងន់ធ្ងរ និងផ្តល់នូវភាពអយុត្តិធម៌ដល់រូបខ្ញុំបាទ/នាងខ្ញុំដែលជាជនរងគ្រោះ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើនេះ ខ្ញុំបាទ/នាងខ្ញុំស្នើសុំ **ឯកឧត្តមប្រធាន** មេត្តាទទួលនិងចាត់ការតាមនីតិវិធីច្បាប់។

សូម ឯកឧត្តមប្រធាន មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី......ខែ.......ឆ្នាំ..........

**ស្នាមមេដៃស្តាំ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំអនុវត្តដោយបណ្ដោះអាសន្ន

ម្ចាស់បំណុលអនុវត្ត៖ ឈ្មោះ.......................តំណាងស្របច្បាប់ដោយលោក................................តួនាទី ................អាស័យដ្ឋាននៅ....................។

កូនបំណុលអនុវត្ត៖ ឈ្មោះ..........ភេទ...............កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេ....................... អាស័យដ្ឋាននៅ...............ភូមិ............................។

**សូមគោរពចូលមក**

**ឯកឧត្តមប្រធាន**...............................................

**កម្មវត្ថុ** សុំអនុវត្តបណ្ដោះអាសន្ន ត្រង់សេចក្ដីសម្រេចបញ្ចប់ ចំណុចទី.........នៃសាលក្រមរដ្ឋប្បវេណី លេខ........ចុះថ្ងៃទី.........ខែ.......ឆ្នាំ ២០........របស់ ......................លើអចលនវត្ថុដែលជា .......................មានផ្ទៃក្រឡា..................ម៉ែត្រការេ៉ ជាទីលំនៅដ្ឋាន មានទីតាំងស្ថិតនៅ ...............................ដើម្បីលក់ឡាយឡុងសងបំណុលមកឲ្យ.......................

យោង -សាលក្រមរដ្ឋប្បវេណីលេខ.....ចុះថ្ងៃទី.........ខែ.........ឆ្នាំ២០..............របស់សាលាដំបូង ខេត្ត/ក្រុង......................

-រូបមន្តអនុវត្តសាលក្រមលេខ..........ចុះថ្ងៃទី.......ខែ..........ឆ្នាំ ២០...................។

-វិញ្ញាបនប័ត្រសំគាល់ម្ចាស់ អចលនវត្ថុលេខ ចុះថ្ងៃទី.........ខែ.........ឆ្នាំ២០...........។

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមគោរពជូន **ឯកឧត្តមប្រធាន** មេត្តាជាបថា៖ កាលថ្ងៃទី.............ខែ...............ឆ្នាំ ..............របស់..........បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ លើសំណុំរឿងរដ្ឋប្បវេណីលេខ.........ចុះថ្ងៃទី............ខែ.................ឆ្នាំ២០.....ដោយបានសេចក្ដីសម្រេចតាម សាលក្រមរដ្ឋប្បវេណីលេខ.............ចុះថ្ងៃទី.......ខែ........ឆ្នាំ២០.........របស់........................ត្រង់ចំណុចទី .....នៃវិនិច្ឆ័យសេចក្ដីសម្រេចបញ្ចប់ដែលមានខ្លឹមសារថា៖ សាលក្រមនេះមានអនុភាពអនុវត្តជាបណ្ដោះអាសន្ន បានត្រង់វិនិច្ឆ័យទី........មានខ្លឹមសារាថា៖ បង្គាប់ឲ្យចុងចម្លើយឈ្មោះ.........................សងប្រាក់ដើមចំនួន .................ឲ្យដើមចោទ.................។

ដើម្បីការពារផលប្រយោជន៍របស់ម្ចាស់បំណុលអនុវត្ត ស្របតាមខ្លឹមសារ នៃសាលក្រមរដ្ឋប្បវេណីលេខ ...... ចុះថ្ងៃទី.........ខែ.........ឆ្នាំ............ខ្ញុំបាទ/នាងខ្ញុំស្នើសុំអនុវត្តជាបណ្ដោះអាសន្ននូវចំណុចខាងលើ ដើម្បី លក់ឡាយឡុងសងបំណុលមកម្ចាស់បំណុលអនុវត្ត ។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តមប្រធាន មេត្តាសម្រេចតាមសំណូមពររបស់ខ្ញុំបាទ/ នាងខ្ញុំ ដូចបាន បញ្ជាក់ក្នុងកម្មវត្ថុខាងលើដោយក្ដីអនុគ្រោះ ។

សូម ឯឧត្តមប្រធាន ទទួលកាគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី.....ខែ ........ឆ្នាំ............

**ស្នាមមេដៃស្ដាំ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំដកពាក្យបណ្ដឹង

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.......................មានអាសយដ្ឋានផ្ទះលេខ...................ផ្លូវលេខ................ ភូមិ............ឃុំ/សង្កាត់.......................។

**សូមគោរពជូន**

**ឯកឧត្តមប្រធាន**...........................

**កម្មវត្ថុ៖** សំណើសុំដកពាក្យបណ្ដឹងរដ្ឋប្បវេណីលេខ...........ចុះថ្ងៃទី........ខែ...........ឆ្នាំ២០...........។

**យោង៖** សំណុំរឿងរដ្ឋប្បវេណីលេខ........ចុះថ្ងៃទី.........ខែ.........ឆ្នាំ..............។

តបតាមកម្មវត្ថុ និងយោងខាងលើ សូម ឯកឧត្តមប្រធាន ជ្រាបថា៖ កាលពីថ្ងៃទី.......ខែ........ឆ្នាំ.......... បានដាក់ពាក្យប្ដឹង ឈ្មោះ..............ភេទ........អាយុ..........ឆ្នាំ........... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ...........មានទីលំនៅបច្ចុប្បន្ននៅភូមិ.........ឃុំ/សង្កាត់...........ស្រុក/ខណ្ឌ.............ខេត្ត/ក្រុង.............។ បន្ទាប់ពីតុលាការចេញដីកាកោះក្នុងនីតិវិធីត្រៀម កូនបំណុលក៏យល់ព្រមសង្រោះកាតព្វកិច្ចតាមកិច្ចសន្យាខ្ចីបរិភោគឡើងវិញបន្ទាប់ពីបានពីឯកភាពគ្នាទាំងស្រុង ហេតុដូច្នេះទើបខ្ញុំបាទ/នាងខ្ញុំ សម្រេចចិត្តសុំដកពាក្យបណ្ដឹងដើម្បីបញ្ចប់នីតិវិធី។

អាស្រ័យដូចបានជម្រាបជូនខាងលើសូម **ឯកឧត្តមប្រធាន** មេត្តាសម្រេចតាមសំណូមពររបស់ខ្ញុំបាទ/នាង ដូចមានក្នុងកម្មវត្ថុខាងលើ ដោយក្ដីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី.......ខែ.......ឆ្នាំ.........

**ស្នាមមេដៃស្ដាំ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹង...

ខ្ញុំបាទ/នាងខ្ញុំមេធាវី............ជាមេធាវីតំណាងដោយអាណត្តឲ្យឈ្មោះ...........អាយុ..................ឆ្នាំ ជនជាតិខ្មែរ មុខរបរ......មានទីលំនៅបច្ចុប្បន្នភូមិ...................................................................... ក្នុងករណី សុំទាមទារដី-ផ្លាកទីន និង ម៉ូតូ មានសំណុំរឿងរដ្ឋប្បវេណីលេខ................ចុះថ្ងៃទី...........ខែ....... ឆ្នាំ...............របស់....................។

**សូមគោរពចូលមក**

**ឯកឧត្តមប្រធាន**...............................................

**កម្មវត្ថុះ** សុំធ្វើលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹង..............ដើម្បីការពារផលប្រយោជន៍របស់កូនក្តី ខ្ញុំបាទ/នាងខ្ញុំក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ......ចុះថ្ងៃ.........ខែ..........ឆ្នាំ................របស់ .......................។

យោង -ដីកាបង្គាប់ឲ្យដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹង........ចុះថ្ងៃទី........ខែ...............ឆ្នាំ ..................របស់......................។

-សំណុំរឿងរដ្ឋប្បវេណីលេខ..................ចុះថ្ងៃទី..............ខែ...............ឆ្នាំ............របស់ ..............។

ពាក្យតំណាងដោយអាណត្តចុះថ្ងៃទី..............ខែ ................ឆ្នាំ....................។

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមជម្រាប់ជូន ឯកឧត្តមប្រធាន មេត្តាជ្រាបពីដំណើររឿងដូចខាងក្រោមះ

**១/អំពីអង្គហេតុ**..........................................................................................

..........................................................................................................

..........................................................................................................

....................។

**២/អង្គច្បាប់**...............................................................................................

..........................................................................................................

..........................................................................................................

....................។

**៣/អំពីការសម្រេចសេចក្តីរបស់តុលាការ**...................................................................

..........................................................................................................

.......................................................................................................................................

.......................................................................................................................................

...................។

**៤/សំណូមពរ**....................................................................................................................

.......................................................................................................................................

.......................................................................................................................................

.........................។

អាស្រ័យដូចបានជម្រាបខាងលើសូម ឯកឧត្តមប្រធាន មេត្តាទទួលនូវការស្នើសុំរបស់ខ្ញុំបាទ នាងខ្ញុំ ដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី.....ខែ ........ឆ្នាំ...........

**ស្នាមមេដៃស្តាំ**

# ឧបសម្ព័ន្ធទី២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**តុលាការរដ្ឋប្បវេណី**

សំណុំរឿងលេខ ........

ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៩

សាលក្រមលេខ ........

ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០១៩

# សាលក្រម[1]

# ក្នុងនាមប្រជារាស្ត្រខ្មែរ

# សាលាដំបូងរាជធានីភ្នំពេញ [2]

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅ

ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៩ [3] [4]

## ចៅក្រមជំនុំជម្រះ

លោក J ជាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

## ក្រឡាបញ្ជី

លោកស្រី C ជាក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

---

[1] ការសម្រេចសេចក្តី គឺចែកចេញជា សាលក្រម និង ដីកាសម្រេច (មាត្រា ១៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដូច្នេះ មានភាពចាំបាច់នៅក្នុងការបញ្ជាក់ឲ្យបានច្បាស់លាស់ថា អំពីប្រភេទនៃការសម្រេចសេចក្តីដាក់នៅត្រង់ចំណុចចាប់ផ្តើម។ ដោយសារតែ សាលក្រម និង ដីកាសម្រេចមានភាពខុសគ្នាចំពោះវិធីក្នុងការធ្វើឧបាស្រ័យជាអាទិ៍ ។ ជាគោលការណ៍បណ្តឹងឧបាស្រ័យចំពោះសាលក្រម គឺ បណ្តឹងឧទ្ធរណ៍ ហើយ បណ្តឹងឧបាស្រ័យចំពោះដីកាសម្រេច គឺ បណ្តឹងជំទាស់ (កថាខណ្ឌទី ១ មាត្រា ២៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[2] សាលក្រមរដ្ឋប្បវេណីត្រូវតែសរសេរអំពីចំណុចដែលចែងនៅក្នុងមាត្រា ១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[3] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៨៩ កថាខណ្ឌទី ១ ចំណុច ខ ។ សាលក្រមនឹងត្រូវកំណត់ជាស្ថាពរនូវទំនាក់ទំនងសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តិនាពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៩៤ កថាខណ្ឌទី ២) ហេតុនេះ ចាំបាច់ត្រូវសរសេរឲ្យបានច្បាស់លាស់អំពី ពេលដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។ សាលក្រមគឺជាការសម្រេចសេចក្តីរបស់តុលាការដែលត្រូវបានធ្វើឡើងដោយកំណត់ជាមុននូវទំនាក់ទំនងអង្គហេតុគិតមកដល់ត្រឹមថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។

[4] ការប្រកាសសាលក្រមត្រូវធ្វើឡើងក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា ១៨៧ នៃក្រមរដ្ឋប្បវេណី)។ ហើយការប្រកាសសាលក្រមចាំបាច់ត្រូវធ្វើឡើងដោយផ្អែកលើច្បាប់ដើមនៃមូលសាលក្រម (កថាខណ្ឌទី ១ មាត្រា ១៨៨ នៃក្រមរដ្ឋប្បវេណី) ដូច្នេះហើយ ចាំបាច់ត្រូវតែបញ្ចប់នូវការតាក់តែងច្បាប់ដើមនៃមូលសាលក្រមឲ្យបាន គិតត្រឹមពេលប្រកាសសាលក្រម។

**ដើមចោទ**

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ**

លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖ ..............................

ការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖ ................................................

លេខទូរស័ព្ទ ៖ ...........................................................................................

**ចុងចម្លើយ**

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ**

លោក/លោកស្រី ៖ B

អាសយដ្ឋានការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖ ....................

ការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖ ......................................

លេខទូរស័ព្ទ ៖ ...........................................................................................

## អង្គហេតុ និងចំណុចវិវាទ

### ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ

(១) បង្គាប់ឲ្យចុងចម្លើយប្រគល់អចលនវត្ថុដែលបានកត់ត្រាក្នុងបញ្ជីឧបសម្ព័ន្ធ[5]ឲ្យទៅដើមចោទ។

(២) បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីអចលវត្ថុដែលបានកត់ត្រាក្នុងបញ្ជីឧបសម្ព័ន្ធឲ្យទៅដើមចោទ។

(៣) ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

## ខ. ដំណើររឿងក្តី និង ចំណុចវិវាទ

### ខ.១. ការសង្ខេបអំពីរឿងក្តី

នៅក្នុងរឿងក្តីនេះ ដើមចោទបានទាមទារនូវការប្រគល់អចលនវត្ថុដែលបានកត់ត្រាក្នុងបញ្ជីឧបសម្ព័ន្ធ (តទៅហៅថា "ដី L") និង ការធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលលើអចលនវត្ថុដដែលដោយផ្អែកលើកិច្ចសន្យាលក់ទិញចុះថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៨ ពីចុងចម្លើយ។

### ខ.២. អង្គហេតុដែលគ្មានវិវាទ[6]

**ខ.២.១.** នៅថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៨ ដើមចោទបានទិញ "ដី L" ក្នុងតម្លៃ ២០០.០០០ (ពីរសែន) ដុល្លារអាមេរិកពីចុងចម្លើយ (តទៅហៅថា "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ")។

---

[5] ឧបសម្ព័ន្ធ ជាឯកសារមួយដែលបានបង្កើតដើម្បីដាក់បញ្ចូលព័ត៌មាននោះ ហើយជាផ្នែកតែមួយនៃឯកសារដើម។ ដូច្នេះហើយចំពោះអនុសារនៃសាលក្រម (កថាខណ្ឌទី ២ មាត្រា ១៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ក៏ ប្រាកដជាត្រូវតែ**ធ្វើឡើងដោយរួមបញ្ចូលទាំងឧបសម្ព័ន្ធ**ផងដែរ។ ឧបសម្ព័ន្ធ គឺជាគ្រាន់តែសរសេរដើម្បីធ្វើការសរុបនូវខ្លឹមសារមួយផ្នែកដាក់នៅក្នុងទំព័រចុងក្រោយតែប៉ុណ្ណោះ ដោយផ្អែកធ្វើការពិចារណាអំពីភាពងាយស្រួលនៃការអានខ្លឹមសារទាំងស្រុងនៃអត្ថបទ។ ប្រសិនបើនៅក្នុង លិខិតសាលក្រម មានការដកស្រង់ខ្លឹមសារទៅដាក់នៅក្នុងឧបសម្ព័ន្ធនោះមានន័យថា គេគ្រាន់តែបានយកខ្លឹមសារមួយផ្នែកដែលមានភាពចាំបាច់ត្រូវសរសេរនៅក្នុងលិខិតសាលក្រមមកសរសេរសរុបដាក់នៅក្នុងទំព័រចុងក្រោយតែប៉ុណ្ណោះ ហើយ**ខ្លឹមសារនៃលិខិតសាលក្រមក៏រួមបញ្ចូលទាំងឧបសម្ព័ន្ធ**ផងដែរ។

រីឯ ឯកសារភ្ជាប់ ជាឯកសារដែលគេបានយកមកភ្ជាប់ជាមួយឯកសារដើម ហើយឯកសារភ្ជាប់នេះមិនមែនជាផ្នែកមួយនៃឯកសារដើមឡើយ។

[6] មាត្រា ១២៣ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ចំណុចនេះនឹងត្រូវសរសេរអំពីអង្គហេតុដែលភាគីបានសារភាពនៅចំពោះមុខតុលាការ និង អង្គហេតុដែលតុលាការយល់ឃើញថា អត្ថិភាពនៃអង្គហេតុនោះមានភាពជាក់ស្តែង។

**ខ.២.២.** "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ត្រូវបានធ្វើឡើងជាលិខិតយថាភូត[7]។

**ខ.២.៣.** ដើមចោទបានព្រមព្រៀងបង់ប្រាក់កក់ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិកចំពោះការចុះ "កិច្ចសន្យានៃរឿងក្តីនេះ" ជាមួយចុងចម្លើយ ហើយបានប្រគល់ប្រាក់នេះឲ្យទៅចុងចម្លើយ។

**ខ.២.៤.** នៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៨ ចុងចម្លើយបានធ្វើសំណើផ្តល់ [8]ប្រាក់ជាក់ស្តែងចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិកនៅផ្ទះរបស់ដើមចោទ (ផ្ទះលេខ ០០ ផ្លូវលេខ ០០ សង្កាត់ទំនប់ទឹក ខណ្ឌចំការមនរាជធានីភ្នំពេញ) ហើយបានបង្ហាញឆន្ទៈថា នឹងរំលាយ "កិច្ចសន្យានៃរឿងក្តីនេះ" [9]។

## សំអាងហេតុ

### ក. ការវិនិច្ឆ័យអំពីការទាមទារ

ផ្អែកតាមអង្គហេតុដែលគូភាគីគ្មានវិវាទ តុលាការទទួលស្គាល់ថា "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ត្រូវបានចុះរវាងដើមចោទ និង ចុងចម្លើយមានសុពលភាព ប៉ុន្តែចុងចម្លើយដែលជាភាគីអ្នកលក់បានរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ដោយធ្វើសំណើផ្តល់ប្រាក់ជាក់ស្តែងចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិកដែលជាចំនួនទឹកប្រាក់ពីរដងនៃចំនួនប្រាក់កក់ដែលត្រូវបានប្រគល់នៅពេលចុះ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" (យោងមាត្រា ៥១៨ នៃក្រមរដ្ឋប្បវេណី)។

ដូច្នេះហើយ ការទាមទាររបស់ដើមចោទដែលទាមទារនូវការប្រគល់ "ដី L" និងការធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល ដោយផ្អែកតាម "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" គឺពុំមានមូលហេតុទេ (កថាខណ្ឌទី ១ មាត្រា ៤១៤ និង កថាខណ្ឌទី ១ មាត្រា ៤១១ នៃក្រមរដ្ឋប្បវេណី )។

---

[7] ក្រមរដ្ឋប្បវេណី មាត្រា ៣៣៦ កថាខណ្ឌទី ២។ អង្គហេតុដែលមានភាពចាំបាច់ដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់នូវ "កិច្ចសន្យានៃរឿងក្តីនេះ" ដែលបានបង្កើតឡើងដោយមានសុពលភាព។ (ការពន្យល់លម្អិត សូមយោងតាម Footnote នៃពាក្យបណ្តឹង។)

[8] ការពន្យល់លម្អិតអំពីពីពាក្យថា "ការធ្វើសំណើផ្តល់ជាក់ស្តែង" សូមយោងតាម Footnote នៃឯកសារចម្លើយ។

[9] មាត្រា ៥១៨ មាត្រា ៤១៤ កថាខណ្ឌទី ១ មាត្រា ៤០៩ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី ។ (ការពន្យល់លម្អិត សូមយោងតាម Footnote នៃឯកសារចម្លើយ។)

**ខ. ស្ដីពីបន្ទុកនៃប្រាក់ប្រដាប់ក្ដី**

ដោយសារតែការទាមទារទាំងអស់របស់ដើមចោទពុំមានមូលហេតុ ដូច្នេះ ប្រាក់ប្រដាប់ក្ដី គឺជាបន្ទុករបស់ដើមចោទ (មាត្រា ៦៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

## សេចក្ដីសម្រេចបញ្ចប់

១. ច្រានចោលការទាមទារទាំងអស់របស់ដើមចោទ។

២. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ ។

សាលក្រមនេះត្រូវបានប្រកាសនៅសវនការជាសាធារណៈនៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៩ ។ ក្នុងករណីដែលប្ដឹងឧទ្ធរណ៍ ត្រូវតែធ្វើឡើងនៅក្នុងរយៈពេល ០១ (មួយ) ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

ថ្ងៃអង្គារ ១១ រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃ ទី៣០ ខែ មេសា ឆ្នាំ២០១៩

**ចៅក្រម**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ ភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណី
លេខ: ៤៣៤
ចុះថ្ងៃទី០១-០៨-២០១៩
សាលដីកា
លេខ: ១៦ ក្រ VII ភស
ចុះថ្ងៃទី១០-០៣-២០២០

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ ដោយមានសមាសភាពដូចតទៅ:

**សមាសភាពក្រុមប្រឹក្សា**

| | | |
|---|---|---|
| លោក | គួ ពៅស៊ុន | ជាប្រធានក្រុមប្រឹក្សា |
| លោក | ធូ មណី | ជាចៅក្រមប្រឹក្សា |
| លោកស្រី | ចាន់ ម៉ាឌីណា | ជាចៅក្រមប្រឹក្សា |

**ក្រឡាបញ្ជីសវនាការ**

**លោក ថន រដ្ឋា**

ដើម្បីទាញហេតុផលដោយផ្ទាល់មាត់លើសំណុំរឿងរដ្ឋប្បវេណីលេខ: ៤៣៤ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍រវាង:

-ដើមចោទឈ្មោះ **សំអាន ផុស្សត្តី** ភេទស្រី អាយុ៥២ឆ្នាំ ជាតិខ្មែរ មុខរបរ មេផ្ទះ មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ៣៥០ ផ្លូវ៣០CC ភូមិជ្រៃកោង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។ (ចុងបណ្តឹងឧទ្ធរណ៍)

មានមេធាវីឈ្មោះ ជា ភារ៉ា តំណាងដោយអាណត្តិ ។

-សហចុងចម្លើយ

១-ឈ្មោះ ស្រ៊ុន ធុំ ភេទប្រុស អាយុ៧៥ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើចំការ ។

២-ឈ្មោះ ស្រ៊ុន តុប ភេទស្រី អាយុ៤៣ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ ។

មានទីលំនៅបច្ចុប្បន្នភូមិភ្នំធំខាងត្បូង ឃុំអូរប្រាសាទ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ។ (ដើមបណ្តឹងឧទ្ធរណ៍)

មានមេធាវីឈ្មោះ សាយ សុខហេង និងឈ្មោះ សេង សុខឃីម តំណាងដោយអាណត្តិ ។

## អង្គហេតុ នឹង ចំណុចវិវាទ

### ក-ខ្លឹមសារនៃសាលក្រមដែលទាមទារឲ្យតុលាការចេញ

១-បញ្ជាក់ទទួលស្គាល់ដីទំហំ ៣៥១០ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹងឈ្មោះ **ឃឹម សាលី** ខាងកើតទល់នឹងផ្លូវ និងខាងលិចទល់នឹងផ្លូវ ស្ថិតក្នុងភូមិភ្នំធំត្បូង ឃុំអូរប្រាសាទ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ជាកម្មសិទ្ធិរបស់ដើមចោទ ។

២-ប្រគល់ដីទំហំ ៣៥១០ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹងឈ្មោះ **យឹម សាលី** ខាងកើតទល់នឹងផ្លូវ និងខាងលិចទល់នឹងផ្លូវ ស្ថិតក្នុងភូមិភ្នំធំត្បូង ឃុំអូរប្រាសាទ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ឲ្យមកដើមចោទ ។

៣-បង្គាប់ឲ្យសហចុងចម្លើយ និងតតិយជន ចាកចេញ រុះរើណង់ និងការ្យគ្រប់ប្រភេទលើដីខាងលើនេះ ។

៤-ទាមទារការខូចខាត ការខាតបង់ពេលវេលា និងជម្ងឺចិត្តចំនួន ១០,០០០,០០០ (ដប់លាន) រៀល ។

៥-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ ។

៦-សុំអនុវត្តសាលក្រមជាបណ្ដោះអាសន្ន ។

**ខ-ដំណើររឿងក្ដី និងចំណុចវិវាទ**

តាមពាក្យបណ្ដឹង ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨ របស់ឈ្មោះ **សំអាន ផុស្សត្ថិ** បានបញ្ជាក់ថាៈ កាលពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៦ ឈ្មោះ **អ៊ុច សំអាន** ភេទប្រុស ទំហំ ៣៥១០ ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹងឈ្មោះ **យឹម សាលី** ខាងកើតទល់នឹងផ្លូវ និងខាងលិចទល់នឹងផ្លូវ ស្ថិតក្នុងភូមិភ្នំធំត្បូង ឃុំអូរប្រាសាទ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ឲ្យមកខ្លួន (**សំអាន ផុស្សត្ថិ**) ដោយមានការទទួលស្គាល់ពីអាជ្ញាធរសាធារណៈត្រឹមត្រូវតាមច្បាប់ ហើយខ្លួនបានចូលកាន់កាប់លើដីនេះ និងបានរៀបចំឯកសារដើម្បីចុះបញ្ជីជាប្រព័ន្ធ ប៉ុន្តែត្រូវបានឈ្មោះ **ស្រ៊ុន ធុំ** និងឈ្មោះ **ស្រ៊ុន តុប** ចូលកាន់កាប់រស់នៅដោយគ្មានការអនុញ្ញាត និងជំទាស់ការចុះបញ្ជីនេះ ។ ខ្លួនបានដាក់ពាក្យបណ្ដឹងទៅអាជ្ញាធរ ដើម្បីដោះស្រាយជាបន្តបន្ទាប់សំណុំរឿងនេះ ។ នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៨ ការដោះស្រាយនៅសាលាស្រុកមង្គលបូរី ដោយអាជ្ញាធរបានបញ្ជាក់ថាដីនេះជាដីរបស់ខ្លួន និងអនុញ្ញាតឲ្យខ្លួនចាក់ដី និងធ្វើរបង ដូចមានបញ្ជាក់ ក្នុងកំណត់ហេតុស្ដីពីការប្រជុំសម្របសម្រួលករណីវិវាទនៅភូមិភ្នំធំត្បូង ឃុំអូរប្រាសាទ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៨ ហើយអាជ្ញាធរថ្នាក់ស្រុកក៏បានបង្គាប់ឲ្យឈ្មោះ **ស្រ៊ុន ធុំ** និងឈ្មោះ **ស្រ៊ុន តុប** រុះរើ សំណង់ និងការ្យផ្សេងៗចេញ ។

-**បានឃើញ**ៈ សាលក្រមរដ្ឋប្បវេណីលេខៈ ០៩ (ឋ) ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅៈ

១-បញ្ជាក់ទទួលស្គាល់ដើមចោទឈ្មោះ **សំអាន ផុស្សត្ថិ** ភេទស្រី ជាម្ចាស់កម្មសិទ្ធិលើអចលនវត្ថុ (ដី) ទំហំ ៣,៥១០ (បីពាន់ប្រាំរយដប់)ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវ ខាត្បូងទល់នឹងឈ្មោះ **យឹម សាលី** ខាងកើតទល់នឹងផ្លូវ និងខាងលិចទល់នឹងផ្លូវ ស្ថិតក្នុងភូមិភ្នំធំត្បូង ឃុំអូរប្រាសាទ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ជាកម្មសិទ្ធិករ ។

២-ប្រគល់អចលនវត្ថុ(ដី)ទំហំ ៣,៥១០(បីពាន់ប្រាំរយដប់)ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវ ខាត្បូងទល់នឹងឈ្មោះ **យឹម សាលី** ខាងកើតទល់នឹងផ្លូវ និងខាងលិចទល់នឹងផ្លូវ ស្ថិតក្នុងភូមិភ្នំធំត្បូង ឃុំអូរប្រាសាទ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ឲ្យទៅដើមចោទឈ្មោះ **សំអាន ផុស្សត្ថិ** ។

៣-បង្គាប់ឲ្យសហចុងចម្លើយ និងតតិយជន ចាកចេញ រុះរើសំណង់ និងការ្យគ្រប់ប្រភេទ ពីដីរបស់ដើមចោទ ដែលមានបញ្ជាក់ក្នុងចំណុចទី១ និងទី២ នៃសេចក្ដីសម្រេចបញ្ចប់ការខាងលើនេះ ។

-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍តបរបស់មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ ជាចុងបណ្តឹងឧទ្ធរណ៍

-ក្រោយពីបានពិនិត្យភស្តុតាងត្រឹមត្រូវតាមច្បាប់ហើយ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុថាៈ

១-បណ្តឹងឧទ្ធរណ៍លេខៈ ១៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សហចុងចម្លើយឈ្មោះ **ស្រ៊ុន ធុំ** និងឈ្មោះ **ស្រ៊ុន តុប** សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមរដ្ឋប្បវេណីលេខៈ ០៩ (ឋ) ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ សភារដ្ឋប្បវេណីសាលាឧទ្ធរណ៍ទទួលសំណុំរឿងនេះ ធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់បាន យោងតាមមាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២-តាមលទ្ធផលនៃការទាញហេតុផលផ្ទាល់មាត់ សាលាឧទ្ធរណ៍ឃើញថាៈ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១២ ឈ្មោះ **សំអាន ផុស្សត្តិ** បានដាក់ពាក្យបណ្តឹងទៅសាលាដំបូងខេត្តបន្ទាយមានជ័យ នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខៈ **១៤៧** ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១២ ដែលមានសាលក្រមរដ្ឋប្បវេណីលេខៈ ០៩ (គ) ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ បានសម្រេចលើកពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ **សំអាន ផុស្សត្តិ** ចោល ដោយសាលាដំបូង យល់ឃើញថា សំណុំរឿងនេះពុំមែនជាសមត្ថកិច្ចរបស់តុលាការទេ គឺជាសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដី យោងតាមមាត្រា ១ កថាខណ្ឌទី២ នៃប្រកាសអន្តរក្រសួងលេខ ០២ប្រករ.០៣ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ រវាងក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការកំណត់ភារកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដី ពាក់ព័ន្ធនឹងរឿងវិវាទដីធ្លី ដោយសារគូភាគីពុំទាន់មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬប័ណ្ណកម្មសិទ្ធិនៅលើដីទំនាស់នៅឡើយ ។ គណៈកម្មការសុរិយោដីខេត្តបន្ទាយមានជ័យ កំពុងតែធ្វើការដោះស្រាយ ដោយពុំទាន់បានសម្រេចសេចក្តីអំពីករណីវិវាទដីធ្លីនេះផង ស្រាប់តែនៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨ ឈ្មោះ **សំអាន ផុស្សត្តិ** បានដាក់ពាក្យបណ្តឹងទៅសាលាដំបូងខេត្តបន្ទាយមានជ័យជាថ្មីម្តងទៀត ហើយសាលាដំបូងខេត្តបន្ទាយមានជ័យ ក៏បានចេញសាលក្រមរដ្ឋប្បវេណីលេខៈ ០៩ (ឋ) ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩ សម្រេចទទួលស្គាល់ការទាមទាររបស់ដើមចោទឈ្មោះ **សំអាន ផុស្សត្តិ** ដោយសាលាដំបូងយល់ឃើញថា បញ្ញត្តិប្រការ២ នៃប្រកាសអន្តរក្រសួងលេខ ០២ប្រករ.០៣ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ ត្រូវបាននិរាករណ៍ហើយ ។

សភារដ្ឋប្បវេណីសាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថា សាលក្រមរដ្ឋប្បវេណីលេខៈ ០៩ (ឋ) ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ពុំមានលក្ខណៈត្រឹមត្រូវតាមច្បាប់ឡើយ ដោយហេតុថា ប្រកាសអន្តរក្រសួងលេខ ០២ប្រករ.០៣ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ មិនត្រូវបាននិរាករណ៍ទេ គឺនៅតែមានអានុភាពអនុវត្តរហូតដល់បច្ចុប្បន្ននេះ ។ ម្យ៉ាងវិញទៀត តាមពាក្យបណ្តឹង ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨ និងពាក្យបណ្តឹង ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១២ របស់ឈ្មោះ **សំអាន ផុស្សត្តិ** គឺជាបណ្តឹងជាន់គ្នា យោងតាមមាត្រា ៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ហើយសាលក្រមរដ្ឋប្បវេណីលេខៈ ០៩ (គ) ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ បានសម្រេចអំពីសមត្ថកិច្ចបានចូលជាស្ថាពរហើយ បណ្តាលឲ្យមានអាជ្ញាអស់ជំនុំលើបណ្តឹងទាមទារដីរបស់ដើមចោទខាងលើ គឺរង់ចាំគណៈកម្មការសុរិយោដី ដោះស្រាយវិវាទដីខាងលើចប់សព្វគ្រប់សិន បើភាគីណាមួយមិនសុខចិត្តទើបប្តឹងទៅតុលាការនឹង

**សហចុងចម្លើយ (ចុងបណ្តឹងសាទុក្ខ) ៖**

១-ឈ្មោះ ស្រ៊ុន អ៊ុំ ភេទប្រុស អាយុ៧៥ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើចំការ (ស្លាប់) ។

២-ឈ្មោះ ស្រ៊ុន តុប ភេទស្រី អាយុ៤៣ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ មានទីលំនៅបច្ចុប្បន្ន ភូមិភ្នំធំខាងត្បូង ឃុំអូរប្រាសាទ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ។

អ្នកតំណាងដោយអាណត្តិ៖ លោកមេធាវី សាយ សុខហេង និងលោកមេធាវី សេង សុខឃីម

**កម្មវត្ថុបណ្តឹងៈ ខ្លឹមសារនៃសាលក្រមដែលទាមទារឱ្យតុលាការចេញ៖**

១-បញ្ជាក់ទទួលស្គាល់ដីទំហំ ៣៥១០ ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹងឈ្មោះ ឃឹម សាលី ខាងកើតទល់នឹងផ្លូវ និងខាងលិចទល់នឹងផ្លូវ ស្ថិតក្នុងភូមិភ្នំធំត្បូង ឃុំអូរប្រាសាទ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ជាកម្មសិទ្ធិរបស់ដើមចោទ។

២-ប្រគល់ដីទំហំ ៣៥១០ ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹងឈ្មោះ ឃឹម សាលី ខាងកើតទល់នឹងផ្លូវ និងខាងលិចទល់នឹងផ្លូវ ស្ថិតក្នុងភូមិភ្នំធំត្បូង ឃុំអូរប្រាសាទ ស្រុកមង្គលបូរី ខេត្តបន្ទាយ-មានជ័យ ឱ្យមកដើមចោទ។

៣-បង្គាប់ឱ្យសហចុងចម្លើយ និងតតិយជន ចាកចេញ រុះរើសំណង់ និងការគ្រប់ប្រភេទលើដីខាងលើនេះ។

៤-ទាមទារការខូចខាត ការខាតបង់ពេលវេលា និងជំងឺចិត្តចំនួន ១០.០០០.០០០ (ដប់លានរៀល)។

៥-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ។

៦-សុំអនុវត្តសាលក្រមបណ្តោះអាសន្ន។

## អង្គហេតុ និង ចំណុចវិវាទ

### ក. អំពីអង្គហេតុជាមូលហេតុនៃការទាមទារ

តាមពាក្យបណ្តឹង ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨ របស់ឈ្មោះ សំអាន ផស្សុត្តិ បានបញ្ជាក់ថា កាលពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៦ ឈ្មោះ អ៊ុច សំអាន ភេទប្រុស ដែលជាឪពុកបង្កើតរបស់ខ្លួន បានប្រគល់ដីទំហំ ៣,៥១០ ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹងឈ្មោះ ឃឹម សាលី ខាងកើតទល់នឹងផ្លូវ និងខាងលិចទល់នឹងផ្លូវ ស្ថិតនៅភូមិភ្នំធំត្បូង ឃុំអូរប្រាសាទ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ឱ្យមកខ្លួន (សំអាង ផុស្សុត្តិ) ដោយមានការទទួលស្គាល់ពីអាជ្ញាធរសាធារណៈត្រឹមត្រូវតាមច្បាប់ ហើយខ្លួនបានចូលកាន់កាប់លើដីនេះ និងបានរៀបចំឯកសារ ដើម្បីចុះបញ្ជីជាប្រព័ន្ធ ប៉ុន្តែត្រូវបានឈ្មោះ ស្រ៊ុន អ៊ុំ និងឈ្មោះ ស្រ៊ុន តុប ចូលកាន់កាប់រស់នៅដោយគ្មានការអនុញ្ញាត និងជំទាស់ការចុះបញ្ជីនេះ។ ខ្លួនបានដាក់ពាក្យបណ្តឹងទៅអាជ្ញាធរដើម្បីដោះស្រាយជាបន្តបន្ទាប់សំណុំរឿងនេះ។ នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៨ ការដោះស្រាយនៅសាលាមង្គលបូរី ដោយអាជ្ញាធរបានបញ្ជាក់ថា ដីនេះជាដីរបស់ខ្លួន និងអនុញ្ញាតឱ្យខ្លួនចាក់ដី និងធ្វើរបង ដូចមានបញ្ជាក់ក្នុងកំណត់ហេតុស្តីពីការប្រជុំសម្របសម្រួលករណីវិវាទ នៅភូមិភ្នំធំត្បូង ឃុំអូរប្រាសាទ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៨ ហើយអាជ្ញាធរថ្នាក់ស្រុក ក៏បានបង្គាប់ឱ្យឈ្មោះ ស្រ៊ុន អ៊ុំ និងឈ្មោះ ស្រ៊ុន តុប រុះរើសំណង់ និងការផ្សេងៗចេញ។

-បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ០៩ (ប) ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១.បញ្ជាក់ទទួលស្គាល់ដើមចោទឈ្មោះ សំអាន ផុស្សុត្ថិ ភេទស្រី ជាម្ចាស់កម្មសិទ្ធិលើអចលនវត្ថុ (ដី) ទំហំ ៣,៥១០ (បីពាន់ប្រាំរយដប់) ម៉ែត្រការ៉េ មានព្រំប្រទល់ ខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹងឈ្មោះ យឹម សាលី ខាងកើតទល់នឹងផ្លូវ និងខាងលិចទល់នឹងផ្លូវ ស្ថិតក្នុងភូមិភ្នំធំត្បូង ឃុំអូរប្រាសាទ ស្រុកមង្គលបូរី ខេត្តបន្ទាយ-មានជ័យ ជាកម្មសិទ្ធិករ។

២.ប្រគល់អចលនវត្ថុ(ដី) ទំហំ ៣,៥១០ (បីពាន់ប្រាំរយដប់) ម៉ែត្រការ៉េ មានព្រំប្រទល់ ខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹងឈ្មោះ យឹម សាលី ខាងកើតទល់នឹងផ្លូវ និងខាងលិចទល់នឹងផ្លូវ ស្ថិតក្នុងភូមិភ្នំធំត្បូង ឃុំអូរប្រាសាទ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ឲ្យទៅដើមចោទឈ្មោះ សំអាន ផុស្សុត្ថិ។

៣.បង្គាប់ឲ្យសហចុងចម្លើយ និងតតិយជន ចាកចេញ រុះរើសំណង់ និងការរៀបចំគ្រប់ប្រភេទ ពីដីរបស់ដើមចោទ ដែលមានបញ្ជាក់ក្នុងចំណុចទី១ និងទី២ នៃសេចក្តីសម្រេចបញ្ចប់ការខាងលើនេះ។

៤.បង្គាប់ឲ្យសហចុងចម្លើយរួមគ្នាសងការខូចខាត ការខាតបង់ពេលវេលា និងជម្ងឺចិត្តចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល ឲ្យទៅដើមចោទឈ្មោះ សំអាន ផុស្សុត្ថិ។ ការទាមទារលើសពីនេះ ត្រូវបដិសេធចោល។

៥.ច្រានចោលការទាមទារផ្សេងទៀតរបស់ដើមចោទ ដែលសុំអនុវត្តសាលក្រមជាបណ្តោះអាសន្ន។

៦.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

៧.សាលក្រមនេះ ទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ និងសហចុងចម្លើយ។

បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ ១៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ឈ្មោះ ស្រ៊ុន អុំ និងឈ្មោះ ស្រ៊ុន តុប ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ០៩ (ប) ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ គ្រង់ចំណុច លើសេចក្តីសម្រេចទាំងមូល។

-បានឃើញសាលដីការដ្ឋប្បវេណីលេខ ១៦ ក្រ VII ភស ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ១៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សហចុងចម្លើយឈ្មោះ ស្រ៊ុន អុំ និងឈ្មោះ ស្រ៊ុន តុប ។

២-លុបចោលសាលក្រមរដ្ឋប្បវេណីលេខ ០៩ (ប) ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ជាអសារបង់។

៣-ច្រានចោលពាក្យបណ្តឹង ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨ របស់ឈ្មោះ សំអាន ផុស្សុត្ថិ។

៤-ប្រាក់ប្រដាប់ក្តី នៅសាលាឧទ្ធរណ៍ជាបន្ទុករបស់ដើមចោទឈ្មោះ សំអាន ផុស្សុត្ថិ។

សាលដីកានេះ ប្រកាសជាសាធារណៈ នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ ទុកសិទ្ធិឲ្យប្តឹងសារទុក្ខអំឡុងពេល ០១ខែ ចាប់គិតពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ។

-ដើមចោទឈ្មោះ សំអាន ផុស្សត្តិ បានធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួនមិនយល់ព្រមឲ្យខាងសុរិយោដីជាអ្នកដោះស្រាយនោះទេ ព្រោះដីនេះ ខាងសាលាស្រុកបានប្រគល់ និងទទួលស្គាល់ថាខ្លួនជាម្ចាស់ដីនេះហើយ។

-ចុងចម្លើយឈ្មោះ ស្រ៊ុន គុប បានធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួនយល់ព្រមឲ្យខាងគណៈកម្មការសុរិយោដី ជាអ្នកដោះស្រាយ។

-លោក មួន សៀងលី មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ សំអាន ផុស្សត្តិ បានធ្វើសេចក្តីថ្លែងការណ៍ថា ចំពោះការសម្រេចរបស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសមត្ថកិច្ចរបស់តុលាការ ដែលយល់ឃើញថាប្រកាសអន្តរក្រសួងលេខ ០២ ប្រករ.០៣ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ ត្រូវប្រគល់ទៅឲ្យខាងគណៈកម្មការសុរិយោដី ជាអ្នកដោះស្រាយ នោះ ជាការមិនត្រឹមត្រូវទេ ពីព្រោះថា ចុងចម្លើយមិនបានធ្វើពាក្យសុំឲ្យលើកចោលឬបដិសេធ ចំពោះសមត្ថកិច្ចរបស់តុលាការទេ យោងតាមមាត្រា ១៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចំពោះការប្តឹងខុសសមត្ថកិច្ចបែបនេះ ភាគីអាចទៅដាក់ពាក្យសុំបាន។ នៅក្នុងសាលក្រមសាលាដំបូងខេត្តបន្ទាយមានជ័យ ពុំមានការតវ៉ា ឬជំទាស់ទេ គឺមានតែសេចក្តីឆ្លើយដោះសារ ទៅលើអង្គសេចក្តីទាំងមូលទៅវិញ។ ចំណែក ប្រកាសអន្តរក្រសួងលេខ ០២ ប្រករ.០៣ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ ក៏ត្រូវបាននិរាករណ៍ទៅហើយ តាមមាត្រា៥៨៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ តុលាការកំពូល ក៏ធ្លាប់ជំនុំជម្រះសំណុំរឿងបែបនេះដែរ ពាក់ព័ន្ធនឹងរឿងដីគ្មានប័ណ្ណ ហើយតុលាការកំពូលទទួលស្គាល់ជាសមត្ថកិច្ចរបស់តុលាការ។ ការយល់ឃើញរបស់សាលាឧទ្ធរណ៍អំពីអាជ្ញាអស់ជំនុំចំពោះសាលក្រមប្រភេទនេះ ខ្លួនយល់ថាមិនត្រឹមត្រូវទេ សាលក្រមដែលលើកចោលបណ្តឹង មិនមែនជាសាលក្រមដែលសម្រេចអំពីលក្ខណៈសារធាតុនៃអង្គសេចក្តីទាំងមូល នេះជាសាលក្រមបែបលក្ខណៈនីតិវិធី ដែលមិនគប្បីឲ្យបកស្រាយពីអាជ្ញាអស់ជំនុំឡើយ ព្រោះសាលក្រមនេះកំណត់អំពីលក្ខណៈទម្រង់តែប៉ុណ្ណោះ ដូច្នេះហើយតុលាការកំពូល នៅតែអាចទទួលយកបណ្តឹងនេះមកជំនុំជម្រះបានផងដែរ។ ជាក់ស្តែង កូនក្តីខ្លួនមានលិខិតបញ្ជាក់ពីមេឃុំ និងឯកសារដែលបញ្ជាក់អំពីការកាន់កាប់ផ្សេងៗ ស្របតាមច្បាប់។

សំណូមពរ សូមក្រុមប្រឹក្សាជំនុំជម្រះ មេត្តាសម្រេចបដិសេធសាលដីការដ្ឋប្បវេណីលេខ ១៦ ក្រ VII ភស ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ ចោល និងតម្កល់សាលក្រមរដ្ឋប្បវេណីលេខ ០៩ (ប) ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ទុកជាបានការ ។

-លោក សាយ សុខហេង មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ ស្រ៊ុន គុប បានធ្វើសេចក្តីថ្លែងការណ៍ថា ការសម្រេចរបស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលផ្ទេរសមត្ថកិច្ចទៅខាងគណៈកម្មការសុរិយោដី គឺជាការត្រឹមត្រូវហើយ ព្រោះប្រកាសអន្តរក្រសួងលេខ ០២ ប្រករ.០៣ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ មិនទាន់ត្រូវបាននិរាករណ៍នោះទេ គឺនៅមានអានុភាពអនុវត្តរហូតមកដល់បច្ចុប្បន្ននេះ។

-លោក សេង សុខឃីម មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ ស្រ៊ិន តុប បានធ្វើសេចក្តីថ្លែងការណ៍ថា ពាក់ព័ន្ធទៅនឹងសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដី តាមរយៈប្រកាសលេខ ០២ ប្រករ.០៣ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ គឺនៅមានអានុភាពអនុវត្តនៅឡើយ។ បន្ទាប់ពីគណៈកម្មការសុរិយោដីថ្នាក់ជាតិ ចេញសេចក្តីសម្រេចរួចហើយ បើមានភាគីណាម្ខាងមិនសុខចិត្តនឹងសេចក្តីសម្រេចនោះ គឺអាចប្តឹងមកតុលាការក្នុងរយៈពេល ៣០ថ្ងៃ ហើយសព្វថ្ងៃនេះក៏កំពុងតែបន្តអនុវត្តជាធរមាន។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមទទួលបញ្ហា

-ក្រោយពីបានស្តាប់យោបល់របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់គូភាគី និងមេធាវីតំណាងដោយអាណត្តិឱ្យគូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## តុលាការកំពូល

១.យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៧១ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ របស់ដើមចោទ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន តាមមាត្រា៦៥ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា២៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២.យល់ឃើញថា ដើមចោទជាដើមបណ្តឹងសាទុក្ខ និងមេធាវីបានលើកឡើងថា៖

-ការដែលសភារដ្ឋប្បវេណីសាលាឧទ្ធរណ៍ភ្នំពេញសម្រេច ដោយផ្អែកលើប្រកាសអន្តរក្រសួងលេខ ០២ ប្រករ.០៣ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ គឺមិនត្រឹមត្រូវទេ ពីព្រោះថា ប្រការ២ នៃប្រកាសអន្តរក្រសួងនេះ ត្រូវបាននិរាករណ៍ ដោយផ្អែកតាមមាត្រា ៥៨៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-សាលក្រមរដ្ឋប្បវេណីលេខ ០៩ (គ) ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ គឺជាសាលក្រមនីតិវិធី ដែលពុំមានអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុនៃអង្គសេចក្តីឡើយ ដូច្នេះ ការយល់ឃើញរបស់សាលាឧទ្ធរណ៍អំពីអាជ្ញាអស់ជំនុំនេះ គឺផ្ទុយនឹងមាត្រា ១៩៤ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-ចុងចម្លើយបានធ្វើការតវ៉ាពីសមត្ថកិច្ចរបស់សាលាដំបូង ដោយមិនបានធ្វើជាលាយលក្ខណ៍អក្សរនៅដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ប៉ុន្តែមិនបានលើកឡើងពីបញ្ហានេះនៅពេលទាញហេតុផលដោយផ្ទាល់មាត់ ដោយធ្វើការឆ្លើយដោះសារលើអង្គសេចក្តីរហូត ហេតុដូច្នេះបានន័យថា ចុងចម្លើយបានទទួលស្គាល់សមត្ថកិច្ចរបស់តុលាការក្នុងការដោះស្រាយលើរឿងក្តីនេះហើយ។

ចំពោះការលើកឡើងយ៉ាងដូច្នេះ តុលាការកំពូលពិនិត្យឃើញថា ក្រោយពីពាក្យបណ្តឹង ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១២ របស់ដើមចោទត្រូវបានលើកចោល តាមសាលក្រមរដ្ឋប្បវេណីលេខ ០៩ (គ) ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ វិវាទរវាងគូភាគីត្រូវបានដោះស្រាយដោយគណៈកម្មការសុរិយោដីជាបន្តបន្ទាប់ ដោយដើមចោទមិនបានប្តឹងឧបាស្រ័យប្រឆាំងនឹងសាលក្រមខាងលើឡើយ ស្រាប់តែលុះឆ្នាំ ២០១៨ ទើបដើមចោទដាក់ពាក្យបណ្តឹងមកសាលាដំបូងខេត្តបន្ទាយមានជ័យសាជាថ្មីម្តងទៀត នៅខណៈពេលដែលវិវាទនេះកំពុងត្រូវបានបានដោះស្រាយដោយគណៈកម្មការសុរិយោដីនៅឡើយ ដោយបញ្ហាសមត្ថកិច្ចនេះ ត្រូវបាន

ចុងចម្លើយតវ៉ានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ស្របតាមមាត្រា ១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ហេតុដូច្នេះ តុលាការត្រូវមានសមត្ថកិច្ចដោះស្រាយលើវិវាទនេះ ក្រោយពេលដែលគណៈកម្មការសុរិយោដីធ្វើការសម្រេចសេចក្តីរួចហើយសិន។

៣.យល់ឃើញថា បណ្តឹងសាទុក្ខរបស់ដើមចោទ មិនមានមូលហេតុនៃបណ្តឹងសាទុក្ខ តាមមាត្រា ២៨៤ និងមាត្រា ២៨៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីទេ។

៤.យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ១៦ ក្រ VII ភស ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចមកនេះ ត្រឹមត្រូវតាមច្បាប់ហើយ។

៥.យល់ឃើញថា តាមមាត្រា ៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមបណ្តឹងសាទុក្ខ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី

១.ច្រានចោលបណ្តឹងសាទុក្ខលេខ ៧១ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ របស់ដើមចោទ។

២.តម្កល់សាលដីការដ្ឋប្បវេណីលេខ ១៦ ក្រ VII ភស ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ។

៣. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

សាលដីកានេះបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ ។

| | | | |
|---|---|---|---|
| ឯកឧត្តម | **ជីវ** | **កេង** | ប្រធាន |
| លោកជំទាវ | **គិម** | **សន្តាវី** | ចៅក្រម |
| ឯកឧត្តម | **សោម** | **សិរីវឌ្ឍ** | ចៅក្រម |
| ឯកឧត្តម | **គង់** | **តារានាគ** | ចៅក្រម |
| លោកជំទាវ | **ចាំង** | **ស៊ីណាត** | ចៅក្រម |
| លោកស្រី | **គន់** | **ម៉ីស៊ីណា** | ក្រឡាបញ្ជី |

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
ថ្ងៃពុធ ១៣កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
ក្រុងភ្នំពេញ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០
ក្រឡាបញ្ជី
គន់_ម៉ីស៊ីណា

**បានឃើញ**
ថ្ងៃពុធ ១៣កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
ក្រុងភ្នំពេញ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
ជីវ កេង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

# សាលដីកា

សំណុំរឿងរដ្ឋប្បវេណី
លេខ :៧៥
ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦
សាលដីកា
លេខ : ៣៥១ -ឈ-
ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ ២០១៧

តាងនាមប្រជាពលរដ្ឋខ្មែរ
តុលាការកំពូល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ជាសាធារណៈ នៅថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០១៧ ដោយមានសមាសភាពដូចតទៅ ៖

| | | |
|---|---|---|
| ឯកឧត្តម | **គង់ ស្រ៊ីម** | ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| -លោកស្រី | **គិម សន្ធាវី** | ជាចៅក្រម |
| -លោក | **សោម សិរីវឌ្ឍ** | ជាចៅក្រមរបាយការណ៍ |
| -លោក | **ទី ណេង** | ជាចៅក្រម |
| -លោកស្រី | **ចាំង ស៊ីណាត** | ជាចៅក្រម |
| -លោក | **សុខ ម៉ៅ** | ជាក្រឡាបញ្ជី |

**តំណាងអយ្យការអមអយ្យការ**

| | | |
|---|---|---|
| -លោក | **ឌុច គីមសន** | ជាព្រះរាជអាជ្ញា |

លើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ២០៧/VIIភត ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៣៧៣ ចុះថ្ងៃទី០៦ ខែ សីហា ឆ្នាំ២០១៥ របស់សាលាឧទ្ធរណ៍ រវាង ៖

**-ដើមចោទ** :ឈ្មោះ សំ ភិរក្ស ភេទប្រុស អាយុ៣២ ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករ មានទីលំនៅបច្ចុប្បន្នភូមិព្រៃចង្ក្រាលិច ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ (ដើមបណ្តឹងសាទុក្ខ)។

**-សហចុងចម្លើយ** :

១.ឈ្មោះ អ៊ុំ ផាន ភេទប្រុស អាយុ៨១ ឆ្នាំ មុខរបរធ្វើស្រែ មានទីលំនៅបច្ចុប្បន្ន ភូមិព្រៃចង្ក្រាខាងលិច ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ។

២-ឈ្មោះ ជួន វៃ ភេទប្រុស ថ្ងៃខែឆ្នាំកំណើត ១៩៥២ មុខរបរធ្វើស្រែ មានទីលំនៅបច្ចុប្បន្ន ភូមិព្រៃចង្ក្រាខាងលិច ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ។

៣-ឈ្មោះ ប៉ែន អៀត ភេទប្រុស អាយុ៥៦ ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន ភូមិព្រៃចង្ហាខាងលិច ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ។

៤-ឈ្មោះ មិច មឿត ភេទប្រុស អាយុ៥០ ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន ភូមិព្រៃចង្ហាខាងលិច ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ។

៥-ឈ្មោះ ជៀក ហួរ ភេទប្រុស អាយុ៥៨ ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន ភូមិព្រៃចង្ហាខាងលិច ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ។

៦-ឈ្មោះ ខាន់ រស់ និងឈ្មោះ ស្រី វ៉ែន ។

-មេធាវីតំណាងអាណត្តិ អៀង រិទ្ធា និង ចាន់ សុភា ។

**កម្មវត្ថុបណ្តឹង**:

១-ប្តឹងសុំបញ្ជាក់ និងទទួលស្គាល់សិទ្ធិកាន់កាប់អចលនវត្ថុនៃដីទំហំ ១៨.២១៥ ម៉ែត្រការេ ។

២-ឲ្យសហចុងចម្លើយបញ្ឈប់ការរំលោភលើដីស្រែរបស់ខ្លួន ។

៣-ឲ្យសហចុងចម្លើយរុះរើផ្ទះ និងទ្រព្យសម្បត្តិខ្លួនចេញពីដីចំការរបស់ខ្លួន ។

៤-ឲ្យសហចុងចម្លើយរាប់រងនូវប្រាក់ពន្ធផ្សេងៗ ។

**អំពីអង្គហេតុ និង ចំណុចទាស់**

-តាមពាក្យបណ្តឹង ចុះថ្ងៃទី៣១ ខែ មករា ឆ្នាំ២០១៤ របស់ដើមចោទឈ្មោះ សំ ភិរក្ស បានបញ្ជាក់ថា ដីស្រែដែលមានទំហំ ១៨,២១៥ $m^2$ ជាកម្មសិទ្ធិរបស់ឪពុកខ្លួនឈ្មោះ ឡាំ សំវុទ្ធា បានមកពីការបែងចែករបបទៅតាមមុខងារហើយបានកាន់កាប់បង្កបង្កើនផលរហូតមក ។ នៅឆ្នាំ១៩៩៧ ឪពុករបស់ខ្លួនបានចែកដីស្រែខាងលើឲ្យមកកូនប្រាំពីរនាក់ ហើយបងប្អូនទាំងអស់បានឯកភាពឲ្យខ្លួនជានាក់ប្រើប្រាស់ដើម្បីយកផលសម្រាប់ផ្គត់ផ្គង់ឪពុកម្តាយ ។ នៅឆ្នាំ២០១០ សហចុងចម្លើយខាងលើ បានប្តឹងសុំដីការក្សាការពារ ទាមទារយកធ្វើជាដីរបស់សហគមន៍ ក្រោយពេលដែលតុលាការចេញដីកាសម្រេចរក្សាការពារហើយ ចុងចម្លើយឈ្មោះ ជួន រ៉ៃ បានយកប្រើប្រាស់ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួនទៅវិញ ។

-ចំណែកដីចំការដែលមានទំហំ ៣,៧៤១ ម២ ជាដីកម្មសិទ្ធិរបស់ឪពុកខ្លួនបានមកពីការស្នើសុំពីការិយាល័យកសិកម្មស្រុកមង្គលបូរី នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩២ ។ ក្នុងអំឡុងឆ្នាំ២០០៣ សហចុងចម្លើយឈ្មោះ ជៀក ហួរ និងឈ្មោះ ឌី បានចូលទៅរស់នៅលើដីចំការរបស់ឪពុកខ្លួន ហើយនៅឆ្នាំ២០១០ សហចុងចម្លើយទាំងអស់ បានប្តឹងសុំដីកាសម្រេចរក្សាការពារក្នុងសំណុំរឿងរក្សាការពារលេខ: ៤៧ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១០ ។បន្ទាប់ពីតុលាការចេញដីកាសម្រេចរក្សាការពាររួច ចុងចម្លើយខាងលើបានអនុវត្តយកប៉ុន្តែមិនបានដេញសហចុងចម្លើយឈ្មោះ ជៀក ហួរ និងឈ្មោះ ឌី រស់នៅរហូតមក ។ ម្យ៉ាងទៀត ចុងចម្លើយឈ្មោះ អ៊ុំ ផាន បានក្លែងបន្លំជាមេភូមិ ជំនួសឪពុកខ្លួនទៅវិញ ។

-ឪពុករបស់ខ្លួន បានទទួលមរណភាព នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១១ ហើយខ្លួនជាអ្នកបន្តក្នុងសំណុំរឿងរក្សាការពារ រហូតដល់សាលាឧទ្ធរណ៍ ក្នុងការការពារទ្រព្យសម្បត្តិដែលជាប្រយោជន៍របស់គ្រួសារខ្លួន ។

ធ្វើស្រែជាង ២០ ឆ្នាំហើយ សុំរកយុត្តិធម៌ផង ។ដីទំនាស់ ពុំមែនជាដីសហគមន៍ទេ ប៉ុន្តែ ជាដីដែលឪពុកខ្លួនឈ្មោះ ឡាំ សំវុទ្ធា បានគ្រប់គ្រងកាន់កាប់រហូតមក ហើយចុងចម្លើយជាអ្នករំលោភយក។

-មេធាវី ចាន់ សុភា ៖ តំណាងអាណត្តិឱ្យចុងចម្លើយបានធ្វើសេចក្តីសន្និដ្ឋានថា ដីទំនាស់ជាដីទំនេរ និងជាដីសហគមន៍ មិនមែនជាដីរបស់ដើមចោទទេ តាមប្រកាសអន្តរក្រសួងលេខ០២កំណត់ថា មិនមែនជាសមត្ថកិច្ចរបស់តុលាការក្នុងការដោះស្រាយដីធ្លី ចំពោះដីដែលមិនទាន់ចុះបញ្ជីទេ ពុំមានភស្តុតាង និងឯកសារណាបញ្ជាក់ថាជាដីជាកម្មសិទ្ធិរបស់ភាគីណាមួយឡើយទេ មានលិខិតបញ្ជាក់របស់មេភូមិថាដីទំនាស់ជាដីកម្មសិទ្ធិរបស់សហគមន៍មែន ។ សុំដម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកបានការ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមទទួលបញ្ហា

-ក្រោយពីបានស្តាប់យោបល់របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់ដើមចោទ និងមេធាវីរបស់ចុងចម្លើយ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៦៩ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ របស់ដើមចោទ សំ ភិរក្ស ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះ មកជំនុំជម្រះបានតាមមាត្រា ៦៥ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ២៨៣ មាត្រា ២៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២-យល់ឃើញថា នាពេលទាញហេតុផលដោយផ្ទាល់មាត់នេះ ក៏ដូចជាក្នុងលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខដែរ ដើមចោទ សំ ភិរក្ស បានអះអាងថា ដីទំនាស់ ពុំមែនជាដីសហគមន៍ទេ ប៉ុន្តែ ជាដីដែលឪពុកខ្លួនឈ្មោះ ឡាំ សំវុទ្ធា បានគ្រប់គ្រងកាន់កាប់រហូតមក ហើយចុងចម្លើយជាអ្នករំលោភយក ។ ចំណែកមេធាវីតំណាងដោយអាណត្តិរបស់ចុងចម្លើយបានអះអាងថា ដីទំនាស់ជាដីសហគមន៍ មិនមែនជាដីរបស់ដើមចោទទេ ហើយ តាមប្រកាសអន្តរក្រសួងលេខ ០២ កំណត់ថា មិនមែនជាសមត្ថកិច្ចរបស់តុលាការក្នុងការដោះស្រាយដីធ្លីចំពោះដីដែលមិនទាន់ចុះបញ្ជីទេ នោះ_ តុលាការកំពូលពិនិត្យឃើញថា ដើមចោទបានដាក់ពាក្យបណ្តឹងទាមទារសិទ្ធិលើដីទំនាស់ទៅតុលាការខេត្តបន្ទាយមានជ័យ នៅក្នុងឆ្នាំ ២០១៤ ដោយអះអាងអំពីអត្ថភាពនៃសិទ្ធិរបស់ខ្លួនលើដីទំនាស់ បន្តពីសពរបស់ឪពុកខ្លួនដែលបានគ្រប់គ្រងកាន់កាប់រហូតមក ចំណែកចុងចម្លើយបានអះអាងអំពីនត្ថិភាពនៃសិទ្ធិរបស់ដើមចោទ ដោយសារដីទំនាស់ជាដីសហគមន៍ ។ ការអះអាងនេះ មិនត្រូវបានតុលាការខេត្តបន្ទាយមានជ័យនិងសាលាឧទ្ធរណ៍ ពិចារណាអំពីការអះអាងរបស់គូភាគីនៃបណ្តឹងទេ ប៉ុន្តែបែរជាផ្អែកលើប្រកាសអន្តរក្រសួង លេខ ០២ ប្រ.ក.រ/០៣ ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកំណត់ភារកិច្ចរបស់តុលាការ និងគណកម្មការសុរិយោដី ហើយសម្រេចថា តុលាការពុំមានសមត្ថកិច្ចដោះស្រាយវិវាទនេះទៅវិញនោះ ជាការមិនត្រឹមត្រូវទេ ព្រោះថា ៖

-បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ០៨ (ឃ) ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ របស់សាលាដំបូងខេត្តបន្ទាយមានជ័យមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១-លើកចោលពាក្យបណ្តឹងចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ របស់ដើមចោទឈ្មោះ សំ ភិរក្ស ចោលជាអសារបង់ ។

២-បង្វិលប្រាក់ប្រដាប់ក្តីចំនួនពាក់កណ្តាល ដែលដើមចោទបានបង់រួចហើយ ឲ្យទៅដើមចោទវិញ ។

៣-បើសាម៉ីខ្លួនមិនសុខចិត្ត មានសិទ្ធិប្តឹងជំទាស់ក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងតវ៉ាលេខ២៦ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៥ របស់ដើមចោទឈ្មោះ សំ ភិរក្ស ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ០៨ (ឃ) ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ គ្រប់ចំណុចទាំងមូល នៃសេចក្តីសម្រេច ។

-បានឃើញសាលដីការដ្ឋប្បវេណីលេខ២៣ ក្រV I I "ភស" ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ របស់សាលាឧទ្ធរណ៍ មានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ច្រានចោលបណ្តឹងឧទ្ធរណ៍លេខ ២៦ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៥ របស់ដើមចោទឈ្មោះ សំ ភិរក្ស។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ០៨ (ឃ) ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ទុកជាបានការដដែល ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទឈ្មោះ សំ ភិរក្ស។

- សាលដីកានេះ ទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៥ និងប្រកាសជាសាធារណៈ នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ ។ បើកសិទ្ធិប្តឹងសាទុក្ខក្នុងអំឡុងពេល១ ខែ ចាប់គិតពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ ។

-បានឃើញបណ្តឹងសាទុក្ខលេខ៣៦៩ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ របស់ឈ្មោះ សំ ភិរក្សដែលប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ២៣ ក្រVII"ភស" ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ របស់សាលាឧទ្ធរណ៍ គ្រប់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

-បានឃើញលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ របស់ឈ្មោះ សំ ភិរក្ស ។

-បានឃើញលិខិតឆ្លើយតបបញ្ជាក់អំពីមូលហេតុបណ្តឹងសាទុក្ខចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ របស់ឈ្មោះ អៀង រិទ្ធា និង ចាន់ សុផា មេធាវីតំណាងអាណត្តិឲ្យចុងចម្លើយ ។

## ដំណាក់កាលទាញហេតុផលដោយផ្ទាល់មាត់

-សំ ភិរក្ស៖ ដីឪពុកខ្លួនកាន់កាប់យូរហើយ ឪពុកខ្លួនមានកូន១០ នាក់ឯចុងចម្លើយជាអ្នកភូមិជាមួយគ្នា ពេលនេះចូលខ្លួនក្នុងនាមបងប្អូនទាំងអស់គ្នា ទាមទារយកដីសម្រាប់បងប្អូនទាំងអស់គ្នាការប្តឹងនេះក្នុងនាមបងប្អូនទាំងអស់គ្នា ការកាត់ក្តីរបស់សាលាឧទ្ធរណ៍អយុត្តិធម៌សម្រាប់រូបខ្លួន ព្រោះកន្លងមកធ្លាប់បានប្តឹងគ្រប់ការិយាល័យហើយ គ្រួសារខ្លួនបានបំពេញបែបបទសុំបណ្ណ័ទៅសុរិយោដីហើយ តែគេពុំទាន់ចេញប្លង់ឲ្យ ព្រោះឪពុកខ្លួន

-តាមរយៈពាក្យបណ្ដឹងរបស់ដើមចោទ ការទាមទារសិទ្ធិលើដីធ្លី ជាប្រភេទបណ្ដឹងរដ្ឋប្បវេណី ដែលដើមចោទ បានប្រើប្រាស់នៅក្នុងនីតិវិធីរដ្ឋប្បវេណីដោយផ្អែកតាមគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន និងគោលការណ៍នៃសិទ្ធិពឹងពាក់តុលាការ ឲ្យធ្វើការដោះស្រាយបណ្ដឹងទាមទារមាត្រា២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចំពោះសិទ្ធិដែលត្រូវបានអះអាងថា មានការរំលោភបំពាន ។

-ម្យ៉ាងទៀត ទោះបីជាមាត្រា ១៦-១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានផ្ដល់អគ្គាធុសិទ្ធិដល់តុលាការ ក្នុងការពិនិត្យភស្ដុតាង និងសម្រេចអំពីបញ្ហាទាក់ទងនឹងសមត្ថកិច្ចរបស់តុលាការក៏ដោយ ក៏តាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា ៥៨៨ (ការធ្វើឲ្យនិរាករណ៍នូវច្បាប់ផ្សេងជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៧បានកំណត់ចំពោះបញ្ញត្តិនៃច្បាប់ផ្សេងទៀត ដែលមានអានុភាពនៅ ពេលក្រមនីតិវិធីរដ្ឋប្បវេណីត្រូវបានអនុវត្ត ហើយផ្ទុយនឹងបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីត្រូវចាត់ទុកជាគ្មានអានុភាពត្រឹមទំហំដែលផ្ទុយនឹងក្រមនីតិវិធីរដ្ឋប្បវេណី ចាប់ពីថ្ងៃដែលក្រមនេះត្រូវបានអនុវត្ត ឃើញថា បញ្ញត្តិប្រការ២ នៃប្រកាសអន្តរក្រសួង លេខ ០២ ប្រក/០៣ ចុះថ្ងៃទី២៦ខែវិច្ឆិកា ឆ្នាំ២០០៣ ដែលកំណត់ថា តុលាការត្រូវបញ្ឈប់ការទទួលបណ្ដឹងវិវាទដីធ្លីមិនទាន់ចុះបញ្ជីសុរិយោដី ដែលជាសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដី ត្រូវបាននិរាករណ៍ហើយ។ដូច្នេះ តុលាការរដ្ឋប្បវេណីមានសិទ្ធិជម្រះក្ដី ចំពោះការទាមទារតាមពាក្យបណ្ដឹងចុះថ្ងៃទី៣១ខែមករា ឆ្នាំ២០១៤ របស់ដើមចោទ សំ ភិរក្ស ។

៣-យល់ឃើញថា រឿងក្ដីនេះ ត្រូវបានតុលាការខេត្តបន្ទាយមានជ័យ និងសាលាឧទ្ធរណ៍ ធ្វើការវិនិច្ឆ័យតែលើសិទ្ធិជម្រះក្ដីរបស់តុលាការ ប៉ុន្តែមិនបានធ្វើការពិនិត្យ និងធ្វើការវិនិច្ឆ័យអំពីអត្ថិភាព ឬ នត្ថិភាពចំពោះការអះអាងអំពីការទាមទារតាមផ្លូវបណ្ដឹងនៅឡើយទេ ។ ដូច្នេះ តុលាការកំពូល គប្បីធ្វើការវិនិច្ឆ័យ និងបញ្ជូនរឿងក្ដីនេះ ទៅតុលាការមានសមត្ថកិច្ច ដើម្បីចាត់ការតាមនីតិវិធីនៃបណ្ដឹងបន្ត ។

៤-យល់ឃើញថា តាមមាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ភាគីចាញ់ក្ដី ។ ដូច្នេះ ប្រាក់ប្រដាប់ក្ដីនៅជាន់តុលាការកំពូលជាបន្ទុករបស់ចុងចម្លើយ ។

៥-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ២៣ក្រVII "កស" ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ របស់សាលាឧទ្ធរណ៍ និងសាលក្រមរដ្ឋប្បវេណីលេខ ០៨ "ឃ" ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលបានសម្រេចសេចក្ដីមកនេះ មិនត្រឹមត្រូវតាមច្បាប់ទេ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្ដី**

១- ទទួលបណ្ដឹងសាទុក្ខលេខ ៣៦៩ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ របស់ដើមចោទ សំ ភិរក្ស។

២-បដិសេធសាលដីការដ្ឋប្បវេណីលេខ ២៣ ក្រVII "កស" ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ របស់សាលឧទ្ធរណ៍ និងសាលក្រមរដ្ឋប្បវេណីលេខ ០៨ "ឃ" ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

៣-បញ្ជូលសំណុំរឿងរដ្ឋប្បវេណីលេខ ៧៥ ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០១៦ របស់តុលាការកំពូល ទៅតុលាការខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការតាមនីតិវិធីនៃបណ្ដឹង ។

៤-ប្រាក់ប្រដាប់ក្ដីជាន់តុលាការកំពូល ជាបន្ទុករបស់ចុងចម្លើយ។

-សាលដីកានេះបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០១៧ និងប្រកាសសាលដីកាជាសាធារណៈ នៅថ្ងៃទី២០ ខែ វិច្ឆិកា ឆ្នាំ២០១៧ ។

| | | |
|---|---|---|
| -ឯកឧត្តម | **គង់ ស្រ៊ីម** | ជាប្រធាន |
| -លោកស្រី | **គិម សន្ធាធី** | ជាចៅក្រម |
| -លោក | **សោម សិរីវឌ្ឍ** | ជាចៅក្រម |
| -លោក | **ឌី ណោច** | ជាចៅក្រម |
| -លោកស្រី | **ចាំង ស៊ីណាត** | ជាចៅក្រម |
| -លោក | **សុខ ម៉ៅ** | ជាក្រឡាបញ្ជី |

---

បានឃើញ

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៧

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

គង់ ស្រ៊ីម

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០១៧

ក្រឡាបញ្ជី

សុខ ម៉ៅ

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

រាជធានី[illegible]ថ្ងៃទី១៤ ខែ[illegible] ឆ្នាំ២០១៨

ក្រឡាបញ្ជី

សុខ ម៉ៅ

# ឧបសម្ព័ន្ធទី៣

# គន្ថីទី ៣
# បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

មាត្រា ២៥៩ ប្រភេទនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់

១-ប្រភេទនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ចំពោះការសម្រេចសេចក្តីដែលមិនទាន់ចូលជាស្ថាពរ មានដូចខាងក្រោមនេះ :

ក- បណ្តឹងឧទ្ធរណ៍ ចំពោះសាលក្រមរបស់សាលាដំបូង ឬ បណ្តឹងសាទុក្ខ ក្នុងករណីមានការព្រមព្រៀងរវាងភាគីដែលបានកំណត់នៅក្នុងចំណុច ក កថាខណ្ឌទី ១ នៃមាត្រា ២៦០ ( សាលក្រមដែលអាចប្តឹងឧទ្ធរណ៍បាន ជាអាទិ៍ ) នៃក្រមនេះ។

ខ- បណ្តឹងសាទុក្ខ ចំពោះសាលដីការបស់តុលាការនៃបណ្តឹងឧទ្ធរណ៍។

គ- បណ្តឹងជំទាស់ ចំពោះដីកាសម្រេច។

២- បណ្តឹងជំទាស់ អាចធ្វើឡើងបាន លុះត្រាតែមានបញ្ញត្តិក្នុងច្បាប់។

៣- ចំពោះដីកាសម្រេចលើបណ្តឹងជំទាស់ មិនអាចប្តឹងជំទាស់ទៀតបានឡើយ។

## ជំពូកទី ២
## បណ្តឹងឧទ្ធរណ៍

មាត្រា ២៦០.- សាលក្រមដែលអាចប្តឹងឧទ្ធរណ៍បាន ជាអាទិ៍

១- បណ្តឹងឧទ្ធរណ៍អាចធ្វើចំពោះសាលក្រមចុងក្រោយរបស់សាលាដំបូងបាន លើកលែងតែករណីដែលបានកំណត់ខាងក្រោមនេះ :

ក- គូភាគីបានព្រមព្រៀងគ្នាមិនប្តឹងឧទ្ធរណ៍ ដោយរក្សាទុកនូវសិទ្ធិប្តឹងសាទុក្ខក្រោយពេលតុលាការបានចេញសាលក្រមចុងក្រោយ។

ខ- សាលក្រមចុងក្រោយនោះវិនិច្ឆ័យទៅលើរឿងក្តីរដ្ឋប្បវេណី ឬ ពាណិជ្ជកម្មដែលមានតម្លៃកម្មវត្ថុបណ្តឹងមិនលើសពី ៥.០០០.០០០ ( ប្រាំលាន ) រៀល។

២- សេចក្តីព្រមព្រៀងដែលបានកំណត់នៅក្នុងចំណុច ល នៃកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុភាពឡើយ ប្រសិនបើមិនបានធ្វើលិខិតជាលាយលក្ខណ៍អក្សរ។

មាត្រា ២៦១.- ការកម្រិតបណ្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចលើបន្ទុកនៃប្រាក់ប្រដាប់ក្តី

ចំពោះសេចក្តីសម្រេចលើបន្ទុកនៃប្រាក់ប្រដាក់ក្តី មិនអាចប្តឹងឧទ្ធរណ៍ដោយឯករាជ្យតែឯកឯងបាន.ឡើយ។

មាត្រា ២៦២.- សេចក្តីសម្រេចដែលត្រូវទទួលការវិនិច្ឆ័យរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍

សេចក្តីសម្រេចនៅមុនសាលក្រមចុងក្រោយ ត្រូវទទួលការវិនិច្ឆ័យរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសេចក្តីសម្រេចដែលមិនអាចធ្វើឧបាស្រ័យបាន និង សេចក្តីសម្រេចដែលអាចធ្វើឧបាស្រ័យបានដោយការប្តឹងជំទាស់។

មាត្រា ២៦៣.- ការលះបង់សិទ្ធិប្តឹងឧទ្ធរណ៍

១- ភាគីអាចលះបង់ចោលនូវសិទ្ធិប្តឹងឧទ្ធរណ៍របស់ខ្លួនបាន។

២- នៅក្រោយពេលបានប្តឹងឧទ្ធរណ៍រួចហើយ សេចក្តីថ្លែងការណ៍ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើជាមួយគ្នានឹងការដកពាក្យបណ្តឹងឧទ្ធរណ៍។

មាត្រា ២៦៤.- អំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍

១- បណ្តឹងឧទ្ធរណ៍ត្រូវធ្វើនៅក្នុងអំឡុង ១ ( មួយ ) ខែ ដោយគិតចាប់តាំងពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រម ឬ ថ្ងៃដែលបានជូនដំណឹងអំពីដីកាសម្រេចច្រានចោល ឬ លើកចោលនូវបណ្តឹងទាស់ចំពោះសាលកំបាំងមុខ។ ប៉ុន្តែ ករណីនេះមិនមែនជាការរារាំងលើអានុភាពនៃបណ្តឹងឧទ្ធរណ៍ដែលបានដាក់នៅមុនអំឡុងពេលនេះឡើយ។

២- អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចពន្យារបានឡើយ។

មាត្រា ២៦៥.- របៀបប្តឹងឧទ្ធរណ៍

១- ដើម្បីប្តឹងឧទ្ធរណ៍ ភាគីត្រូវដាក់ពាក្យបណ្តឹងឧទ្ធរណ៍ទៅតុលាការដើម។ នៅក្នុងករណីនេះ តុលាការដើម ត្រូវធ្វើឲ្យបានឆាប់រហ័សនូវពាក្យបណ្តឹងឧទ្ធរណ៍ និង សំណុំរឿងទៅតុលាការនៃបណ្តឹងឧទ្ធរណ៍។

២- ពាក្យបណ្តឹងឧទ្ធរណ៍ត្រូវសរសេរនូវចំណុចដូចខាងក្រោមនេះ :

ក- ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

ខ. សញ្ញាណសាលក្រមនៃការជំនុំជម្រះលើកទី ១និងសេចក្តីសម្រេចដែលប្តឹងឧទ្ធរណ៍ចំពោះសាលក្រមនោះ។

៣- ក្នុងករណីដែលពុំបានសរសេរច្បាស់លាស់អំពីមូលហេតុនៃការទាមទារឲ្យលុបចោល ឬ ផ្លាស់ប្តូរនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ ក្នុងពាក្យបណ្តឹងឧទ្ធរណ៍ទេ ដើមបណ្តឹងឧទ្ធរណ៍គប្បីដាក់លិខិត

ជាលាយលក្ខណ៍អក្សរដែលសរសេរអំពីចំណុចនោះ ទៅតុលាការនៃបណ្ដឹងឧទ្ធរណ៍ នៅក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់តាំងពីថ្ងៃដែលបានដាក់ពាក្យបណ្ដឹងឧទ្ធរណ៍នោះ។

មាត្រា ២៦៦.- សិទ្ធិពិនិត្យពាក្យបណ្ដឹងឧទ្ធរណ៍របស់តុលាការនៃបណ្ដឹងឧទ្ធរណ៍

១- ក្នុងករណីដែលពាក្យបណ្ដឹងឧទ្ធរណ៍ផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ២៦៥ (របៀបប្ដឹងឧទ្ធរណ៍) នៃក្រមនេះ តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវកំណត់អំឡុងពេលសមរម្យមួយ និង បង្គាប់ឲ្យកែតម្រូវចំណុចខ្វះខាតនោះអំឡុងពេលនោះ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលពន្ធសម្រាប់ដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ មិនត្រូវបានបង់តាមបញ្ញត្តិនៃកថាខណ្ឌទី ៤ មាត្រា ៦១ (ពន្ធដាក់ពាក្យសុំ) នៃក្រមនេះ។

២- ករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើដើមបណ្ដឹងឧទ្ធរណ៍មិនបានកែតម្រូវចំណុចខ្វះខាតនោះទេ តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវលើកចោលពាក្យបណ្ដឹងឧទ្ធរណ៍មិនបានកែតម្រូវចំណុចខ្វះខាតនោះទេ តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវលើកចោលពាក្យបណ្ដឹងឧទ្ធរណ៍នោះ ដោយដីកា សម្រេច។

៣- ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើ អាចប្ដឹងជំទាស់បាន។

មាត្រា ២៦៧.- ការបញ្ជូនពាក្យបណ្ដឹងឧទ្ធរណ៍

១- ពាក្យបណ្ដឹងឧទ្ធរណ៍ត្រូវបញ្ជូនទៅចុងបណ្ដឹងឧទ្ធរណ៍។

២- បញ្ញត្តិនៃមាត្រា ២៦៦ (សិទ្ធិពិនិត្យពាក្យបណ្ដឹងឧទ្ធរណ៍របស់តុលាការនៃបណ្ដឹងឧទ្ធរណ៍) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមិនអាចបញ្ជូនពាក្យបណ្ដឹងឧទ្ធរណ៍បាន រួមទាំងករណីដែលមិនបានបង់ជាមុន នូវសោហ៊ុយចាំបាច់សម្រាប់បញ្ជូនពាក្យបណ្ដឹងឧទ្ធរណ៍។

មាត្រា ២៦៨.- ការលើកចោលបណ្ដឹងឧទ្ធរណ៍ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់

ក្នុងករណីដែលបណ្ដឹងឧទ្ធរណ៍មានលក្ខណៈផ្ទុយនឹងច្បាប់ ហើយចំណុចខ្វះខាតនោះមិនអាចកែតម្រូវបានទេ តុលាការនៃបណ្ដឹងឧទ្ធរណ៍អាចលើកចោលបណ្ដឹងឧទ្ធរណ៍នោះដោយមិនឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ ដោយសាលដីកាបាន។

មាត្រា ២៦៩.- ការដកពាក្យបណ្ដឹងឧទ្ធរណ៍

១- បណ្ដឹងឧទ្ធរណ៍អាចដកវិញបាន រហូតដល់សាលដីកាចុងក្រោយរបស់តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវបានប្រកាស។

២- ការដកពាក្យបណ្តឹងឧទ្ធរណ៍ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។ ប៉ុន្តែ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការផ្សះផ្សារ ការដកពាក្យបណ្តឹងឧទ្ធរណ៍នោះ អាចធ្វើឡើងដោយផ្ទាល់មាត់បាន។

៣- ផ្នែកនៃបណ្តឹងឧទ្ធរណ៍ដែលត្រូវបានដកចេញ ត្រូវចាត់ទុកថាមិនបានចាត់ការតាំងពីដំបូងនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍។

៤- បញ្ញត្តិនៃមាត្រា ២១៩ (ការចាត់ទុកថា ដកពាក្យបណ្តឹង) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការចាត់ទុកថា ដកពាក្យបណ្តឹងឧទ្ធរណ៍។

មាត្រា ២៧០.- បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ

១- ចុងបណ្តឹងឧទ្ធរណ៍ ទោះជាសិទ្ធិប្តឹងឧទ្ធរណ៍នោះ ត្រូវបានរលត់ហើយក៏ដោយ ក៏អាចប្តឹងឧទ្ធរណ៍បន្ទាប់បន្សំបានដែរ រហូតដល់ពេលដែលការទាញហេតុផលដោយផ្ទាល់មាត់ត្រូវបានបញ្ចប់។

២- បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំត្រូវអស់អានុភាព នៅក្នុងករណីដែលពាក្យបណ្តឹងបណ្តឹងឧទ្ធរណ៍ ត្រូវបានដក ឬ នៅក្នុងករណីដែលបណ្តឹងឧទ្ធរណ៍នោះ ត្រូវបានលើកចោលដោយសារមានភាពផ្ទុយនឹងច្បាប់។ ប៉ុន្តែ ចំពោះបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំដែលមានល័ក្ខខ័ណ្ឌនៃបណ្តឹងឧទ្ធរណ៍គ្រប់គ្រាន់ ត្រូវចាត់ទុកថាជាបណ្តឹងឧទ្ធរណ៍ឯករាជ្យ។

៣- បញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ។

មាត្រា ២៧១.- ការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្នដោយតុលាការនៃបណ្តឹងឧទ្ធរណ៍

១- តុលាការនៃបណ្តឹងឧទ្ធរណ៍អាចប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន ត្រឹមតែផ្នែកដែលពុំមានពាក្យសុំប្តឹងឧបាស្រ័យ ចំពោះសាលក្រមនៃការជំនុំជម្រះលើកទី ១ បាន តាមពាក្យសុំ ដោយដីកាសម្រេច។

២- ចំពោះការសម្រេចសេចក្តីរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍អំពីការអនុវត្តជាបណ្តោះអាសន្ន មិនអាចធ្វើឧបាស្រ័យបានឡើយ។

មាត្រា ២៧២.- ទំហំនៃការទាញហេតុផលដោយផ្ទាល់មាត់ ជាអាទិ៍

១- ការទាញហេតុផលដោយផ្ទាល់មាត់ត្រូវធ្វើ ត្រឹមតែក្នុងទំហំដែលភាគីបានទាមទារឲ្យផ្លាស់ប្តូរនូវសាលក្រមនៃការជំនុំជម្រះលើកទី១ តែប៉ុណ្ណោះ។

២- ភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់នៅក្នុងការជំនុំជម្រះលើកទី ១ ។

មាត្រា ២៧៣.- ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីនីតិវិធីនៃការជំនុំជម្រះលើកទី១

លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេស បញ្ញត្តិនៃគន្ថីទី ២ (នីតិវិធីនៃការជម្រះក្តីលើកទី ១) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះមាត្រា ៨០ (ការកំណត់ការបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង) មាត្រា ១០៤ (ការសាកល្បងផ្សះផ្សារនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល) ផ្នែកទី៥ (សាលក្រមកំបាំងមុខ) ជំពូកទី ៥ នៃគន្ថីទី ២ និងជំពូកទី ៧ (បទបញ្ញត្តិពិសេសស្តីពីរឿងក្តីចំនួនទឹកប្រាក់តិច) នៃគន្ថីទី ២ នៃក្រមនេះ។

មាត្រា ២៧៤.- អានុភាពនៃសកម្មភាពបណ្តឹងនៅក្នុងការជំនុំជម្រះលើកទី ១ ជាអាទិ៍

១- សកម្មភាពបណ្តឹងដែលបានធ្វើក្នុងការជំនុំជម្រះលើកទី ១ មានអានុភាពក្នុងការជំនុំជ្រះបណ្តឹងឧទ្ធរណ៍។

២- នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលបានធ្វើនៅក្នុងការជំនុំជម្រះលើកទី ១ មានអានុភាពក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍។

មាត្រា ២៧៥.- ការកម្រិតនូវការអះអាងស្តីពីអសមត្ថកិច្ចក្នុងការជំនុំជម្រះលើកទី ១

នៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ភាគីមិនអាចអះអាងអំពីសមត្ថកិច្ចរបស់សាលាដំបូងបាន ឡើយ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសមត្ថកិច្ចផ្តាច់មុខ។

មាត្រា ២៧៦.- ការដាក់ពាក្យបណ្តឹងតប

១- ការដាក់ពាក្យបណ្តឹងតបនៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ អាចធ្វើបានលុះត្រាតែមានការយល់ព្រមពីភាគីម្ខាងទៀត។

២- បើភាគីម្ខាងទៀតមិនបានតវ៉ា តែបានធ្វើការទាញហេតុផលលើអង្គសេចក្តីអំពីការប្តឹងតប នោះត្រូវចាត់ទុកថា ភាគីនោះបានយល់ព្រមនឹងការដាក់ពាក្យបណ្តឹងតប។

មាត្រា ២៧៧.- ការច្រានចោលបណ្តឹងឧទ្ធរណ៍

១- តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវច្រានចោលនូវបណ្តឹងឧទ្ធរណ៍ ក្នុងករណីដែលយល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី ១ ត្រឹមត្រូវ។

២. ទោះជាក្នុងករណីដែលសំអាងហេតុនៃសាលក្រមនៃការជំនុំជម្រះលើកទិ ១ មិនត្រឹមត្រូវក៏ដោយ ក៏តុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវច្រានចោលនូវបណ្តឹងឧទ្ធរណ៍នោះដែរ បើយល់ឃើញថា សេចក្តីសម្រេចបញ្ចប់នៃសាលក្រម ត្រឹមត្រូវ ដោយផ្អែកលើសំអាងហេតុផ្សេងទៀត។

មាត្រា ២៧៨.- ទំហំនៃការផ្លាស់ប្តូរសាលក្រមនៃការជំនុំជម្រះលើកទី ១

ការផ្លាស់ប្តូរសាលក្រមនៃការជំនុំជម្រះលើកទី ១ អាចធ្វើបាន ត្រឹមតែកម្រិតនៃឧបាស្រ័យ ដោយបណ្តឹងឧទ្ធរណ៍ ឬ បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំតែប៉ុណ្ណោះ។

មាត្រា ២៧៩.- ការលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១

១- តុលាការបណ្តឹងឧទ្ធរណ៍ត្រូវលុបចោលនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ ក្នុងករណីដូចមានខាងក្រោមនេះ :

ក- បើយល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី ១ មិនត្រឹមត្រូវ។

ខ- បើនីតិវិធីនៅតុលាការជាន់ទី ១ នោះផ្ទុយនឹងច្បាប់ធ្ងន់ធ្ងរ។

២- ក្នុងករណីដូចកថាខណ្ឌទី ១ ខាងលើនេះ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវធ្វើការជំនុំជម្រះទៅលើបណ្តឹងនោះ លើកលែងតែករណីដែលបានកំណត់នៅមាត្រា ២៨០ (ការបញ្ជូនរឿងក្តីត្រឡប់ទៅវិញ) ឬ មាត្រា ២៨១ (ការផ្ទេរដោយមូលហេតុខុសសមត្ថកិច្ចផ្តាច់មុខរបស់តុលាការនៃការជំនុំជម្រះលើកទី ១) នៃក្រមនេះ។

មាត្រា ២៨០.- ការបញ្ជូនរឿងក្តីត្រឡប់ទៅវិញ

១- ក្នុងករណីដែលតុលាការនៃបណ្តឹងឧទ្ធរណ៍លុបចោលនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ ដែលលើកចោលបណ្តឹង ដោយយល់ឃើញថា បណ្តឹងនោះមិនត្រឹមត្រូវតាមច្បាប់ តុលាការនៃបណ្តឹងត្រូវបញ្ជូនរឿងក្តីនោះ ត្រឡប់ទសាលាដំបូងវិញ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលគ្មានការចាំបាច់ត្រូវទាញហេតុផលបន្ថែមទៀតអំពីរឿងក្តីនោះ។

២- ក្រៅពីករណីដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ខាងលើនេះក្នុងករណីដែលតុលាការនៃបណ្តឹងឧទ្ធរណ៍លុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១ បើមានភាពចាំបាច់ទាញហេតុផលបន្ថែមទៀត អំពីរឿងក្តីនោះ តុលាការនៃបណ្តឹងឧទ្ធរណ៍អាចបញ្ជូនរឿងក្តីនោះត្រឡប់ទៅសាលាដំបូងវិញបាន។

៣- ប្រសិនបើរឿងក្តីនោះត្រូវបានបញ្ជូនត្រឡប់ទៅវិញ ដោយមូលហេតុថា នីតិវិធីបណ្តឹងនៅសាលាដំបូងផ្ទុយនឹងច្បាប់ នីតិវិធីនៃបណ្តឹងនោះត្រូវចាត់ទុកថា បានលុបចោល ដោយសារការបញ្ជូនត្រឡប់ទៅវិញ។

មាត្រា ២៨១.- ការផ្ទេរដោយមូលហេតុខុសសមត្ថកិច្ចផ្តាច់មុខរបស់តុលាការនៃការជំនុំជម្រះលើកទី ១

ប្រសិនបើតុលាការនៃបណ្តឹងឧទ្ធរណ៍លុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១ ដោយមូលហេតុហេតុថា រឿងក្តីនោះ ខុសសមត្ថកិច្ចផ្តាច់មុខ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវចេញសាលដីកាផ្ទេររឿងក្តីនោះទៅតុលាការដែលមានសមត្ថកិច្ចវិញ។

មាត្រា ២៨២.- ការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្នក្នុងសាលដីកានៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍

ចំពោះសាលដីកាអំពីការទាមទារសំណងជាប្រាក់ បើមានពាក្យសុំ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវប្រកាសថា សាលដីកាអាចអនុវត្តជាបណ្តោះអាសន្នបានដោយពុំចាំបាច់ឲ្យដាក់ប្រាតិភោគ លើកលែងតែករណី

ដែលយល់ឃើញថា ការប្រកាសឲ្យអនុវត្តជាបណ្ដោះអាសន្ននោះមិនមានលក្ខណៈចាំបាច់។ ប៉ុន្តែ បើយល់ឃើញថាសមរម្យ តុលាការនៃបណ្ដឹងឧទ្ធរណ៍អាចកំណត់ល័ក្ខខ័ណ្ឌឲ្យដាក់ប្រាតិភោគសម្រាប់ការអនុវត្តជាបណ្ដោះអាសន្ននោះបាន។

## ជំពូកទី ៣
## បណ្ដឹងសាទុក្ខ

មាត្រា ២៨៣.- តុលាការនៃបណ្ដឹងសាទុក្ខ

១- បណ្ដឹងសាទុក្ខអាចធ្វើទៅតុលាការកំពូលបាន ចំពោះសាលដីកាចុងក្រោយដែលត្រូវបានជំនុំជម្រះលើកទី ២ ដោយសាលាឧទ្ធរណ៍។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរចំពោះសាលដីកាចុងក្រោយដែលសាលាឧទ្ធរណ៍បានជំនុំជម្រះលើកទី ១ តាមបញ្ញត្តិនៃច្បាប់ពិសេស។

២- ចំពោះសាលក្រមចុងក្រោយដែលត្រូវបានជំនុំជម្រះលើកទី ១ ដោយសាលាដំបូងនៅក្នុងករណីដែលគូភាគីបានព្រមព្រៀងគ្នាមិនប្ដឹងឧទ្ធរណ៍នៅក្រោយពេលដែលតុលាការបានចេញសាលក្រមនោះ ដោយរក្សាទុកនូវសិទ្ធិប្ដឹងសាទុក្ខ បណ្ដឹងសាទុក្ខអាចធ្វើទៅតុលាការកំពូលដោយផ្ទាល់បាន។

មាត្រា ២៨៤.- មូលហេតុទូទៅនៃបណ្ដឹងសាទុក្ខ

បណ្ដឹងសាទុក្ខអាចធ្វើបាន ដោយយកមូលហេតុនៃភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ ឬ បទដ្ឋានគតិយុត្តដែលមានឥទ្ធិពលលើសាលដីកា ឬ សាលក្រម។

មាត្រា ២៨៥.- មូលហេតុដាច់ខាតនៃបណ្ដឹងសាទុក្ខ

១- ក្នុងករណីណាមួយដូចបានកំណត់ខាងក្រោមនេះ ត្រូវចាត់ទុកថា មានមូលហេតុនៃបណ្ដឹងសាទុក្ខជាដរាប:

ក- តុលាការដែលចេញសាលដីកា ឬ សាលក្រម មិនត្រូវបានចាត់តាំង ដោយស្របទៅតាមច្បាប់។

ខ- ចៅក្រមដែលច្បាប់មិនអនុញ្ញាតឲ្យចូលរួមក្នុងការចេញសាលដីកា ឬ សាលក្រម តែបានចូលរួម។

គ- ភាពផ្ទុយនឹងបញ្ញត្តិស្ដីពីសមត្ថកិច្ចផ្ដាច់មុខរបស់តុលាការ។

ឃ- ការខ្វះសិទ្ធិតំណាងដែលបានកំណត់ដោយច្បាប់ សិទ្ធិតំណាងដោយអាណត្តិ ឬ ការប្រគល់សិទ្ធិតំណាងដោយអាណត្តិ ឬ ការប្រគល់សិទ្ធិចាំបាច់សម្រាប់អ្នកតំណាងដើម្បីធ្វើសកម្មភាពបណ្ដឹង។

ង- ភាពផ្ទុយនឹងបញ្ញត្តិស្ដីពីការបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ។

ច- សាលដីកា ឬ សាលក្រម គ្មានសំអាងហេតុ ឬ មានសំអាងហេតុ តែផ្ទុយនឹងគ្នា។

២- បញ្ញត្តិនៃចំណុច ឃ នៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណី

ដែលមានការទទួលស្គាល់ពេលក្រោយ តាមបញ្ញត្តិកថាខណ្ឌទី ២ នៃមាត្រា ៣៥ (វិធានការក្នុងករណីដែលខ្វះសមត្ថភាពក្នុងការធ្វើបណ្ដឹង ជាអាទិ៍) ឬ កថាខណ្ឌទី ៣ នៃមាត្រា ៥៧ (វិធានក្នុងករណីនៃការខ្វះសិទ្ធិតំណាង) នៃក្រមនេះ។

មាត្រា ២៨៦.- ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្ដីពីបណ្ដឹងឧទ្ធរណ៍

បញ្ញត្តិនៃជំពូកទី ២ នៃគន្ថីទី ៣ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្ដឹងសាទុក្ខ និង នីតិវិធីនៃការជំនុំជម្រះបណ្ដឹងសាទុក្ខ លើកលែងតែមានបញ្ញត្តិពិសេស។

មាត្រា ២៨៧.- របៀបប្ដឹងសាទុក្ខ

ដើម្បីប្ដឹងសាទុក្ខ ភាគីត្រូវដាក់ពាក្យបណ្ដឹងសាទុក្ខទៅតុលាការដើម។ នៅក្នុងករណីនេះ តុលាការដើម ត្រូវធ្វើឲ្យបានឆាប់រហ័ស នូវពាក្យបណ្ដឹងសាទុក្ខ និង សំណុំរឿងទៅតុលាការនៃបណ្ដឹងសទុក្ខ។

មាត្រា ២៨៨.- ការបញ្ជូនលិខិតទទួលពាក្យបណ្ដឹងសាទុក្ខ ជាអាទិ៍

១- នៅក្នុងករណីដែលមានការដាក់ពាក្យបណ្ដឹងសាទុក្ខ តុលាការនៃបណ្ដឹងសាទុក្ខត្រូវបញ្ជូនលិខិត ទទួលពាក្យបណ្ដឹងសាទុក្ខទៅភាគី លើកលែងតែក្នុងករណីដែលលើកចោលពាក្យបណ្ដឹងសាទុក្ខនោះ។

២- នៅពេលដែលតុលាការបញ្ជូនលិខិតទទួលពាក្យបណ្ដឹងសាទុក្ខទៅចុងបណ្ដឹងសាទុក្ខ ដោយ យោលតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការនៃបណ្ដឹងសាទុក្ខត្រូវបញ្ជូនទាំងពាក្យបណ្ដឹងសាទុក្ខ ទៅជាមួយផង។

មាត្រា ២៨៩.- ការសរសេរមូលហេតុនៃបណ្ដឹងសាទុក្ខ

១- ប្រសិនបើមិនបានសរសេរនូវមូលហេតុនៃបណ្ដឹងសាទុក្ខក្នុងពាក្យបណ្ដឹងសាទុក្ខទេ ដើមបណ្ដឹងសាទុក្ខត្រូវដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខនេះ ជូនទៅតុលាការនៃបណ្ដឹងសាទុក្ខ ក្នុងអំឡុងពេល ៣០ ថ្ងៃ បន្ទាប់ពីបានទទួលការបញ្ជូននូវលិខិតទទួលពាក្យបណ្ដឹងសាទុក្ខ។

២- ក្នុងករណីដែលបណ្ដឹងសាទុក្ខធ្វើឡើង ដោយយកមូលហេតុដែលបានកំណត់នៅក្នុងមាត្រា ២៨៤ (មូលហេតុទូទៅនៃបណ្ដឹងសាទុក្ខ) ខាងលើនេះ ដើមបណ្ដឹងសាទុក្ខត្រូវសរសេរមូលហេតុនៃបណ្ដឹងសាទុក្ខនេះ ដោយបញ្ជាក់អំពីបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្តនោះ។ នៅក្នុងករណីនេះ ប្រសិនបើហេតុនោះ មានទំនាក់ទំនងនឹងនីតិវិធីនៃបណ្ដឹង ត្រូវសរសេរបញ្ជាក់ឲ្យបានច្បាស់លាស់ នូវអង្គហេតុដែលផ្ទុយនោះ។

៣- ក្នុងករណីដែលបណ្ដឹងសាទុក្ខឡើង ដោយមូលហេតុដូចចំណុចណាមួយដែលបានកំណត់នៅកថាខណ្ឌទី ១ នៃមាត្រា ២៨៥ (មូលហេតុដាច់ខាតនៃបណ្ដឹងសាទុក្ខ) នៃក្រមនេះ ដើមបណ្ដឹងសាទុក្ខត្រូវ

សរសេរមូលហេតុនៃបណ្ដឹងសាទុក្ខ ដោយបញ្ជាក់នូវចំណុចក្នុងកថាខណ្ឌទី ១ នៃមាត្រា ២៨៥ និង អង្គហេតុដែលត្រូវនឹងចំណុចនោះ។

មាត្រា ២៩០.- ការលើកចោលបណ្ដឹងសាទុក្ខ

ប្រសិនបើត្រូវនឹងចំណុចណាមួយខាងក្រោមនេះ យ៉ាងជាក់ច្បាស់ តុលាការនៃបណ្ដឹងសាទុក្ខ ត្រូវលើកចោលបណ្ដឹងសាទុក្ខ ដោយដីកាសម្រេច :

ក- បើបណ្ដឹងសាទុក្ខនោះមិនស្របច្បាប់ ហើយមិនអាចកែតម្រូវចំណុចខ្វះខាតនោះបាន។

ខ- បើមិនបានដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ២៨៩ (ការសរសេរមូកហេតុនៃបណ្ដឹងសាទុក្ខ) ខាងលើនេះ ឬ បើការសរសេរមូកហេតុនៃបណ្ដឹងសាទុក្ខផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ២៨៩។

មាត្រា ២៩១.- ដីកាសម្រេចបង្គាប់ឲ្យកែតម្រូវ

១- ប្រសិនបើការសរសេរមូលហេតុទាំងមូលនៃបណ្ដឹងសាទុក្ខ ដែលត្រូវបានបញ្ជាក់ក្នុងពាក្យបណ្ដឹងសាទុក្ខ ឬ ក្នុងលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខ ដែលត្រូវបានដាក់ក្នុងអំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ២៨៩ (ការសរសេរមូលហេតុនៃបណ្ដឹងសាទុក្ខ) នៃក្រមនេះ ផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ២៨៩ នោះយ៉ាងជាក់ច្បាស់ តុលាការនៃបណ្ដឹងសាទុក្ខ ត្រូវកំណត់អំឡុងពេលនោះ ដោយដីកាសម្រេច។

២- ដីកាសម្រេចលើកចោលនូវបណ្ដឹងសាទុក្ខដែលបានកំណត់ក្នុងចំណុច ខ នៃមាត្រា ២៩០ (ការលើកចោលបណ្ដឹងសាទុក្ខ) ខាងលើនេះ ត្រូវធ្វើឡើង ក្នុងករណីដែលដើមបណ្ដឹងសាទុក្ខមិនបានធ្វើការកែតម្រូវនូវចំណុចខ្វះខាត នៅក្នុងអំឡុងពេលដែលបានកំណត់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ។

មាត្រា ២៩២.- ការបញ្ជូនឯកសារចម្លងនៃលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខ

ប្រសិនបើតុលាការនៃបណ្ដឹងសាទុក្ខមិនចេញដីកាសម្រេចលើកចោលបណ្ដឹងសាទុក្ខតាមបញ្ញត្តិនៃមាត្រា ២៩០ (ការលើកចោលបណ្ដឹងសាទុក្ខ) នៃក្រមនេះទេ តុលាការនៃបណ្ដឹងសាទុក្ខត្រូវបញ្ជូនឯកសារចម្លងនៃលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខនោះ ទៅចុងបណ្ដឹងសាទុក្ខ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលតុលាការនៃបណ្ដឹងសាទុក្ខជំនុំជម្រះ និង សម្រេចសេចក្ដី ដោយពុំឆ្លងកាត់ការទាញហេតុផលមាត់ ហើយយល់ឃើញថា ពុំចាំបាច់បញ្ជូនឯកសារចម្លងនៃលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខនោះ។

មាត្រា ២៩៣.- ការបង្គាប់ឲ្យដាក់ឯកសារត្រៀម

តុលាការនៃបណ្ដឹងសាទុក្ខអាចកំណត់អំឡុងពេលសមរម្យ ហើយបង្គាប់ឲ្យចុងបណ្ដឹងសាទុក្ខដាក់ឯកសារត្រៀមលើកដំបូងបាន។

មាត្រា ២៩៤.- ការច្រានចោលបណ្ដឹងសាទុក្ខដោយមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់

តុលាការនៃបណ្ដឹងសាទុក្ខអាចច្រានចោលបណ្ដឹងសាទុក្ខដោយសាលដីកាបាន ដោយមិនចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ បើយល់ឃើញថា បណ្ដឹងសាទុក្ខនោះគ្មានមូលហេតុ ក្រោយពីបានពិនិត្យពាក្យបណ្ដឹងសាទុក្ខបានដាក់លើកដំបូង ឬ ឯកសារផ្សេងទៀត។

មាត្រា ២៩៥.- ទំហំនៃការស្រាវជ្រាវ

តុលាការបណ្ដឹងសាទុក្ខ ត្រូវធ្វើការស្រាវជ្រាវត្រឹមតែកម្រិតនៃឧបាស្រ័យ ដោយផ្អែកលើមូលហេតុនៃបណ្ដឹងសាទុក្ខ។

មាត្រា ២៩៦.-ចំណងនៃអង្គហេតុស្ថាពររបស់សាលដីកាដើម ឬ សាលក្រមដើម

១- អង្គហេតុដែលបានចូលជាស្ថាពរដោយត្រឹមត្រូវតាមច្បាប់ក្នុងសាលដីកាដើម ឬ សាលក្រមដើម ត្រូវមានចំណងចំពោះតុលាការនៃបណ្ដឹងសាទុក្ខ។

២- ក្នុងករណីដែលមានបណ្ដឹងសាទុក្ខដែលយោលទៅតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ២៨៣ (តុលាការនៃបណ្ដឹងសាទុក្ខ) នៃក្រមនេះ តុលាការនៃបណ្ដឹងសាទុក្ខមិនអាចបដិសេធចោលសាលក្រមឡើយ ដោយយកមូលហេតុថា ការចូលជាស្ថាពរនៃអង្គហេតុក្នុងសាលក្រមដើមនោះ ផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្ត ។

មាត្រា ២៩៧.- ករណីលើកលែងនៃការអនុវត្តចំពោះចំណុចដែលស្រាវជ្រាវដោយឆន្ទានុសិទ្ធិ

បញ្ញត្តិនៃមាត្រា ២៩៥ (ទំហំនៃការស្រាវជ្រាវ) និង មាត្រា ២៩៦ (ចំណងនៃអង្គហេតុស្ថាពររបស់សាលដីកាដើម ឬ សាលក្រមដើម) ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយចំពោះចំណុចដែលតុលាការត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់ខ្លួន។

មាត្រា ២៩៨.- ការប្រកាសឲ្យអនុវត្តឃាបណ្ដោះអាសន្ន

តុលាការនៃបណ្ដឹងសាទុក្ខអាចប្រកាសឲ្យអនុវត្តជាបណ្ដោះអាសន្ន តាមពាក្យសុំ ដោយដីកាសម្រេចបាន ត្រឹមតែចំពោះផ្នែកដែលពុំមានឧបាស្រ័យនៅក្នុងសាលដីកាដើម ឬ សាលក្រមដើមតែប៉ុណ្ណោះ។

មាត្រា ២៩៩.- ការបដិសេធចោល ហើយបញ្ជូនត្រឡប់ទៅតុលាការដើមវិញ ជាអាទិ៍

១- នៅក្នុងករណីដែលមានមូលហេតុដែលបានកំណត់ក្នុងមាត្រា ២៨៤ (មូលហេតុទូទៅនៃបណ្ដឹងសាទុក្ខ) ឬ មាត្រា ២៨៥ (មូលហេតុដាច់ខាតនៃបណ្ដឹងសាទុក្ខ) នៃក្រមនេះតុលាការនៃបណ្ដឹងសាទុក្ខត្រូវបដិសេធចោលនូវសាលដីកាដើម ឬ សាលក្រមដើម ហើយត្រូវបញ្ជូនរឿងក្ដីត្រឡប់ទៅតុលាការដើមវិញ ឬ ផ្ទេររឿងក្ដីនោះទៅតុលាការផ្សេងដែលមានថ្នាក់ដូចគ្នា លើកលែងតែក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ៣០០ (ការបដិសេធចោល ហើយវិនិច្ឆ័យដោយខ្លួនឯង) នៃក្រមនេះ។

២- តុលាការដែលបានទទួលរឿងក្ដីដោយការបញ្ជូនត្រឡប់មកវិញ ឬ ការផ្ទេរ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើការសម្រេចសេចក្ដីដោយផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់សាជាថ្មីម្ដងទៀត។ ក្នុងករណីនេះ សេចក្ដីវិនិច្ឆ័យលើអង្គហេតុ និងអង្គច្បាប់ ដែកតុលាការនៃបណ្ដឹងសាទុក្ខយកជាមូលហេតុនៃការបដិសេធចោល មានចំណងទៅលើតុលាការដែលបានទទួលការបញ្ជូន ឬ ការផ្ទេរ។

៣- ចៅក្រមដែលពាក់ព័ន្ធនឹងសាលដីកាដើម ឬ សាលក្រមដើម មិនអាចចូលរួមក្នុងការសម្រេចសេចក្ដីដែលបានកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះទេ។

មាត្រា ៣០០.- ការបដិសេធចោល ហើយវិនិច្ឆ័យដោយខ្លួនឯង

តុលាការនៃបណ្តឹងសាទុក្ខត្រូវធ្វើការសម្រេចសេចក្តីអំពីរឿងក្តីផ្ទាល់ខ្លួនឯងចំពោះករណីដូចខាងក្រោមនេះ :

ក- តុលាការនៃបណ្តឹងសាទុក្ខបដិសេធចោលនូវសាលកដីកា ឬ សាលក្រមដើម ដោយយកមូលហេតុថា តុលាការនៃការជំនុំជម្រះដើមមានកំហុសក្នុងការអនុវត្តរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្ត ចំពោះអង្គហេតុ ដែលបានចូលជាស្ថាពរ ហើយតុលាការនៃបណ្តឹងសាទុក្ខអាចសម្រេចសេចក្តីអំពីរឿងក្តីនោះ ដោយផ្អែកលើអង្គហេតុនេះបាន។

ខ- តុលាការនៃបណ្តឹងសាទុក្ខបដិសេធចោលនូវសាលដីកាដើម ឬ សាលក្រមដើម ដោយយកមូលហេតុថា រឿងក្តីនោះមិនស្ថិតនៅក្រោមសិទ្ធិជម្រះក្តីរបស់តុលាការ។

## ជំពូកទី ៤
## បណ្តឹងជំទាស់

មាត្រា ៣០១.- របៀបប្តឹងជំទាស់

១- ដើម្បីប្តឹងជំទាស់ ភាគីត្រូវដាក់ពាក្យបណ្តឹងជំទាស់ទៅតុលាការដើម។ នៅក្នុងករណីនេះ តុលាការដើម ត្រូវធ្វើឲ្យបានឆាប់រហ័ស នូវពាក្យបណ្តឹងជំទាស់ និង សំណុំរឿងទៅតុលាការនៃបណ្តឹងជំទាស់។

២- ក្នុងករណីដែលពុំបានសរសេរច្បាស់លាស់អំពីមូលហេតុនៃការទាមទារឲ្យលុបចោល ឬ ផ្លាស់ប្តូរនូវដីកាសម្រេចដើម ក្នុងពាក្យបណ្តឹងជំទាស់ទេ ម្ចាស់បណ្តឹងជំទាស់គប្បីដាក់លិខិតជាលាយលក្ខណ៍អក្សរដែលសរសេរអំពីចំណុចនោះ ទៅតុលាការនៃបណ្តឹងជំទាស់ នៅក្នុងអំឡុងពេល ២ សប្តាហ៍ គិតចាប់ពីថ្ងៃដែលបានដាក់ពាក្យបណ្តឹងជំទាស់នោះ ។

មាត្រា ៣០២.- បណ្តឹងឧបាស្រ័យចំពោះដីកាសម្រេចរបស់ចៅក្រមដែលទទួលបញ្ជា ឬ ចៅក្រមដែលទទួលការប្រគល់សិទ្ធិ

១- ភាគីដែលមិនយល់ព្រមចំពោះដីកាសម្រេចរបស់ចៅក្រមដែលទទួលបញ្ជា ឬ ចៅក្រមទទួលការប្រគល់សិទ្ធិ អាចដាក់ពាក្យសុំប្តឹងតវ៉ាទៅតុលាការទទួលបណ្តឹងបានតែក្នុងករណីដែលច្បាប់អនុញ្ញាតឲ្យប្តឹងជំទាស់ ប្រសិនបើដីកាសម្រេចនោះជាដីកាសម្រេចរបស់តុលាការទទួលបណ្តឹង។ ប៉ុន្តែ ក្នុងករណីដែលតុលាការទទួលពាក្យបណ្តឹងជាតុលាការកំពូល ឬ សាលាឧទ្ធរណ៍ ភាគីអាចដាក់ពាក្យសុំប្តឹងតវ៉ាបាន លុះត្រាតែច្បាប់អនុញ្ញាតឲ្យប្តឹងជំទាស់ ប្រសិនបើដីកាសម្រេចនោះជាដីកាសម្រេចរបស់សាលាដំបូង។

២- ចំពោះដីកាសម្រេចលើពាក្យសុំនៃកថាខណ្ឌទី ១ ខាងលើនេះ អាចធ្វើបណ្តឹងជំទាស់បាន។

មាត្រា ៣០៣.- អំឡុងពេលសម្រាប់ប្តឹងជំទាស់

១- បណ្តឹងជំទាស់ត្រូវធ្វើក្នុងអំឡុងពេល ១ សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានទទួលដំណឹងអំពីដីកាសម្រេច។

២- អំឡុងពេលនៃកថាខណ្ឌទី ១ ខាងលើនេះ មិនអាចពន្យារបានឡើយ។

មាត្រា ៣០៤.- ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍ ឬ បណ្តឹងសាទុក្ខ

១- បញ្ញត្តិស្ដីពីបណ្ដឹងឧទ្ធរណ៍ និងនីតិវិធីនៃការជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្ដឹងជំទាស់លើដីកាសម្រេចរបស់សាលាដំបូង និង នីតិវិធីនៃតុលាការនៃបណ្ដឹងជំទាស់នោះ លើកលែងតែករណីដែលបញ្ញត្តិនោះមានភាពផ្ទុយនឹងលក្ខណៈបណ្ដឹង ឬ នីតិវិធីនោះ។

២- បញ្ញត្តិស្ដីពីបណ្ដឹងសាទុក្ខ និង នីតិវិធីទាក់ទងនឹងការជំនុំជម្រះបណ្ដឹងសាទុក្ខនោះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្ដឹងជំទាស់លើដីកាសម្រេចដែលសាលាឧទ្ធរណ៍បានចេញក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី ១ និង នីតិវិធីទាក់ទងនឹងបណ្ដឹងជំទាស់នោះ លើកលែងតែករណីដែលបញ្ញត្តិនោះមានភាពផ្ទុយនឹងលក្ខណៈនៃបណ្ដឹង ឬ នីតិវិធីនោះ។

មាត្រា ៣០៥.- ការផ្អាកអានុភាពនៃដីកាសម្រេចដើម

១- បណ្ដឹងជំទាស់ត្រូវផ្អាកអានុភាពនៃដីកាសម្រេចដើម។

២- តុលាការនៃបណ្ដឹងជំទាស់ ឬ តុលាការដែលបានចេញដីកាសម្រេចដើម អាចបង្គាប់ផ្អាកជាបណ្ដោះអាសន្ននូវការអនុវត្តដោយបង្ខំ ដោយផ្អែកលើដីកាសម្រេចដើម ឬ បង្គាប់ឲ្យចាត់ចែងហាជាចាំបាច់ផ្សេងទៀតបាន រហូតដល់ពេលមានដីកាសម្រេចអំពីបណ្ដឹងជំទាស់។

មាត្រា ៣០៦.- ការទាញហេតុផលដផយផ្ទាល់មាត់តាមឆន្ទៈស្ម័គ្រចិត្ត និងការសួរជំនួសការទាញហេតុផល ដោយផ្ទាល់មាត់

១- ការសម្រេចសេចក្ដីលើបណ្ដឹងជំទាស់ អាចធ្វើបាន ដោយមិនបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់។

២- ក្នុងករណីដែលតុលាការនៃបណ្ដឹងជំទាស់មិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់អំពីបណ្ដឹងជំទាស់ទេ តុលាការអាចធ្វើការសួរម្ចាស់បណ្ដឹងជំទាស់ ឬ អ្នកផ្សេងទៀតដែលមានទំនាក់ទំនងនឹងផលប្រយោជន៍នៃបណ្ដឹងបាន។